INSTITUT DE CIVILISATION INDIENNE
N° 2631

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្តីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ៨

ខែ ៧, ៨, ៩, រួមគ្នា

កុងស៊ីយសេនាបតីបានអនុញ្ញាតហើយ

សម្តេចសង្ឃនាយកទាំងពីរគណយល់ព្រម

PER
933




ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៧៩

គ. ស. ១៩៣៦

ÉCOLE FRANÇAISE D'EXTRÊME ORIENT
BIBLIOTHÈQUE

# បញ្ជីរឿង

ទំព័រ

១ — បរិវត្តគមនាគម ដំណើរអង់តួរលោកក្នុងដែនកូសាំងស៊ីន ព្រះសាសនសោភ័ណ
ជ. ណាត ចាងហ្វាងរងសាលាបាលីរៀបរៀង (ទេវត្តឡុងផ្សេង) (ត) . . . ៥

២ — ខេមរាខេមសរណកថា ព្រះមហាពិទូរក្រសេមគន្ធរចនបណ្ឌិត រៀបរៀង (ត). ២៧

៣ — ពិធីបុណ្យប្រូតេនកញ្ចប់ជាយ នៅស្រុកលាវ ភិក្ខុសុមនតិស្ស ស៊ុ-អូន
រៀបរៀង . . . . . . . . . . . . . . . . . . . . . . . . ៣៧

៤ — រឿងតេមិយជាតក សេចក្តីចាស់ . . . . . . . . . . . . . . . . . . ៤៣

៥ — តម្រាធនសាស្ត្រ ព្រះមហាពិទូរក្រសេមគន្ធរចនបណ្ឌិត រៀបរៀង (ត). . ៥៧

៦ — រឿងធ្មេញដៃយបណ្ឌិត សេចក្តីចាស់ (ត). . . . . . . . . . . . . . . . ៧១

## រូបផ្សេង ៗ

១ — ព្រះចេតិយ៍ធាតុហ្លួង នៅក្នុងដែនក្រុងវៀងចន្ទន៍ (លាវ). . . . . . . . : ១

២ — ព្រះចេតិយ៍បញ្ចុះព្រះសារីរិកធាតុ នៅក្រុងបាគន (ភូមា) . . . . . . . . . . ២៣

៣ — ព្រះចេតិយ៍ប្ញូភណា នៅវត្តយាគយី ស្រុកព្រហ្មេ (ភូមា) . . . . . . . . . ៤១

# TABLE DES MATIÈRES


| | Pages. |
|---|---|
| I. Tournée en Cochinchine de M. le secrétaire général de l'Institut Bouddhique (Long-Xuyên et Rach-Gia)....... | 5 |
| II. Khemā Khema Saranakatha ou Religions, refuge des hommes par Préas Maha Pitou Krasem à la Bibliothèque Royale (à suivre)........................... | 27 |
| III. Offrande aux bonzes des repas mis en paquet-Cérémonie laotienne.................................. | 37 |
| IV. Temiyajātaka ou Bouddha dans ses vies antérieures....... | 43 |
| V. Le théâtre cambodgien par Préas Maha Pitou Krasem..... | 57 |
| VI. Conte populaire cambodgien inédit: Histoire de Thmenh-Chhey (à suivre).................................. | 71 |


## HORS TEXTE:


| | |
|---|---|
| I. That Luong de Vientiane.............................. | 1 |
| II. Chedi contenant l'os frontal et une dent du Bouddha — Pagode de Maha-Vijaya Pagan (Birmanie)................. | 23 |
| III. Un des plus vieux Chedi de Birmanie Pagode de Pyagyi-Prôme.................................. | 41 |

ថាតល្អង

ព្រះចេតិយ៍ ថាតល្អង (ធាតុល្អង) តាំងនៅចំនួន៣គីឡូម៉ែត្រខាងកើតក្រុងវៀងចន្ទន៍ ព្រះបាទសម្តេចព្រះចៅសិត្ថាធិរាជ (ជេដ្ឋាធិរាជ) ទ្រង់កសាងពីក្នុង ព.ស. ២១០៩ ព្រះចេតិយ៍នេះទំនងជាកសាងពី ព.ស. ១៥៤៣ គ្របលើព្រះចេតិយ៍ ១ អង្គដែលដំកល់នូវព្រះកេសធាតុព្រះសម្មាសម្ពុទ្ធបរមគ្រូ ។



ព្រះចេតិយ៍នេះជាកន្លែងដែលអ្នកទៅទស្សនការទីសំរេជនិយស្ថាន តែងទៅកាន់រហូតដល់មកសព្វថ្ងៃនេះ ក្នុងកំផែងព្រះចេតិយ៍នេះហើយដែលព្រះចៅសុលិញ៉ាវង្ស

ទទួលអ្នកដំណើរជាតិហុល្លង់ដេឈ្មោះវ៉ាន វុស្តហ្វ កាលពីក្នុង ព. ស. ២១៨៤ ។

ប៉ុន្តែឋាតល្បង កាលពីក្នុង ព. ស. ២៤១៦ ត្រូវពួកចោរជាតិចិនទៅភ្នំយុនណាំនមកទំលាយកំទេច ។ រាជការក្រុងបារាំងសែស នៅវេលាដែលមកតាំងនៅក្នុងស្រុកលាវក៏តាំងចាត់ការជួសជុលព្រះចេតិយ៍នេះឡើងវិញ ។

បរិវដ្ត គមនាគមន៍

ដំណើរអង់គ្លេសលោស្រុកកូសាំងស៊ីន

( គ )

## ខេត្តឡុងស្វៀន

ថ្ងៃអង្គារ ២៨ ណោវែម ១៩៣៣ (១១ កើតខែមិគសិរ)

ម៉ោង ៦ កន្លះ (ព្រឹក) យើងចុះកាណូតរាជការ ចេញពីទីរួមខេត្ត តាមព្រែកឡុងស្វៀង (ព្រែកបារ៉ាច) ទៅ ម៉ោង ៧ កន្លះដល់វត្តបារ៉ាច (យួនហៅ ជួយញត្រាច់) ក្នុងឃុំយិញត្រាច់ ខណ្ឌឱញភូ ។ វត្តនេះនៅក្បែរមាត់ព្រែក ជាវត្តតូច ប៉ុន្តែគេកសាងយូរអង្វែងឆ្នាំមកហើយ គេប្រាប់ថាជួនកាលមានដាច់គតលោកសង្ឃម្តង ៗ ព្រោះពួកខ្មែរក្នុងស្រុកនេះច្រើនតែអ្នកក្រីក្រ មិនសូវមានអ្នកទំនុកបំរុងវត្តអារាម កាលពីមុននេះមានដាច់គតលោកសង្ឃសោះដល់ ២ ឆ្នាំ ។ សព្វថ្ងៃនេះមានលោកភិក្ខុ ៥ រូប សាមណេរ ៥ រូប លោកចៅអធិការឈ្មោះ កៅ កាលពីដើមធ្វើជាគ្រូសូត្រ វត្តស្មោងក្នុងឃុំស្មោងខណ្ឌត្រឡាចខេត្តតាកែវ (កម្ពុជរដ្ឋ) ពួកឧបាសកស្រុកបារ៉ាចគេទៅនិមន្តលោកមកធ្វើជាចៅអធិការវត្តនេះ ពីក្នុងឆ្នាំ ១៩៣២ ។ លោកចៅអធិការព្រមទាំងភិក្ខុសាមណេរវត្តនេះ មានសណ្តាប់ធ្នាប់ស្លៀកដណ្តប់នឹងឫកពាររម្យទមត្រឹមត្រូវបែបបទ ចេញទំនងឲ្យឃើញថាជាអ្នកពេញ

ចិត្តនឹងវិន័យសិក្ខាការរៀនសូត្រ ។ មនុស្សដែលមកប្រជុំក្នុងទីនេះទាំងបព្វជិតទាំងគ្រហស្ថ មានប្រហែលជាង ៨០ នាក់ ។ ប្រជាជនជាតិខ្មែរក្នុងស្រុកនេះ ស្រី ៗ សុទ្ធតែបួងសក់ស្លៀកខោពាក់អាវបែបយួន ប្រុស ៗ បួងសក់ខ្លះកាត់សក់ខ្លះ តែងគ្រឿងស្លៀកដូចយួនទាំងអស់ ។ ខ្ញុំកាលដែលទើបឡើងទៅដល់ឃើញភ្លាមនឹកស្មានថា សុទ្ធតែពួកយួន លុះដល់សួរទៅប្រាប់ថាសុទ្ធតែខ្មែរទាំងអស់គ្នា ។ លោកអគ្គលេខាធិការបានប្រគល់ភារៈមកខ្ញុំថា ឲ្យនិយាយពន្យល់ឲ្យប្រើនបន្តិច ហើយឲ្យខ្ញុំនិយាយពន្យល់ម្យ៉ាងទៀតថា ស្រុកខ្មែរឯណោះមានដីទំនេនៅសល់ច្រើនកន្លែងណាស់បើបណ្ដាអស់អ្នករាល់គ្នា មានអ្នកណាទីទាល់គ្មានដី ហើយពេញចិត្តនឹងទៅនៅគាស់រានដីឯស្រុកខ្មែរនោះទំនងជាមិនពិបាកសុំទេ ។ ខ្ញុំក៏បាននិយាយពន្យល់ជាស់តឿនរំឭកដោយសព្វគ្រប់ ហើយបាននិយាយពន្យល់អំពីដំណើរដីទំនេរនោះ ឲ្យល្មមអ្នកទាំងនោះស្ដាប់បានជាក់ ។ អ្នកទាំងនោះក៏សំដែងអាការរីករាយ ប៉ុន្តែត្អូញថា

ទាស់នឹងពិបាកសុំសំបុត្រថ៉ុងហាញ់ ៗ (សំបុត្រអីដង់ទីតេ) ពីព្រោះសុំសំបុត្រនោះលុះតែបង់ប្រាក់ច្រើនៗទើបបាន ក្នុងស្រុកបារ៉ាបនេះមានសុទ្ធតែមន្ត្រីជាតិយួន អស់យើងខ្ញុំជាតិជាខ្មែរអ្នកក្រីក្រ មិនងាយនឹងសុំសំបុត្រថ៉ុងហាញ់នោះបានទេ ៗ យើងបាននិយាយពន្យល់តាមផ្លូវរាជការឲ្យអ្នកទាំងនោះស្ដាប់បាន រួបហើយឲ្យបែករូបផ្ដិតពុម្ព ។ លោកអគ្គលេខាធិការបានថតរូបពួកខ្មែរទាំងនោះ ៣ លើក ដើម្បីនឹងទុកជាភស្ដុតាងឲ្យឃើញដំណើរ បែបបទខ្មែរដែលប្រែក្លាយជាយួន ។ លុះរួបការទាំងនេះហើយយើងក៏ធ្វើភត្តកិច្ចនៅវត្តនេះ ។

ម៉ោង ១១ កន្លះ យើងចុះកាណូតចេញពីវត្តបារ៉ាបនេះទៅវត្តភ្នំបាថេ, ម៉ោង ១៤ កន្លះដល់វត្តភ្នំបាថេ (យួនហៅថ្វយ៉ង់ថេ) វត្តនេះមាននាមម្យ៉ាងទៀតហៅថាវត្ត កល្បព្រឹក្ស (ក្លាយមកពីពាក្យសំស្ក្រឹតថា កល្បវ្រឹក្ស> កល្បព្រឹក្ស) ក្នុងឃុំយ៉ង់ថេខណ្ឌឱញភូ ។ ក្នុងទីប្រជុំនេះមានពួកបព្វជិត ១៦ រូប គ្រហស្ថប្រហែល ៥០ នាក់ មានសណ្ដាប់ធ្នាប់ដូចគ្នានឹងពួកខ្មែរស្រុកបារ៉ាបខ្លះ នៅមានបែបភាពល្មមស្គាល់ថាជាខ្មែរបានខ្លះ ។

លោកអគ្គលេខាធិការបានពន្យល់អំពីកិច្ចការតាមសមគួរហើយ ខ្ញុំក៏បាននិយាយដាស់តឿនក្រើនរំឭកពន្យល់ដោយសេចក្ដីសព្វគ្រប់ដូចខាងវត្តបារ៉ាចដែរ ។

លុះនិយាយរួចហើយ មានមនុស្សប្រុសខ្លះស្រីខ្លះលើកដៃច្រងប្រាងសំពះលោកអគ្គលេខាធិការ ថ្លែងសេចក្ដីទុក្ខលំបាកក្ដៅក្រហាយ អំពីដំណើរយួនអ្នកមានទ្រព្យម្នាក់បំបាត់យកដីស្រែរបស់ពួកខ្មែរស្រុកនេះ (ជាដីនៅក្នុងខែត្រារ៉ាប់យ៉ា ដែលពីដើមជាដីទំនេរហើយបានគាស់រានរកស៊ី ៥ ឆ្នាំខ្លះ ៦ ឆ្នាំខ្លះ ៧, ៨, ៩ ឆ្នាំខ្លះមកហើយ) ដោយកល់ឧបាយយ៉ាងសំខាន់ នឹងអាចប្ដឹងតវ៉ាយកវិញពុំបាន . . . . . ។ មានយាយម្នាក់យកដៃគក់ទ្រូងគក់ស្មារំប៉ាប្ដឹងសុំឲ្យជួយទំនុកបំរុងស្រោចស្រង់ផង ព្រោះពួកខ្មែរស្រុកនេះសព្វថ្ងៃមានសេចក្ដីក្ដៅក្រហាយលំបាកដោយក្រៃលែងនឹងថ្លែងជំរាបលោកមិនអស់ទេ ជួនកាលគ្រាន់តែគោក្របីចូលទៅក្នុងទីដីដែលពីដើមជាដីរបស់យើងប្រឹងគាស់រានទាំងនោះ សូម្បីតែ ១ ស្របក់ក៏ពុំបានឡើយលុះតែយក

ប្រាក់យ៉ាងតិចណាស់ ត្រឹម ១ រៀលទៅហោះទើបយកមកវិញបាន...... ។ លោកអគ្គលេខាធិការបានសួរបញ្ជាក់សព្វគ្រប់រួចហើយក៏ឲ្យបែករូបថតពុម្ពជួបសព្វដងរៀងមក ។

ម៉ោង ១៧ យើងបេញពីវត្តនេះបុះកាណូតត្រឡប់មកទីរួមខេត្តឡុងធៀងវិញ ម៉ោង ២១ មកដល់ឡុងធៀង ឈប់សំណាក់នៅភោជនាគារដដែល ។

ក្នុងខេត្តឡុងធៀងនេះមានវត្តខ្មែរតែ ៤ វត្ត នៅសល់វត្តតូច ៗ ពីរទៀតគឺវត្តជះស្ដៅ (យួនហៅ ជួចាក់កាដៅ) ១ វត្តព្រះស្ទឹង (យួនហៅ ជួម៉ាក់យឹង) ១ ទាំង ២ នេះជាវត្តធម្មយុត្តិ គេប្រាប់ថានៅជាខាងឯជើងវត្តបារ៉ាប ថាផ្លូវដែលនឹងទៅវត្តទាំងពីរនេះពិបាកណាស ប្រសិនបើមានបង្គាប់ពីរាជការឲ្យលោកទាំងពីរវត្តនោះមកប្រជុំឯវត្តបារ៉ាប ឬបើមិនបាច់មានបង្គាប់ នោះគ្រាន់តែដឹងដំណឹងក៏គង់មានលោកនឹងនុបាសកខ្លះមកប្រជុំមិនខាន ប៉ុន្តែអ្នករាជការឃុំឥតមានឲ្យដំណឹងអ្វីសោះសូម្បីតែវត្តបារ៉ាប នឹងវត្តភ្នំបាថេទាំង ២ នេះក៏ទើបតែនឹងបានដឹងដំណឹងជាក់មុននេះ ១ ថ្ងៃប៉ុណ្ណោះ ។

## ខេត្តរ៉ាច់យ៉ា

ថ្ងៃពុធ ២៩ ណោវែម ១៩៣៣ (១២ កើតមិគសិរ)

ម៉ោង ៩ (ព្រឹក) យើងចេញពីទីរួមខេត្តឡុងធៀងឆ្ពោះទៅខេត្តរ៉ាប់យ៉ា (ខ្មែរហៅ ខេត្តក្រមួនស) ។ លុះចេញផុតពីទីរួមខែត្របន្តិចទៅ ក្រឡេកមើលទៅទីខាងផ្លូវទាំងឆ្វេងស្តាំ ឃើញសុទ្ធតែដំណាំ របស់អ្នកស្រុកដាំតាន់តាប់ក្បែរផ្លូវរាជការ ទៅសល់ដីទំនេរពីចិញ្ចើមថ្នល់ទៅប្រហែលជា ២ ម៉ែត្រប៉ុណ្ណោះ ក្រៅពីនោះឥតមានដីទំនេរឡើយ ឃើញសុទ្ធសឹងតែដំណាំ ដាំលើដីទីខ្ពស់ដែលផុតពីទឹកលិច ទៅទល់ទើសនឹងវាលស្រែ នឹងមាត់ព្រែក ដំណាំនោះច្រើនតែក្រូចផ្អែម ចេក ម្នាស់ អំពៅ នឹងដំឡូងមី (ដែលស្រុកយើងឯអាយហៅថាដំឡូងឈើ ឬ ដែលស្រុកខ្លះហៅថាដំឡូងបារាំង ជារបស់សំខាន់មួយយ៉ាង របស់អ្នកកូសាំងស៊ីន យកមើមស្ងោបរិភោគក៏បាន ធ្វើជាម្សៅក៏បាន) ក្រៅពីនេះ មានដំណាំវាយរងខ្លះទៀតដោយអន្លើ ៗ ។ បម្ងាយផ្លូវជាង៥០គីឡូម៉ែត្រ នោះមានផ្ទះលំនៅក្តី ឆ្ងាយ ៗ

ពីផ្ទះពីភូមិក្ដី ក្រឡេកមើលទៅទីទាំងសងខាងផ្លូវ ឥតមានប្រទះ
ឃើញដើមឈើ ឬស្មៅត្រែងអ្វីដែលដុះតាមទំនើងជាព្រៃផ្សៃ
ឥតអំពើឡើយ ឃើញសុទ្ធតែដំណាំមានប្រយោជន៍ទាំងអស់
គួរទុកជាគំរូនៃការរបរឲ្យអស់ប្រជាជនគ្រប់ស្រុក ដែលបាន
ទៅឃើញហើយយកដម្រាប់តាម ឬបើនៅទីដំបន់ស្រុកភូមិរបស់
ខ្លួនមានដីដែលល្មមដាំដំណាំអ្វីមួយកើតដែរ ហើយមិនដាំ
ទុកឲ្យនៅទំនេរឥតអំពើ ព្រោះខ្លួនជាមនុស្សខ្ជិលរៀងមក ក៏
នឹងមានអៀនខ្មាសយ៉ាងខ្លាំង លុះត្រឡប់មកដល់ស្រុកខ្លួនវិញ
នឹងប្រែក្លាយជាមនុស្សមានឧស្សាហ៍ព្យាយាមឡើងពុំខាន ។
ប៉ុន្តែទៅទីដំបន់ទាំងនេះមិនឃើញមានផ្ទះខ្មែរទេ ឃើញមាន
សុទ្ធតែផ្ទះយួន យួរ ៗ ឃើញមានផ្ទះបិនខ្លះដោយអន្លើ ៗ
ឃើញមានវិហារពួកកោដាយច្រើនអន្លើ ដែលដឹងថាជាវិហារ
ពួកកោដាយបាននោះ ដោយមានរូបស្វស្តិកៈដាក់លើដម្បូល
ជាសំគាល់ ។

ម៉ោង ១១ ដល់ទៅទីរួមខេត្តរ៉ាប់យ៉ា យើងហួសចូលទៅវត្តឧដុង្គមានជ័យ[1] (យួនហៅ ជួជឹកឡឹង វត្តព្រះធំ) ធ្វើភត្តកិច្ចនៅវត្តនេះ ។ លោកអគ្គលេខាធិការទៅសំណាក់ឯភោជនាគាររ៉ាប់យ៉ា ។ ម៉ោង១៤ ប្រជុំក្នុងវត្តឧដុង្គមានជ័យនេះ មានពួកបព្វជិតនឹងគ្រហស្ថប្រហែលជាង ១០០ នាក់មកប្រជុំ មានលោកភិក្ខុ១រូបឈ្មោះងង់ រៀនបានសញ្ញាបត្រពីសាលាវត្តលង្កាក្រុងភ្នំពេញក្នុងឆ្នាំ១៩២៩ សព្វថ្ងៃធ្វើជាគ្រូបង្រៀននៅសាលាវត្តនេះ មានកុមារជាតិខ្មែរជាសិស្សសាលាចំនួន២០ នាក់ ។ យើងបាននិយាយពន្យល់ដោយសព្វគ្រប់រួចហើយបានហៅកុមារសិស្សសាលានោះខ្លះមក ឲ្យមើលសៀវភៅព្រមទាំងចោទបំណោទលេខខ្លះយ៉ាងស្រាល ៗ រួចហើយចែកសៀវភៅឲ្យពួកកុមារទាំងនោះ ហើយឲ្យចែករូបផ្តិតពុម្ពរូបវត្តឯទៀត ៗ រៀងមក ។

ម៉ោង ១៧ ចេញពីវត្តនេះទៅវត្តអង្គជុំនៅជាខាងត្បូងជាប់នឹងទីរួមខេត្ត ។ វត្តនេះមានបព្វជិតតែ ៣ រូប នៅជុំវិញ

---

១ អ្នកស្រុកច្រើនហៅថា វត្តចម្ការត្រើយខាងជើង ឬ វត្តត្រើយខាងជើង ។

វត្តមានច្រើនតែផ្ទះឃ្លួននឹងផ្ទះបិទ ផ្ទះខ្មែរមានតិចណាស់ មានមនុស្សមកប្រជុំប្រហែលជាង៥០នាក់ ។ យើងបាននិយាយពន្យល់ហើយឲ្យបែករូបផ្តិតពុម្ព រូបត្រឡប់មកសំណាក់ឯវត្តឧដុង្គមានជ័យ លោកអគ្គលេខាធិការទៅសំណាក់ឯភោជនាគារ ។

ថ្ងៃព្រហស្បតិ៍៣០ ណោវ៉ែម ១៩៣៣ (១៣ កើតមិគសិរ)

ម៉ោង ៨ កន្លះ (ព្រឹក) យើងចេញពីទីរួមខេត្តទៅវត្តអូរជុំក្នុងឃុំអាបណ្ដុក (ខ្មែរហៅឃុំអំពាច[១] វែង) ម៉ោង ៩ កន្លះដល់វត្តនេះ ។ ក្នុងទីប្រជុំនេះ មានបព្វជិតវត្តឯទៀត ១០វត្តជា ១១ នឹងវត្តនេះ មនុស្សដែលមកប្រជុំប្រហែលជាង ៣០០ នាក់ ។ មានលោកភិក្ខុ ១ រូបឈ្មោះលី មានសញ្ញាបត្រសាលាវត្តលង្កាក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៣៣នេះ សព្វថ្ងៃធ្វើជាគ្រូបង្រៀននៅសាលាវត្តនេះ មានកុមារសិស្សសាលាបំនួន ៤៦ នាក់ ។ យើងបាននិយាយពន្យល់ដោយសព្វគ្រប់ព្រមទាំងឲ្យពួកកុមារ

---

១ ពាក្យថា អំពាច នេះប្រែថា ខ្វាច គឺខ្វាចឬថ្នាក់ដែលក្របីដេក ជាពាក្យពួកខ្មែរខេត្តក្រមួនសនឹងខ្មែរស្រុកស្វាយទង ។

មើលសៀវភៅ ហោទបំណោទលេខហើយឡ្យបែករូបផ្តិតពុម្ពរូប ហើយធ្វើភត្តកិច្ចនៅវត្តនេះ ។

ម៉ោង ១៣ កន្លះ បេញពីវត្តនេះត្រឡប់មកឯវត្តកំពង់ប៊ិន ក្នុងឃុំឃិញដាំង ដែលនៅខាងអាយឯណោះវិញ ម៉ោង ១៤ កន្លះ ដល់វត្តនេះ ។ ក្នុងទីប្រជុំនេះ មានបព្វជិតវត្តឯទៀត ២ វត្តជា ៣ នឹងវត្តនេះ មនុស្សដែលមកប្រជុំក្នុងទីនេះ មានជនជាតិខ្មែរ យួន ចិនប្រុំស្រុកប្រុស្សីគ្នាប្រហែលជាង ៤០០ នាក់ មាត់ទ្រហឹង អឺងកងឥតសណ្តាប់ធ្នាប់ អ្នកណាឃាត់ក៏មិនស្តាប់ ស្ទើរតែនឹង និយាយពន្យល់ការអ្វីមិនកើត ។ មានគ្រូបង្រៀនម្នាក់ឈ្មោះ សែម កាលនៅជាបព្វជិតបានទទួលសញ្ញាបត្រសាលាវត្តលង្កា ក្រុងភ្នំពេញ ពីក្នុងឆ្នាំ ១៩៣១ សព្វថ្ងៃធ្វើជាគ្រូបង្រៀនសាលា វត្តនេះ មានកុមារជាសិស្សសាលាបំនួន ២០ នាក់ ។ លោក ចៅហ្វាយខណ្ឌជាតិខ្មែរ (ឈ្មោះត្រឹង-គូ) ធ្វើជាចៅហ្វាយខណ្ឌ គៀងទឿង (ខណ្ឌនេះ) ២៦ ឆ្នាំមកហើយ ក៏អញ្ជើញមកក្នុង ទីប្រជុំនេះដែរ ។ យើងបានធ្វើការសព្វគ្រប់រួចហើយក៏ត្រឡប់ មកឯទីរួមខេត្តវិញ (សំណាក់នៅវត្តខង្គមានជ័យ) ។

ថ្ងៃសុក្រ ១ ដេសម ១៩៣៣ (១៤ កើតមិគសិរ)

ម៉ោង ៨ (ព្រឹក) ចេញទៅវត្តក្លាងមឿង(១) ក្នុងឃុំមិញលឿង ម៉ោង ៨ កន្លះដល់វត្តនេះ ។ លោកចៅហ្វាយខណ្ឌគៀងទៀងអញ្ជើញមករង់ចាំយើងនៅវត្តនេះមុន ។ មានលោកចៅអធិការវត្តកំពង់ចិនថ្មីព្រមទាំងភិក្ខុសាមណេរនឹងពួកគ្រហស្ថជើងវត្តនោះខ្លះមកប្រជុំក្នុងទីនេះដែរ ។ ក្នុងទីប្រជុំនេះមានសុទ្ធតែខ្មែរនឹងកូនចិន ចៅចិនខ្លះ មិនឃើញមានយួនទេ មនុស្សដែលមកប្រជុំទាំងបព្វជិតនឹងគ្រហស្ថប្រហែលជាង ៣០០ នាក់ មានសណ្ដាប់ធ្នាប់សុភាពរាបសាស្ងៀមស្ងប់របបរៀបរយស្រួលណាស់ ប្រហែលជាលោកចៅហ្វាយខណ្ឌមករៀបចំមុន ដោយឃើញថាការប្រជុំនៅវត្តកំពង់ចិនពីថ្ងៃម្សិលឥតរបបណាស់ ព្រោះមានពួកយួនចូលមកលាយឡំប្រប្លូកប្របល់ ឬក៏ដោយសារអំណាចលោកគ្រូចៅអធិការវត្តក្លាងមឿងនេះផងទេដឹង

១ ក្លាងមឿង ជាពាក្យសៀម ខ្មែរថា កណ្ដាលស្រុក ប្រហែលជាកាលដែលពួកសេនាយោធាសៀមលើកមកច្បាំងនឹងយួន សៀមបានជួយឧបត្ថម្ភពួកខ្មែរខេត្តក្រមួនសនេះហើយឲ្យឈ្មោះវត្តនេះជាពាក្យរបស់ខ្លួនទុកជាកេរ្តិ៍មកឯអនាគតកាលទេដឹង ។

ព្រោះលោកគ្រូនេះ សម្តេចព្រះមហាសង្ឃរាជទ្រង់ព្រះនាមទៀង (ក្នុងព្រះកោដ្ឋ) បានតាំង[illegible]ណាស័ក្តិឲ្យជាព្រះមហាបទុមវង្សា (ធម្មបរិយាសេដ្ឋាមហាគណៈ) តាំងពីក្នុងឆ្នាំ ១៩០៦ ដល់មកឆ្នាំ ១៩០៧ មានប្រទានសញ្ញាបត្រ ១ ទៀតឲ្យមានអំណាចធ្វើជាឧបជ្ឈាយ៍លើវត្តក្រៅ ៧ វត្តជា ៨ នឹងវត្តក្លាងមឿងនេះ ។ មានពួកឧបាសកទាយកជាបំណុះ (ជើងវត្ត) ដល់ ៤ ឃុំ មានផ្ទះប្រហែលជិត ១ ពាន់ខ្នង មានចំនួនមនុស្សប្រហែលជាង ២ ពាន់ ៥០០ នាក់ ជាសិស្សស្តាប់ឱវាទលោកទាំងអស់ ។ សព្វថ្ងៃលោកកំពុងឲ្យសង់សាលារៀន ១ ធ្វើដោយឥដ្ឋ បំរុងចាំឲ្យតែលោកភិក្ខុ ១ រូបឈ្មោះរិង ជាសិស្សរបស់លោក ដែលកំពុងនៅរៀនឯសាលាវត្តលង្កាក្រុងភ្នំពេញនៅឡើយ កាលបើលោកភិក្ខុរិង បានសញ្ញាបត្រហើយ លោកនឹងតាំងឲ្យមានការសិក្សាតាមរបៀបដែលរាជការរៀបចំនោះតទៅ ។ យើងបានធ្វើការដោយសព្វគ្រប់ហើយក៏សម្រេចភត្តកិច្ចនៅវត្តនេះ ។

ម៉ោង ១២ យើងចេញពីវត្តក្លាងមឿង ត្រឡប់មកឯវត្តក្លាងឡឹង[១] ដែលនៅខាងអាយឯណោះវិញ ម៉ោង ១២ កន្លះ ដល់វត្តក្លាងឡឹង ក្នុងឃុំមិញលឿងដែរ ។ មានពួកបព្វជិតវត្តដង្ហិត ១ មកប្រជុំក្នុងទីនេះដែរ ក្នុងទីប្រជុំនេះមានបណ្ដាជនប្រហែលជាង ២១០ នាក់ ។ លោកគ្រូចៅអធិការវត្តក្លាងឡឹងនេះធ្វើជាឧបជ្ឈាយ៍លើវត្តក្រៅ ៥ វត្តជា ៦ នឹងវត្តនេះ ។ យើងបានធ្វើការរូបសព្វគ្រប់ហើយក៏ត្រឡប់មកឯទីរួមខេត្តវិញ ។

ម៉ោង ១៥ កន្លះ យើងចុះកប៉ាល់ (សាល្វប) រាជការចេញពីទីរួមខេត្តតាមព្រែកធំ ១ (ដែលបែកពីព្រែកបារ៉ាបទៅ) បើកសំដៅទៅខណ្ឌថាញ់បិញ់ ម៉ោង ២៤ (អាធ្រាត្រ) ដល់ទៅកំពង់យិញភូ ក្នុងខណ្ឌហាញ់បិញ កប៉ាល់ឈប់ចតនៅនោះដោយឃើញទឹកនាចរាក់ពេកមិនហ៊ានទៅ យើងជួលទូកយួនឲ្យបែរជូនទៅរកវត្តសិង ព្រោះកប៉ាល់តូចនឹងសិងមិនកើត

១ ក្លាងឡឹង ជាពាក្យសៀមនឹងយួនលាយគ្នា ខ្មែរថា កណ្ដាលធំ ប្រហែលជាសំដៅសេចក្ដីថា វត្តធំកណ្ដាលស្រុក ទេដឹង ។

ទុកកន្លែងបន្ទប់ជូនលោកអគ្គលេខាធិការ ។ យួនបែរទូកជូនយើងទៅសិងឯវត្តតូប ១ ហៅថា វត្តង៉ាបា (វត្តពាមបី) ។

ថ្ងៃសៅរ៍ ២ ធ្នូ ១៩៣៣ (១៥ កើតមិគសិរ)

ម៉ោង ៧ កន្លះ (ព្រឹក) កប៉ាល់ចេញពីកំពង់យិញភូ ទៅកំពង់ភ្នៀកឡង់ (សំដៅទៅវត្តកោះដូង) ម៉ោង ៩ ដល់ភ្នៀក-ឡង់ កប៉ាល់ត្រូវឈប់ចតនៅនេះ ព្រោះព្រែកដែលត្រូវចូលទៅវត្តកោះដូងនោះតូចហើយរាក់ណាស់ ។ គេយកទូក ២ មកចាំទទួលយើងនៅទីនេះ យើងចុះទូកចូលតាមព្រែកតូចទៅវត្តកោះដូង ក្នុងឃុំយិញភូ ខណ្ឌថាញ់បិញ ម៉ោង ១១ ដល់ទៅវត្តកោះដូង ។ ក្នុងទីប្រជុំនេះ មានពួកបព្វជិតវត្តក្រៅ ៥ វត្តជា ៦ នឹងវត្តនេះ មនុស្សដែលមកប្រជុំទាំងអស់ប្រហែលជាង ៥០០ នាក់ ។ មានលោកភិក្ខុ ១ រូបឈ្មោះសឺន-កេត មានសញ្ញាបត្រសាលាវត្តលង្កាក្រុងភ្នំពេញក្នុងឆ្នាំ ១៩៣២ សព្វថ្ងៃធ្វើជាគ្រូបង្រៀននៅវត្តកោះដូងនេះ មានកុមារសិស្សសាលាចំនួន ៣៥ នាក់ ។ យើងបានធ្វើការសព្វគ្រប់ហើយក៏ត្រឡប់

មកឯភើ្មកឡង់វិញ ម៉ោង ១៥ កន្លះបេញកប៉ាល់ពីភើ្មកឡង់តាមផ្លូវដើមមកវិញសំដៅទៅវត្តង៉ាងយឿ ក្នុងឃុំយិញឡុក ម៉ោង ១៧ ដល់វត្តង៉ាងយឿ ។ ក្នុងទីប្រជុំនេះមានពួកបព្វជិត ៦ វត្តជា ៧ នឹងវត្តនេះ មានបណ្ដាជនមកប្រជុំប្រហែលជាង ១០០ នាក់ ។ យើងបានធ្វើការសព្វគ្រប់ហើយបេញកប៉ាល់តាមផ្លូវដើមមកឯទីរួមខេត្តវិញ លុះដល់មកទីរួមខេត្តមិនបានឈប់ទេ បើកកប៉ាល់បង្ហួសសំដៅទៅឃុំបិញសឹង ខណ្ឌគៀងហាវ បើកកប៉ាល់តាមព្រែកជីករំហូតពេញ ១ យប់ទាល់ព្រឹក ។

ថ្ងៃអាទិត្យ ៣ ធ្នូ ១៩៣៣ (រោចមិគសិរ)

ម៉ោង ៦ (ព្រឹក) ដល់ទៅកំពង់វត្តបិទមាស ឃុំបិញសឹង ខណ្ឌគៀងហាវ ឈប់បតកប៉ាល់នៅកំពង់នេះ ។ ទីដំបន់នេះជាដីថ្មី គេប្រាប់ថា កាលពីដើមសុទ្ធតែព្រៃ រាជការទើបនឹងបាត់ការឲ្យជីកព្រែកនេះ៩ឆ្នាំមកហើយ ។ ពួកខ្មែរដែលមកនៅគាស់រានដីត្រង់ទីដំបន់នេះ មិនមែនសុទ្ធតែខ្មែរខេត្តរ៉ាប់យ៉ា (ក្រមួនស)ទេ ខ្មែរមកពីខេត្តឯទៀតៗក្នុងដែនកូសាំងស៊ីន

ក៏មានច្រើន មានខ្មែររួបរួមទាំងអស់ប្រហែល ២៥០ ផ្ទះ ក្រៅពីនោះសុទ្ធតែយួន ។ នៅទីដំបន់នេះ ត្រង់កន្លែងខ្លះមានដីមិនទាន់អស់ជាតិប្រែនៅឡើយ មានទឹកជូរ ដីត្រង់ណាដែលល្អ ៗ ច្រើនបានទៅពួកយួនគាស់រាន ឯពួកខ្មែរច្រើនបានតែដីដែលមានទឹកជូរ ធ្វើស្រែមិនសូវកើត ហេតុទាំងនេះជាប្រស្នាគួរឲ្យខ្មែរអ្នកមានប្រាជ្ញា អាចគិតឃើញតាមការពិតបានដោយងាយ ៗ ហើយគួរឲ្យនឹកខ្លាសយួនពេកណាស់ ។ វត្តបិទមាសនេះកើតមានឡើងដោយពួកខ្មែរទាំងនេះ ព្រមព្រៀងគ្នាប្ដឹងសុំអនុញ្ញាតអំពីរាជការ ៗ ក៏បានបេញសំបុត្រអនុញ្ញាតឲ្យក្នុងឆ្នាំ ១៩៣៣ នេះ សព្វថ្ងៃមិនទាន់មានកុដិសាលាវិហារមាំទាំនៅឡើយទេ គ្រាន់តែមានទីសេនាសនជាបណ្ដោះអាសន្នប៉ុណ្ណោះ ព្រោះខ្មែរអ្នកស្រុកនេះកំពុងទាល់ក្រណាស់ ។ វត្តបិទមាសនេះមានភិក្ខុ ៤ រូបទាំងលោកចៅអធិការផង មានសាមណេរ ២ រូប មានក្មេងសិស្សវត្ត ២០ នាក់ មានមនុស្សមកប្រជុំក្នុងទីនេះប្រហែលជាង ២០០ នាក់ ។ បន្ទាប់អំពីសេចក្ដីពន្យល់របស់អគ្គលេខាធិការមក ខ្ញុំបាននិយាយបំភ្លឺអំពីទោសនៃសេចក្ដីខ្ជិល

ទោសលេងល្បែងភ្នាល់ ទោសផឹកទឹកស្រវឹងជាដើម ឲ្យអ្នកទាំងនោះស្ដាប់ រួចហើយឲ្យបែករូបផ្ដិតពុទ្ធរូបវត្តឯទៀត ៗ ។ ម៉ោង ១៣ យើងចេញពីវត្តបិទមាសត្រឡប់មកទីរួមខេត្តវិញ (សំណាក់នៅវត្តឧដុង្គមានជ័យ) ។

ថ្ងៃចន្ទ ៤ ដែសម ១៩៣៣ (២ កេចមិគសិរ)

ម៉ោង ៨ (ព្រឹក) យើងចេញពីទីរួមខេត្តប៉ាប់យ៉ាបំពោះទៅខេត្តបាក់លីវ (ខ្មែរហៅខេត្តពោលៀវ) បំរុងនឹងស្រូតទៅធ្វើភត្តកិច្ចឯទីរួមខេត្តសុកត្រាំង ប៉ុន្តែដល់ឃើញថាក្រែងទៅមិនទាន់នឹងហួសពេលបង្ហាន់ ក៏ឈប់ឆាន់តាមផ្លូវសិន ម៉ោង ១២ ដល់ទៅទីរួមខេត្តសុកត្រាំង (ខ្មែរហៅខេត្តឃ្លាំង) ឈប់សម្រាកនៅនោះអស់ ២ ម៉ោង លុះដល់ម៉ោង ១៤ យើងចេញពីទីរួមខេត្តសុកត្រាំងឆ្ពោះទៅខេត្តបាក់លីវ ម៉ោង ១៥ កន្លះដល់ទៅទីរួមខេត្តបាក់លីវ យើងហួសទៅសំណាក់ឯវត្តខ្វែងប្របែលលោកអគ្គលេខាធិការសំណាក់នៅភោជនាគារបាក់លីវ ។



ព្រះចេតិយនៅក្រុងបាគន (ភូមា) បញ្ចុះព្រះនលាតធាតុ នឹងព្រះទន្តធាតុ
ព្រះពុទ្ធអង្គ សាងក្នុងកាល ព ស. ៩៥០ ។

# ខេមាខេមសរណកថា

ព្រះមហាពិទូរ ក្រសេម រៀបរៀង

# ខេមាខេមសរណគាថា

ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា
នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ
នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

មនុស្សទាំងឡាយដ៏ច្រើន កាលត្រូវសេចក្ដីភិតភ័យគ្របសង្កត់ហើយ រមែងដល់នូវភ្នំខ្លះ ព្រៃខ្លះ អារាមខ្លះ រុក្ខ-ចេតិយខ្លះ ជាសរណៈទីពឹង តែសរណៈនោះមិនក្សេម សរណៈនោះមិនឧត្ដម អ្នកអាស្រ័យសរណៈនោះហើយ មិនផុតចាកទុក្ខទាំងពួងទៅបាន ។

យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ
ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សះណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

បំណែកឯអ្នកឯណាដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈទីពឹង ព្រមទាំងឃើញដោយបញ្ញាដ៏ប្រពៃនូវអរិយសច្ច ៤ គឺទុក្ខ ១ ហេតុឲ្យកើតទុក្ខ ១ សេចក្ដីកន្លងបង់នូវទុក្ខ ១ ផ្លូវមានអង្គ ៨ ប្រការដ៏ប្រសើរជាហេតុដល់នូវសេចក្ដីរលត់ទុក្ខ ១ សរណៈនោះឯង ទើបក្សេម សរណៈនោះទើបឧត្ដម អ្នកអាស្រ័យសរណៈនោះហើយ រួចចាកទុក្ខទាំងពួងបានដោយពិត ។

ព្រះគាថានេះជាពុទ្ធភាសិត មានមកក្នុងគម្ពីរធម្មបទខុទ្ទកនិកាយ ព្រះពុទ្ធឃោសាចារ្យតែងសេចក្ដីអធិប្បាយប្រកបនឹងព្រះពុទ្ធភាសិតគាថានេះទុកថា សម្ដេចព្រះបរមគ្រូទ្រង់ទូន្មានអគ្គិទត្តព្រាហ្មណ៍ ដែលអំពីដើមជារាជបុរោហិតរបស់ព្រះរាជាកោសល មានសេចក្ដីនឿយណាយក្នុងភេតយវាស ទើបក្រាបថ្វាយបង្គំលាចាកដំណែងរាជការ ចេញទៅបួសកាន់ភេតជាឫសី អាស្រ័យនៅទីមួយអន្លើរវាងតដែនគរអង្គៈមគធៈនឹងនគរកុរុរដ្ឋៈ ៗ គ្រានោះមានមនុស្សប្រុស ៗ ជាច្រើនជ្រះថ្លា ទៅបំណុះបុះបួលជាអន្ដេវាសិកនៅឧបដ្ឋាកនឹងរៀនសូត្រលទ្ធិធម៌

ក្នុងសំណាក់អគ្គិទត្ត ៗ បានប្រៀនប្រដៅសិស្សនឹងប្រជាជន ដែលរាប់អានខ្លួនថា ឲ្យដល់នូវសរណៈគឺ បព៌ត វនៈ អារាមរុក្ខចេតិយ និងរូបបាកទុក្ខទាំងពួង ។

គ្រាមួយនោះ ព្រះបរមសាស្ដាស្ដេចទៅកាន់ទីនោះ ប្រោស ប្រទានព្រះធម៌ទេសនា សំដែងអំពីរឿងសរណៈដូចពោលមក ហើយ ឫសីអគ្គិទត្តនឹងមនុស្សក្នុងគណៈរបស់លោកជាច្រើនគ្នា បានលុះភូមិធម៌ជាន់ខ្ពស់ក្នុងព្រះពុទ្ធសាសន៍ សុខចិត្តលើក លែងសរណៈដើមរបស់ខ្លួនចេញហើយស្ម័គ្រចូលជាពុទ្ធសាស-និក ទទួលរាប់អានព្រះពុទ្ធអង្គមួយអន្លើនឹងព្រះធម៌ ព្រះសង្ឃ ជាសរណៈប្រចាំជីវិតរបស់ខ្លួន ។ សេចក្ដីពិស្ដារនៃរឿងនេះ មាននៅក្នុងអគ្គិទត្តបរោហិតវត្ថុ គម្ពីរធម្មបទដ្ឋកថា ។

លំដាប់នេះ នឹងពណ៌នាតាមក្រសែសេចក្ដីនៃពុទ្ធភាសិត គាថានេះតទៅ កាលមកពីគ្រោះមើលរូបសេចក្ដីក្នុងគាថានេះ ហើយ បានសេចក្ដីជា ២ ផ្នែក ផ្នែកទី ១ និយាយដោយសរណៈ ដ៏មិនក្សេមមិនឧត្ដម; ផ្នែកទី ២ និយាយដោយសរណៈដ៏ក្សេម ឧត្ដមខ្ពង់ខ្ពស់ ក៏សរណៈដែលមិនក្សេមខ្ពង់ខ្ពស់នោះទ្រង់លើក

ឡើងកាន់ទេសនាត្រឹមតែ បព៌ត វនៈ អារាម រុក្ខចេតិយ ក្រៅអំពីនេះមិនបានពោលដល់ ព្រោះហេតុអ្វី ការរាប់អានព្រះជាម្ចាស់ប្រភេទដែលគ្មានរូប នឹងប្រភេទដែលមានរូបរហូតដល់តិរច្ឆានជំពូកខ្លះនឹងវត្ថុដទៃប្លែក ៗ ដែលជាសរណៈរបស់មនុស្សក៏មានមកខ្លះហើយ តាំងអំពីមុនពុទ្ធកាល ការដែលព្រះអង្គមិនលើកឡើងកាន់ទេសនាក្នុងវេលានោះ ព្រោះសរណៈអំបាលនោះមិនចូលក្នុងបំណោមសរណៈរបស់អ្នកស្ដាប់ទេសនាបទនេះ ។

បព៌តក្នុងទីនេះបង្អួលត្លយ៉ាងជា ភ្នំឥសិគិលិ ភ្នំវេបុល ភ្នំវេភារ ។ វនៈបាននឹងព្រៃធំ ដូចយ៉ាងព្រៃមហាវ័ន ព្រៃសិង្គាលវ័ន ។ អារាមបាននឹងសួនឧទ្យាន ដូចយ៉ាង សួនវេឡុវ័នសួនជីវកម្ពវ័ន ។ រុក្ខចេតិយ បាននឹងដើមឈើធំមួយដើម ៗ ដ៏ជាចេតិយ (គោលបារិក) គឺដើមឈើចាស់ទុំ ឈើដែលអស្ចារ្យ ដែលគេរាប់អានថាសក្តិសិទ្ធ ដូចយ៉ាងឧទេនចេតិយ គោតមចេតិយ, ត្លយ៉ាងអំបាលនេះមាននៅក្នុងប្រទេសគណ្ឌៀ (មជ្ឈិមប្រទេស) ក្នុង

សម័យពុទ្ធកាល មានមនុស្សនិកររាប់អានយកជាសរណៈមកហើយ ។

បំណែកឯសរណៈដែលក្រេមកំពូលក្នុងទីនេះ សំដៅយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នឹងរួមទាំងការឃើញអរិយសច្ច ៤ ដោយបញ្ញាដ៏ប្រពៃផង បែបនេះក៏មានមនុស្សនិកររាប់អានយកជាសរណៈសម្រាប់ជីវិតមកហើយដែរ ។ ព្រះពុទ្ធជាម្ចាស់ដ៏ប្រេះជាផូវឡែសន្និដ្ឋានក្នុងរឿងនេះខ្លះថា ព្រះពុទ្ធអង្គទ្រង់ទទួលវត្ថុទាំងពួងបណ្ដាដែលមនុស្សផ្ចង់ចិត្តរាប់អានថា ជាសរណៈរបស់ខ្លួនទាំងអស់ នឹងបានទ្រង់យល់ព្រមខ្លះ បដិសេធខ្លះក៏ទេ តែមានអាការប្លែកគ្នាតែត្រង់ដែលថា សរណៈ ១ យ៉ាងមិនក្រេម, សរណៈ ១ យ៉ាងក្រេមប៉ុណ្ណោះ; ក៏ឯសេចក្ដីប្លែកគ្នាត្រង់នេះជាគ្រឿងសំគាល់សរណៈដោយពោលរូបចុងតែម្ដងដើម្បីនឹងស្រិតឲ្យឃើញប្រភេទនៃសរណៈច្បាស់លាស់ឡើង ទាំងទុកជាគោលសម្រាប់នឹងពិចារណាជ្រើសរើសសរណៈបានយ៉ាងល្អផង ។

សរណៈរបស់មនុស្សក្នុងលោកនេះ មានច្រើនបែបច្រើនយ៉ាងណាស់ យ៉ាងឯកឯងមិនមានទាក់ទងនឹងរបស់យ៉ាងដទៃ

ក៏មាន យ៉ាងឈាយឡើគឺទាក់ទិននឹងវិត្ថុយ៉ាងដទៃក៏មាន មាន ជាតិកំណើតនឹងប្រវត្តិផ្សេងគ្នាខ្លះ ប្រហែលគ្នាខ្លះ ប្រកបដោយ រឿងមុខគួរបេះដូង មុខគួរអស្ចារ្យ មុខគួរពិផល ជាច្រើនក្បួន ពាសពេញទាំងសកលលោក គឺក្នុងទ្វីបជម្ពូ ទ្វីបអឺរុប ទ្វីប អមេរិកាន់ សុទ្ធតែមានទាំងអស់ វិចិត្រពិស្តារដោយលទ្ធិប្លែក ៗ ផុតវិស័យនឹងប្រមូលរូបរាប់ឲ្យសព្វគ្រប់ តែទោះបីដូចម្ដេច ក្ដី សរណៈទាំងនោះគង់រួមនៅក្នុងប្រភេទ មិនក្បៀមនឹងក្បៀម ប៉ុណ្ណោះ ក្រៅអំពី ២ យ៉ាងនេះគ្មាន ហេតុដូច្នោះទើបគួរបំប្រួញ ឲ្យខ្លីជាបំផុតថា ក្នុងលោកនេះមានសរណៈតែត្រឹម ២ ប្រភេទ ប៉ុណ្ណោះ នឹងរកសរណៈដែលប្លែកអំពីនេះទៅទៀតគ្មាន ។ ក៏ការ ដែលនឹងពិភាក្សារកឲ្យឃើញទៅថា យ៉ាងម្ដេចជាសរណៈមិន ក្បៀម យ៉ាងម្ដេចជាសរណៈក្បៀម ឬនឹងប្រៀបធៀបសរណៈទាំង ពីរនេះជាមួយគ្នា ដើម្បីនឹងពិសោធ្យមើលឲ្យដឹងយ៉ាងណាប្រសើរ មានវិសេសជាងគ្នាត្រង់ណា ទាំងនេះត្រូវរកគោលចារិក តឹកតាងដែលពិតប្រាកដយកមកវិនិច្ឆ័យ ហើយតោងដឹងជាមុន ថា ការដែលកាន់សរណៈនោះដើម្បីអ្វី កាន់ហើយនឹងបានផល

ដូចបំណងឬទេ ផលនោះតើជាឧត្តមសម្រេចសម្រប ផុតបំណង
របស់មនុស្សហើយឬនៅ ត្រូវប្រមូលបញ្ចូលមករកគោលវិនិច្ឆ័យ
ទើបនឹងគួរដោយផ្លូវពិចារណា ការដែលគ្រាន់តែពិចារណារក
ខុសរកត្រូវ (ធម្មវិចយ) ព្រះជាម្ចាស់មិនហាម ឯការដែល
ហោលុផ្លូវពិចារណាដោយខ្លួនឯង ត្រឹមតែចាំស្តាប់ពាក្យនិន្ទា
ឬសរសើរអំពីសំណាក់នៃបុគ្គលអ្នកមិនកាន់ ឬអំពីសំណាក់នៃ
បុគ្គលដែលកាន់ត្រុក ៗ ទៅតាម ៗ គ្នាថា យ៉ាងនេះល្អ យ៉ាង
នេះមិនល្អដូច្នេះ មិនគួរនឹងប្រញាប់ឃើញសមផង ព្រោះប្រាស
ចាកបញ្ញាពិចារណាស៊ើបសាកឲ្យច្បាស់លាស់ ជាការទាស់
នឹងដំឡើជីវិតរបស់ខ្លួន ដែលយកទៅផ្គូរនឹងសរណៈសិងគត
ខ្លិមសារ តែដោយច្រើន ៗ តែបដិសេធដាត់ទាត់តែម្តង មិនបង់
យកមកផ្ទឹមនឹងសរណៈដែលខ្លួនកាន់ ដោយវាយដំឡើរបស់
គេថាមិនដល់របស់ខ្លួនតែម្តង ថែមទាំងដាក់បញ្ញត្តិមិនឲ្យគិតនឹក
ដល់សរណៈដទៃទំនងដូចជាត្រាប់គ្នា អ្នកណាកាន់សរណៈណា
ក៏ថាសរណៈនោះល្អ នឹងល្អត្រង់ដែលថា ឬល្អត្រង់ដែលឃើញ

ឬល្អត្រង់អាការដែលកាន់ ឬសរណៈនោះល្អមកពីកំណើត មិនបាច់អ្នកណាលើក មិនបាច់អ្នកណាសរសើរ ក៏ល្អឯងជាប្រក្រតី។ ក៏ឃើញតែថា ៗ ទៅ នឹងយកឡប្រាកដត្រង់ណាក៏អិនបាន ហើយនៅមិនប្រាកដទៀតថា អ្នកដែលកាន់សរណៈនោះ ៗ ឃើញល្អមកមុនហើយ ទើបកាន់ជាក្រោយក៏ទេ ដោយប្រើនកាន់ហើយក៏គោងឃើញល្អ ក៏អ្នកណានឹងអាចបដិសេធថា សរណៈដែលខ្លួនកាន់នោះមិនល្អ បើមិនល្អហេតុម្តេចក៏កាន់ ៗ

# បុណ្យប្រគេនកញ្ចប់បាយ
# នៅស្រុកលាវ

## (បុណ្យហ៉ៅខារបដាប់ឌិន) នៅស្រុកលាវ

កាលណាដល់រនោចខែស្រាពណ៍រាល់ឆ្នាំ បណ្ដាមហាជនទាំងឡាយដែលនៅក្នុងនគរលាវ បំពោះអ្នកដែលកាន់តាមសណ្ដាប់ព្រះពុទ្ធសាសនាទាំងអស់ គេតែងធ្វើវិធីបុណ្យ១យ៉ាងហៅតាមភាសាអ្នកស្រុកគេថា (បុណ្យហ៉ៅខារបដាប់ឌិន) ជួនក៏ហៅត្រឹមតែ បុណ្យខារហ៉ៅ ឬបុណ្យឡើនកៅ ដូច្នេះក៏បាន គឺគេសន្មតឈ្មោះបុណ្យនេះតាមរបៀបវិធីដែលគេធ្វើនោះឯង ។ ឯពាក្យថា បុណ្យហ៉ៅខារបដាប់ឌិន ឬបុណ្យខារហ៉ៅនោះប្រែថា បុណ្យធ្វើកញ្ចប់បង្អាន់ដាក់បាត្រ តាមទំលាប់ពីដើមមកគេធ្វើនៅថ្ងៃខែដាប់ខែស្រាពណ៍ បានជាឲ្យឈ្មោះបុណ្យឡើនកៅខ្លះប្រែថាបុណ្យខែស្រាពណ៍ ។

ឯរបៀបដែលគេធ្លាប់ធ្វើនៅគ្រប់ស្រុកនោះដូច្នេះ ចាប់ដើមអំពីថ្ងៃ១រោចខែស្រាពណ៍ បណ្ដាពពួកពុទ្ធសាសនិកជនគឺឧបាសកឧបាសិកា គេតែងនឹកសង្ឃឹមគ្រប់គ្នាថានឹងបានធ្វើបុណ្យខែស្រាពណ៍ ដើម្បីឧទ្ទិស្សផលទៅដល់បុព្វការីបុគ្គលមានមាតាបិតា ជីដូនជីតា មីងមាជាដើម ដែលមានដំណើរព្រាត់ប្រាសទៅ

កាន់បរលោកទាំងប៉ុន្មាន សូម្បីអ្នកមានអ្នកក្របើខ្វះខាតរបស់អ្វីដែលគួរនឹងប្រកបក្នុងកងការកុសលនេះ គេតែងប្រមែប្រមូលខ្វល់ខ្វាយរកសន្សំបំរុងទុករាល់គ្នា ។ លុះដល់ថ្ងៃមុននឹងដាក់បាត្រ ១ថ្ងៃគឺក្នុងថ្ងៃ ១៣ រោចនោះ នៅក្រុងហ្លួងព្រះបាង ពេលព្រឹកគេនាំគ្នាទៅទិញឥវ៉ាណនៅផ្សារទាំងចាស់ទាំងក្មេង ប្រុសស្រីក្តីណា ។ នៅទីវានផ្សារគ្រប់កន្លែង សុទ្ធសឹងដេរដាសដោយរបស់របរបន្លែផ្លែផ្កាគ្រប់យ៉ាង ទាំងមនុស្សម្នាមហាជនក៏មានជាច្រើនណែនណាន់តាន់តាប់ ទាំងសូរសព្ទសំឡេងក៏លាន់ឮគឹកកងរំពងឈូឆរ គួរជាទីទស្សនាការដល់ពពួកមហាជនផងទាំងឡាយពន់ពេក ។

ដល់វេលារសៀលព្រលប់ថ្ងៃនោះ គេរើសយកម្ហូបចំណីណាដែលគួរទុកបានយូរមានបន្លែផ្លែឈើនឹងត្រីសាច់ជាដើមមកធ្វើជាកញ្ចប់ទុកជាស្រេច ទាំងម្លូស្លាបារីឈើគូស ក៏រៀបចំធ្វើជាកញ្ចប់ទុកក្នុងពេលព្រលប់ល្ងាចនោះឲ្យហើយទាំងអស់ ។ លុះដល់ថ្ងៃខែដាច់នោះ អ្នកស្រុកគ្រប់ផ្ទះក្រោកឡើងពីយប់ចាត់ចែង

ធ្វើម្ហូបចំណីស្រស់ដើម្បីនាំទៅប្រគេនដល់ព្រះសង្ឃក្នុងទីព្រះវិ-ហារ ។ រួចដល់ម៉ោង ៦ ព្រឹកមនុស្សម្នាមហាជនទាំងក្មេងទាំងចាស់ប្រញាប់ប្រញាល់រៀបផ្លាស់គ្រឿងសំលៀកបំពាក់សុទ្ធសឹងជារបស់ថ្មីមានដំឡៃច្រើន រៀបតែងខ្លួនស្អាតបាតគួរជាទីជ្រះថ្លារួចអ្នកខ្លះក៏សែង រែក ជញ្ជូនកញ្ចប់បង្អាន់នោះទៅដំកល់ទុកក្បែរថ្នល់ ឬច្រកណា ១ ដែលជាទីគោចរបិណ្ឌបាតនៃពួកភិក្ខុសង្ឃសាមណេររាល់ថ្ងៃទើបអង្គុយចាំដាក់បាត្រលោក ។

ចំណែកខាងភិក្ខុសាមណេរគ្រប់វត្តវិហារ នៅវេលាព្រឹកនោះវាយជួងឬស្គរធំជាសញ្ញាគ្នាពីព្រលឹមម៉ោង៣ឬម៉ោង៤រហ័សរហួនម្នីម្នាគ្រងចីពរគ្រប់អង្គឡើងទៅកាន់ព្រះវិហារថ្វាយបង្គំព្រះសូត្រធម៌មាតិកា ធម្មចក្ក មហាសម័យ បរាភវសូត្រជាដើមតាមសមគួរដល់ពេលវេលា ។ ដល់ម៉ោង៦កន្លះព្រឹកឡើងនាំគ្នានិមន្តចេញទៅបិណ្ឌបាតជាជួរតាមថ្នល់ជាអណ្តាប់អណ្តោយចាស់ខ្ចីដើរសំដៅទៅកាន់ទីកន្លែងដែលខ្លួនធ្លាប់ត្រាច់គោចរ រួចវិលត្រឡប់មកកាន់អារាមវិញ ។ ដល់អស់កិច្ចដាក់បាត្រនេះហើយពួកឧបាសកឧបាសិកានាំយកចំណីចំណុកភោជនាហារ

គឺបង្អែមនឹងបំអាបចូលទៅកាន់វិហារវេរប្រគេនដល់ព្រះសង្ឃ រួបសូត្រធម៌ថ្វាយបង្គំព្រះ សមាទានសីលរួចត្រឡប់ទៅផ្ទះគេវិញ ។

ដល់ពេលព្រលប់ថ្ងៃនោះនៅគ្រប់ផ្ទះគេនិមន្តភិក្ខុសាមណេរទៅសំដែងធម៌ទេសនាផ្លូងវិធីបុណ្យនោះមានទេសនាតាមសាស្ត្រាទសបារមីជាដើម មានភូមិខ្លះក៏នាំគ្នាទៅស្តាប់ធម៌នៅទីព្រះវិហាររក្សាឧបោសថសីលនៅឯវត្តរហូតអស់ ១ យប់នោះ ព្រឹកឡើងរៀបចំបង្ហាត់ថ្វាយព្រះសង្ឃ ហើយទើបទៅផ្ទះវិញ ជាការស្ងួតបុណ្យ ។

ចប់បុណ្យហ៊ីការបជាប់ទិន តែប៉ុណ្ណោះ ។

ភិក្ខុ ស៊ី-អ៊ួន ( សុមនតិស្ស )



ព្រះចេតិយ ប៉ូភណា នៅវត្តឃាំគយី ក្នុងស្រុកព្រហ្មេ (ភូមា) ប្រហែលជាសាង ក្នុងរវាង ព.ស. ៩៥០ ។

នមោ តស្ស ។ មាបន្និបយរិភាយតិ ឥទំ សត្ថា ជេតវ-
នេ វិហរន្តោ មហាភិនិក្ខមនបារមឹ អារព្ភ កថេសិ ។ សត្ថា មោះ
សត្ថុវិបោក សត្ថនាយកោ រឺព្រះអង្គហោងជ័ជានាយកតែងនឹង
នាំនាយសត្វ ជនទាំងឡាយប្រមូលបញ្ចូលទៅឮជ័ផ្លូវអម្រឹត
បុរីស្រីមហាគរនិព្វាន ស្រេចហើយស្តេចគង់សម្រាន្តខាន
នៅឮជ័ព្រះស្រីជេជេតពន សុគន្ធកុដីស្រីមហាវិហារ អារព្ភ
មោះអារម្មណ៍ កត្វា ទើបព្រះអង្គធ្វើឡជាហេតុបន្តិបហើយ ។
មហាភិនិក្ខមនបារមី នឹងមហាភិនិស្ក្រមបន្ទំបារមី ៗ កថេ-
សិមោះ ទេសេសិ ទើបព្រះអង្គសំដែងថ្លែងធម្មវិសេស
ទេសនា ។ ឥទំ តេមិយជាតកំ នូវនិទានដំណើរជម្មាល
កាលព្រះអង្គត្រេបរង្គាត់នៅនឹងវដ្តសង្សារត្រអាលយោនយក
កំណើត កើតជាពោធិសត្វមួយព្រះអង្គទ្រង់ព្រះនាមរបរឈ្មោះ
ហៅព្រះតេមិយនេះ ។ អាទិកថាបទេន អត្តនា ឧប-
លិក្ខិតំ ទើបព្រះអង្គកត់សំគាល់នូវបទព្រះគាថានេះជាដើម ។

មាបន្និបយវិភាវិយា ឥតិ មាបន្និបយវិភាវិយា នេះហោង ដ៏ជាដើមបទទាំងឡាយ ។ ឯកទិវសម្ហិ ភិក្ខូ ធម្មសភាយំ សន្និសិន្នា ភគវតោ មហាភិនិក្ខមនបារមី វណ្ណយន្តា និសីទឹសុ អបិ សត្ថា អាគន្ត្វា សុគន្ធកុដិយំ កាយនុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នាតិ បុច្ឆិត្វា ឥមាយ នាមាតិ វុត្តេ ន ភិក្ខវេ ឥទានេវ បុព្វេ មម បុរិតបារមីវឌ្ឍិ ធរេត្វា មហាភិនិក្ខមនំ នាម នអច្ឆរិយំ អហំ ហិ បុព្វេ អបរិបក្កញាណោ បារមិយោ បូរេន្តោ វឌ្ឍិ ធរេត្វា និក្ខមន្តោ យេភាតិ វត្វា តុណ្ហី អហោសិ ។ មានកាលសម័យថ្ងៃ ១ ហោង អស់ភិក្ខុសង្ឃផងទាំងឡាយទៅជុំនុំគ្នានៅនាធម្មសភាសាលា រីភិក្ខុដ៏ជាបាស់នោះមកស្រដីទៅនឹងអស់ភិក្ខុកម្លោះផងទាំងឡាយថា អាវុសោភិក្ខុផងទាំងឡាយអើយ រីព្រះដ៏មានបុណ្យអម្ចាស់វិសេសនៃយើង ព្រះអង្គមានបារមីរិទ្ធិអានុភាពនោះប្រើនក្រៃ ឥតអ្នកឯណាមួយនឹងស្មើព្រះអង្គបានឡើយ រីពាក្យអស់ភិក្ខុសង្ឃផងទាំងឡាយនោះមិនស្ងាត់បាត់តែនៅក្នុងធម្មសភាសាលានោះឡើយ វាឮជ្រួតជ្រាបដរាបទៅដល់ព្រះស្រោតទិព្យវិសេសថ្លៃនៃព្រះដ៏មានបុណ្យ ព្រះអង្គជ្រាបហើយទ្រង់ព្រះ

ពិចារណាថា ភោ អស់ភិក្ខុសង្ឃផងទាំងឡាយ ទៅជុំនុំគ្នានៅនា ធម្មសភាសាលានោះហើយហ្នះនៅ ក៏ថាបើដូច្នោះអញទៅកាន់ ជុំនុំអស់ភិក្ខុសង្ឃផងទាំងឡាយនោះក៏បាននេះ ថាបើអញមិន ទៅកាន់ជុំនុំអស់ភិក្ខុសង្ឃផងទាំងឡាយនោះហើយ រីកំណើត អញជាព្រះតេមិយមិញ ភាគនឹងកំបាំងបាត់ស្ងាត់ទេឯងអះ លុះ អញទៅកាន់ជុំនុំសង្ឃអស់ភិក្ខុសង្ឃផងទាំងឡាយនោះនៃទើប កំណើតអញជាព្រះតេមិយភាគនឹងឮខ្ចរខ្ចារ ជាអស្ចារ្យក្រៃឭដ៍ លោកនេះ ព្រះដ៏មានបុណ្យព្រះអង្គទ្រង់ពិចារណានូវប្រការ អម្បាលនេះហើយ ទើបព្រះអង្គយកត្រៃចីវរមកឃ្លុំគ្រលុំស្អាត ស្រែបស្តេចសីហនាទគតាតទៅកាន់ធម្មសភាសាលាហើយ ដណ្តឹងទៅអស់ភិក្ខុសង្ឃផងទាំងឡាយថា ម្នាលអាវុសោភិក្ខុ ផងទាំងឡាយអើយ នាអ្នកទាំងឡាយមកជុំនុំគ្នានៅនាធម្ម សភាសាលានេះ តើមានបើស្រដីនូវពាក្យអ្វី ក៏មិនដោះឡើងទៅ បម្រើនមេត្តាភាវនា ប្រាថ្នាសម្បត្តិសួគ៌ សម្បត្តិនិព្វាន ជាស្ថាន ពំនាក់ទីទៃៗ ហ៏ះ ។ ឥមាយ នាមាតិ វុត្តេ ទើបអស់ភិក្ខុផងទាំង ឡាយថ្វាយបង្គំប្រណម្យទូលថា ភន្តេ ភគវា បពិត្រព្រះដ៏មាន

បុណ្យប្រសើរអើយ នាយើងខ្ញុំមកជុំគ្នានៅនាធម្មសភាសាលា នេះយើងខ្ញុំមិនស្រដីនូវឥត្ថិភាគបុរិសភាគឲ្យជាមន្ទិលរវល់នៅក្នុងកំឡុងព្រះសាសនាព្រះអង្គនេះឡើយ យើងខ្ញុំស្រដីសរសើរតែព្រះបារមីវិសេសថ្លៃនោះឯងជាអស្ចារ្យក្រៃ ព្រះដ៏មានបុណ្យព្រះអង្គជ្រាបហើយបន្ទូលថា ម្នាលអាវុសោភិក្ខុផងទាំងឡាយអើយ អស្ចារ្យអ្វីតថាគតបានត្រាស់ជាព្រះពុទ្ធហើយ នេះលោកមិនរាប់ហៅថាអស្ចារ្យឡើយ កាលមុនឡើយអញតថាគតមានព្រះបារមីពុំទាន់ទុំ មានប្រាជ្ញាពុំទាន់ចាស់ អាចប្រះលះលែងរវែងបង់ស្វេតច្ឆត្ររាជសម្បត្តិ ចេញទៅសាងមហាភិនិស្ក្រមសន្សំបារមី ប្រយោជន៍ដើម្បីនឹងឲ្យបានត្រាស់ នោះក៏លោករាប់ជាអស្ចារ្យក្រៃអេះ ព្រះដ៏មានបុណ្យព្រះអង្គបន្ទូលបានមួយព្រះឱស្ឋពីរព្រះឱស្ឋហើយ ។ តុណ្ហី អហោសិ ព្រះអង្គបញ្ឈប់ព្រះពុទ្ធដីកាស្ងៀមនៅវិញហោង ពាក្យបំណោទចោទថាអ្នកអើយ នាព្រះដ៏មានបុណ្យព្រះអង្គបន្ទូលបានមួយព្រះឱស្ឋពីរព្រះឱស្ឋហើយ ហេតុអ្វីព្រះអង្គបញ្ឈប់ព្រះពុទ្ធដីកាស្ងៀមទៅវិញហ៎ះ ជាធម៌ទេសនាព្រះអង្គអស់តែម្ល៉ោះឯងឬហ៎ះ ថាទេ ធម៌ទេសនា

ព្រះអង្គនោះ ៨ម៉ឺន ៤ ពាន់ខណ្ឌព្រះគម្ពីរអ្វីអើយ ក៏នឹងអស់ងាយតាយដូច្នោះហ៎ះ អើថាបើមិនអស់ហើយតើ ព្រះអង្គស្ងៀមនៅថ្វី ព្រះអង្គខ្ជិលឬអ្វី ថាទេព្រះអង្គអ្វីក៏ទៅខ្ជិលងាយតាយដូច្នោះ ថាដ្បិតព្រះអង្គនឹងឲ្យឆ្ងាយទូលាយអាបិធម៌វិសេសទេសនាព្រះអង្គនោះហោង ។ ព្រះអង្គគង់ស្ងៀមមម៉ឹងនៅថាយើសម្ដែងមកក៏នឹងបានឆ្ងាយទូលាយ គង់ស្ងៀមមម៉ឹងនៅហើយ តើឆ្ងាយទូលាយធម៌ទេសនានោះនឹងអ្វីវិញហ៎ះ ថាដ្បិតព្រះអង្គរមិលមើលនូវកំណើតសត្វផងទាំងឡាយមានបារមីសត្វឯណាឥតបុណ្យបារមីមិញឮធម៌ទេសនាព្រះអង្គហើយជឿស្ដាប់តាប់តែងរងរសអត្ថធម៌វិសេសទេសនា សត្វឯណាថាបើធ្វើអំពើដូច្នោះហើយ ក៏សត្វនោះឯងនឹងប្រាថ្នាសម្បត្តិសួគ៌សម្បត្តិនិព្វានក្ដីមិនក្រឡើយ សត្វឯណាថាបើឥតបុណ្យបារមីហើយឮធម៌វិសេសទេសនាព្រះអង្គ ខ្វះប្រែត្មះតិះដៀល ឯអាបិធម៌វិសេសទេសនាព្រះអង្គនោះមិញ ថាឱព្រះពុទ្ធអើយយល់តែបានត្រាស់ប្រាជ្ញប្រើនក្សូវ នៅៗទេសនាសរសើរតែកំណើតឯង នៅៗទេសនាសរសើរតែអាត្មាឯង មែនក៏មិនដឹងភូត

ក៏មិនដឹង នរណាគេទៅដឹងទៅយល់ផង សត្វឯណាថាបើត្រះ តិះដៀលធម៌ទេសនាព្រះអង្គដូច្នោះហើយក៏សត្វនោះស្មើអ្នកយក ថ្មប៉ុនភ្នំមកធ្វើលិងកប្រកកអាត្មានោះ នឹងលិចទៅឮដ៏បត្- ភាញយនោះប្រាកដហោង មិនយល់ថាព្រះអង្គទេសនានាំសត្វ ឲ្យបាននូវសម្បត្តិសួគ៌សម្បត្តិនិព្វាននោះឡើយ យល់ហាក់ ដូចព្រះអង្គទេសនានាំសត្វឲ្យទៅនរកវិញ ហេតុនោះហោងព្រះ អង្គបញ្ឈប់ព្រះពុទ្ធដីកាស្ងៀមនៅ ដើម្បីនៅឲ្យបានអ្នកឯណា មួយអារាធនាសូមធម៌ទេសនាព្រះអង្គនោះនៃ ៗ ទើបព្រះអង្គនឹង សំដែងឲ្យជាក់ច្បាស់ទៅ ។ តេហិ យាចិតោ អតីតំ អាហរិ អស់ភិក្ខុសង្ឃផងទាំងឡាយដឹងហេតុដូច្នោះហើយ លើកកំបង់ ផ្គង់អញ្ជលី ដាក់លើសិរសីថ្វាយបង្គំទូលថា ។ ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ សូមទានព្រះអង្គយកព្រះ ប្រាជ្ញាទិព្យវិសេសព្រះអង្គ ១ ឈ្មោះបុព្វេនិវាសានុស្សតិញាណ នោះមកឧបក្រសោបរូបនូវព្រះកំណើតព្រះអង្គ កាលជាពោធិ- សត្វនោះមកសំដែងថ្លែងធម៌វិសេសទេសនាឲ្យជាសណ្ដាប់នៃ យើងខ្ញុំហោង ព្រះដ៏មានបុណ្យព្រះអង្គជ្រាបហើយព្រះអង្គនឹង

សំដែងថ្លែងធម៌វិសេសទេសនាជាសណ្តាប់ភិក្ខុសង្ឃផងទាំងឡាយ បន្ទូលជាបទព្រះបាឡីថា ។ អតីតេ ភិក្ខវេ ពារាណសិ-កាសិករាជានាម ធម្មេន រជ្ជំ ការេសិ ។ តស្ស អគ្គមហេសិយាបត្ថាទេវី នាម សោឡសហស្ស ឥត្ថិយោ ជេដ្ឋា កត្វា តាសុ ឯកាបិ បុត្តំ វា ធីតរំ វា នលភិ ។ នាគរា អម្ហាកំ រញ្ញោ វំសានុរក្ខិតោ ឥត្ថិ វត្វា កុសរាជជាតកេ អាគតនយេនេវ សន្និបតិត្វា រាជានំ ទេវ បុត្តំ បត្ថេថាតិ អាហំសុ ថាម្នាលអរុំសោភិក្ខុផងទាំងឡាយអើយ នាកាលកពភន្តរកប្បកាលខាំងកំបាំងកន្លងរម្លងទៅហើយនោះ កាលណោះ មានមហាក្សត្រាធិរាជមួយព្រះអង្គទ្រង់ព្រះនាមឈ្មោះហៅព្រះបាទកាសិករាជសោយរាជសម្បត្តិ ស្ថិតនៅនាពារាណសីនគរប្រកបដោយនូវធម៌ប្រសើរ រីអគ្គមហេសីមហាក្សត្រាធិរាជនោះសោត ទ្រង់ព្រះនាមឈ្មោះហៅនាងបត្ថា-ទេពីដ៏ជាធំក្រៃលែងស្រីផងទាំងឡាយ នោះសឹងតែអារគ្មានកូនប្រុសកូនស្រីមួយឡើយ កាលណោះ អស់អ្នកនគរផងទាំងឡាយទៅជុំគ្នានៅនាកណ្តាលព្រះលាន ហើយស្រដីថា អ្នកទាំងឡាយអើយ នាមហាក្សត្រាធិរាជអម្ចាស់វិសេសនៃយើង ព្រះ

អង្គៈសោយរាជសម្បត្តិស្ថិតដ៏ជាសុខសប្បាយក្សេមក្សាន្ត អស់ប្រជានុរាស្ត្រផងទាំងឡាយ មែនពិត គឺមោះព្រះអង្គគ្មានព្រះរាជបុត្រមួយឡើយ ថាបើព្រះអង្គគង់ធម្មានៅដូច្នោះទៅមិញក៏បានហោង ថាបីអម្នើសនឹងព្រះអង្គហើយឥតអ្នកឯណា ១ នឹងសេពសោយប្រពៃណីស្នងព្រះអង្គឡើយ អ្នកទាំងឡាយអើយមកយើងនឹងទៅពិត្រទូលព្រះអង្គ ឲ្យព្រះអង្គប្រាថ្នាព្រះរាជបុត្រដោយនូវនិយាយ កសរាជជាតកនេះហោង អស់អ្នកនគរផងទាំងឡាយគិតពិចារណានូវប្រការអម្បាល្មោះ ហើយចូលទៅទូលមហាក្សត្រាធិរាជថា បពិត្រព្រះសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរពើយ នាព្រះអង្គសោយរាជសម្បត្តិសព្វថ្ងៃនេះជាសុខសប្បាយក្សេមក្សាន្តអស់ប្រជានុរាស្ត្រផងទាំងឡាយ គឺមោះព្រះអង្គគ្មានព្រះរាជបុត្រាព្រះរាជបុត្រីមួយឡើយ ថាបើព្រះអង្គគង់ធម្មានៅដូច្នោះក៏បានហោង ថាបើអម្នើសនឹងព្រះអង្គទៅហើយឥតអ្នកឯណាមួយ នឹងសេពសោយប្រពៃណីស្នងព្រះអង្គឡើយ ក៏ហេតុនោះហោងកុំបីព្រះអង្គប្រហែសឡើយ ចូរព្រះអង្គប្រាថ្នាព្រះរាជបុត្រ កុំថាច្រើនឡើយបានតែមួយព្រះអង្គគ្រាន់

តែសេពសោយប្រពៃណីស្នងព្រះអង្គនេះហោង ។ តំ សុត្វា រាជា សោឡសសហស្សឥត្ថិយោ តុម្ហេ បដ្ឋេហិតិ អាណាបេសិ ។ តា ឥត្ថិយោ បត្វាទីនំទេវតានំបុត្តយាចនាយ ឧបដ្ឋានាទិកំ កត្វា បដ្ឋេន្តិយោបិ ឯកបុត្តំ នលភិំសុ តស្ស អគ្គមហេសិចន្ទសម្មទ្ទាភ រាជធីតា ចន្ទាទេវី នាម សីលសម្បន្នា អហោសិ ។ រាជា បុត្តំ បដ្ឋេហិ ទេវីតិ អាហ ។ សា បុន្ទរិសេ ឧបោសថកម្មំ សមាទយិត្វា បុលសយនេ និបន្នា សា អត្តនោ សីលំ អាវជ្ជិត្វា សចាហំ អខណ្ឌំ សីលំ រក្ខាមិ ភវេយ្យ ឥមិនា សច្ចេន បុត្តោ មេ ឧបជ្ជតូតិ សច្ចកិរិយំ អកាសិ ។ មហាក្សត្រាធិរាជព្រះអង្គជ្រាបហើយ មានព្រះបន្ទូលថា បើអ្នកទាំងឡាយជាទោះយល់មែនពិតហ: នៅ ជាបើដូច្នោះ អញនឹងប្រាថ្នាកូនហោង ទើបមហាក្សត្រាធិរាជព្រះអង្គបង្គាប់ប្រើទៅអស់ស្ត្រីផងទាំងឡាយមួយម៉ឺន ៦ពាន់នោះថា ម្នាលស្ត្រីផងទាំងឡាយអើយ ចូរនាងទាំងឡាយប្រាថ្នាកូនដោយនូវអាត្មាទីទៃ ៗ ហោង ជាបើស្ត្រីឯណាប្រាថ្នាបានកូនដូចក្តីបម្នងប្រាថ្នាហើយអញនឹងឲ្យស្ត្រីនោះឯង

ជាធំក្នុងក្រៃលែងស្ត្រីផងទាំងឡាយ ស្មេត្រធត្រាជសម្បត្តិអញសោតអញនឹងឲ្យកូនទោះឯង កាលណោះអស់ស្ត្រីផងទាំងឡាយឮព្រះបន្ទូលមហាក្សត្រាធិរាជនោះ ក៏ទទួលយកព្រះបន្ទូលមហាក្សត្រាធិរាជនោះហើយ ថយទៅកាន់ស្ថានលំនៅអាត្មាទីទៃ ៗ ហើយ ធ្វើសច្ចាធិដ្ឋានប្រាថ្នាសូមកូន ថាបពិត្រអស់ទេវតាគន្ធព្វផងទាំងឡាយដ៏មានបុណ្យប្រសើរអើយ ហេតុតែតេជៈយើងខ្ញុំធ្វើសច្ចាធិដ្ឋានប្រាថ្នានេះ សូមឲ្យទេវតា ទេវបុត្តឯណាមួយ មានបារមីច្រើនច្បុតមកកើតនៅនាក្នុងផ្ទៃយើងខ្ញុំនេះហោង អស់ស្ត្រីផងទាំងឡាយសូម្បីប្រាថ្នាដល់ប៉ុន្មាន ៗ ក្ដី មិនបានកូនប្រុសកូនស្រីមួយឡើយ រីអគ្គមហេសីមហាក្សត្រាធិរាជនោះ ឈ្មោះនាងបត្មាទេពីដ៏ជាព្រះរាជបុត្រី ព្រះបាទមុទ្ទរាជនាងប្រកបនូវសីលវត្តប្រតិបត្តិប្រពៃ មហាក្សត្រាធិរាជបន្ទូលនឹងនាងថា ម្នាលនាងបត្មាទេពីអើយ រីនាងឯងសោតចូរនាងប្រាថ្នាកូនហោង ថាបើនាងប្រាថ្នាបានកូនដូចក្ដីបម្នងនាងហើយ ស្មេត្រធត្រាជសម្បត្តិអញសោតអញនឹងឲ្យកូននាងនោះឯងបាន នាងបត្មាទេពីឮព្រះបន្ទូល

មហាក្សត្រាធិរាជនោះហើយ នាងថ្វាយបង្គំប្រណម្យទទួលយក
ព្រះបន្ទូលនោះហើយ នាងថយទៅកាន់ទីលំនៅអាត្មាហើយនាង
ឲ្យប្រដាប់ព្រះរាជមន្ទីរក្រាលនីទៅនូវកំរាលជៀមបមព្រៃត្រិទិព្យ
ទន់ល្មន់ប្រពៃ ស្រេចហើយនែឲ្យយកពិតាននូវនាំងរាំងននទៅ
បាំងរាំងនូវព្រះរាជមន្ទីរនោះហើយ ឲ្យបងព្យូរនីទៅនូវរំយោល
គន្ធមាលា រំយោលផ្កាភ្ញីផងទាំងឡាយ លុះព្រឹកព្រហាមតាម
ព្រះឱណោភាទ័យថ្ងៃរះឡើងនោះនាងស្លៀកដណ្ដាប់សម្មាទានកាន់
យកសីលឧបោសថ ហើយនាងចូលទៅផ្ទំហាំសីលនៅនា
ល្វែងក្រឡាបន្ទំតូច លុះដល់អាធ្រាត្រស្ងាត់នោះនាងមកពិចា-
រណាសីលអាត្មាថា បពិត្រទេវតាផងទាំងឡាយដ៏មានបុណ្យ
ប្រសើរទីទៃ ៗ អើយ ហេតុតែតេជៈអញខ្ញុំរក្សាសីលពិព្យា-
យាម ដោយនូវអំពើពានក្សត្រនេះសូមឲ្យទេវបុត្រទេវតាង
ណាមួយមានរិទ្ធីអានុភាពច្យុតមកចាប់បដិសន្ធិនៅនាផ្ទៃខ្ញុំក្នុង
កាលឥឡូវនេះហោង ។ តស្សា សីលតេជេន សក្កស្ស ភវនំ
ឧណ្ហាការំ ទសេសិ, សក្កោ-ទេវរាជា អាវជ្ជេន្តោ តំ ការណំ

ញត្វា ចន្ទាទេវី បុត្តំ បត្ថេតិ ហន្ទាហំ តស្ស បុត្តំ ទស្សាមីតិ តស្សា អនុច្ឆវិកបុគ្គលំ ឧបធារេន្តោ ពោធិសត្តំ បស្សិ ។ តទា ពោធិសត្តោ វីសតិវស្សានិ ពារាណសិយំ រជ្ជំ ការេសិ តតោ ចុត្តោ ឧស្សទនិរយេ និព្វត្តោ អសីតិវស្សសហស្សានិ តត្ថ បច្ចិត្វា តតោ ចវិត្វា តាវតិំសភវនេ និព្វត្តិ តត្ថ យាវតាយុកំ ឋត្វា តតោ ចវិត្វា ឧបរិទេវលោកំ គន្តុកាមោ អហោសិ អថ សក្កោ តស្ស សន្តិកំ គន្ត្វា ។

# តំរាទាងសាស្ត្រ

## គឺក្បួនរាំ

ព្រះមហាពិទូរ ក្រៈសេម ប្រែចេញអំពីភាសាសៀម

ការរាំជាប្រវេណីមានមកហើយក្នុងពពួកមនុស្សគ្រប់ជាតិ គ្រប់ភាសាទាំងអស់ក្នុងពិភពនេះ មិនថានៅក្នុងប្រទេសទីណាៗ គង់មានវិធីរាំតាមវិស័យនៃជាតិរបស់ខ្លួនទាំងអស់ កុំថាឡើយតែមនុស្ស សូម្បីតែសត្វតិរច្ឆានក៏មានវិធីរាំរបស់វាដែរ ។ នេះអាចនឹងសង្កេតបានដោយងាយ ដូចយ៉ាងផ្ទៃនឹងមាន់ ក្អែកជាដើម កាលណាវាប្រទះអារម្មណ៍ដ៏ជាគ្រឿងរីករាយហើយវា ក៏លោតកែក្រាយ ធ្វើកិរិយាលំនាំបានផ្សេង ៗ នេះក៏គឺការរាំតាមវិស័យរបស់សត្វនោះឯង ប្រាជ្ញអ្នកគិតស្រាវជ្រាវរកហេតុដើមនៃការរាំ ទើបសម្រេចសន្និដ្ឋានបុះថា ការរាំនេះមូលហេតុដើមកើតមកអំពីវិស័យសត្វកាលសោយអារម្មណ៍ ជាសុខវេទនា ឬជាទុក្ខវេទនា កាលសោយអារម្មណ៍នោះខ្លាំងក្លា ទប់មិនបានក៏ផុលបេញមកជាកិរិយាឲ្យឃើញប្រាកដ លើកឧទាហរណ៍ដូចយ៉ាងទារក កាលអារម្មណ៍សោយសុខវេទនា ក៏លោតកញ្ច្រោលប៉ផ្លាក់ប៉ផ្លើកយ៉ាងសប្បាយ កាលអារម្មណ៍សោយទុក្ខវេទនាក៏-យំស្រែកបម្រះនឿលអន្ទះអន្ទែង សំដែងកិរិយាបេញមកឲ្យដឹង

ជាអារម្មណ៍ក្នុងខ្លួនដូចម្ដេច ៗ លុះធំដឹងក្ដីឡើងដរាបណា កិរិយាដែលអារម្មណ៍បណ្ដាលចេញមក ក៏រឹតតែមានច្រើនឡើងដរាបនោះ រហូតដល់កិរិយាដែលសំដែងសេចក្ដីជំរេកត្រេកអរក្នុងកាមារម្មណ៍ និងកិរិយាដែលសំដែងសេចក្ដីអាឃាដខឹងក្រោធជាដើម កិរិយាដ៏កើតអំពីវេទនាសេចក្ដីសោយអារម្មណ៍នេះ រាប់ថាជាមូលហេតុដើមនៃការរាំ ។

តមក១ជាន់ទៀត កើតអំពីមនុស្សទាំងឡាយដឹងសេចក្ដីបំណង របស់កិរិយាផ្សេង ៗ យ៉ាងដែលពោលមក ក៏ប្រើកិរិយាអំបាលនោះហាក់ដូចជាភាសាម្យ៉ាង កាលប្រាថ្នានឹងសំដែងឲ្យប្រាកដដល់អ្នកដទៃដោយពិត តាមទឹកចិត្តក្ដី ឬដោយមាយាដូចយ៉ាងក្នុងវេលាលេងសើចក្ដី ថាខ្លួនមានអារម្មណ៍យ៉ាងណាក៏សំដែងកិរិយាដ៏ជាគ្រឿងសំគាល់អារម្មណ៍យ៉ាងនោះមានដើមថា បើនឹងសំដែងសេចក្ដីស្នេហា ក៏ធ្វើកិរិយាញញឹមញញែមអែនអននឹងសំដែងសេចក្ដីសប្បាយរីករាយ ក៏ច្រៀងរាំកែក្រាយ, នឹងគំរាមឲ្យអ្នកដទៃខ្លាច ក៏ធ្វើមុខធ្មឹងភ្នែកក្រលោតនឹងលោតទន្ទ្រាំគំរោះគំរាម ទើបកើតបែបផែននៃលំនាំដែលសំដែង

អារម្មណ៍ផ្សេងដ៏ជាដើមរបស់ក្បួនរាំឡើង រាប់ជាលំដាប់ទីពីរ ។

តមក១ជាន់ទៀត កើតអំពីអ្នកឆ្លាសជ្រើសរើសយកលំនាំកិរិយាដែលសំដែងអារម្មណ៍ផ្សេង ៗ នោះ មករៀបរៀងឲ្យទាក់ទងជាប់គ្នាជាក្បួនរាំឲ្យមើលល្អ ត្រូវចិត្តត្រូវភ្នែកមនុស្ស ទើបកើតមានក្បួនរាំឡើង រាប់ជាលំដាប់ទីបី ។ សេចក្ដីដែលពោលមកនេះ មានជាសាមញ្ញប្រវេណីដល់មនុស្សទាំងពួងទូទៅគ្រប់ជាតិគ្រប់ភាសា ទើបកើតមានទំនៀមរាំតាមរបៀបក្បួនដែលពួករបស់ខ្លួនឃើញថាល្អផងគ្នា តែដូច្នេះគ្រប់ ៗ ប្រទេសទៅ ។

ឯប្រវេណីការរាំនេះ នឹងមានគ្រាន់តែសម្រាប់បង្ហាត់ពួកអ្នករកស៊ីដោយល្បែងរាំប៉ុណ្ណោះក៏ទេ អំពីដើមមករមែងមានជាប្រវេណីសម្រាប់បុគ្គលគ្រប់ជាន់ នឹងមានលេងរហូតដល់ទៅក្នុងការសង្គ្រាមនឹងការពិធីផ្សេង ៗ ជាច្រើនយ៉ាង នឹងលើកតួយ៉ាងប្រវេណីរាំដែលមានមកក្នុងប្រទេសស្យាម ដូចយ៉ាងក្នុងតម្រាគជសាស្ត្រដែលរាប់អានថាជាវិជ្ជាជាន់ខ្ពស់សម្រាប់ការសង្គ្រាមក្នុងបុរាណសម័យ អ្នកណាមួយនឹងហាត់ជិះដំរីប្រែដល់ ក៏ត្រូវ

ហាត់រាំឲ្យសង្ហាផង សូម្បីតែព្រះរាជាក៏គោងទ្រង់ហាត់ មានគួយ៉ាងមកដរាបដល់រជ្ជកាលទី៥ គឺព្រះបាទសម្តេចព្រះបុលាលង្ករណ៍ ក៏ទ្រង់សិក្សាវិជ្ជាគជសាស្ត្រនឹងសម្តេចក្រុមព្រះយ៉ាប់រ៉ាបបរបក្ខ ។ បានឮថា ធ្លាប់ទ្រង់រាំព្រះសែងអង្កុសា (កង្វេរ) លើកដំរីព្រះទីនាំងជាពុទ្ធបូជា កាលស្តេចទៅនមស្សការព្រះពុទ្ធបាទតាមបូរាណរាជប្រវេណី កាលនៅឆ្នាំរក ព.ស.២៤១៥ ។ ការរាំក្នុងក្បួនសង្គ្រាមយ៉ាងដទៃ ដូចយ៉ាងរាយគុន ក៏ជាវិជ្ជាដែលក្សត្រិយ៍ហាត់មកអំពីដើម បំណែកឯក្បួនរាំក្នុងពិធី នៅមានតួយ៉ាងក្នុងមណ្ឌលពាយ័ព្យ គឺកាលមានបុណ្យទានធំដុំក៏មានទំនៀមថា ក្សត្រិយ៍តាំងអំពីអ្នកគ្រប់គ្រងព្រះនគរបុះមកត្រូវរាំជាការសំដែងសទ្ធាសោមនស្សក្នុងការបុណ្យទាន ។ ក្សត្រីក៏មានការហាត់រាំដែរ ហើយមានឱកាសចូលរាំក្នុងពិធីបំពួកខ្លះមានមកដរាបដល់សព្វថ្ងៃនេះ ទំនៀមផ្សេងៗដែលពោលមកសរឲ្យឃើញថា អំពីបូរាណគេរមែងប្រកាន់ការរាំថាជាវិជ្ជាបំណែក ១ ក្នុងការសិក្សា គេទើបសិក្សាជាសាមញ្ញវិជ្ជាសម្រាប់បុគ្គលគ្រប់ជាន់តមក ។

ការដែលបង្ហឹកតែបុគ្គលបំពួកខ្លះឲ្យរាំ ដូចយ៉ាងរាំល្ខោនជាដើមនោះគង់កើតអំពីសេចក្ដីបំណងចង់មើលក្បួនរាំថា ដែលល្អបំផុតនោះត្រឹមណា ទើបជ្រើសរើសតែបុគ្គលបំពួកខ្លះយកមកបង្ហឹកបង្ហាត់ឲ្យស្ទាត់បំពោះតែក្នុងវិជ្ជារាំប៉ុណ្ណោះ សំរាប់នឹងសំដែងឲ្យមនុស្សទាំងឡាយមើល ឲ្យឃើញថាការរាំអាចនឹងល្អបានត្រឹមណោះ កាលបង្ហាត់បានតាមប្រាថ្នាហើយ រើសចេញលេងរមែងជាប់ចិត្តនៃមនុស្សទាំងឡាយ ទើបមានអ្នករាំឡើង ១ ពួកដោយឡែកផ្សេង តែដែលពិតវិជ្ជារាំក៏មកអំពីបែបផែនជាមួយគ្នានោះឯង ។

របៀបរាំដែលសៀមរាំជាបែបផែនក្នុងប្រទេសសៀមនោះជា២ យ៉ាង គឺ ១ យ៉ាងជាក្បួនរាំរបស់ប្រជាជនអ្នកស្រុក ដូចយ៉ាងដែលរាស្ត្ររាំស៊ុយឬរាំលេងមែស៊ី នឹងរាំភ្លេងប្រុតស្រីរ ក្បួនរាំរបស់សៀមអំបាលនេះ ប្រហែលជាមានមកតាំងអំពីសម័យព្រេងនាយ ។ ក្បួនរាំ ១ យ៉ាងទៀត ដូចយ៉ាងដែលរាំក្នុងពិធីរហូតបុះមកដល់លេងរបាំនឹងល្ខោនខោលនោះ បានបែបមកអំពីប្រទេសឥណ្ឌៀ ពួកព្រាហ្មណ៍បាននាំយកបែបផែនមក

បង្ហាត់អ្នកស្រុកអាយនេះ ហើយបានជាគ្រូរបស់អ្នកស្រុកអាយនេះផង ព្រោះពួកឥណ្ឌៀគេប្រកាន់ថាការរាំជាល្បែងរបស់ព្រះជាម្ចាស់ទ្រង់គិតប្រឌិតឡើង ហើយទ្រង់ប្រដៅមនុស្សទាំងឡាយឲ្យរាំដើម្បីមង្គលសួស្តី អ្នកណារាំឬឲ្យមានការរាំតាមទេវបញ្ញត្តិ ក៏ឈ្មោះថាបានប្រយោជន៍ និងបានសុគតិទៅថ្ងៃមុខ ៗ

តម្រារាំដែលពួកព្រាហ្មណ៍ឥណ្ឌៀនាំមកបង្ហាត់ក្នុងប្រទេសស្យាមនេះហៅថា នាដសាស្ត្រ ថាជារបស់ព្រះភារតឫសីតែងទុកមក ដោយអាងថាព្រះឥសូរជាម្ចាស់ជាគ្រូរាំដើម មានប្រ-វត្តិពោលរឿងរ៉ាវដែលព្រះឥសូរទ្រង់តាំងតម្រារាំនៅក្នុងកោលិយបុរាណថា ក្នុងសម័យមួយនោះមានឫសី ១ ពួកតាំងអាស្រមនៅជាមួយនឹងភរិយាក្នុងព្រៃតារក បំណោរមកឫសីពួកនោះប្រព្រឹត្តអនាចារពុះពារទេវបញ្ញត្តិមិនកោតក្រែងព្រះជាម្ចាស់ ព្រះឥសូរទ្រង់ព្រះពិរោធ ទើបបបួលព្រះនារាយណ៍ចុះមកកាន់មនុស្សលោក ដើម្បីនឹងទូន្មានឫសីអំបាលនោះ ព្រះឥសូរទ្រង់និមិត្តព្រះអង្គជាយោគីកំឡោះ ឲ្យព្រះនារាយណ៍និមិត្ត

ជាភរិយាក្រមុំ មានសរីរៈរូបមុខគួរបេតីទាំងពីរព្រះអង្គដើរចូល
ទៅក្នុងព្រៃតារកនោះ ពួកឫសីឃើញក៏កើតដំរេកស្រឡាញ់
នាងនារាយណ៍ បំណែកឯភរិយាឫសីក៏នាំគ្នាស្នេហាយោគីឥ-
ស្សូរ ទាល់តែកើតវិវាទគ្នាជាកោលាហលដោយអំណាចរាគចរិត
ពួកឫសីព្យាយាមចង់យ៉ាងម្ដេចក៏មិនបានសមប្រាថ្នា ណាស់
ជាណាស់ពួកឫសីក្រោធ ទើបនាំគ្នាដាក់បណ្ដាសា តែក៏មិន
មានអន្តរាយយ៉ាងទំនាយ ពួកឫសីទើបនិមិត្តជាខ្លាឡើងដើម្បី
ឲ្យខាំយោគីនឹងភរិយា ព្រះឥស្សូរក៏សម្លាប់ខ្លានោះបង់ រះយក
ស្បែកមកធ្វើជាប្រមខន្ធ (ស្បែកទ្រាប់អង្គុយ) និមិត្តជានាគ
ឲ្យព្រួសពិស ព្រះឥស្សូរក៏ចាប់យកនាគនោះទៅធ្វើជាសង្វារពាក់
ពួកឫសីទាល់គំនិតមិនដឹងបើនឹងគិតធ្វើម្ដេចទៅទៀត ព្រះឥស្សូរ
ឃើញពួកឫសីអស់ឫទ្ធិហើយ ទើបទ្រង់រាំធ្វើបាដិហារ្យ ខណៈ
នោះមានយក្ខគម ១ ឈ្មោះមុយកលស្ទុះចូលមកជួយពួកឫសី
ព្រះឥស្សូរក៏យកព្រះបាទម្ខាងជាន់ខ្នងយក្ខគមនោះហើយ ទ្រង់
រាំតទៅទាល់តែអស់ក្បួន ពួកឫសីក៏លះទិដ្ឋិសុខចិត្តទទួលខុស
នឹងទទួលសុំអច្ចយោទោសនឹងព្រះជាម្ចាស់ទាំងពីរអង្គ ។

កាលទ្រង់បំបាក់ឫសីបានសម្រេចហើយ ព្រះឥសូរក៏ស្ដេចត្រឡប់ទៅភ្នំកៃលាស ព្រះនារាយណ៍ក៏ត្រឡប់ទៅក្សេរសមុទ។ គ្រានោះស្ដេចអនន្តនាគរាជបានតាមហែស្ដេចទៅក្នុងកាលទៅកម្រាបពួកឫសី បានឃើញព្រះឥសូររាំល្អចាប់ចិត្ត លុះតាមព្រះនារាយណ៍ទៅដល់ក្សេរសមុទ នឹកចង់ឃើញព្រះឥសូររាំទៀត ទើបទូលអង្វរព្រះនារាយណ៍ឲ្យជួយទូល ព្រះនារាយណ៍ត្រាស់ថា ដែលនឹងឲ្យទូលអញ្ជើញព្រះឥសូរឲ្យរាំជាថ្មីទៀតនោះឃើញមិនបាន បើអនន្តនាគរាជចង់មើលរាំទៀត ក៏ចូរទៅតាំងពិធីធ្វើតប្បកិច្ចបូជានៅជើងភ្នំកៃលាសឲ្យព្រះឥសូរទ្រង់មេត្តាប្រទានពរ ទើបទូលសុំពរឲ្យបានមើលទ្រង់រាំបានតាមប្រាថ្នា អនន្តនាគរាជក៏ធ្វើតាមព្រះនារាយណ៍ណែនាំ ដោយអំណាចតប្បកិច្ចពិធីធ្វើរបស់អនន្តនាគរាជ ក្ដៅដល់ព្រះឥសូរក៏ស្ដេចចុះមកប្រទានពរថា ស្រេចតែចិត្ត បើត្រូវការអ្វីចូររើសយករបស់នោះ នឹងទ្រង់ប្រសិទ្ធិឲ្យ ឲ្យសម្រេចដូចបំណង អនន្តនាគរាជក្រាបទូលថា របស់ដែលមានក្នុងត្រៃភពនេះមិនចង់បានទាំងអស់ សូមតែពរម្យ៉ាង គឺឲ្យបានឃើញព្រះអង្គរាំម្ដង

ទៀត ព្រះឥសូរក៏ព្រមត្រាស់ថានឹងចុះទៅរាំឲ្យមើលក្នុងមនុស្សលោក នៅដំបន់ចិទម្ពរម ដ៏ជាទីកណ្ដាលលោក លុះដល់ថ្ងៃកំណត់ ព្រះឥសូរក៏ស្ដេចចុះមកកាន់ដំបន់ចិទម្ពរម ព្រមដោយទេពនិករជាបរិវារ ទ្រង់និមិត្តជាសុវណ្ណសាលាឡើងហើយរាំតាមដែលបានប្រទានពរដល់អនន្តនាគរាជម្ដងទៀត ។

សម័យដទៃទៀត ព្រះឥសូរស្ដេចប្រថាប់នៅឰដកណ្ដាលទេវសភាលើភ្នំកៃលាស មានព្រះរាជប្រាថ្នានឹងទ្រង់សំដែងនាដកម៌ឲ្យជាបែបច្បាប់ ទើបអញ្ជើញព្រះឧមាឲ្យគង់ជាប្រធានលើសុវណ្ណបល្លង្ក ឲ្យព្រះសរស្វតីដេញពិណ ឲ្យព្រះឥន្ទ្រផ្លុំខ្លុយ ឲ្យព្រះព្រហ្មវាយឈឹង ឲ្យព្រះលក្ស្មីច្រៀង ឲ្យព្រះនារាយណ៍វាយជោន ព្រះឥសូរទ្រង់រាំដោយព្រះអង្គឯង ឲ្យទេវតានឹងឫសីគន្ធព្វយក្ខនាគទាំងឡាយ ដែលឡើងទៅគាល់បានមើលម្ដងទៀត កាលព្រះឥសូររាំហើយមើលទៅដូចជាព្រះឫសីនារទបានទទួលទេវបញ្ញាឲ្យមកតែងតម្រាប្រដៅមនុស្សទាំងឡាយតាមលំអាននោះ ។

អាស្រ័យរឿងដំណាលដូចះពោលមក ពួកឥណ្ឌៀកាន់ថា នៅស្រុកចិទម្ពរមេដ៍នៅក្នុងឥណ្ឌៀខាងត្បូង (នៅក្នុងមណ្ឌលម័-ទរដ្ឋ)ជាទីដែលព្រះឥសូរស្តេចបានមកសំដែងការរាំ លុះយូរមក គេក៏គិតសាងរូបព្រះឥសូរគ្រាដែលទ្រង់សំដែងការរាំ ហៅថា នាដរាជ (សៀមហៅទេវរូបនេះថា គ្រាកំរ៉ាបអសូរមូលាគនី) ហើយនាំគ្នាផ្ទេរបែបនោះសាងសាយភាយទៅ សូម្បីក្នុងប្រទេស សៀម ប្រទេសខ្មែរក៏មានជាច្រើន ព្រោះពួកព្រាហ្មណ៍ដែល មកជាគ្រូក្នុងប្រទេសអំបាលនេះមកអំពីប្រទេសឥណ្ឌៀខាងត្បូង ដោយច្រើន នៅស្រុកចិទម្ពរមនោះនៅមានទេវស្ថាន ១ កន្លែង សាងទុកតាំងអំពីប្រមាណ ព. ស. ១៨០០ ក្បាច់គ្រឿងប្រ-ដាប់សុំគេឆ្លាក់ជារូបព្រះឥសូរទ្រង់រាំគ្រប់ទាំង ១០៨ បែប តាម ដែលមានក្នុងតម្រារបស់ព្រះភារតឫសី រូបទាំងនេះភ្នាក់ងារក្នុង មណ្ឌលម័ទរដ្ឋ បាននាំមកបោះពុម្ពក្នុងសៀវភៅរាយការត្រួត របស់បូរាណ កាល គ. ស. ១៩១៤ មានច្បាប់នៅក្នុងហោសៀវ ភៅសៀម សៀមទើបចំឡងរូបភាពអំបាលនោះ នឹងប្រែពាក្យ អធិប្បាយដែលនៅក្នុងសៀវភៅនាដសាស្ត្រ មកបោះពុម្ពទុកក្នុង

សៀវភៅដែលឲ្យឈ្មោះថា តម្រាហូនរាំ សឹងបោះពុម្ពកាល ព.ស. ២៤៦៦ ។

តែដែលបោះពុម្ពជាខ្មែរគ្រានេះ មិនបានយករូបគំនូរពីតណ្ហៀនោះមកបោះផងទេ យកតែរូបដែលជាស្នាដៃរបស់សៀមគូរមកបោះដូចមានតទៅនេះ ។

# រឿងធ្មេញជែបណ្ឌិត

(គ)

ឯមហាសេដ្ឋីស្ដាប់ហើយក៏គិតថាអញប្រើអាដៃនេះ នឹងកើតទោសច្រើនទៅទៀត ហើយប្រើមនុស្សម្នាក់ថា អាឯងទៅហៅអាដៃ ហើយយកទាំងគោដែលចាប់នោះមកផង ឯបំរើនោះស្ដាប់ហើយ ក៏ដើរទៅហៅធ្មេញដៃដូចពាក្យមហាសេដ្ឋីប្រើនោះឯង ទៅដល់ហើយប្រាប់ថា ធ្មេញដៃឥឡូវនេះលោកមហាសេដ្ឋីប្រើអញមកហៅចៅធ្មេញដៃឯង ហើយឲ្យយកទាំងគោដែលចាប់របស់គេនោះទៅផង ឯធ្មេញដៃស្ដាប់ហើយក៏ឆ្លើយថា បើដូច្នោះឯងជួយដឹកគោឲ្យអញផង ហើយក៏ដឹកគោនោះយកទៅដល់មហាសេដ្ឋី អាបំរើនោះទៅជំរាបថា ធ្មេញដៃមកដល់ហើយ យកទាំងគោនោះមកផងហើយ ឯមហាសេដ្ឋីក៏សួរថា អាដៃឯងដូចម្ដេចក៏បានជាទៅចាប់គោគេហើយថាជាលួចប្រពន្ធអាឯង ឯធ្មេញដៃជំរាបថា ខ្ញុំបាទបានជំរាបសូមយកគោញីនោះឯងជាប្រពន្ធខ្ញុំបាទ ឥឡូវនេះគោឈ្មោលទាំងអស់នេះឯងវាដេញចង់ប្រពន្ធខ្ញុំបាទ ហើយបានជាខ្ញុំបាទចាប់

បងទុកនឹងយកប្ដឹងលោកតា បើលោកតាមានប្រសាសន៍ដូច ម្ដេចក៏ខ្ញុំបាទព្រមមិនហ៊ានទទឹងទេ ។

ឯមហាសេដ្ឋីស្ដាប់ធ្មេញដៃជំរាបដូច្នោះហើយ ទើបប្រាប់ ថា អាឯងឲ្យគោរបស់គេទៅម្ចាស់គេវិញ ហើយខ្លួនអាឯងកុំទៅ ឃ្វាលគោទៀតវាបង្កើតទោសច្រើនណាស់ អាឯងបានតែប្រើការ ក្នុងផ្ទះវិញទើបជា ឯធ្មេញដៃក៏ខានពុំបានទៅឃ្វាលគោអំពីថ្ងៃ នោះឯង ឯមហាសេដ្ឋីក៏ប្រើការធ្មេញដៃ តែនៅក្នុងផ្ទះសព្វ ៗ ថ្ងៃទៅ ។

មានកាលថ្ងៃ ១ មហាសេដ្ឋីចេញទៅអង្គុយនៅសាលាក្រៅ និយាយអស់នឹងនាម៉ឺនដែលគេមកគិតការអ្វី ៗ នឹងមហាសេដ្ឋី អំពីព្រឹកដល់ថ្ងៃម៉ោង ៣ ពេលឃ្លានបាយប្រពន្ធមហាសេដ្ឋីស្រដី ប្រើថា អាដៃទៅហៅលោកតាអាឯងមកពីសាបាយវាថ្ងៃណាស់ ហើយ ។

ឯធ្មេញដៃស្ដាប់ហើយក៏ដើរទៅហៅមហាសេដ្ឋី ថាលោក តាអើយពីសាបាយ ដើរបន្តិចទៅហៅម្ដង ស្រែកហៅទៅឮ ដល់មហាសេដ្ឋី ៗ ក៏ខ្មាសគេណាស់តែមិនស្រដីថាឲ្យដឹងឡើយ

ឯធ្មេញដៃហៅហើយដើរទៅដល់មហាសេដ្ឋី ហើយស្រែកហៅថាលោកយាយឲ្យមកហៅលោកតាទៅពីសាបាយ ដ្បិតថ្ងៃណាស់ហើយ ឯមហាសេដ្ឋីខឹងហើយចុះពីសាលាដើរទៅដល់ផ្ទះហើយស្រដីថា អាដៃឯងដូចម្តេចក៏បានជាអាឯងស្រែកហៅតក់ខ្លាំងម្ល៉េះ បើដើរដល់ជិតសឹមប្រាប់វាថ្វី ធ្មេញដៃឆ្លើយថាខ្ញុំបាទនឹងធ្វើឯងក៏ទេ ដ្បិតលោកយាយប្រើឲ្យហៅលោកតាមកពីសាបាយបានជាខ្ញុំបាទហៅដូច្នេះឯង ទើបមហាសេដ្ឋីស្រដីថាអាឯងអំពីថ្ងៃនេះទៅបើគេប្រើឲ្យទៅហៅអញ អាឯងដើរឲ្យដល់ទៅសឹមប្រាប់អញថាតិច ៗ កុំឲ្យគេឮឡើយ បើអាឯងហៅដូចពីមុននោះទៀត អញនឹងវាយអាឯងមិនខានឡើយ ឯធ្មេញដៃក៏ចាំទុកក្នុងចិត្តហើយនៅយូរបន្តិចទៅ ។

មានកាលមួយថ្ងៃមហាសេដ្ឋីដើរទៅអង្គុយសាលាក្រៅបង្គាប់ឲ្យធ្វើការ គ្រានោះ ភ្លើងឆេះផ្ទះមហាសេដ្ឋីនោះឯងឯប្រពន្ធមហាសេដ្ឋីភ័យហើយហៅថា អាដៃអាទៅហៅលោកតាអាឯង ប្រាប់ថាភ្លើងឆេះផ្ទះអស់ហើយ ឯធ្មេញដៃក៏ដើរទៅហៅមហាសេដ្ឋីថា លោកតាអើយភ្លើងវាឆេះផ្ទះអស់ហើយ

តែថាតិចៗ ឯជើងប្រឹងតែដើរឯមាត់ក៏ប្រាប់ថាតិចៗ ថាលោកតាអើយភ្លើងវាឆេះផ្ទះអស់ហើយ ឯមហាសេដ្ឋីក្រឡេកមើលមកឃើញធ្មេញដៃដើរហើយធ្មើមាត់នោះមហុៗ ហើយមហាសេដ្ឋីមន្ទិលក្នុងចិត្តហើយស្រែកសួរថាអាដៃយើយអាឯងថាឥតក៏មិនថាឲ្យខ្លាំងមកអញនឹងឮ ឯធ្មេញដៃក៏ថាតែតិចៗដូចដែលនោះឯងលុះដើរទៅដល់ហើយទនទៅខ្សឹប ថាលោកតាភ្លើងឆេះផ្ទះអស់ហើយ ។

ឯមហាសេដ្ឋីស្តាប់ដឹងដូច្នោះហើយប្រើថាអាដៃទៅយករបស់សម្រាលឲ្យឆាប់ឡើងទៅ ឯធ្មេញដៃក៏រត់ទៅយកឯសំបុកមាន់ដែលវាពុំបានឆេះភ្លើង នោះយកទៅទុកច្រើនប្រមាណបាន៣០សំបុកមាន់នោះ លុះដល់ភ្លើងរលត់ហើយមហាសេដ្ឋីស្រដីថាឲ្យយកអស់របស់ដែលយកបានភ្លើងពុំបានឆេះនោះមកអស់ហើយ បាត់តែធ្មេញដៃពុំឃើញមកយកនោះមហាសេដ្ឋីហៅថាអាដៃ អាឯងយកបានរបស់ឥទុកខ្លះ យកមកឲ្យអញនឹងមើល ឯធ្មេញដៃថាខ្ញុំបាទយកបានច្រើនបាខ្ញុំបាទទៅយកមកជូនហើយធ្មេញដៃទៅយកសំបុកមាន់នោះមកឲ្យមហាសេដ្ឋី ឯ

មហាសេដ្ឋីថាអាដែងឯងដូចម្ដេចក៏ទៅយកឯសំបុកមាន់វិញ ឯរបស់ឯទៀតក៏អាឯងមិនយក ឯធ្មេញដែឆ្លើយថាដ្បិតលោកតាផ្ដាំថាយករបស់ស្រាល ៗ នោះឯង បានជាខ្ញុំយកសំបុកមាន់នោះឯងវាស្រាលជាងអស់របស់ដទៃ ។

ឯមហាសេដ្ឋីក៏ប្រាប់ថាអាឯងទៅរកចាប់នរណាជាដើមភ្លើងឲ្យឆេះផ្ទះនេះ ឯធ្មេញដែឮហើយក៏ដើរទៅចាប់ចង្រៃនោះចងដាក់ឃ្នាង នាំមកជូនមហាសេដ្ឋី ហើយស្រដីជំរាបថាចង្រៃនេះឯងជាដើមភ្លើង តែងតែនឹងឆេះអំពីចង្រៃនេះឯងរាល់ផ្ទះមនុស្សសព្វថ្ងៃ ប្រាកដជាឆេះពីចង្រៃនេះឯង ថាបើមិនមែនទេ ខ្ញុំបាទទទួលខុសឲ្យលោកតាធ្វើទោស ឯមហាសេដ្ឋីស្ដាប់ហើយក៏គិតតែក្នុងចិត្តថា អាដែនេះឃើញថាអញនឹងប្រើមិនបាន បើខំប្រើទៅឃើញជានឹងខូចរបស់ទ្រព្យច្រើន បើដូច្នេះមានតែអញនឹងយកទៅថ្វាយស្ដេចឲ្យស្រឡះអំពីខ្លួនអញ គិតដូច្នោះហើយក៏ប្រាប់ថា អាដែងឯងអញនឹងយកទៅថ្វាយលួងក្នុងព្រឹកស្អែកនេះឯងហើយ ឯធ្មេញដែក៏ស្ងៀមនៅ ។

លុះដល់ព្រឹកឡើង ឯមហាសេដ្ឋីក៏រៀបខ្លួននឹងឡើងទៅគាល់ ហើយយកធ្មេញដៃទៅផង លុះដល់ហើយក្រាបបង្គំគាល់ទើបទូលថា សូមទានក្រាបទូលដ្បិតទូលព្រះបង្គំជាខ្ញុំមានក្មេងម្នាក់មានប្រាជ្ញាណាស់ នឹងដេញប្រាជ្ញាវាមិនទាន់ឡើយ គ្មានមនុស្សឯណានឹងកុហកដូចគ្មាន ឥឡូវនេះខ្ញុំទូលបង្គំយកមកថ្វាយជាខ្ញុំល្អងធូលីព្រះបាទ ឯព្រះមហាក្សត្រស្ដាប់ហើយក៏មានបន្ទូលត្រាស់ហៅថា អាដៃអាចូរមកអាយ ឯធ្មេញដៃឆ្លើយថា ព្រះករុណាពិសេសហើយខិតចូលទៅក្រាបជិតនៅមុខព្រះភក្ត្រ ទើបមហាក្សត្រសួរថា អាដៃឯងចេះកុហកមែនឬទេ ឯធ្មេញដៃក្រាបទូលថាចេះមែន ស្ដេចត្រាស់ថាបើដូច្នោះអាឯងកុហកអញនឹងមើល ទើបធ្មេញដៃក្រាបទូលថា ឯកុហកនេះមានក្បួននៅឯផ្ទះទូលបង្គំជាខ្ញុំ ទើបស្ដេចត្រាស់ថា បើដូច្នោះអាឯងទៅយកមកនឹងកុហកអញមើល ទើបធ្មេញដៃក្រាបទូលថាមានតែសូមមហាឡឹកម្នាក់ឲ្យទៅយកក្បួនអំពីផ្ទះទូលបង្គំជាខ្ញុំ ទើបស្ដេចត្រាស់ប្រើមហាឡឹកម្នាក់ថា អាឯងទៅយកក្បួនកុហកអំពីផ្ទះអាដៃឲ្យឆាប់ ឯមហាឡឹកនោះក្រាប

ថ្វាយបង្គំហើយក៏រត់ទៅដល់ផ្ទះធ្មេញជៃ ហើយប្រាប់ម្ដាយធ្មេញជៃថា ដ្បិតធ្មេញជៃប្រាប់ថាឲ្យមកយកក្បួនកុហកនោះ ឯម្ដាយស្ដាប់ហើយឆ្លើយថាគ្មានទេ ឯមហាទ្បឹកស្ដាប់ហើយក៏វិលមកក្រាបទូលវិញថា ទូលបង្គំទៅសួរម្ដាយធ្មេញជៃ ៗ ប្រាប់ថាក្បួនកុហកនោះគ្មានទេ ទើបស្ដេចមានព្រះបន្ទូលត្រាស់សួរថា អាជៃអាឯងថាមានក្បួនកុហកនៅឯផ្ទះ តែទ្បើរផ្ទះឲ្យទៅយកម្ដាយអាឯងប្រាប់ថាគ្មានទេ ទើបធ្មេញជៃក្រាបទូលថា នេះហើយហៅកុហកថ្វាយហើយ សូមទានជ្រាប ។

# បញ្ជីរឿង

ទំព័រ

១ – បរិវត្តគមនាគម ដំណើរអង់គួរណោ ក្នុងដែនកូសាំងស៊ីន (ខេត្តបាក់លីវ) ព្រះសាសនសោភ័ណ ជ.ណាត រៀបរៀង (ត) ........ ៨៥

២ – សេចក្ដីយល់ឃើញអំពីប្រាសាទនគរវត្ត លោកព្រឹលុស្គី រៀបរៀង ក្រម្ការ ដុំ-ម៉ៅ ប្រែជាភាសាខ្មែរ................... ៩៣

៣ – ខេមាខេមសរណកថា ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត រៀបរៀង (ត) ........................ ១០៩

៤ – រឿងតេមិយជាតក សេចក្ដីចាស់ (ត)............. ១២១

៥ – សាសនីភាវ ពាក្យកាព្យ ឃុនស្នេហា ហ៊ឹម រៀបរៀង...... ១៣១

៦ – រឿងធ្មេញដៃបណ្ឌិត សេចក្ដីចាស់ (ត)............. ១៣៩

## រូបផ្សេងៗ

១ – រូបប្រាសាទនគរវត្តទាំងមូល ................ ៩៥

២ – ព្រះទេវរូបស្នាដៃខ្មែរសាង សព្វថ្ងៃនៅក្នុងស្រុកភូមា......... ១០៣

៣ – រូបលោកសង្ឃភូមាកំពុងមើលគម្ពីរស្លឹករឹត............. ១២៣

# TABLE DES MATIÈRES


| | | Pages. |
|---|---|---|
| I. | Tournée en Cochinchine de M. le secrétaire général de l'Institut Bouddhique (Baclièu) | 85 |
| II. | Sur la destination d'Ang-Kor-Vat par Przyluski — Traduit du Français en Cambodgien par Kromokar Chum-Mau... | 97 |
| III. | Khemā Khema Saranakatha ou Religions, refuge des hommes par Krasem | 109 |
| IV. | Temiyajātaka ou Bouddha dans ses vies antérieures | 121 |
| V. | Sāsanivāda Poème ou Bons conseils aux hommes d'après la Morale Bouddhique par Khhunsnehā Him. (à suivre).. | 131 |
| VI. | Conte populaire cambodgien inédit: Histoire de Thmenh-Chhey (à suivre) | 139 |


## HORS TEXTE:


| | | |
|---|---|---|
| I. | Ang-Kor-Vat après le débroussaillement | 95 |
| II. | Bonzes brahmaniques représentant Çiva avec sa monture — Pagode d'Arakan Mandalay (Birmanie) | 117 |
| III. | Bonzes lisant un manuscrit laqué rougé et or avec l'écriture sacrée laquée noire — Monastère de Taiktaw — Mandalay (Birmanie) | 129 |

បរិវត្តកម្មជាតិ

ដំណើរអង្គរនៅស្រុកកូសាំងស៊ីន

# លោកគ្រូព្រះសាសនសោភ័ណ

រៀបរៀង

## ខេត្រតាកែវ

ថ្ងៃអង្គារ ៥ ធ្នូ ១៩៣៣ (៣រោចមិគសិរ)

ម៉ោង ៨ (ព្រឹក) ចេញពីវត្តខ្វែងប្របែលទៅកាន់ទីប្រជុំនៅវត្តប៉ោលៀវ (យួនហៅជួសុកដួង) ក្នុងឃុំហ៊ឹងហ្វួយ ខណ្ឌហាញ់វ៉ា ។ លេខាធិការឈ្មោះ ស៊ឺន-ស ជាតិជាខ្មែរបានទៅជាមួយផងដែរ (ទៅជាមួយរាល់ថ្ងៃត្រាតែអស់ការអង្កេតរណោក្នុងខែត្របាក់លីវ) ។ ក្នុងទីប្រជុំនេះមានពួកបព្វជិតនឹងគ្រហស្ថប្រហែលជាង ២០០ នាក់ ។ យើងបាននិយាយពន្យល់សព្វគ្រប់ហើយ លោកគ្រូចៅអធិការវត្តនេះបានសុំលោកអគ្គលេខាធិការថា សុំឲ្យជួយទំនុកបំរុងប្តូងរាជការទីរួមខែត្របាក់លីវឲ្យបានតាំងលោកភិក្ខុ ១ រូបឈ្មោះទ្រៀង-សាង មានសញ្ញាបត្រសាលាវត្តលង្កា ក្រុងភ្នំពេញ ក្នុងឆ្នាំ ១៩៣២ ដែលសព្វថ្ងៃនៅក្នុងវត្តនេះ ឲ្យបានពេញទីជាគ្រូសាលាបង្រៀនក្នុងវត្តប៉ោ-លៀវនេះ ។ លោកអគ្គលេខាធិការមានប្រសាសន៍សួរសព្វគ្រប់ហើយ ទទួលភារៈថានឹងប្តឹងលោកឡុតម៉ិនិស្ត្រាទ័រខែត្រ

បាក់លីវ[1] ឲ្យបានបើកសាលារៀនវត្តនេះ នៅថ្ងៃព្រហស្បតិ៍ព ជេសម(ខានស្អែក)។ លុះស្រេចកិច្ចការហើយក៏ត្រឡប់ទៅឯវត្តខ្វែងប្របែលវិញ លោកអគ្គលេខាធិការត្រឡប់ទៅទីរួមខេត្ត ។

ម៉ោង ១៤ ប្រជុំនៅវត្តខ្វែងប្របែល (យួនហៅ ជ្វកៈយ៉ា) ក្នុងឃុំហ៊ុំងហ្វួយ ខណ្ឌហាញ់វ៉ា ។ វត្តនេះមានសាលារៀន លោកអាចារ្យឈ្មោះ កាន់ ដែលបានទៅនៅរៀនព្រះបរិយត្តិធម៌ឯវត្តឧណ្ណាលោមក្រុងភ្នំពេញជាយូរឆ្នាំ បានចូលរៀនរបៀបធ្វើគ្រូនៅសាលាវត្តលង្កា ក្រុងភ្នំពេញ ប្រឡងបានសញ្ញាបត្រក្នុងឆ្នាំ ១៩៣០ ហើយត្រឡប់មកធ្វើជាគ្រូបង្រៀននៅសាលាវត្តនេះ ។ សាលារៀននេះមានកូនសិស្សកុមារ ២៤ នាក់ កុមារី ២០នាក់ ។ ក្នុងទីប្រជុំនេះមានមនុស្សប្រហែលជាង២០០នាក់ មានកុមារីម្នាក់ អាយុ ១០ ឆ្នាំ ឈរសូត្រសុន្ទរកថា ជាដំណាងក្រុមសន្និបាតនេះ ថ្លែងអំណរគុណរបស់រាជការដែលបានបង្កើតឲ្យមានពុទ្ធសាសនបណ្ឌិត្យ ទំនុកបំរុងអស់ប្រជាជនជាតិខ្មែរក្នុងខេត្តនេះឲ្យបានភ្លឺស្វាងបន្តិចគ្រាន់បើជាងពីដើម ។ រួចហើយ

---

១ លោកឡាត់មិនិស្រ្តាទ័រ ខេត្តបាក់លីវនេះ នាម ប្រ៊ែយែរដឺលិល (Brière de l'Isl) ។

កូនសិស្សទាំង ៤៤ នាក់សូត្រធម៌ប្រែឲ្យយើងស្ដាប់តាមគួរដល់វេលា បេះសូត្របបគ្នាត្រឹមត្រូវពីរោះគួរឲ្យពេញចិត្តនឹងការសិក្សាហាត់រៀនរបស់សិស្សទាំងនេះពេក ។ យើងបានថ្លែងសេចក្ដីពេញចិត្តព្រមទាំងនិយាយពន្យល់សព្វគ្រប់ហើយឲ្យបែករូបផ្ដិតព្រះពុទ្ធរូបលោកអគ្គលេខាធិការអញ្ជើញទៅឯទីរួមខេត្តវិញ ។

ថ្ងៃពុធ ៦ ធ្នូ ១៩៣៣ (៤ រ.ចមិគសិរ)

ម៉ោង ៨ (ព្រឹក) ចេញទៅវត្តពុតធ្លេ(១) (យួនហៅជួស៊ុ) ក្នុងឃុំបិញ ខណ្ឌវ៉ាប៊ិញ ម៉ោង ៩ ដល់វត្តពុតធ្លេ ។ ក្នុងទីប្រជុំនេះមានមនុស្សប្រហែលជាង ២០០ នាក់ ។ យើងបានធ្វើការសព្វគ្រប់ហើយក៏ធ្វើភត្តកិច្ចនៅវត្តនេះ ។

ម៉ោង ១២ ចេញពីវត្តពុតធ្លេត្រឡប់មកឯទីរួមខេត្តវិញ ហើយបង្ហួសសំដៅទៅវត្តព្រៃផាប់ ម៉ោង ១៣ កន្លះទៅដល់វត្តព្រៃផាប់ ក្នុងឃុំឡាយវ៉ា ខណ្ឌឋាញ់ហឹង ។ មានលោកភិក្ខុ ១ រូបឈ្មោះ ឡឹម–កែស មានសញ្ញាបត្រសាលាវត្តលង្កាពីក្នុង

១ ពាក្យថា "ពុតធ្លេ" នេះជាឈ្មោះឈើមួយយ៉ាងដែលយើងឯអាយហៅថា "ភ្ញាំពាក់" នៅទីដំបន់នេះមានដើមភ្ញាំពាក់ដុះច្រើនណាស់ ពួកខ្មែរខេត្រពាក់លីវហៅថា "ពុតៈធ្វ" គេច្រើនប្រើធ្វើជាខស ។

ឆ្នាំ ១៩២៩ រាជការតាំងឲ្យធ្វើជាគ្រូបង្រៀនក្នុងសាលាវត្តនេះ មានសិស្សកុមារ ២៤ នាក់ កុមារី ១១ នាក់ សិស្សទាំងនេះមានការបេះដឹងប្រជុំប្រសងគ្នានឹងពួកសិស្សសាលាវត្តខ្វែងព្រវែលដែរ ។ ក្នុងទីប្រជុំនេះ មានមនុស្សប្រហែលជាង ២០០ នាក់ ។ លុះយើងបានពន្យល់កិច្ចការសព្វគ្រប់ហើយ លោកចៅអធិការព្រមទាំងឧបាសកឧបាសិកាក្នុងសន្និបាតនេះ បានជំរាបលោកអគ្គលេខាធិការថា សុំនិមន្តខ្ញុំឲ្យអាណិតមេត្តាសំដែងធម៌ផ្លូវពុទ្ធ-សាសនាឲ្យបាន ១ ម៉ោង ព្រោះចង់ស្ដាប់ណាស់ ខ្ញុំក៏បានសំ-ដែងធម៌ទេសនាបំពេញសទ្ធាអ្នកទាំងនោះជិត ១ ម៉ោង ។ ក្រុមសន្និបាតនេះក៏សំដែងអាការរីករាយណាស់ ហើយមានពាក្យត្អូញជំរាបលោកអគ្គលេខាធិការថា បើប្រសិនជាពុទ្ធសាសន-បណ្ឌិត្យ មេត្តាចាត់លោកធម្មកថិកពីក្រុងភ្នំពេញឲ្យនិមន្តមកទេសនាដាស់តឿនរំឭកអស់យើងខ្ញុំក្នុង ១ ឆ្នាំ ៗ បានពីរដង ៗ រៀងរាល់ឆ្នាំទៅ នោះយើងខ្ញុំមុខជានឹងអាចកំចាត់នូវអពមង្គលគឺសេចក្ដីល្ងង់ខ្លៅឲ្យឃ្លាតចេញបន្តិចម្ដង ៗ ដោយលំដាប់ទៅ

ពុំខាន ។ លុះរួចកិច្ចសព្វគ្រប់ហើយ យើងត្រឡប់មកឯទីរួមខែត្រវិញ (សំណាក់នៅវត្តខ្វេងប្របែល) ។

(ថ្ងៃព្រហស្បតិ៍ ៧ ធ្នូ ១៩៣៣ (៨ រោចមិគសិរ)

ម៉ោង ៧ កន្លះ (ព្រឹក) ចេញទៅវត្តដើមអម្ពិល (ឃួនហៅ ជួកីម៉ែ) ក្នុងឃុំឃិញភឿក ខណ្ឌបាញ់ហ៊ុង ម៉ោង ៨ កន្លះទៅដល់វត្តដើមអម្ពិល ។ វត្តនេះមានសាលារៀន មានគ្រូបង្រៀន ២ នាក់ ជាបព្វជិត ១ រូប ជាគ្រហស្ថ ១ នាក់ សុទ្ធតែមានសញ្ញាបត្រសាលាវត្តលង្កា ពីក្នុងឆ្នាំ ១៩២៩ នឹងឆ្នាំ ១៩៣២ មានសិស្សកុមារ ៦៤ នាក់ កុមារី ១៥ នាក់ មានការចេះដឹងគ្រាន់បើល្មមប្រើការបានខ្លះហើយ ។ ក្នុងទីប្រជុំនេះមានមនុស្សប្រហែលជាង ៤០០ នាក់ ។ លោកអគ្គលេខាធិការមានថ្លែងសេចក្ដីសរសើរដល់ពួកសិស្សសាលាវត្តនេះជាច្រើន ។ លុះយើងធ្វើកិច្ចការសព្វគ្រប់ហើយ ក្រុមសន្និបាតនេះបានសុំនិមន្តឲ្យខ្ញុំនិយាយពន្យល់អំពីធម៌វិន័យព្រះពុទ្ធសាសនា ខ្ញុំក៏បានពន្យល់តាមគួរដល់វេលាហើយធ្វើភត្តកិច្ចនៅវត្តនេះ ។

ម៉ោង ១២ កន្លះ បេញពីវត្តនេះឆ្ពោះទៅវត្តកណ្ដាល (យួនហៅ ជួអុងថុង) ក្នុងឃុំខណ្ឌជាមួយគ្នានឹងវត្តដើមអម្ពិលដែរ ទៅតែបន្តិចទៅក៏ដល់វត្តកណ្ដាល ។ វត្តនេះមានសាលារៀនធំដុំគេសង់ជា ២ ជាន់ មានគ្រូបង្រៀនដល់ ៤ នាក់ ជាបព្វជិត ១ រូប ជាគ្រហស្ថ ៣ នាក់ គ្រូ ២ នាក់មានសញ្ញាបត្រសាលាវត្តលង្កា គ្រូ ២ នាក់ទៀតមានសញ្ញាបត្រសាលារៀននៅទីរួមខេត្របាក់លីវ សាលាវត្តកណ្ដាលនេះមានបង្រៀនអក្សរបារាំងខ្លះផង បែកមុខការរៀនជា ៤ ថ្នាក់ មានសិស្សកុមារ ១០៥ នាក់ កុមារី ១៧ នាក់ (រួមទាំងអស់ជា ១២២ នាក់) ។ ក្នុងទីប្រជុំនេះមានមនុស្សប្រហែល ៣០០ នាក់ ។ កាលដែលយើងចូលទៅដល់ក្រុមសន្និបាតក៏បានប្រជុំព្រមមូលរៀបរយ ហើយមានកុមារម្នាក់ឈ្មោះសុព័ណ៌ (ជាសិស្សបញ្ជូនពីសាលាវត្តខ្វែងប្របែលមកឲ្យរៀននៅសាលាវត្តនេះថែមទៀត) ចូលមកឈរសូត្រសុន្ទរកថាជាខ្មែរ បន្ទាប់មក មានកុមារម្នាក់ឈ្មោះសឺន-ទៀន ចូលមកឈរសូត្រសុន្ទរកថាជាបារាំង (សេចក្ដីប្រែពីសុន្ទរកថាខ្មែរ) ។ សុន្ទរកថានោះថ្លែងសេចក្ដីសរសើរគុណរាជការដែលបានបង្កើត

ពុទ្ធសាសនបណ្ឌិត្យ ហើយជួយឃឹតយោងស្រោចស្រង់ប្រជាជនជាតិខ្មែរខេត្តបាក់លីវនេះ ។ យើងបានធ្វើការសព្វគ្រប់ហើយក៏ត្រឡប់មកឯទីរួមខេត្តវិញ (សំណាក់នៅវត្តខ្វែងប្របែល) ។

ថ្ងៃសុក្រ ៨ ធ្នូ ១៩៣៣ (៦ កើតមិគសិរ)

ម៉ោង ៧ កន្លះ (ព្រឹក) បេញទៅវត្តក្រសាំង ក្នុងឃុំឃិញប្ញូរ ខណ្ឌហ៊ាញ់ហ៊ឹង ម៉ោង ៨ កន្លះដល់ទៅព្រែក ១ តូចឆ្ងាយពីវត្តក្រសាំងជាង ២ គីឡូម៉ែត្រ ស្ពានចាស់ទ្រុឌទ្រោមណាស់មិនហ៊ានបើករថយន្តឆ្លងទៅ យើងនាំគ្នាដើរទៅរហូតដល់វត្តក្រសាំង ឃើញមានមនុស្សទាំងបព្វជិតទាំងគ្រហស្ថប្រហែល៣០ នាក់ ហៅអធិការវត្តនេះសំដែងអាការតោះតើយ ឲ្យឃើញហាក់តមានត្រូវការអ្វីនឹងដំណើរដែលយើងមកនេះទេ ។

យើងបានខំប្រឹងអត់ធ្មត់និយាយពន្យល់តាមសមគួរ លុះស្រេចការហើយ លេខាធិការ សឺន-ស ក៏នាំយើងចេញពីវត្តនេះទៅសម្រេចភត្តកិច្ចនៅផ្ទះឈ្មោះ លិម-ឡុងភី ជាក្រុមប្រឹក្សាចាស់សម្រាប់ខេត្តបាក់លីវ ។

ម៉ោង ១៣ យើងចេញពីផ្ទះ លិម-ឡុង-ភី ដើរតាមផ្លូវដដែលមកដល់វិញ ឡើងរថយន្តបើកសំដៅទៅវត្តដូនទ្រៃ ក្នុងឃុំខណ្ឌជាមួយគ្នានឹងវត្តក្រសាំងដែរ ម៉ោង១៤កន្លះដល់វត្តដូនទ្រៃ។ មានពួកបព្វជិតនឹងគ្រហស្ថប្រហែលជាង ១០០ នាក់ ឈូធរមកទទួលដោយអាការរីករាយហាក់ដូចគេឃើញពួកញាតិដែលព្រាត់ប្រាសនិរាសអស់កាលយូរ ។ យើងបានធ្វើការសព្វគ្រប់ហើយក៏ចេញពីវត្តនេះត្រឡប់មកឯទីរួមខេត្តវិញ ។ លុះមកដល់ផ្សារព្រៃកតាមុម (យួនហៅយិញភឿក) នៅជិតវត្តដើមអម្ពិល មានដង្ហៅម្នាក់ឈ្មោះ សឺន-សំ ដង្ហៅម្នាក់ទៀតឈ្មោះ សឺន-ឡាយ មកឈរចាំ បានឲ្យសញ្ញាដោយការគោរពឱនលំទោនសុំឲ្យយើងឈប់ ហើយបានអង្វរឋាសុំឲ្យយើងចូលផ្ទះបាន ១ ស្របក់ ដើម្បីជាមង្គលតាមអធ្យាស្រ័យនឹងបំណងរបស់គេ យើងបានឆ្លៀតចូលទៅ ១ ស្របក់ ។ ដង្ហៅទាំង ២ នាក់ក៏បានថ្លែងអំណរគុណចំពោះពុទ្ធសាសនបណ្ឌិត្យ ដែលបានចាត់ការបោះពុម្ពព្រះត្រៃបិដក ដោយខ្លួនគេទាំង ២ នាក់បានចេញប្រាក់ជាវ ១ ចប់ម្នាក់ ដោយសោមនស្សពន់ពេក

ណាស់ ។ យើងបានសំដែងសេចក្ដីរាក់ទាក់បំពោះអ្នកទាំងនោះតាមសមគួរហើយ ក៏លាគេបេញមកឯទីរួមខេត្តវិញ (សំណាក់នៅវត្តខ្វែងប្រវែល) ។

ថ្ងៃសៅរ៍ ៩ ដេសម ១៩៣៣ (ឥភោចមិគសិរ)

ម៉ោង ៦ (ព្រឹក) យើងបេញពីទីរួមខេត្តទៅស្រុកកាម៉ៅ (ខ្មែរហៅទឹកខ្មៅ) ម៉ោង ៨ កន្លះទៅដល់ផ្សារស្រុកកាម៉ៅ ។ គ្រាន់តែដល់ទៅភ្លាមក៏ចុះកាណូតរាជការដែលហៅហ្វាយស្រុកកាម៉ៅ (ជាតិយួន) បានចាត់ការទុកបំរុងចាំយើងជាស្រេច បេញកាណូតតាមព្រែកធំឆ្ពោះទៅវត្តជុំប្រាសាទនឹងស្រុករ៉ាច់គួយ ៗ លុះបើកកាណូតទៅដល់ព្រែក ១ តូចហៅថា ព្រែករ៉ាច់គួយ (ព្រែកឃ្លាយ) ដែលបែកចូលទៅវត្តជុំប្រាសាទ កាណូតឈប់នៅនោះ គេយកទូក ៣ មកទទួលយើងនៅទីនោះ ។ ដំណើរដែលចូលទូកតាមព្រែករ៉ាច់គួយទៅនេះ បែរឬអុំក៏មិនកើតលុះតែដោលខ្លះ ទាញពួរអន្ទងដើរតាមក្បែរព្រែកខ្លះទើបទៅបានព្រោះវេលានោះទឹកកំពុងនាចខ្លាំង ម៉ោង ១៣ កន្លះទៅដល់វត្តជុំប្រាសាទ ក្នុងឃុំខាញ់បិញ ខណ្ឌខាងជៀង ។ វត្តនេះ



ប្រាសាទនគរវត្ត មើលឃើញទាំងស្រះព័ទ្ធក្រុងផង ។

## សេចក្ដីយល់ឃើញអំពីប្រាសាទនគរវត្ត
## របស់លោកព្រឹលុស្ស៊ី

លោកព្រឹលុស្ស៊ីជាអ្នកប្រាជ្ញធំ ១ សម្រាប់ព្រះពុទ្ធសាសនា នឹងព្រាហ្មណសាសនា ។ លោកបានពន្យល់ដូចសេចក្ដីខាងក្រោមនេះអំពីប្រាសាទនគរវត្ត នឹងអំពីដែលប្រាសាទនេះបែរមុខផ្ដោះទៅទិសខាងលិច ។

ប្រាសាទនគរវត្ត តាំងនៅក្រៅកំផែងនគរធំចំ ងាយប្រ-មាណ ១ គីឡូម៉ែត្រមកទិសខាងត្បូង ។

នៅខាងមុខទិសខាងកើតនឹងទិសខាងលិចនោះក្នុងមុខមួយ ៗ មានទ្វារ ៣ នៅត្រង់កណ្ដាល ។ ឯទ្វារខាងកើតនោះឥតមានត្រូវចេញចូលឡើយ ព្រោះទ្វារទាំងនោះគ្មានជណ្ដើរ ។ ទ្វារធំសម្រាប់ចូលនោះ បែរមុខទៅទិសខាងលិច ហើយនៅមុខនេះមានបោះទ្វារ ៣ យ៉ាងធំ ៗ ដំរីដើរចូលបានយ៉ាងស្រួលឥតទើសទែង ។ គឺជាទ្វារកិត្តិយស ហើយប្រហែលជាធ្វើសម្រាប់ក្បួនដង្ហែស្ដេចយាងចូលចេញ ។ ឯបំណែកមនុស្សធម្មតាដែលគេបើកឲ្យចូលកាលជាន់នោះ ត្រូវដើរព័ទ្ធជុំវិញកំ-

ជើង ហើយត្រូវចូលតាមទ្វារដែលមានពោះតែមួយៗ ពីខាងជើងឬពីខាងត្បូង ឬចូលតាមទ្វារដែលមាននៅជ្រុងគ្រប់ជ្រុងទាំងអស់ ។ នៅពីខាងស្តាំទ្វារនៅមុខខាងត្បូងមានក្បាច់បំឡាក់ឆ្លាក់រឿងត្រង់វិនិច្ឆ័យទោសមនុស្សដែលស្លាប់ទៅទាំងប៉ុន្មាន ហើយមានស្ថានសួគ៌ និងស្ថាននរក ។ ក្បាច់បំឡាក់ផ្ទាំងនេះ រៀបបំអ្នកដែលចូលមើលឲ្យមើលនៅកន្លែងដំកល់ព្រះបរមសពស្តេច[១] ។ ដូច្នេះយើងត្រូវឧបមាថាកន្លែងដែលចូលទៅមើលនោះត្រូវចាប់ពីខាងស្តាំទ្វារខាងត្បូងទៅ ។ នៅវេលាដែលទទួលយកនូវសេចក្តីវិនិច្ឆ័យដោយកដូច្នេះហើយ ក្បាច់រចនាទាំងឡាយនៅជញ្ជាំង ក៏លេចសេចក្តីភ្លឺច្បាស់ឡើងដល់គំនិត ក្បាច់បំឡាក់នៅជញ្ជាំងជារឿងរ៉ាវនោះមានទំនងតៗ គ្នាស្រួលមានលក្ខណ៍មានខណ្ឌ ដែលអ្នកស្រាវជ្រាវប្រាសាទបុរាណមុនៗមិនបានដឹង ។ គឺតពីពួកស្ថានសួគ៌និងស្ថាននរកទៅ គេប្រទះឃើញរឿងកូរសមុទ្រ រួចឃើញរឿងចម្បាំងពួកទេវតានឹង

---

១ គំនិតក្នុងព្រះពុទ្ធសាសនាក៏មានទំនងដូចគ្នាដែរ គឺក្នុងព្រះវិហារចិនជាច្រើនគេតែងឃើញរឿងស្ថាននរកនៅខ្លោងទ្វារចូល...។

ពួកអសុរ ឃើញរឿងបរាជ័យនៃពានរនឹងមានរឿងចម្បាំងពួកទេវតានឹងពួកអសុរ១ពួកទៀត តពីនេះទៅឃើញរឿងស្ថានមនុស្សលោកយើង មានរឿងចម្បាំងធំ ២ នៅលង្កានឹងនៅកុរុ-ក្សេត្រ រឿងទី១ ខ្ចីមកពីរឿងរាមាយណ ហើយរឿងទី២ ខ្ចីមកពីរឿង មហាភារត នៅផ្ទៃខាងចុងនៃជញ្ជាំងខាងត្បូង ឃើញមានបំឡាក់រឿងកងទ័ពព្រះបាទសូរ្យវរ្ម័នទី២ ។ ឯក្បាច់ជញ្ជាំងនោះមានរឿងត ៗ គ្នាតាមរបៀបប្រវត្តិការនៃរឿងរ៉ាវដូចមានក្នុងរឿងបុរាណនឹងក្នុងឃ្លោងរឿងចម្បាំងដែលអ្នកបានមើលចាំបានស្រាប់ ។ គឺថាជាបន្ទាប់តពីរឿងវិនិច្ឆ័យសេចក្ដីមនុស្សស្លាប់នោះឃើញរឿងកទឹកកដី (គឺកូរសមុទ្រ) ឃើញចម្បាំងទេវតានឹងអសុរ រួចពីនេះឃើញរឿងចម្បាំងធំ ៗ ដែលទៅបញ្ចូលគ្នានឹងរឿងកងទ័ពព្រះបាទសូរ្យវរ្ម័នទី ២ អ្នកតុបតែងក្បាច់ប្រា-សាទនគរវត្ត បានប្រតិស្ឋរឿងរ៉ាវតាំងអំពីរឿងកទឹកកដីរហូតដល់មកសម័យកសាងប្រាសាទនេះ គឺរឿងកដីទឹក រឿងទេវតានឹងអសុរ រឿងរ៉ាវដែលមានត ៗ មកនឹងពង្សាវតារ ។ គេគិតមានបហាជាមួយនឹងលោកសឺដេសឡើយអំពីលំដាប់នឹងទំនង

ដែលត្រូវពិនិត្យក្បាច់ផ្ចាំងនោះមិនដូចទីឯទៀតសោះ ។ គឺក្បាច់ផ្ចាំងរៀងគ្នាតាមលំដាប់ប្រសព្វ ហើយទំនងនេះក៏ដូចជាទំនងប្រាសាទដែលតាំងនៅពីខាងត្បូង ហើយជាខាងក្រៅក្រុងស្តេចនោះដែរ គឺធ្វើឲ្យឃើញថាសម្រាប់ដំកល់នូវព្រះបរមសព ។ ដូច្នេះប្រាសាទនគរវត្តមិនមែនជាកាលដំបូងដើមគេកសាងសម្រាប់ឧទ្ទិសថ្វាយព្រះវិស្ណុឡើយ គឺជាប្រាសាទសម្រាប់ដំកល់នូវព្រះបរមសពរបស់ព្រះបាទសូរ្យវរ្ម័នទី២ដែលទ្រង់មានព្រះនាមក្រោយទិវង្គតជា បរមវិស្ណុលោក ។

ដោយជាប់ជំពាក់នឹងការឯទៀតជាច្រើន មិនមានឱកាសនឹងបញ្ចេញផ្សាយនូវផលដែលកើតឡើងដោយការស្រាវជ្រាវរបស់ខ្ញុំ នោះខ្ញុំគ្រាន់តែស្រង់សេចក្តីមកពោលបន្តិចអំពីការទាំងនេះតាមសេចក្តីដូចមាននៅខាងក្រោយ នៅវេលាក្រោយដែលបានពិនិត្យក្បាច់ចំឡាក់ ដែលរចនាថែវទី ១ នៃប្រាសាទនគរវត្ត នោះបានសេចក្តីខុសអំពីសេចក្តីជឿដែលគេធ្លាប់បានជឿទៅគ្រប់គ្នាទាំងអស់ គឺថាក្បាច់ចំឡាក់នៅផ្ចាំងរៀបរៀងតគ្នាតាមលំដាប់មុនក្រោយយ៉ាងត្រឹមត្រូវ ។ អ្នកដំណើរដែល

ដើរមើលរឿងគេត្រូវដើរជុំវិញប្រាសាទទុកកន្លែងកណ្ដាលឲ្យនៅជាខាងឆ្វេងដៃជរាប នេះហើយជាហេតុដែលប៉ះពាល់ដល់រឿងដើមរបស់ប្រាសាទនគរវត្ត ។

ដើម្បីនឹងឲ្យបានយល់អំពីក្បាច់ជញ្ជាំងប្រាសាទនគរវត្តនោះត្រូវដើរក្រឡឹងជុំវិញដាក់ប្រាសាទពីខាងឆ្វេងដៃជរាប ។ ការធ្វើបំពានច្បាប់ប្រទក្សិណដូច្នេះ ទំនងជាកើតឡើងដោយប្រាសាទនេះជាប្រាសាទសម្រាប់ដំកល់នូវព្រះបរមសព ហើយម្យ៉ាងវិញទៀតទិសដែលឆ្ពោះមុខទៅរកក៏មិនជាទិសធម្មតាផង។

បំពោះនឹងបំណោទដែលចោទដូច្នេះ ខ្ញុំបានពន្យល់រួចហើយ ហាក់ុឲ្យញញើតនឹងឆ្លើយដោយយ៉ាងជាក់លាក់ ។ ឯប្រទក្សិណនោះគឺត្រូវដើរជុំវិញវត្ថុអ្វី ១ ឬមនុស្សណា ១ ដោយទុកវត្ថុនោះឬមនុស្សនោះពីស្ដាំដៃជាជរាប គឺជាពិធីដែលគោរពកិត្តិយសដល់ព្រះ ដល់ទេវបុត្រទេវតា ឯប្រសវ្យវិញនោះ គឺដើរបញ្ច្រាស់មកវិញ គឺជាពិធីដែលគោរពជាកិត្តិយសដល់ខ្មោច ។ ដើម្បីនឹងឲ្យយល់នូវក្បាច់ជញ្ជាំងប្រាសាទនគរវត្ត នោះត្រូវដើរក្រឡឹងតាមក្បាច់ចំឡាក់នោះដោយដាក់ផ្ចិតកណ្ដាលពីខាងឆ្វេង

ជាដរាប គឺប្រសព្វ ហើយឯភាពសណ្ឋានទីតាំងរបស់ប្រាសាទនេះបំពោះនឹងទីក្រុងស្តេចនោះទំនងតែជាការសម្រាប់ព្រះបរមសពប៉ុណ្ណោះ ។ ដូច្នោះឃើញថាប្រាសាទនគរវត្តកាលដែលកសាងនោះមិនជាទីទេវស្ថានឡើយ គឺច្បាស់ជាទីដំកល់សពដោយពិត (អនុសាវរិយស្ថាន) ។

គេនឹងពោលទាស់តវិញមិនខានថាព្រះបាទបរមវិស្ណុលោកដែលគេសាងប្រាសាទនគរវត្តថ្វាយនេះ កាលមុននឹងទ្រង់ព្រះទិវង្គតលោកបានលើកព្រះអង្គជាព្រះរូបទៅហើយ ហើយប្រាសាទដែលគេសាងថ្វាយព្រះអង្គក៏ជាប្រាសាទសាងថ្វាយព្រះដែរ បើដូច្នេះគេទុកជាក់ជាទេវស្ថានក៏បាន ។ សេចក្តីដែលពោលទាស់នេះអាចនឹងបដិសេធចេញបានដោយងាយ ។ ដើម្បីនឹងឲ្យច្បាស់ការនោះត្រូវពិចារណា កុំយកតាមសេចក្តីឃើញរបស់យើង គឺត្រូវយកតាមសេចក្តីយល់ឃើញ នឹងគំនិតរបស់អ្នកកសាងនឹងអ្នកដើរមើលនូវប្រាសាទ ។ ដើម្បីនឹងរើសតាមប្រាសាទក្នុងពាក្យ ទេវស្ថាន នឹង អនុសាវរិយស្ថាន នោះត្រូវពិចារណាអំពីបុណ្យដែលគេធ្វើគោរព នោះជាគោរពដល់សព

មនុស្សឬដល់ព្រះអង្គរបស់ព្រះ ។ ក្នុងស្ថានទី ១ គឺប្រាសាទ ហើយក្នុងស្ថានទី ២ គឺប្រទក្សិណ ។ បុះបើក្បាប់ជញ្ជាំងតាំងរៀបរៀងឲ្យអ្នកដែលចូលទៅតាំងធ្វើប្រសវ្យដូច្នេះហើយ នោះយើងមិនត្រូវយល់ថាជាទេវស្ថានឡើយ ។ ពិតមែនតែសាជារណាជនមានទំលាប់ហៅតាមពួកអ្នកប្រាជ្ញ ថាប្រាសាទនគរវត្តជាទេវស្ថានគ្រប់ ៗ គ្នាមកហើយ តែថាសេចក្ដីដែលហៅនេះមិនត្រូវបំលើឈ្មោះមែនរបស់ប្រាសាទនេះទេ ។

សេចក្ដីយល់ឃើញរបស់យើង មានសំអាងដោយដំណឹងដែលអ្នកពិនិត្យស្រុកទេសជាន់ពីដើម បានបារិកទុកៈ

ក្នុង គ. ស. ១២៩៥ មានរាជទូតចិនម្នាក់បានមកដល់នគរវត្តក្នុងស្រុកខ្មែរ ដោយព្រះចៅ ចេន-ត្សុង ដែលជាស្ដេចរាជាធិរាជពួកយុអានទ្រង់ចាត់មក ។ ក្នុងបណ្ដាពួករាជទូតទាំងនោះ មានម្នាក់ឈ្មោះ ជាវ-តា-ក្លូន ជាអ្នកបង់បេះបង់ដឹងឧស្សាហ៍សាកសួរកត់ត្រា ហើយបានទុកស្នាដៃដែលកត់ឲ្យយើងបានដឹង អំពីភាពភូមិស្ថានយ៉ាងសំខាន់នៃទីក្រុងខ្មែរ ។ ប្រហែលជា ជាវ-តា-ក្លូន បានឃើញប្រាសាទព្រះវិស្ណុលោក តែឃើញ

តែពីខាងក្រៅ ព្រោះគាត់បានសារសព្វអំពីភាពទំនងយ៉ាងប្លែក ដូចសេចក្ដីខាងក្រោយនេះ

វេលាដែលចេញតាមក្លោងទ្វារខាងត្បូងទៅ គេប្រទះឃើញប្រមាណកន្លះ "លី" មានប្រាសាទសាងដោយថ្ម ១ ដែលអ្នកស្រុកពោលថាព្រះល្វប៉ានបានសាងតែ ១ យប់ហើយស្រេច ។ ហើយប្រាសាទដំកល់សពល្វប៉ាននោះនៅចំងាយប្រហែល ១ លីពីក្រៅកំផែងខាងត្បូង បណ្ដោយជុំវិញប្រាសាទនោះប្រមាណ ១០ លី ។ ក្នុងទីនោះឃើញមានផ្ទះតូច ៗ សាងដោយថ្មជាច្រើនរយខ្នង ។

បណ្ដោយជុំវិញប្រាសាទដំកល់សពល្វប៉ាន (១០លីស្មើនឹង៤០០ម៉ែត្រ) ប្រវែងនេះប្រហែលគ្នានឹងនគរវត្ត ទីកន្លែងប្រាសាទក៏ត្រូវគ្នា មានតែចំងាយពីក្លោងទ្វារខាងត្បូងនគរធំមកឃើញជិតពេកគឺតិចដល់ទៅពាក់កណ្ដាល ប៉ុន្តែការបន្ថិចបន្ថួចនេះមិនជាមានប្រយោជន៍ប៉ុន្មានទេ ព្រោះនៅទីកន្លែងដែលពោលនេះ មិនដែលឃើញមានប្រាសាទឯណាផ្សេង ៗ ដែលមានទំហំដូច្នេះឡើយ ។ ការនេះគ្មានអ្វីជាទីនាំឲ្យសង្ស័យ

ទៀតទេ ដែល ជាវ-តា-កួន ហៅថាប្រាសាទដំកល់សព លូប៉ាននោះគឺប្រាសាទនគរវត្ត ជាយពិត ។

ហេតុអ្វីបានជាគាត់ហៅឈ្មោះបំទ្បែកដូច្នេះ លូប៉ាន នេះ ក្នុងស្រុកចិន គឺជាឈ្មោះទេវបុត្រដែលធ្វើជាងផ្ទះ ទេវបុត្រនេះ ត្រូវគ្នានឹងវិស្វកម្ម របស់ហិណ្ឌូ ហើយឈ្មោះនេះមកក្លាយក្នុង ស្រុកខ្មែរជាវិស្ណុកម្ម ដែលអ្នកស្រុកធម្មតាហៅថាព្រះពិស្ណុការ ដែលមានក្នុងរឿងបរម្បរាតៗ មកថាបានសាងនគរវត្ត ។ ម្យ៉ាង វិញទៀតប្រាសាទនេះជាទេវស្ថាន ហើយប្រហែលជាទីដំកល់ សពព្រះបរមវិស្ណុលោកផង ដែលហៅតាមអ្នកស្រុកថាព្រះពិស្ណុ-លោក ។ គេអាចនឹងប្រទ្បបានដោយងាយ អំពីព្រះនាមស្ដេច នឹងជាងគឺ ពិស្ណុលោកនឹងពិស្ណុការ គឺអ្នកដែលឲ្យដំណឹងដល់ ជាវ-តា-កួន ប្រទ្បហើយប្រាប់សេចក្ដីដូច្នេះមក យកប្រាសាទ ដំកល់ព្រះពិស្ណុលោក ទៅជាប្រាសាទដំកល់ព្រះពិស្ណុការវិញ ដែល ជាវ-តា-កួន គាត់យកទៅប្រែតាមឈ្មោះទេវតាដែលហៅ ជាភាសាចិន ។

ខេមាខេមសរណកថា

ព្រះមហាពិទូរ ក្រសេម រៀបរៀង

( គ )

ក្នុងលោកនេះ មានមនុស្សជាច្រើនដែលមិនហ៊ានត្រិះរិះដោយកំលាំងគំនិតខ្លួនឯង ជាគ្រឿងពិសោធន៍របស់ពិតច្រើនតែដាក់ធុរៈចាំតែទទួលជឿលទ្ធិឯណានីមួយសឹងមានអ្នកប្រដៅឲ្យដោយអគតិ ហើយក៏វង្វេងកាន់ទៅតាមគេដឹកប្រមុះ ។ ចំណែកឯអ្នកដែលត្រិះរិះរកហេតុផលហើយទើបជឿនឹងបដិបត្តិតាមក្រសែសេចក្តីដែលខ្លួនឃើញហើយនោះ ឈ្មោះថាដំណើរជីវិតទៅក្នុងផ្លូវដ៏ត្រង់ គាប់នឹងភាសិតថា និសម្មករណំ សេយ្យោពិចារណាហើយសឹមធ្វើប្រសើរជាជាង ទាំងជាប្រយោជន៍ដល់មនុស្សជាតិផងគ្នា ខនេះអាចឃើញបានក្នុងប្រវត្តិលោកជាគណៈឬប្រទេសនីមួយ ៗ ក្នុងលោកពិភពនេះ រមែងចំរើនរុងរឿងឡើង ដោយមានមនុស្សយកចិត្តទុកដាក់ត្រិះរិះជ្រាវរាវរកហេតុផល ។ រីឯសេចក្តីសន្តោសជាគុណធម៌គួរឲ្យមាន អ្នកណាមានហើយ អ្នកនោះក៏ឈ្មោះថាមានទ្រព្យដ៏ប្រសើរ សមដូចព្រះពុទ្ធភាសិតថា សន្តុដ្ឋី បរមំ ធនំ សេចក្តីសន្តោសជាទ្រព្យដ៏ប្រសើរក្រៃលែងដូច្នេះ ព្រោះនឹងបានមិនបាច់ត្រដរ

ត្រដួសស្វែងរកដោយអំណាចតណ្ហាបង្គាប់ ដែលជាហេតុនាំឲ្យប្រព្រឹត្តទុច្ចរិតសឹងមិនត្រូវផ្លូវ តែសេចក្ដីសន្តោសដែលពោលនេះលោកសំដៅឲ្យសន្តោសតែត្រឹមទ្រព្យសម្បត្តិ ឬលាភសក្ការយ៉ាងដទៃ ៗ មិនមែនសំដៅដល់ទៅសេចក្ដីចេះដឹង ឬសេចក្ដីពិសោធស្រាវរកខុសត្រូវផងទេ ព្រោះសេចក្ដីចេះដឹងជារបស់ដែលយើងគប្បីស្វែងរក គប្បីបំពេញឲ្យសម្បូណ៌ឡើងក្នុងសន្ដាន មិនគួរពេញចិត្តត្រឹមដែលខ្លួនដឹងហើយប៉ុណ្ណោះ ប្រសិនបើមនុស្សយើងគាប់ចិត្តត្រឹមវិជ្ជាដែលខ្លួនដឹងហើយ មិនគិតជ្រាវរករបស់ដែលប្លែក ៗ ឲ្យសុខុមតទៅទៀត ឬមិនត្រិះរិះរកហេតុផលដោយខ្លួនឯងខ្លះហើយ លោកយើងនេះក៏គង់ជាមិនប្រែចេញអំពីសភាពជាព្រៃមកជារម្មណីយស្ថាន ដេរដាសពាសពេញដោយគេហស្ថានប្រាង្គណ៍ប្រាសាទមណ្ឌប គ្រឿងចក្រសម្រាប់ប្រើការផ្សេងៗដូចយ៉ាងគ្រឿងពុម្ពអក្សរ គ្រឿងចក្រកិនស្រូវ គ្រឿងអគ្គិសនី គ្រឿងទោរលេខ ទោរសព្ទ យន្តហោះរថយន្ត កប៉ាល់ ។ល។ រហូតដល់គ្រឿងឧបភោគ និងគ្រឿងបរិភោគយ៉ាងល្អ ៗ ជាអនេកយ៉ាងដែលមនុស្សប្រើប្រាស់

សព្វថ្ងៃនេះទេ គួរកាន់យកតាមក្រសែសេចក្ដីនៃព្រះពុទ្ធដម្រាស់ដ៏មានមកក្នុងកាលាមសូត្រ ដែលទ្រង់ប្រារព្ធនឹងជនកាលាមគោត្រថា ម្នាលកាលាមគោត្រអ្នកទាំងឡាយកុំគប្បីជឿពាក្យអាចារ្យត ៗ មក កុំគប្បីជឿគម្ពីរតម្រា កុំគប្បីជឿពាក្យតថាគតតែម្ដង កាលបានស្ដាប់កាលបានឃើញពាក្យប្រដៅឯណានីមួយ គប្បីពិចារណាឲ្យឃើញច្បាស់ដោយបញ្ញាចក្ខុរបស់ខ្លួនជាមុនសិន សឹមជឿកាន់យក ព្រះពុទ្ធភាសិតនេះសរឲ្យឃើញថា កាលបានឮរឿងអ្វីមិនត្រូវឲ្យមៅជឿភ្លាមតែម្ដង ព្រោះការដែលមៅជឿទាំងមូលដូច្នោះ អាចមានវេលាខុសឬប្រែប្រួលទៅបានក្នុងកាលដែលឃើញអ្វីប្លែក ៗ តទៅទៀត ត្រូវពិចារណាដោយល្អិតល្អ ឲ្យជ្រួតជ្រាបដោយបញ្ញារបស់ខ្លួន ត្រូវទំពាឲ្យបែកជញ្ចៀបជញ្ជាក់ភ្លក់មើលឱជារសឲ្យដឹងជាយ៉ាងម្ដេចហើយសឹមកាន់យកនោះ ទើបគ្មានផ្លូវខុស មិនតោងស្ដាយក្រោយ ។

ការដែលសិក្សាវិជ្ជា ក៏ដើម្បីឲ្យកើតបញ្ញាគិតឃើញដោយខ្លួនឯងបានក្នុងថ្ងៃមួយ មិនមែនសម្រាប់តែយកភាគគំនិតរបស់គេមកប្រែកក្នុងខួរក្បាលរបស់យើង គ្រប់មុខគ្រប់យ៉ាងនោះទេ

រឿងសរណៈនេះតាំងតែពីណាមកហើយ មើលទៅមនុស្សទាំងឡាយសុទ្ធតែសរសើរបស់ខ្លួន បង្អាប់របស់អ្នកដទៃ តែការដែលពោលដូច្នេះមិនមែនជាគតិនៃប្រាជ្ញ តែទោះបីដូចម្ដេចក៏តាមកាលមកត្រូវតមើលតាមអាការនៃពាក្យនិន្ទា និងពាក្យសរសើរសរណៈនោះៗ ហើយគង់ឃើញបានថា មាន ៣ បំណែក គឺ ១ និយាយដោយសេចក្ដីកម្លៅ ២ និយាយដោយទាល់ផ្លូវ ៣ និយាយដោយដឹងច្បាស់ហើយ ហេតុដូច្នោះសក្ដានុភាពនៃសរណៈទើបមានជាអនេកសល់ផល ទាល់តែជួនកាលកើតជាអង្គសេចក្ដីទាស់ទែងគ្នាឯងក៏មានជាច្រើន ។ ឱកាសដែលនឹងជ្រើសរកសរណៈដែលល្អបំផុតបាន ចូលជាលំបាកបន្តិច តែក៏មិនលំបាកហួសវិស័យ ដ្បិតមានពាក្យប្រៀបផ្ទើទុកដើម្បីកុំឱ្យអស់សង្ឃឹម ថាភ្លើងអគ្គិសនីម្ដេចនៅក្នុងអំណាចទេវជាងប្រតិស្នកម្មអាចត្រិះរិះរកទាល់តែឃើញ នាំយកមកប្រកបធ្វើជាកំលាំងភ្លើងអាស្រ័យពន្លឺ និងប្រកបប្រើជាទោរលេខ ទោរសព្ទ ។ ល ។ មានប្រយោជន៍ដល់មនុស្សជាច្រើន ត្រឹមតែបម្រាញ់យកទឹកដ៏បរិសុទ្ធអំពីរបស់ដែលប្រូកឡូក នឹងលំបាកជាងនោះណាស់

ទៅឬ រឿងសរណៈសូម្បីជាការស្មុកស្មាញក៏ពិត តែក៏គង់មិនក៏បិទកំបាំងដល់ទៅផុតវិស័យនឹងលៃលករកឡើបាន គង់មាន ១ យ៉ាងដែលមានសារបរិសុទ្ធពិត ហើយនៅក្នុងវិស័យត្រិះរិះរបស់មនុស្សផង ប្រហែលជាជ្រាបហើយថា មនុស្សរាល់រូបតោងមានសរណៈសម្រាប់ខ្លួន អ្នកគ្មានសរណៈលោកថា ដូចជាអាក្រាតកាយ ។ បំណែកឯសរណៈវិញសោតរមែងមានអំណាចខ្ពស់លើអ្នករាប់អាន រមែងមានដំឡៃលើសបុគ្គលអ្នកបូជាជាដរាប ក៏ក្នុងលោកនេះអ្វីដែលប្រសើរបំផុតមិនមែនមនុស្សទេឬ កាលមនុស្សជាសត្វវិសេសហើយៗតោងរាប់អានសរណៈទៀតនោះ បើសរណៈមិនថ្លៃថ្លាជាងខ្លួនអ្នកកាន់មិនជាការបន្ថយសក្តិរបស់ខ្លួនឡើទាបចុះទៅឬ ទើបសមគួរណាស់ ដែលមនុស្សយើងរាល់រូប ត្រូវអំពល់ក្នុងរឿងសរ-ណៈឡើក្រៃល ៗ ឡើជាការងារមួយយ៉ាង សម្រាប់តស្សូរ-សក្តិ នឹងប្រយោជន៍នៃជីវិតខ្លួនផង មិនគួរនឹងបណ្តោយជីវិតឡើដំណើរទៅក្នុងអសារលទ្ធិ ឬរលត់ទៅទទេនោះឡើយ ។

សេចក្ដីខ្លាចជាហេតុឲ្យស្វែងរកសរណៈ ។ សរណៈ ប្រែតាមទំនងនេះថា ជាទីពឹង ជាទីរលឹក ជាទីជ្រកកោន កំចាត់ភ័យ ។ ជាធម្មតាមនុស្សយើងអ្នកដែលមាននាមថា បថុជ្ជនតោងមានសរណៈ កំដរជីវិតទៀតនោះ មកពីខ្លាចក្រែង ភប់ប្រសព្វអនិដ្ឋារម្មណ៍ ដោយបង់ភប់ប្រសព្វតែឥដ្ឋារម្មណ៍ ក្នុងលោកនេះខ្លះ ខ្លាចក្រែងទៅកើតក្នុងទីអាក្រក់ក្នុងលោកឯមុខ ខ្លះ ម្ល៉ោះហើយកាលឃើញអ្វីចំឡែកប្លែកអស្ចារ្យ ក៏បួលទៅ សូមពឹងពាក់ដើម្បីនឹងឲ្យជួយកំចាត់ភ័យទាំងនោះ កុំឲ្យមកជិត ដល់ បើមុខជាត្រូវប្រសព្វមិនខាន ក៏សូមឲ្យសម្រាលធ្ងន់ ជាស្រាល ឬសូមកុំឲ្យរួសរាន់មកដល់ពេក មេត្តាបង្អង់ទៅ ដល់នេះទៅដល់នោះសិនចុះ ទើបអំពាវរកព្រះនេះព្រះនោះឲ្យ បួលមកជួយដោយគិតថា ប្រហែលជាជួយរម្ងាប់ភ័យបានខ្លះ ទេដឹង? ទើបកើតមានសរណៈផ្សេង ៗ ជាសប្របំពី តែបើនឹង រួបរួមមកកំណត់តាមលក្ខណៈដែលកើតគង់មានត្រឹម ២ យ៉ាង គឺបញ្ញត្តិឡើងដោយសេចក្ដីស្មាន ហៅថា អនុមានបញ្ញត្តិ ប្រភេទ ១ បញ្ញត្តិឡើងដោយសេចក្ដីយល់ច្បាស់ធ្លុះធ្លាយហៅថា

បច្ចុប្បញ្ញត្តិប្រភេទ ១ ។ អនុមានបញ្ញត្តិ បានតែងការបញ្ញត្តិឡើងដោយសេចក្ដីល្ងង់ខ្លៅ ខ្វះសេចក្ដីពិចារណាត្រួតត្រាឲ្យដល់ទី ហើយក៏បង្អោនចិត្តជឿតាម ផ្អែកទៅលើសេចក្ដីស្រពេចស្រពិល សិងមានដើមថា ប្រហែលជាជួយបានទេដឹង គង់ខ្លាំងពូកែមែនទេដឹង អ្នកទទួលរាប់អានមិនពិគ្រោះឲ្យអស់ក្បាប់ ជាសមពិត ឬមិនពិត សុំឲ្យតែបានរាប់អានអ្វីមួយរឹង ៗ ក៏ហើយគ្នា កាលរាប់អានជ្រួលខ្លួនទៅហើយ នឹងរាថយក៏ដូចជានឹកខ្មាសមនុស្សលោក ម្ល៉ោះហើយក៏តោងសម្ងំក្ដាប់ទុកក្រអិមហេតុនោះការដល់សរណៈដូច្នេះ ទើបប្រើនតែឥតអំពើ ព្រោះជាសរណៈមិនក្សេម មិនឧត្តមខ្ពង់ខ្ពស់ ជាសរណៈដែលអ្នកប្រាជ្ញរោយរាយបោលដូចដុំក្រួសដូចដុំថ្ម ។

ខដែលមិនត្រិះរិះ នេះឯងជាឱកាសឲ្យសរណៈកើតឡើងក្នុងលោកព្រោងព្រាត សម្រាប់ទទួលសេចក្ដីគោរពនឹងបួងសួងឬជានឹងបំបាត់ទុក្ខសោករោគភ័យវិបត្តិផ្សេង ៗ រហូតដល់ទៅទទួលបាបរបស់បុគ្គលជំពូកនេះ ហើយនឹងប្រសិទ្ធិសិរីសួស្ដីជយមង្គល ឲ្យឬតបាកឧបទ្រពចង្រៃ បង្កើតលាភសក្ការ

សម្បត្តិសម្បូណ៌ហូរហៀរមក  អំបាលនេះជាដើម  តាមឫទ្ធានុភាពនឹងអភិនិហារដែលលោករាប់អាន  ក៏ក្នុងរឿងនេះជាពិតត្រឹមណា  មិនពិតត្រឹមណា  ជាធុរៈរបស់អ្នកទទួលរាប់អានត្រូវត្រិតត្រាឲ្យគួរការជាមុន  សឹមកាន់យកជាសរណៈទីពឹងសម្រេចប្រយោជន៍តាមដែលត្រូវការ មិនគួរនឹងឲ្យត្រូវដំនៀលថាធ្មេចភ្នែកកាន់ ធ្មេចភ្នែករាប់អាន ព្រោះតាំងតែសម័យព្រេងនាយមកដល់ឥឡូវនេះ សរណវត្ថុមានមកហើយដោយលំដាប់ ច្រើនបែបច្រើនប្រភេទ  ហើយអាចទំនាយទុកថា  ទៅខាងមុខនឹងកើតមានសរណៈថ្មីឡើងទៀត គឺថាលោកនេះនៅមានជរាបណាសរណៈក៏នៅមានជរាបនោះ ។



ព្រះទេវរូបសម្រិទ្ធិស្នាដៃខ្មែរសាងបានទៅសៀម ហើយភូមាបានពីសៀមទៅ ១ គទៀត
សព្វថ្ងៃនេះនៅក្នុងវត្តមួយក្នុងក្រុងមណ្ឌលេ ។

# តេមិយជាតក

(ត)

កាលនោះហេតុតែតេជះ សីលនាងចន្ទាទេពីនោះមិញពុំយូរឡើយ កក្រើកអម្តើកទៅដល់អាស្នាសម្តេចឥន្ទ្រាធិរាជ សម្តែងនូវក្តៅក្រហាយនោះក្រៃនឹងនៅពុំបានឡើយ សម្តេចឥន្ទ្រាធិរាជព្រះអង្គពិចារណាថា ហេតុអ្វីក៏មកក្តៅអស់អាស្នាអញដល់ម្ល៉េះ ទើបព្រះអង្គបើកទិព្វចក្ខុពិតពិលរមិលមកដោយនូវយោបល់ព្រះនេត្រទិព្វទាំងមួយពាន់ យល់នាងចន្ទាទេពីនោះហើយបន្ទូលថា មេយោ នាងចន្ទាទេពីនោះឯងកូវនាងធ្វើសច្ចាអធិដ្ឋានប្រាថ្នាសូមឲ្យបានកូនកូវ ក៏ថាបើដូច្នោះអញនឹងទៅបំពេញឲ្យដោយនូវបំណង់នាងហោង ទើបសម្តេចឥន្ទ្រាធិរាជពិចារណាពិតពិលរមិលមើលទេវបុត្រទេវតាផងទាំងឡាយឯណាមានបា-រមីច្រើន សមគួរនឹងជាកូននាង យល់តែពោធិសត្វមហាបុរសរតន៍វិសេសនោះឯងមានបារមីច្រើន សមគួរនឹងជាកូននាងទេពី សម្តេចឥន្ទ្រាធិរាជ នោះហោះឆ្ពោះទៅកាន់ពិមានពោធិសត្វហោង រីពោធិសត្វនោះសោតកាលមុនឡើយព្រះអង្គបានសោយរាជសម្បត្តិស្ថិតនៅពារាណសីនគរនោះ២០ ឆ្នាំ ហេតុតែព្រះអង្គ

ធ្វើអំពើពុំប្រកបដោយនូវធម៌មិញ ព្រះអង្គទៅសោយទុក្ខវេទនា នៅនាឧសុទ្ធនរកនោះ ៨ ម៉ឺនឆ្នាំ ល្ដោះលែងអំពីឧសុទ្ធនរក នោះ បានទៅសោយសម្បត្តិស្ថិតនាពិភពត្រៃត្រឹង្សនោះដោយ កំណត់ព្រះជន្ម នឹងច្យុតអំពីត្រៃត្រឹង្សព្រះអង្គប្រាថ្នាចង់ឲ្យបាន ទៅកើតឰដ៏សួគ៌ទេវលោកឯលើនោះបណ្ដើរ ៗ ទៅ ក៏សម្ដេច ឥន្ទ្រាដល់ហើយ និមន្តពោធិសត្វថា

មារិស តយិ មនុស្សលោកេ ឧប្បន្នេ បារមីយោ ច តេ បុរេស្សន្តិ មហាជនស្ស វុឌ្ឍិ ភវិស្សតិ អយំ ហិ កាសិករញ្ញោ ចន្ទាទេវី នាម អគ្គមហេសី បុត្តំ បត្ថេតិ តស្សា កុច្ឆិយំ ឧប្បជ្ជាហីតិ វត្វា តស្សចេវ អញ្ញេសញ្ច ចវនធម្មានំ បញ្ចសតានំ ទេវបុត្តានំ បដិញ្ញំ គហេត្វា សកដ្ឋានមេវ អគមាសិ ។

បពិត្រអ្នកដ៏មានបុណ្យប្រសើរពើយ និមន្តអម្ចាស់កើតនៅ មនុស្សលោកនាយ ថាបើអម្ចាស់បានទៅកើតនៅនាមនុស្ស លោកនាយហើយ បារមីអម្ចាស់នឹងពេញបរិបូណ៌កាល្មោះឯង

រ័ក្តីបំរើនមហាជនផងទាំងឡាយសោត នឹងកើតមានប្រាកដ ហោង រីអគ្គមហេសីព្រះបាទកាសិករាជ ឈ្មោះនាងបទ្មាទេវី ប្រាថ្នានឹងបង់ឲ្យបានកូន ចូរអម្ចាស់ទៅចាប់ប្រិតិសន្ធិនៅនា ក្នុងផ្ទៃនាងបទ្មាទេវីនោះហោង ។

ពោធិសត្វឮហើយ ទទួលយកព្រះបន្ទូលសម្តេចឥន្ទ្រា-ធិរាជនោះហោង សម្តេចឥន្ទ្រាធិរាជនិមន្តមិនប៉ុន្តែពោធិសត្វនោះ ឡើយ មកនិមន្តទេវបុត្រដទៃផងប្រាំរយ ប្រយោជន៍ដើម្បីនឹង ប្បុតព្រមមួយអន្លើនឹងពោធិសត្វនោះហោង សម្តេចឥន្ទ្រាធិរាជ និមន្តពោធិសត្វ និមន្តអស់ទេវបុត្រផងស្រេចហើយហោះឆ្ពោះ ទៅកាន់ពិមានវិញហោង ។

បញ្ចសតេហិ ទេវបុត្តេហិ សទ្ធឹ បរិត្វា សយំ ពោធិសត្តោ បទ្មាទេវិយា កុច្ឆិម្ហិ បតិសន្ធឹ គណ្ហិ ឥតរេ ទេវបុត្តា អមច្ចភរិយានំ កុច្ឆិម្ហិ បតិសន្ធឹ គណ្ហឹសុ តទា បទ្មាទេវិយា កុច្ឆិម្ហិ វជិរបុណ្ណាវិយ អហោសិ សា គព្ភស្ស បតិដ្ឋិតភាវំ ញត្វា រញ្ញោ អារោចេសិ ។ តំ សុត្វា រាជា

តស្សា បរិហារំ ទាបេសិ សា បរិបុណ្ណគព្ភា ធញ្ញបុញ្ញ-
លក្ខណសម្បន្នំ បុត្តំ វិជាយិ ទិវសមេវ អមច្ចគេហេសុ
បញ្ចកុមារសតានិ វិជាយឹសុ ។

រីអស់ទេវបុត្រផងទាំងឡាយប្រាំរយនោះ ប្បុតព្រមមួយ
អន្លើនឹងពោធិសត្វនោះហោង រីអង្គពោធិសត្វនោះព្រះអង្គទៅ
ចាប់ប្រតិសន្ធិនៅនាក្នុងផ្ទៃនាងចន្ទាទេវី រីអស់ទេវបុត្រផងទាំង
ឡាយនោះ ទៅចាប់ប្រតិសន្ធិនៅនាក្នុងផ្ទៃប្រពន្ធអមាត្យ សព្វ
គ្រប់អស់ទាំងប្រាំរយនោះហោង នាងចន្ទាទេវីនាងទ្រង់គភ៌
ពោធិសត្វនោះបរិបូណ៌បីដូចពជីររតន៍នាងដឹងសភាពគភ៌អាត្មា
កើតមានដូច្នោះហើយទៅទូលមហាក្សត្រាធិរាជ ព្រះអង្គជ្រាប
ហើយព្រះអង្គឡប្រដាប់នូវគ្រឿងបរិក្ខារ រក្សាគភ៌នាងនោះហោង
នាងចន្ទាទេវីនាងទ្រង់គភ៌បានខែដប់គ្រប់បរិបូណ៌ហើយ ប្រ-
សូតព្រះរាជបុត្រចេញមកដ៏ប្រកបនូវធញ្ញបុណ្យលក្ខណាផង
ទាំងពួង នាកាលថ្ងៃនោះឯង អស់ប្រពន្ធអមាត្យផងទាំងឡាយ
សឹងដ៏ប្រសូតកូនដោយផ្ទះអាត្មាទីទៃៗសព្វគ្រប់អស់ទាំងប្រាំរយ
នោះហោង ។

តស្មិំ ខណេ រាជា អមច្ចគណបរិវុតោ មហាតលេ និសិន្នោ អហោសិ អថស្ស បុត្តោ តេ ទេវ ជាតោតិ អារោ-ចយឹសុ, តេសំ វចនំ សុត្វា រាជា រញ្ញោ បឋមំ បុត្តបេមំ ឧប្បជ្ជិត្វា ឆវីយាទិនិ ឆិន្ទិត្វា វិយ អដ្ឋិមិញ្ជំ អាហច្ច អដ្ឋាសិ អព្ភន្តរេបិស្ស បីតិ ឧប្បជ្ជិ, ហទយំ សីតលំ ជាតំ, សោ អមច្ចេ បុច្ឆិ កឹតុម្ហា តុដ្ឋា នុខោ តុម្ហេ មម បុត្តោ ជាតោតិ, តំ សុត្វា អមច្ចា អាហំសុតិ កថេសិ ទេវាតិ មយំ បុព្វេ អនាថា ឥទានិ សនាថា ភវេយ្យាម, សាមិកោ នោ លទ្ធោតិ ។

កាលនោះមហាក្សត្រាធិរាជ ព្រះអង្គគង់នៅនាផ្ទៃរោងធំ ដ៏មានពពួកអមាត្យផងចោមរោមជាបរិវារ កាលនោះសោតមាន រាជអមាត្យមួយចូលទៅទូលថា បពិត្រព្រះសម្មតិទេពមហារាជ ក្សត្រថ្លៃប្រសើរអើយ ឥឡូវនេះសម្ដេចព្រះរាជបុត្រព្រះអង្គមិញ កើតប្រាកដហើយ មហាក្សត្រាធិរាជឮពាក្យរាជអមាត្យនោះ ហើយហេតុតែសភាពព្រះអង្គមានព្រះរាជបុត្រមិញ មានព្រះហ-ឫទ័យត្រេកអរសាទរមោះហំមាក្រៃ ព្រឺព្រួចក្រលួចអស់សាច់ ហឫទ័យពោះផងទាំងសាមសិបសង ហាក់ដូចអ្នកកាត់សាច់

ស្បែកជរាបដល់ឆ្អឹងស្អួងជាបង្អស់ ហេតុតែព្រះអង្គត្រេកអរសាទរក្រៃមិញកើតជាត្រជាក់ក្សេមក្សាន្តក្នុងព្រះរាជហឫទ័យនោះក្រៃពេកបន្ទូលដណ្តឹងទៅអមាត្យផងទាំងឡាយថា អើអ្នកទាំងឡាយ ឥឡូវនេះកូនអញមិញកើតប្រាកដហើយ អញត្រេកអរសាទរមោះហិមាក្រៃ អ្នកទាំងឡាយតើញាំងត្រេកអរសាទរនឹងអញឬទេហ៎ះ អស់រាជអមាត្យឮព្រះបន្ទូលមហាក្សត្រាធិរាជហើយថ្វាយបង្គំប្រណម្យទូលថា បពិត្រសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអើយ ព្រះអង្គបន្ទូលម្តេចដូច្នោះហ៎ះ កាលមុនឡើយយើងខ្ញុំសឹងគិតបារម្ភថា អំណើសនឹងព្រះអង្គហើយឥតបើពំនឹងពំនាក់ឡើយ ឥឡូវនេះកាលបើព្រះអង្គបានព្រះរាជបុត្រយើងខ្ញុំបានជាពំនាក់ជាអម្ចាស់ប្រសើរនៃយើងខ្ញុំឯង មហារាជយើងខ្ញុំសឹងត្រេកអរសាទរនោះមោះហិមាក្រៃពេកហោង ។

រាជា មហាសេនាគុត្តំ បក្កោសាបេត្វា អាណាបេសិ, មម បុត្តស្ស បរិវារំ លទ្ធុំ វដ្ដតិ គច្ឆ ត្វំ អមច្ចគេហេសុ អដ្ឋជាតា ទារកា ឯត្តកា នាមាតិ ឱលោកេហីតិ, តេ គន្ត្វា បញ្ចទារកសតានិ ទិស្វា បុន គន្ត្វា រញ្ញោ អារោចេសុំ,

រាជា តស្ស វចនំ សុត្វា បីតិ ឧប្បជ្ជិ, រាជា បញ្ចទារកសតានំ បសាធនានិ ទាបេត្វា បញ្ចធាតិសតានិ ទាបេសិ ។

កាល្មោះមហាក្សត្រាធិរាជ ឲ្យហៅអង្គសេនាជ៍ជាធំមក បង្គាប់ប្រើថា ម្នាលសេនាជ៍ជាធំ នាកូនអញនេះសមគួរនឹងមាន បរិវារ ក៏ចូរព្រះស្វែងរមិលមើលអស់ផ្ទះអមាត្យផងទាំងឡាយ ថា បើក្មេងឯណាកើតថ្ងៃនេះព្រមល្មមមួយអន្លើនឹងកូនអញ ហើយក៏ក្មេងនោះឯងជាបរិវារសំរាប់កូនអញហោង ក៏ចូរអ្នកទាំង ឡាយត្រារាប់អស់ក្មេងផងទាំងឡាយនោះហោង រាជអមាត្យ ឮព្រះបន្ទូលមហាក្សត្រាធិរាជនោះហើយ ថ្វាយបង្គំប្រណម្យ ទទួលយកព្រះបន្ទូលមហាក្សត្រាធិរាជនោះ ហើយទៅរមិល មើលអស់ផ្ទះប្រពន្ធរាជអមាត្យផងទាំងឡាយ ទៅដល់ផ្ទះមួយ ឃើញក្មេងមួយ ទៅដល់ផ្ទះមួយឃើញក្មេងកើតសព្វគ្រប់អស់ ទាំងប្រាំរយនោះហោង រាជអមាត្យនោះគិតពិចារណាថាអេះ ក្មេងកើតថ្ងៃនេះយល់ច្រើនណាស់ក្តាត់ហា: នូវអញនឹងគណនា រាប់លងមើលហ: រាជអមាត្យគិតពិចារណានូវប្រការអម្បាល្មោះ ហើយ គណនាត្រារាប់អស់ក្មេងផងទាំងឡាយនោះបាន

៥០០ ហើយស្រដីថា អញស្មានជាបន្តិចបន្តួចទេអេះ រឹស័យ ៥០០ជាម្តង រាជអមាត្យខ្លះដំណឹងទៅកាន់គ្នាថា អើអ្នកទាំងឡាយ មហាក្សត្រាធិរាជព្រះអង្គប្រើយើងមករមិលមើលអស់ក្មេងទាំងឡាយ ឥឡូវនេះតើបានគណនាត្រារាប់អស់ក្មេងនោះហើយ ថាអញគណនារាប់ហើយ គណនាតើបានប៉ុន្មាន ថាបាន ៥០០ អើថាបើដូច្នោះហើយមកយើងនឹងទៅទូលព្រះអង្គជាអម្ចាស់យើងឲ្យព្រះអង្គជ្រាបក្នុងព្រះរាជហឫទ័យហោង ទើបរាជអមាត្យនោះត្រឡប់មកទូលមហាក្សត្រាធិរាជដោយនូវដំណើរហេតុនោះហោង មហាក្សត្រាធិរាជឮពាក្យរាជអមាត្យនោះហើយមានព្រះរាជហឫទ័យនោះត្រេកអរសោទរបន្ទូលថា អើអស់ក្មេងទាំងអម្បាលនេះឯង សឹងជាបរិវារសំរាប់កូនអញនេះឯង ទើបព្រះអង្គឲ្យរកមេនំមកបានប្រិរយ ឲ្យទៅបំបៅមើលពិភ័ក្តិរក្សាអស់ក្មេងទាំងប្រិរយនោះឯង ។



លោកសង្ឃភូមានៅវត្តមួយក្នុងក្រុងមណ្ឌលេ កំពុងមើលគម្ពីរស្ទឹករិត ។

## សាសនីភាគ ពាក្យកាព្យ

### ពាក្យកាព្យរបស់ឃុនស្នេហាហ៊ឹមរៀបរៀង

អហំអញខ្ញុំ ឯងារគោរម្យ គឺឃុនស្នេហា នាមដើម ឈ្មោះហ៊ឹម មាតាបិតា លោកសន្មតថា ជានាមឧត្តម ។ ឲ្យ ឈ្មោះនេះខ្ញុំ សាន្តសុខភិរម្យ ជាឈ្មោះគួរសម បំណែកឯងារ នោះព្រះបរម ស៊ីសុវត្ថិឧត្តម ព្រះចៅឥស្សរា ។ លោកតាំង ទុកឲ្យ ទៅជាខាងក្រោយ ឲ្យហៅស្នេហា មានទាំងមេដៃ មាសរបនា ព្រោះធ្វើរាជការ ឆ្លងព្រះបារមី ។ ខ្ញុំសូមបង្គំ រតនឧត្តម គឺកែវទាំងបី ប្រសើរលើសលប់ ផុតទាំងភពត្រៃ សូមឈ្នះសេចក្ដី ឧបទ្រពចង្រៃ ។ ខ្ញុំសូមលើកជា ពាក្យ៤ ពណ៌នា ល្បើកល្បិចកែខៃ សំរាប់ជនក្រោយ ទុកជាបច្ច័យ គ្រាន់ជានិស្ស័យ ដាស់តឿនបញ្ញា ។ កើតមកជាមនុស្ស ទោះស្ត្រីទោះប្រុស តែងតែត្រូវការ យកច្បាប់ដាក់ខ្លួន ជា លក្ខណា អមតាំអាត្មា រក្សាតទៅ ។ ច្បាប់មិនគឺអ្វី គឺសីល៥ក្ដី កម្មបថនោះក្លូវ ជាធម៌របស់មនុស្ស ឲ្យមនុស្សតាំងនៅ ជា ហេតុនាំផ្លូវ ទៅកាន់ទីសុខ ។ បើមនុស្សឯណា មិនបាន

រក្សា យកធម៌នេះទុក មិនមែនជាមនុស្ស ស្រីប្រុសពេញមុខ លោកតែងដាក់ទុក ហាត់រក្សាបាន ។ អ្នកឯណាមានធម៌ ពេញជាមនុស្សល្អ ទើបបរិបូណ៌បាន មិនតែជាតិនេះ ជាតិមុខក៏មាន ឲ្យឈ្មោះថាបាន តាំងនៅជាមនុស្ស ។ ឯធម៌ទីមួយ មិនធ្វើក្តីព្រួយ ឲ្យសត្វធ្លាក់បុះ ឃ្លាតបង់ចាកទីជីវិតដែលរស់ គឺយកចំពោះ ត្រង់មានចេតនា ។ ធម៌ទី ២ ទៀត មិនឲ្យលាក់លៀត លួចយកទ្រព្យ ដែលគេហួងហែង ថែទាំរក្សា ដោយចេតនា ជាការទុច្ចរិត ។ ធម៌ទី ៣ នោះ សំដៅចំពោះ ត្រង់ការប្រព្រឹត្ត ក្នុងកាមទាំងឡាយ យកស្ត្រីជាមិត្រ ដោយរាគចិត្ត ដំរេកតណ្ហា ឯធម៌ទី ៤ ពោលពាក្យសំនួន ហៅថាមុសា ជាពាក្យមិនពិត គិតខុសមាត្រា ភូតភរោហារ ការខុសទំនង ។ ធម៌ទី ៥ នោះ សំដៅចំពោះ សេពសុរាហោង ជាគ្រឿងស្រវឹង នឹងមេរ័យផង ធ្វើឲ្យសៅហ្មង ភ្លាត់ភ្លាំងស្មារតី ។ ធម៌មនុស្សជាន់ទាប ជាធម៌សភាព ប្រព្រឹត្តប្រក្រតី មិនមានកាលឈប់ ដូចសីលប្រាម្បី ប្ចូរបុរសស្ត្រី លះវៀរ

ជានិច្ច ។ ធម៌ជាន់ទី ២ ខ្ពង់ខ្ពស់សោភី រក្សាកុំភ្លេច លោកហៅកម្មបថ វិន័យសម្រេច សម្រាំងទុកស្រេច មាន ១០ ប្រការ ។ ឲ្យគ្រហស្ថប្រតិបត្តិ ដើម្បីកំចាត់ កាយ នឹងវាចា លោកហៅវិន័យ ជាទីរក្សា មារយាទតិរិយា បុរសប្រុសស្ត្រី ។ បំណែកឯកាយ ចេញជាបរិយាយ បែកទៅជាត្រៃ ហៅកាយកម្ម កាយទ្វារនោះនៃ ព្រោះធ្វើ ប្រាស័យ ដៃជាប្រធាន ។ គឺធ្វើបាណា ផ្តាច់បង់ជីវា លុះបាត់-វិញ្ញាណ នឹងលួចយកទ្រព្យ ឈ្មោះអទិន្នាទាន នឹងកាមេមាន ស្ត្រីគេរក្សា ។ បទ ៣ ចូរចាំ ហៅកាយកម្ម ចាំឲ្យច្បាស់ណា ក្រសែព្ធកកាយ មិនឆ្ងាយពីខ្លួន មិនខុសពីក្បួន គឺខ្លួនគេឯង ។ វីឯវចីកម្ម យើងបានបងចាំ បណ្ឌិតសម្តែង ថាមានប្រភេទ នោះ ៤ កន្លែង ចេញទៅឃើញស្តែង ធ្វើដោយវាចា ។ មួយមុសាវាទ គឺពោលនូវពាក្យ កុហកពុំជា ជាពាក្យមិនពិត គិតពោលមាយា យកមកតណាំគ្នា ប្រាប់ គេថាពិត ។ ២ បេសុញ្ញវាទ និយាយឲ្យឃ្លាត ទៅតាមគំនិត ជាពាក្យញុះញង់ ឲ្យគេបែកមិត្រ ឲ្យគេចូលចិត្ត នឹងខ្លួន

ឯងវិញ ។ ជាមនុស្សខូចមាត់ ពោលពាក្យឥតបទ ឲ្យគេទោម្នេញ កើតជាទោមនស្ស ពាក្យមិនបំណោញ កុំផ្លូញកុំបេញ វាចានេះឯង ។ ទី ៣ នោះណា ផរុសវាចា ពោលឥតកោតក្រែង វាចាទ្រគោះ ឈ្លោះជេរគេឯង ប្រើនទាស់ប្រើនទែង មិនក្រែងនរណា ។ ឯមនុស្សយ៉ាងហ្នឹង ប្រើនតែគេខឹង គេប្តឹងវាផការ មិនដែលបានសុខ ព្រោះតែវាចា ពោលដល់អ្នកណា ជាពាក្យគ្រោតគ្រាត ។ រឺឯទី ៤ ពាក្យមិនសំនួន សម្ផប្បលាវាទ ពោលមិនប្រយោជន៍ ឲ្យខូចដល់ញាតិ ឲ្យខូចដល់ជាតិ អ្នកស្តាប់ទាំងឡាយ ។ ជាពាក្យកំប្លែង ជាពាក្យសើចលេង ពីល្បែងជិតឆ្ងាយ នាំគេស្រដី ពីស្ត្រីសហាយ សើចលេងក្អាកក្អាយ ពាក្យមិនប្រយោជន៍ ។ បើអ្នកឯណា លះវៀរវាចា ដែលជាអាសោច៌ វចីទុច្ចរិត ពោលស្អុយដូចខ្មោច ពោលឥតប្រយោជន៍ បង្ខូចខ្លួនឯង ។ មួយឈ្មោះមនោកម្ម យើងបានបងចាំ អាចារ្យសម្តែង គឺធ្វើដោយចិត្ត ពិត ៗ ជាក់ស្តែង មាន ៣ កន្លែង ហៅមនោកម្មហោង ។ មួយឈ្មោះអភិជ្ឈា បង្អោនទ្រព្យ របស់អ្នកផង ដែលគេហ្លួងហែង មានចិត្ត

គួបបង មានចិត្តបំណង មកដើម្បីខ្លួន ។ ២ គឺព្យាបាទ ចិត្តនោះសង្ខាត តាំងនៅមាំមួន ឲ្យគេវិនាស ដោយគំនិតខ្លួន បេះតែគុំគួន សម្ងំក្នុងចិត្ត ។ ៣ ឈ្មោះមិច្ឆា ទិដ្ឋិសោតណា នៅក្នុងគំនិត ច្បាប់ព្រះមិនយក ស្រេចតែនូវចិត្ត ខុសត្រូវមិនគិត ប្រព្រឹត្តតែឯង ។ គឺក្រៅសាសនៈ ដែលសម្ពន្ធៈ លោកទ្រង់សម្ដែង មិនជឿបាបបុណ្យ គុណទោសនោះឯង ហើយថែមពោលក្លែង ថាកម្មគ្មានផល ។ រីឯមិច្ឆា ទិដ្ឋិសោតណា តាមដោយសំគាល់ តាមដោយបរិយាយ ឧបាយយោបល់ គួរមិនឲ្យធ្វល់ មិនឆ្ងាយឡើយណា ។ បើអ្នកនោះឯង ពោលពាក្យដោយក្លែង មានបែងវិភា ពីព្រះនិព្វាន ដូចពាក្យអ្នកថា បំពោះត្រង់ការ សេពគ្នានោះក្ដី ។ រីមួយពោលថា បំណែកធម៌អាថ៌ នោះមិនគឺអ្វី នៅត្រង់កេរត៌ខ្មាស របស់សត្រី ពោលយកសេចក្ដី នេះជាប្រធាន ។ ទុកជាជាប់ពង្ស ទុកជាចូលវង្ស មិច្ឆាទិដ្ឋិបាន មិនបាច់ពោលច្រើន ឲ្យវែងប៉ុន្មាន ប៉ុណ្ណឹងក៏បាន ហៅថាជាក់ស្ដែង ។ បើអ្នកឯណា នឹងបង់ប្រាជ្ញា ធ្វើខ្លួនឲ្យខ្វែង គោងយកចិត្តខំ សន្សំប្រឹងប្រែង តាមច្បាប់នេះ

ឯង បានសុខមិនខាន ។ ព្រោះធម៌ឲ្យផល ឲ្យឃើញឲ្យយល់ ក្នុងបច្ចុប្បន្នបាន មិនបាច់ទៅមុខ ទើបឲ្យសុខសាន្ត ជាតិនេះ ក៏មាន ឲ្យផលខ្លះផង ។ គឺមិនត្រូវទោស ត្រូវបោទកំហុស ប្រវ៉ាក់ណែងណង បំណែកទៅមុខ ឲ្យសុខទៀតហោង សុខ ក្រៃកន្លង សុខលើសជាតិនេះ ។ បើអ្នកឯណា មិនខំឧស្សាហ៍ កាន់ធម៌វិសេស ប្រមាទមើលងាយ រូបធ្វេសប្រហែស តែក្នុង ជាតិនេះ ក៏រកសុខគ្មាន ។ យើងបានឃើញជាក់ បានឃើញ ច្រើននាក់ មនុស្សកោងមនុស្សលោន មនុស្សដែលធ្វើខុស ជាប់ទោសក៏មាន ព្រោះតែបំពាន បំពាខុសច្បាប់ ។ អ្នកណា មានចិត្ត ប្រព្រឹត្តទុច្ចរិត ខុសពីសណ្ដាប់ មិនតាមសេចក្ដី បណ្ឌិតលោកប្រាប់ ប្រាសប្រែក្រឡាប់ កន្លងបោលទៅ ។ អ្នកនោះហៅថា ជាមនុស្សកំព្រា គ្មានញាតិគ្មានផៅ គ្មានទីរំពឹង គ្មានកូនគ្មានចៅ ហើយលោកថែមហៅ មិនស្រឡាញ់ខ្លួន ។

(មានតទៅទៀត)

# រឿងធ្មេញជែបណ្ឌិត

(៣)

ស្ដេចស្ដាប់ក៏ទ្រង់ព្រះសម្រួលហើយក៏មានព្រះបន្ទូលថា អាជៃឯងនៅគាល់បម្រើអញសព្វ ៗ ថ្ងៃកុំឲ្យខាន ឯធ្មេញជៃទទួលព្រះបន្ទូលហើយក៏នៅស្ងៀម ហើយគាល់បម្រើគ្មានខានដល់មួយថ្ងៃ ។

មានកាលមួយថ្ងៃស្ដេចគិតក្នុងព្រះរាជហឫទ័យថា អញនឹងចង់ល្បងប្រាជ្ញាអាជៃចង់ដឹងមើល លុះដល់ព្រឹកឡើងហើយស្ដេចយាងទៅកំពង់ទឹកហើយឲ្យហៅអស់នាម៉ឺនធំតូចមកហើយស្ដេចឃុំបមិនឲ្យធ្មេញជៃដឹងការអ្វី ៗ ឡើយ ហើយថាឲ្យអស់នាម៉ឺនធំតូចប៉ុន្មានៗ ឲ្យរកពងមាន់១ម្នាក់ឲ្យកាន់ក្ដាប់បុះទៅក្នុងទឹកមុជទៅងើបឡើងឲ្យថា តុក្កតតពង ១ ថ្វាយស្ដេច ឯធ្មេញជៃកុំឲ្យដឹងឡើយ ឯអស់នាម៉ឺនរកពងមាន់បាន ១ ម្នាក់ហើយបុះទឹកមុជទៅងើបឡើងថាតុក្កតតពង ១ ថ្វាយហើយ ម្នាក់មុជទៅទៀតហើយងើបឡើងថាដូចគ្នាហើយថ្វាយពងមាន់នោះគ្រប់គ្នាហើយនៅតែធ្មេញជៃក្រោយគេមិនបានដឹងខ្លួនជាស្ដេចឲ្យបុះទឹកកាន់ពងមាន់ទៅដូច្នោះឡើយ ហើយស្ដេចឲ្យហៅមកថាអាជៃអាឯងបុះទឹកទៅមុជទៅងើបឡើងនឹងអាលថ្វាយពងមាន់

ឲ្យដូចគេ ឯធ្មេញដៃនឹងរកពងមាន់គ្មានហើយក៏មុជទឹកទៅដើម ឡើងថា កឹកគិគលគក ឯស្តេចមានបន្ទូលសួរថា ឯណាអាដៃ ពងមាន់ ទើបធ្មេញដៃថា ដ្បិតទូលបង្គំនេះជាមាន់ឈ្មោល ជាន់មាន់ញីទាំងអស់នេះឯងបានជាមានពង បើកុំទូលបង្គំជា ឈ្មោលហើយជាន់មាន់ញីទាំងនេះ គ្មានពងទេក្រាបទូលសូម ទ្រង់ជ្រាប ស្តេចស្តាប់ហើយក៏កោតប្រាជ្ញាធ្មេញដៃហើយមាន ព្រះបន្ទូលសួរថា អាដៃអាយុអាឯងបានប៉ុន្មានឆ្នាំហើយ ធ្មេញ ដៃក្រាបទូលថា អាយុទូលបង្គំជាខ្ញុំបាន១១ឆ្នាំ ។

ស្តេចស្តាប់ហើយ មានព្រះបន្ទូលប្រាប់អស់នាម៉ឺនឲ្យ បានដឹង ដ្បិតស្តេចនឹងយាងទៅប្រពាតព្រៃឲ្យអស់នាម៉ឺនរៀប ខ្លួនចាំកំណត់ដប់ថ្ងៃទៀតទើបស្តេចយាងទៅ ឯអស់នាម៉ឺនបាន ស្តាប់ព្រះបន្ទូលប្រាប់ដូច្នោះហើយ ក៏រៀបខ្លួនគ្រប់នាម៉ឺនមុខងារ ដោយខ្លួន លុះដល់ថ្ងៃស្តេចចេញទៅហើយ ហៅធ្មេញដៃមក មានព្រះបន្ទូលបង្គាប់ថា អាដៃឯងអញឲ្យជិះដំរីដែលដាក់ក្រយ៉ា សោយទៅឲ្យបានទាន់អញ បើមិនទាន់អញឯងនឹងមានសេចក្តី ខុសមិនលែងឡើយ ឯដំរីនោះស្តេចឲ្យយកដំរីចាស់នឹងដើរមិនរួច

ហើយឲ្យធ្មេញដៃជិះបរទៅ ឯធ្មេញដៃក៏ឡើងជិះបរទៅក៏វាដើរមិនទាន់គេឡើយ ធ្មេញដៃក៏ធ្វើក្ដោងហើយយកឃ្នោលដោលលើខ្នងជំរីនោះឯង ។ ព្រះមហាក្សត្រស្ដេចដល់ទៅព្រះពន្លាហើយឲ្យរកធ្មេញដៃក៏បាត់ហើយត្រាស់ថា អាដៃនេះខុសហើយមិនខានទេ លុះដល់យូរបានបីម៉ោងទើបធ្មេញដៃមកដល់ ព្រះមហាក្សត្រស្ដេចឲ្យហៅធ្មេញដៃមកសួរថា អាដៃឯងបរជំរីដូចម្ដេចក៏មិនទាន់អញ អាឯងខុសហើយដ្បិតអញបានប្រាប់ថាឲ្យមកឲ្យទាន់កុំខាន ឯធ្មេញដៃស្ដាប់ព្រះបន្ទូលហើយក៏ក្រាបទូលថាដ្បិតជំរីវាមិនដើរ ទូលព្រះបង្គំជាខ្ញុំធ្វើក្ដោងបើកហើយធ្វើឃ្នោលដោលផង ទូលព្រះបង្គំជាខ្ញុំនឹងបានប្រហែសក៏ទេ សូមទ្រង់ជ្រាប ស្ដេចស្ដាប់ហើយក៏ស្ងៀមនៅពុំមានព្រះបន្ទូលដូចម្ដេចក៏ទេ ហើយស្ដេចក្រសាលសប្បាយទៅ លុះដល់ថ្ងៃរសៀលស្ដេចវិលមកវិញហើយចូលផ្ទំ ។

ហើយស្ដេចគិតក្នុងព្រះរាជហឫទ័យថា អាដៃនេះមានប្រាជ្ញាណាស់នឹងធ្វើដូចម្ដេចនឹងគិតធ្វើឲ្យទាល់ប្រាជ្ញាវានោះ បើដូច្នោះមានតែអញនឹងដេញប្រាជ្ញាវាទៀត ស្ដេចទ្រង់ព្រះរាជហឫទ័យ

ដូច្នោះហើយឲ្យអស់នាម៉ឺនមុខមន្ត្រីនូវអស់មហាឡើកឃុនម៉ឺនសួរ នាម៉ឺនធកងារក្នុងងារដែលនៅក្នុងព្រះនគរ ឲ្យមកជួបជុំនឹងទ្រង់ បង្គាប់ឲ្យហែស្តេចចេញទៅលេងព្រៃក្នុងថ្ងៃស្អែកនេះឯង តែឲ្យជិះសេះហែឲ្យគ្រប់គ្នា តែអ្នកណាគ្មានសេះជិះនឹងបានសេចក្តីខុសមិនលែងឡើយ ឯធ្មេញដែកុំឲ្យវាដឹងសេចក្តីនេះឡើយ បើព្រឹកឡើងនឹងចេញទៅហើយសឹមប្រាប់អាដែហ៊ាឲ្យរកសេះជិះទៅ លុះដល់ព្រឹកឡើងហើយស្តេចចេញទៅ ឯអស់នាម៉ឺនឡើងជិះសេះហែស្តេច ឯព្រះមហាក្សត្រស្តេចឲ្យហៅធ្មេញដែមកហើយទ្រង់បង្គាប់ថា អាដែឯងមកហែអញទៅហើយឲ្យរកសេះជិះទៅ ដើរទៅជើងទទេអញនឹងយកទោសអាឯងខុស ឯធ្មេញដែស្តាប់ហើយទទួលព្រះបន្ទូលរត់ទៅរកសេះគគ្មានឥតនរណានឹងឲ្យ ព្រះមហាក្សត្រប្រាប់ធ្មេញដែហើយស្តេចយាងទៅ ឯធ្មេញដែកាលរកសេះមិនបានហើយទៅយកសេះកូនបត្រង្គក្តាប់នឹងដៃហើយដើរទៅហែរស្តេច ។ ព្រះមហាក្សត្រស្តេចទៅដល់ព្រះពន្លាដាក់ហើយរកធ្មេញដែមិនឃើញ ធ្មេញដែដើរអំពីចម្ងាយ លុះដល់ល្មមស្តេចទតមកឃើញក៏ប្រឹងរត់ទៅដល់

ហើយក្រាបថ្វាយបង្គំ ព្រះមហាក្សត្រមានព្រះបន្ទូលសួរថា អាធ្មេញជ័អញឲ្យអាឯងជិះសេះមកឥឡូវនេះក៏មិនជិះសេះមក ។ ធ្មេញជ័ក្រាបទូលថា សេះទេនេះដែលខ្ញុំជិះហែមា្ចស់ ស្តេចស្តាប់ហើយក៏ស្ងៀមនៅមិនមានព្រះបន្ទូលថាអ្វីៗទៀយ ហើយស្តេចក៏វិលមកក្នុងព្រះរាជវាំងវិញ ។

លុះដល់ព្រឹកឡើងស្តេចត្រាស់ឲ្យហៅធ្មេញជ័មកដល់ហើយមានព្រះបន្ទូលបង្គាប់ថា អាជ័ឯងទៅបោសក្រោមដំណាក់កុំឲ្យមានសម្រាមនៅក្រោមដំណាក់សព្វៗថ្ងៃទៅ បើអាឯងខានតឹងបានសេចក្តីខុសមិនលែងឡើយ ឯធ្មេញជ័ស្តាប់ព្រះបន្ទូលហើយក៏រៀបខ្លួនចូលទៅបោសក្រោមដំណាក់អស់អ្នកម្នាងនោះ ហើយអស់ទាំងស្ត្រីបម្រើរាជើរទន្ត្រំលើក្បាលធ្មេញជ័តែសព្វៗថ្ងៃ ឯធ្មេញជ័គិតថាអស់ទាំងស្ត្រីនេះរាជើរលើក្បាលអញ បើដូច្នោះអញនឹងគិតធ្វើកុំឲ្យស្តេចប្រើមកបោសក្រោមដំណាក់នេះទៀតបានឡើយ គិតស្រេចហើយធ្មេញជ័ក៏ជេរថា មេជកទងបោរទាំងអស់នេះរាបានស៊ីក៏តែពីត្រពោករា មិនបានស៊ីក៏តែពីត្រពោករា ស្រែកជេរឮខ្លាំង ឮដល់ទៅអស់

អ្នកម្នាងនៅលើដំណាក់នោះ នឹកខឹងនឹងធ្មេញដៃហើយបបួលគ្នាឡើងទៅក្រាបទូលថា សូមទានក្រាបទូលសូមទ្រង់ជ្រាបព្រះរាជហឫទ័យ ដ្បិតត្រាស់ប្រើអាដៃឲ្យវាទៅបោសក្រោមដំណាក់ ឥឡូវនេះវាជេរបញ្ចោរអស់យើងខ្ញុំជាទម្ងន់មុខគួរឲ្យខ្មាសអស់មនុស្សផងទាំងពួង នឹងធ្វើជាព្រះម្នាងស្តេចមិនបានសូមជ្រាប ឯព្រះមហាក្សត្រមានព្រះបន្ទូលសួរថា វាជេរដូចម្តេច ទើបអ្នកម្នាងទូលថា ជេរថាមេដកទងបោរទាំងអស់នេះ វាបានស៊ីតែពីត្រពោកវាមិនបានក៏តែពីត្រពោកវា ស្តេចស្តាប់ហើយក៏ទ្រង់ព្រះក្រោធ ត្រាស់ឲ្យហៅធ្មេញដៃមកហើយ មានបន្ទូលសួរថា អាដៃឯងអញប្រើឲ្យអាឯងទៅបោសក្រោមដំណាក់ដូចម្តេចក៏បានជាអាដៃឯងជេរបញ្ចោរអស់ប្រពន្ធអញមែនឬទេ។

ទើបធ្មេញដៃក្រាបទូលថា ខ្ញុំទូលបង្គំពុំបានជេរបញ្ចោរអស់អ្នកជាម្ចាស់ក៏ទេ ។

ប៉ុន្តែកាលទូលបង្គំចូលទៅបោសក្រោមដំណាក់នោះមានពីងពាងវាត់ទូក្រោមដំណាក់នោះច្រើន ដល់ទូលព្រះបង្គំជាខ្ញុំ

ចូលទៅវាជាប់ក្បាលទូលព្រះបង្គំជាខ្ញុំបានជាជេរថា មេហោរដក ទងហោរ វាបានស៊ីក៏តែពីត្រពោក វាមិនបានស៊ីក៏តែពីត្រពោក វា ខ្ញុំទូលបង្គំនឹងបានជេរអស់អ្នកម្នាងជាម្ចាស់ក៏ទេ សូមទ្រង់ជ្រាប ឯព្រះមហាក្សត្រស្តាប់ហើយក៏មានព្រះបន្ទូលនឹងអស់អ្នកម្នាងថា អស់ឯងកុំខឹងនឹងវា ៗ នឹងបានជេរឯងក៏ទេវាជេរពីងពាងទេ ទើបអស់អ្នកក្រាបទូលថា អំពីថ្ងៃនេះទៅម្ចាស់កុំឲ្យអាជៃវាទៅបោសក្រោមដំណាក់នោះទៀតឡើយ ព្រះមហាក្សត្រក៏ហាមធ្មេញជៃមិនឲ្យទៅបោសក្រោមដំណាក់នោះទៀតឡើយអំពីថ្ងៃនោះឯង ។

ឯធ្មេញជៃក៏ខានពុំបានចូលក្រោមដំណាក់នោះអំពីថ្ងៃនោះឯង ។

# បញ្ជីរឿង


ទំព័រ

១ — បរិវត្តគមនាគម ដំណើរអង្គរលោកក្នុងដែនកូសាំងស៊ីន ខេត្តសុកត្រាំង ព្រះសាសនសោភ័ណ ជ. ណាត រៀបរៀង (ត) . . . . . . . . . ១៥៣

២ — សម័យចំរើនរបស់ក្បាច់រចនាខ្មែរ លោក ហ.មាហ្សាលរៀបរៀង ក្រម្ការ ដុំ-ម៉ៅ ប្រែជាភាសាខ្មែរ . . . . . . . . . . . . . . . . . . ១៦៩

៣ — ខេមរាខេមរសរណកថា ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត រៀបរៀង (ត) . . . . . . . . . . . . . . . . . . . . . . . . . ១៧៣

៤ — សាសនីភាព ពាក្យកាព្យយុនស្នេហា ហ៊ឹម តែង (ត) . . . . . . . ១៨៥

៥ — រឿងធ្មេញដៃបណ្ឌិត សេចក្ដីចាស់ (ត) . . . . . . . . . . . . . ១៩៥


## រូបក្រៅរឿងផ្សេង ៗ


១ — យាយជី ភូមា រក្សាសីល ១០ ស្លៀកឥណ្ឌាប់លឿងអាស្រ័យនៅក្នុងវត្ត. . . ១៦៧

២ — លោកសង្ឃភូមាកាន់ផ្ចិតស្លឹកត្នោត ទំនៀមលោកសង្ឃភូមា សុទ្ធតែប្រើផ្ចិតស្លឹកត្នោតរូបធំ ១ ដូច្នេះ . . . . . . . . . . . . . . . . . . . . ១៨៣

# TABLE DES MATIÈRES

Pages.

I. Tournée en Cochinchine de M. le secrétaire général de l'Institut Bouddhique (Soctrang et Cantho)................ 153

II. Les grandes époques de l'art Khmer par H. Marchal — Traduit du Français en Cambodgien par Kromokar Chum-Mau. 169

III. Khemā Khema Saranakatha ou Religions, refuge des hommes par Préas Maha Pitou Krasem à la Bibliothèque Royale (à suivre)................................ 173

IV. Sāsanivāda Poème ou Bons conseils aux hommes d'après la Morale Bouddhique par Khhunsnehā Him. (à suivre).... 185

V. Conte populaire cambodgien inédit Histoire de Thmenh-Chhey (à suivre)................................ 195

## HORS TEXTE:

I. La Supérieure d'un couvent de bonzesses — Mandalay (Birmanie)................................ 167

II. Bonze birman avec son écran pour prière en feuille de palmier — Monastère de Taiktaw — Mandalay.......... 138

# បរិវដ្តគមនាគម

# ដំណើរអង់គ្លេសលោស្រុកកូសាំងស៊ីន

# (គ)

## ខេត្តសុកត្រាំង

ថ្ងៃអាទិត្យ ១០ ដេសម ១៩៣៣ (៨ កេចមិគសិរ)

ម៉ោង ១១ កន្លះ យើងចេញពីទីរួមខេត្តបាក់លីវត្រឡប់ឆ្ពោះមកឯខេត្តសុកត្រាំងវិញ ម៉ោង ១៤ ដល់ទីរួមខេត្តសុក-ត្រាំង ។

ម៉ោង ១៤ ប្រជុំនៅវត្តឃ្លាំង (យួនហៅថ្លូញ៉មឡាង) ឃុំញ៉មឡាង (នៅក្នុងទីរួមខេត្តសុកត្រាំង) ។ មានមន្ត្រីបារាំងម្នាក់ឈ្មោះ ត្រែអាឡង់ ជាអ៊ីងស្ប៉ិកទ័រក្រសួងសិក្សាធិការក្នុងខេត្តសុកត្រាំង បានប្រមូលពួកគ្រូបង្រៀនជាតិខ្មែរបព្វជិតនឹងគ្រហស្ថទាំងអស់ ព្រមទាំងប្រមូលពួកកុមារជាតិខ្មែរសិស្សសាលានៅទីរួមខេត្តសុកត្រាំងឲ្យមកជួបជុំព្រមក្នុងទីប្រជុំនេះ ខ្លួនលោកអ៊ីងស្ប៉ិកទ័រក៏អញ្ជើញមកដែរ អស់លោកមន្ត្រីជាតិខ្មែរមានលោកចៅហ្វាយខេត្ត ចៅហ្វាយខណ្ឌជាដើមក៏អញ្ជើញមកក្នុងទីប្រជុំនេះ ។ ចំណែកខាងពួកបព្វជិតថេរានុថេរព្រមទាំងភិក្ខុសាមណេរច្រើនវត្តមកប្រជុំក្នុងទីនេះប្រហែលជាង ១០០ រូប រួមទាំងបព្វជិតទាំងគ្រហស្ថប្រហែលជាង ១៤០ នាក់ ។

លុះចប់សេចក្ដីពន្យល់ហើយ លោកអគ្គលេខាធិការបានឲ្យសៀវភៅដែលមានប្រយោជន៍ដល់សាលារៀន ទុកសម្រាប់សាលារៀនវត្តឃ្លាំងនេះខ្លះ ។ គ្រូបង្រៀនសាលាវត្តនេះជាបព្វជិតឈ្មោះ ឋាប់-ឌីន មានសញ្ញាបត្រសាលាវត្តលង្កាពីក្នុងឆ្នាំ ១៩២៩ សព្វថ្ងៃមានផ្ទៀតទៅជួយបង្រៀនបាលីពួកកុមារជាតិខ្មែរសិស្សសាលាសិក្សាធិការ ប៉ែកខាងបារាំងនៅទីរួមខេត្តសុកត្រាំងម្ដងៗផង ព្រោះលោកអ៊ំងស្ប៉ិកទ័រត្រូវអាឡង់ដម្រូវការនោះមក ។ លុះស្រេចការប្រជុំហើយ យើងឈប់សំណាក់នៅវត្តឃ្លាំងនេះ លោកអគ្គលេខាធិការឈប់សំណាក់ឯភោជនាគារ ។

ថ្ងៃចន្ទ ១១ ធ្នូ ១៩៣៣ (៩ រោចមិគសិរ)

ម៉ោង ៨ (ព្រឹក) ចេញទៅវត្តអណ្ដូងទឹក (ហៅថាវត្តទឹកប្រៃក៏បាន) ក្នុងឃុំឡុងភូខណ្ឌឧិញមិ ម៉ោង៩កន្លះដល់វត្តនេះៗ មានសាលារៀន គ្រូបង្រៀនជាបព្វជិតឈ្មោះ ឋាប់-ជី មានសញ្ញាបត្រសាលាវត្តលង្កាពីក្នុងឆ្នាំ ១៩៣០ មានសិស្សសាលា ២៧នាក់ ។ លោកអគ្គលេខាធិការបានសួរថា កាលដែល

ខ្ញុំមកពីឆ្នាំមុនឃើញមានសិស្សសាលាច្រើន តែឡូវហេតុម្ដេចក៏មានសិស្សតិចម្ល៉េះ ឆ្លើយជំរាបមកវិញថា កាលពីក្នុងឆ្នាំមុនមានសិស្សសាលាដល់៧០នាក់ តែឡូវបានជាតិចយ៉ាងនេះ ព្រោះមានលោកគ្រូសូត្រ ១រូបក្នុងវត្តនេះបេះតែជំទាស់ឃាត់ខាំងមិនឲ្យពួកកុមារចូលរៀនក្នុងសាលា ។ លោកគ្រូចៅអធិការវត្តនេះត្អូញថាអាត្មាស្រឡាញ់ការរៀនសូត្រណាស់ ប៉ុន្តែស្ដីជាស់តឿនរំឭកគេមិនស្ដាប់ ក៏ទាល់គំនិតមិនដឹងបើនឹងគិតធ្វើម្ដេច ។ ក្នុងទីប្រជុំនេះមានពួកបព្វជិតវត្តក្រៅ៤វត្តមកជួបជុំ មានមនុស្សមកប្រជុំប្រហែលជាង១០០នាក់ ។ យើងបានធ្វើការរួបសព្វគ្រប់ហើយ ត្រឡប់មកទីរួមខេត្តវិញ បានចូលទៅឯសាលាសិក្សាបារាំង ដោយលោកអ៉ីងស្ប៉ិកទ័រត្រៃអាឡង់បានសន្យាពីថ្ងៃម្សិលថាសុំឲ្យចូលមើលសាលារៀនរបស់លោកបាន ១រំពេច ។ ខ្ញុំបានធ្វើប្រស្នាបាលីធៀបនឹងភាសាបារាំងពន្យល់ពួកកុមារក្នុងថ្នាក់ដែលមានឆ្លៀតរៀនបាលីផងនោះ ហើយត្រឡប់មកធ្វើភត្តកិច្ចឯវត្តឃ្លាំងវិញ ។

ម៉ោង ១៥ ចេញទៅវត្តផ្អោរកា ក្នុងឃុំភ្នំណោ ខណ្ឌឱញ្ញាខាញ់ ម៉ោង ១៥ កន្លះដល់វត្តនេះ ។ មានពួកបព្វជិតវត្តឯទៀត ៣ វត្តមកប្រជុំក្នុងទីនេះ មានមនុស្សរួមទាំងអស់ប្រ-ហែលជាង ៣០០ នាក់ ។ គ្រូបង្រៀនសាលាវត្តនេះជាបព្វជិតឈ្មោះ ឋាប់ បន្ទ មានសញ្ញាបត្រសាលាវត្តលង្កាក្នុងឆ្នាំ ១៩២៩ មានសិស្សសាលាចំនួន ៣១ នាក់ ។ យើងបានធ្វើការរួបសព្វគ្រប់ហើយ ត្រឡប់មកទីរួមខេត្តវិញ (សំណាក់នៅវត្តឃ្លាំង) ។

ថ្ងៃអង្គារ ១២ ដេសម ១៩៦៣ (មិគសិរ)

ម៉ោង ៨ (ព្រឹក) ចេញទៅវត្តពោធិថ្លឹង ឃុំកេអាង ខណ្ឌបិញខាញ់ ម៉ោង ៩ ដល់វត្តនេះ ។ ក្នុងទីប្រជុំនេះ មានពួកបព្វជិតវត្តក្រៅ ៥ វត្តជា ៦ នឹងវត្តនេះ មានមនុស្សទាំងអស់ប្រហែលជាង ១៧០ នាក់ ។ វត្តនេះមានគ្រូបង្រៀនជាបព្វជិតឈ្មោះ ឋាប់-ណាំ ឥតសញ្ញាបត្រទេ មានសិស្សសាលាចំនួន ២០ នាក់ ។ លុះស្រេចការហើយ យើងធ្វើភត្តកិច្ចនៅវត្តនេះរួចហើយត្រឡប់មកឯទីរួមខេត្តវិញ ។

ម៉ោង ១៤ កន្លះ បេញទៅវត្តបាយឆៅ ឃុំមីផៀង ខណ្ឌ ញៀវវាញ់ ម៉ោង ១៥ ដល់វត្តនេះ ។ ក្នុងទីប្រជុំនេះ មាន ពួកបព្វជិតវត្តក្រៅ ៨ វត្ត ជា ៩ នឹងវត្តនេះ មានមនុស្សមក ជួបជុំប្រហែលជាង ៩០ នាក់ ។ គ្រូបង្រៀនសាលាវត្តនេះឈ្មោះ ហាង-ព្រហ្ម មានសញ្ញាបត្រសាលាវត្តលង្កាក្នុងឆ្នាំ ១៩២៩ មានសិស្សសាលា ១៥ នាក់ ។ លុះស្រេចកិច្ចការហើយ យើង ត្រឡប់មកឯទីរួមខេត្តវិញ ។

ថ្ងៃពុធ ១២ ធ្នូ ១៩៣៣ (១១ រោចមិគសិរ)

ម៉ោង ៨ កន្លះ (ព្រឹក) បេញទៅវត្តស្រែឡ្វង ឃុំតែស៊ុម ខណ្ឌញៀវវ៉ា ម៉ោង ៩ ដល់វត្តនេះ ។ មានពួកបព្វជិតវត្ត ក្រៅ ៧ វត្ត មកប្រជុំក្នុងវត្តនេះ មនុស្សក្នុងទីប្រជុំនេះប្រហែល ១៥០ នាក់ ។ គ្រូបង្រៀនសាលាវត្តនេះឈ្មោះ សឺន-ផាត មានសញ្ញាបត្រសាលាវត្តលង្កាក្នុងឆ្នាំ ១៩២៩ មានសិស្ស សាលា ៣៨ នាក់ ។ លោកចៅហ្វាយខណ្ឌជាតិខ្មែរពីរនាក់ គឺលោក ឡឹម-លិន ចៅហ្វាយខណ្ឌញៀវវ៉ា ១ លោកយឿង-នី

ចៅហ្វាយខណ្ឌញៀវភ្លូ ១ ក៏អញ្ជើញមកក្នុងទីប្រជុំនេះដែរ ។ លុះស្រេចការហើយ យើងធ្វើភត្តកិច្ចក្នុងវត្តនេះ រួចហើយត្រឡប់មកឯទីរួមខេត្តវិញ ។

ម៉ោង ១៤ ចេញទៅវត្តទំនប់ (យួនហៅថ្លុបោថាវ) ក្នុងឃុំបឹងវ៉ា ខណ្ឌញៀវមី ម៉ោង ១៤ កន្លះដល់វត្តនេះ ។ មានពួកបព្វជិតវត្តក្រៅ ៩ វត្តមកប្រជុំក្នុងវត្តនេះ មនុស្សក្នុងទីប្រជុំនេះប្រហែល ២៥០ នាក់ ។ លោកចៅហ្វាយខណ្ឌញៀវមីនេះឈ្មោះ វិញ-ថាញ់-យ៉ាវ ជាចៅចិនបានអញ្ជើញមកក្នុងទីប្រជុំនេះដែរ មន្ត្រីនេះមានសភាពរាបសាជាអ្នកស្រឡាញ់ព្រះពុទ្ធសាសនា ។ គ្រូបង្រៀនសាលាវត្តនេះឈ្មោះ លឹម-ស៊ុម មានសញ្ញាបត្រសាលាវត្តលង្កាក្នុងឆ្នាំ ១៩៣០ មានសិស្សសាលា ២៣ នាក់ ។ លុះស្រេចកិច្ចការហើយ យើងត្រឡប់មកទីរួមខេត្តវិញ ។

ថ្ងៃព្រហស្បតិ៍ ១៤ ធ្នូ ១៩៣៣ (១២ កោចមិគសិរ)

ម៉ោង ៨ (ព្រឹក) ចេញទៅវត្តព្រៃកតាក្លួន ក្នុងឃុំលិចត្រា ខណ្ឌថាញ់ទ្បើយ ម៉ោង ៨ កន្លះដល់ទៅវត្តនេះ ។ យើងគ្រាន់

តែចូលទៅដល់វត្ត ១ស្រប់កប៉ុណ្ណោះក៏ត្រឡប់ចេញមកវិញ ព្រោះមិនឃើញមានមនុស្ស មកប្រជុំជួបវត្តឯទៀតរៀងមក ។

លុះចេញពីវត្តនេះមក ក៏បង្ហួសសំដៅទៅឯវត្ត នាងរេន យួនហៅជួខបាកក្នុងឃុំឋាញ់ទ្រី ខណ្ឌឋាញ់អាង ម៉ោង ៩ នឹង ២០ មីនុតដល់វត្តនេះ ។ យើងចូលទៅឈប់ធ្វើភត្តកិច្ចហើយ សម្រាករង់ចាំមនុស្សមកជួបជុំ ព្រោះសំបុត្រប្រាប់ដំណឹងរបស់ រាជការថា ដល់ម៉ោង១៣កន្លះទើបឲ្យមនុស្សមកប្រជុំក្នុងវត្តនេះ ម៉ោង ១៤ មនុស្សមកជួបជុំប្រហែល១៥០នាក់ ។ លុះស្រេច កិច្ចការហើយយើងត្រឡប់មកទីរួមខេត្តវិញ ។

ខេត្តកង់ជី

ថ្ងៃសុក្រ ១៥ ធ្នូ ១៩៣៣ (១៣ រោចមិគសិរ)

ម៉ោង ៨ (ព្រឹក) យើងចេញពីទីរួមខេត្តសុកត្រាំងឆ្ពោះទៅ ខេត្តកង់ជឺ (ខ្មែរហៅខេត្តព្រៃកប្ញស្សី) ម៉ោង ៩ ដល់ទីរួមខេត្ត កង់ជឺ យើងឈប់សំណាក់នៅសណ្ឋាគារដ្ឋាន (ផ្ទះសម្រាប់អ្នក រាជការដែលជាអ្នកដំណើរមកឈប់សំណាក់អាស្រ័យទទេមិន បាច់ចេញថ្លៃឈ្នួល) ។

ម៉ោង ១៤ យើងចេញពីទីរួមខេត្តកង់បឺទៅវត្តសំរោង ក្នុងឃុំអូម៉ួង (ខ្មែរហៅឃុំឪម៉ុល) ខណ្ឌបឺយបារ ម៉ោង ១៥ ទៅដល់វត្តនេះ ។ មានពួកបព្វជិត ៥ វត្តមកប្រជុំក្នុងវត្តនេះមនុស្សដែលមកប្រជុំក្នុងទីនេះប្រហែលជាង ១០០ នាក់ ។ វត្តនេះមិនទាន់មានសាលារៀនទេលោកចៅអធិការវត្តបានជំរាបលោកអគ្គលេខាធិការហាសុំឲ្យរាជការជួយទំនុកបំរុង តាំងគ្រូហស្ដម្នាក់ឈ្មោះ ស្រី-វៀម មានសញ្ញាបត្រសាលាវត្តលង្កាក្រុងភ្នំពេញពីក្នុងឆ្នាំ ១៩២៩ ដែលសព្វថ្ងៃនៅក្នុងឃុំនេះ ឲ្យបានពេញទីជាគ្រូបង្រៀនក្នុងវត្តសំរោងនេះឡើង ។ លុះស្រេចកិច្ចការហើយយើងត្រឡប់មកឯទីរួមខេត្តកង់បឺវិញ ។

ថ្ងៃសៅរ៍ ១៦ ដេសំម ១៩៣៣ (១៤ រោចមិគ្គសិរ)

ម៉ោង ៦ កន្លះ (ព្រឹក) ចេញទៅវត្តអរញ្ញិក (ពាក្យធម្មតាហៅវត្តផោរ យួនហៅថ្លញ់ឡុង) ក្នុងឃុំញ៉ឡុង ខណ្ឌឱញកើតម៉ោង ៨ កន្លះដល់ទៅស្ពានឆ្លងព្រែក ១ ចុះទូកតាមព្រែកទៅទៀតទើបបានដល់វត្តអរញ្ញិក ។ មានបព្វជិតនឹងគ្រូហស្ដមក

ប្រជុំប្រហែល ៦០ នាក់ វត្តនេះតូចណាស់ មានកុមារសិស្ស វត្ត ៨ នាក់ ។ លុះស្រេចកិច្ចការហើយ យើងត្រឡប់មកឯទីរួមខេត្តវិញ ។

ម៉ោង ១៣ កន្លះ ចេញពីទីរួមខេត្តផ្លូវទន្លេដោយបាក់ (សាឡាង) ទៅត្រើយខាងកើតបើករថយន្តឆ្ពោះទៅវត្តពោធិ៍ភិរម្យរង្សី ក្នុងឃុំចុងវ៉ា ខណ្ឌហាញ់ទ្រី ម៉ោង ១៤ កន្លះទៅដល់វត្តនេះ ។ គ្រាន់តែទៅដល់មុខវត្ត បញ្ឈប់រថយន្តនៅទីនោះ មិនបានចូលទៅក្នុងវត្តទេ ព្រោះឃើញស្ងាត់ស្ងៀមឥតមានមនុស្ស បានឲ្យបំរើទៅសួរលោកចៅអធិការ ៗ ប្រាប់ថា ពីព្រឹកមិញឃើញជំទប់ក្នុងឃុំនេះមកឲ្យដំណឹងថា ក្នុងថ្ងៃនេះនឹងមានលោកធំអញ្ជើញមក គេគ្រាន់តែឲ្យដំណឹងប៉ុណ្ណោះ គេនឹងបានប្រាប់ថា លោកធំណា ឈ្មោះអ្វី ជាអ្នកត្រួតត្រាមុខរាជការអ្វី លោកនឹងអញ្ជើញមកដល់នៅវេលាម៉ោងប៉ុន្មាន ដូច្នោះក៏គ្មានសោះ ។ យើងបានឲ្យទៅនិមន្តលោកសុំឲ្យមកជួបបាន ១ រំពេច ក៏ឥតមានឃើញលោកភិក្ខុឬសាមណេរណាមួយមកឡើយ យើងក៏ហួសទៅជួបនឹងលោកចៅហ្វាយស្រុកភូរកែ

(ខ្មែរហៅស្រុកកំពង់ស្ពាន) ជាតិជាយួន លោកចៅហ្វាយស្រុកប្រាប់យើងថា លោកបានចាត់ការឲ្យមន្ត្រីឃុំឲ្យដំណឹងលោកចៅអធិការវត្តនោះយូរថ្ងៃហើយ ប៉ុន្តែបានសង្កេតមើលទៅឃើញថា លោកចៅអធិការនោះមិនអើពើព្រោះលោកមិនត្រូវការនឹងរបៀបការសិក្សាដែលរាជការចាត់រៀបចំនោះទេ ។ យើងក៏ត្រឡប់មកឯទីរួមខេត្តវិញ ។

ថ្ងៃអាទិត្យ ៧ ដេសម ១៩៣៣ (១ កើតខែបុស្ស)

ម៉ោង ៧ (ព្រឹក) ចេញពីទីរួមខេត្តឆ្លងទន្លេទៅតាមផ្លូវពីម្សិល បែកសំដៅទៅវត្តសារាវ័នឱឡាន (ពាក្យធម្មតាហៅវត្តពងលលក) ក្នុងឃុំល្ហុងតឹង ខណ្ឌបិញខ្សែ រថយន្តទៅមិនដល់ យើងចុះទូកតទៅទៀត ម៉ោង ៩ កន្លះដល់វត្តនេះ ។ មានខ្មែរកំឡោះម្នាក់ឈ្មោះ សារុន បានសញ្ញាបត្របឋមសិក្សាខ្មែរចេញពីសាលាហ្វ្រង់ស្វ័របូដ៏ងក្រុងភ្នំពេញពីក្នុងឆ្នាំ ១៩២៧ មកធ្វើជាគ្រូបង្រៀននៅសាលាវត្តនេះ មានសិស្សកុមារ ៧នាក់ កុមារី ៣នាក់ ។ ផ្ទះខ្មែរជាបំណុះវត្តនេះមានប្រហែល ១៥០ ខ្នង

ប៉ុន្តែប្រហែលជាអ្នកស្រុកមិនទាន់ពេញចិត្តនឹងឲ្យកូនចូលរៀនក្នុងសាលាទេដឹង បានជាមានសិស្សសាលាតែ ១០ នាក់ប៉ុណ្ណោះ លោកចៅអធិការប្រាប់ថា លោកបានបាត់ភិក្ខុ ១ រូបឈ្មោះ ឋាប់-សាម ឲ្យទៅរៀនឯសាលាវត្តលង្កាក្រុងភ្នំពេញ តាំងពីក្នុងឆ្នាំ ១៩៣២ សព្វថ្ងៃកំពុងរៀននៅឡើយ ។ ក្នុងទីប្រជុំនេះមានមនុស្សប្រហែល៣០នាក់ ។ លុះស្រេចកិច្ចការហើយ យើងធ្វើភត្តកិច្ចនៅវត្តនេះ ។

ម៉ោង ១១ កន្លះ បេញពីវត្តសារាវ័នឱឡានមក ឡើងរថយន្តសំដៅទៅឯឃុំភ្លូលី (ខ្មែរហៅឃុំអង្គុលី) លុះដល់ទៅស្ពានថ្លង់ព្រៃកភ្លូលី យើងចុះកាណូតរាជការបើកសំដៅទៅវត្តអង្គុលីរាជ (យួនហៅជ្ជូភ្លូលី) ក្នុងឃុំភ្លូលី ១ណ្ណាអាងទ្រើង ម៉ោង ១៣ ដល់វត្តនេះ ។ មិនមានសាលារៀនទេ ប៉ុន្តែក្នុងឃុំភ្លូលីនេះមានសាលារៀនអក្សរខ្មែរ—បារាំង ១ ក្នុងភូមិខ្មែរនៅក្បែរសាលាឃុំ រាជការបានបង្កើតឲ្យមានមក ៧ ឆ្នាំហើយ គ្រូបង្រៀនឈ្មោះ អ៊ុង-គល់ មិនមានសញ្ញាបត្រទេ ប៉ុន្តែបានរៀនអក្សរបារាំងនៅសាលា ឌូដារ័ដឺឡាក្រេក្រុងភ្នំពេញ ចំនួន

៦ ឆ្នាំ សាលារៀននោះមានសិស្សកុមារ ១៤ នាក់ កុមារី ៦នាក់ គ្រូបង្រៀនបាននាំសិស្សទាំង ២០ នាក់ នោះមកក្នុងទីប្រជុំនេះដែរ ។ ក្នុងសន្និបាតនេះមានមនុស្សប្រហែល ៨០នាក់ ។ យើងបាននិយាយពន្យល់សព្វគ្រប់ហើយ ឲ្យពួកសិស្សសាលាមើលសៀវភៅ ពោទបំណោទលេខ ហើយបែកសៀវភៅឲ្យខ្លះ រូបឲ្យបែករូបផ្តិតពុម្ព ហើយត្រឡប់មកឯទីរួមខេត្តវិញ ។

ថ្ងៃចន្ទ ១៨ ធ្នូ ១៩៣៣ (២ កើតខែបុស្ស)

ម៉ោង ៩ (ព្រឹក) ចេញពីទីរួមខេត្តឆ្លងសំដៅទៅវត្តកំពង់ស្អាន (ឃុំនហៅជ្ឈភ្នំកែ) ក្នុងស្រុកភ្នំកែ (កំពង់ស្អាន) ម៉ោង ១០ កន្លះដល់វត្តនេះ ។ លុះស្រេចភត្តកិច្ចហើយ ម៉ោង ១២ កន្លះបួលកាន់ទីប្រជុំ ។ មានពួកបព្វជិតវត្តក្រៅ ៣ វត្តមកកាន់ទីប្រជុំនេះៗ មានមនុស្សប្រហែល ៦០០ នាក់ ។ វត្តកំពង់ស្អាទនេះមានសាលារៀនអក្សរខ្មែរ — បារាំង មានគ្រូបង្រៀនជាតិខ្មែរ ២ នាក់ មានសិស្សទាំងប្រុសទាំងស្រី ៦០ នាក់ ។ លោកគ្រូចៅអធិការវត្តនេះបានសង់សាលា ១ ផ្សេងទៀត

សម្រាប់បង្រៀនធម៌វិន័យព្រះពុទ្ធសាសនា បម្រុងនឹងដាក់ទៅជាសាលាបាឡី ប៉ុន្តែសព្វថ្ងៃមិនទាន់មានអាការរៀបបង្រៀនបាឡីនៅឡើយ លុះចប់សេចក្ដីពន្យល់របស់លោកអគ្គលេខាធិការហើយ លោកចៅអធិការវត្តនេះបានសុំឲ្យខ្ញុំនិយាយពន្យល់ឲ្យប្រើនុបន្តិច ខ្ញុំក៏បាននិយាយពន្យល់តាមគួរដល់អាការនៃក្រុមប្រជុំនេះ ។

ម៉ោង ១៤ កន្លះ បេញពីវត្តកំពង់ស្ពានឆ្ពោះទៅវត្តជោរវ័សង្ហារមាស (ពាក្យធម្មតាហៅវត្តបាក់ខ្នា) ក្នុងឃុំបួរជៀងស្រុកភ្នំកែ ម៉ោង ១៥ ដល់វត្តនេះ ។ វត្តនេះមានសាលារៀនប៉ុន្តែលោកភិក្ខុឈ្មោះ ស៊ុន-អ៊ំ ដែលជាគ្រូបង្រៀនគ្មានសញ្ញាបត្រទេ មានសិស្សសាលាចំនួន ៣៧ នាក់ ។ មានពួកបព្វជិតវត្តក្រៅ ៤ វត្តមកកាន់ទីប្រជុំនេះ ។ មានមនុស្សប្រហែល ៤០០ នាក់ ។ លុះយើងនិយាយពន្យល់ក្នុងទីប្រជុំរួចហើយបានចូលទៅក្នុងសាលារៀន ឲ្យកូនសិស្សសាលានេះមើលសៀវភៅ ហោទបំណោទលេខ រួចឲ្យសៀវភៅខ្លះ ទុកសម្រាប់សាលារៀននេះ ។

ម៉ោង ១៧ យើងចេញពីវត្តនេះឆ្ពោះសំដៅទៅខេត្តត្រាវិញ (ខ្មែរហៅខេត្តព្រះត្រពាំង) ម៉ោង ១៨ កន្លះដល់ទីរួមខេត្តត្រាវិញ យើងទៅឈប់សំណាក់នៅវត្តកំពង់ (យួនហៅជួរអុងមាក វត្តលោកគ្រូមាស) នៅក្នុងទីរួមខេត្ត លោកអគ្គលេខាធិការឈប់សំណាក់ឯសណ្ឋាគារដ្ឋាន (ផ្ទះសម្រាប់អ្នករាជការឈប់សំណាក់) ក្នុងទីរួមខេត្តត្រាវិញ ។



យាយជីភូមារក្សាសីល ១០ ស្លៀកដណ្តប់លឿង អាស្រ័យនៅក្នុងវត្ត ។

## សម័យចំរើនរបស់ក្បាច់របាំខ្មែរ

តាមសេចក្ដីយល់ឃើញរបស់លោក ហ.ម៉ាស្សាល់

ចាងហ្វាងក្រសួង ពិនិត្យប្រាសាទបូរាណ ក្នុងប្រទេសឥណ្ឌូស៊ីន

១ – របាំ ឥណ្ឌៀ-ខ្មែរ ព. ស. ១០៤៣ ១១៤៣ ដែលមិនឃើញមានបែបគំរូក្នុងប្រាសាទផ្សេង ៗ ក្នុងប្រជុំអង្គរ ប៉ុន្តែគេឃើញមានស្នាមដានទៅសម្បូរព្រៃគុក (កំពង់ធំ) នឹងនៅប្រាសាទដំរីក្រាប (ភ្នំគូលែន) ។

លក្ខណរបស់របាំក្នុងសម័យនោះ ដូចមានខាងក្រោយប្រាសាទទាំងឡាយធ្វើជាកំពូលជាប់តែឯងឬក៏ផ្តុំគ្នា ហើយមានកំផែងព័ទ្ធជុំវិញ ។ ឯរូបដែលដំកល់ក្នុងប្រាសាទទាំងនេះ សុទ្ធតែយ៉ាងសំខាន់លេខ ១ ទាំងអស់ ដែលគេអាចឃើញនៅទីសារមន្ទីរក្រុងភ្នំពេញគឺជាទេវរូបផ្សេង ៗ សម្រាប់សាសនាព្រាហ្មណ៍ ។

២ – របាំខ្មែរសម័យទី ១ ព. ស. ១៣៤៣-១៤៤៣ ឧទ្ទិស្សដល់ព្រាហ្មណ៍សាសនា ។

គេប្រើតែយកឥដ្ឋមកសាងជាប្រាសាទឡើង ហើយឯថ្មផុកនោះគេគ្រាន់តែយកមកធ្វើជាក្បាច់ សំរាប់បន្ថំប្រាសាទទាំងនេះដែលជាប្រាសាទយ៉ាងល្អ ៗ ផើត ។ ប្រាសាទនៅក្នុងប្រជុំអង្គរទាំងប៉ុន្មាន ដែលកសាងឡើងក្នុងសម័យជាមួយគ្នានេះ ត្រូវរាប់ ភ្នំបាខែង ប្រែរូប ប្រាសាទក្រវាញ លលៃ ព្រះគោ ។ ល, ល ។

៣–របនាខ្មែរ សម័យទី ២ ព. ស. ១៤៤៣-១៥៤៣ ប្រើតែឧទ្ទិសដល់ព្រះឥស្វរ ។

លក្ខណជាគ្រឿងសំគាល់ ប្រាសាទសាងដោយថ្មផុក មានក្បាច់ចំឡាក់យ៉ាងល្អ ។ នៅឱជាងមានរចនាជាក្បាច់ក្បូរផ្សេង ៗ ប្រើនជាជាងដែលរចនាជារឿងរ៉ាវជាផ្លូវសាសនា ។ បណ្ដាប្រាសាទទាំងប៉ុន្មានក្នុងសម័យនោះ ត្រូវរាប់ប្រាសាទបាពួន តាកែវ ចៅសាយ ធម្មនន (ធម្មានន្ទ) ។ ល ។

៤–របនាខ្មែរ សម័យនគរវត្ត ព. ស. ១៦៤៣-១៧៤៣ ប្រើតែឧទ្ទិសដល់ព្រះវិស្ណុ ។

លក្ខណគ្រឿងសំគាល់ក្បាច់ចំឡាក់យ៉ាងថ្មីតផ្ទង់យ៉ាងឆ្មារ ហើយមិនសូវក្រៀមក្រឡោត គឺស្នាដៃជាងប្រតិស្ឋយ៉ាងសំខាន់ ប្រាសាទទាំងប៉ុន្មាន ដែលកើតឡើងក្នុងសម័យនោះគឺ នគរវត្ត បន្ទាយសំរែ បឹងមាលា ។

៥–របនាខ្មែរ ក្នុងសម័យព្រះពុទ្ធសករាជ ១៧៥០-១៨៥០ ប្រាសាទទាំងឡាយនោះ សុទ្ធតែឧទ្ទិសដល់ព្រះពុទ្ធសាសនាប៉ែកមហាយាន គឺព្រះលោកេស្វរ ដែលគេគោរពជំនួសព្រាហ្មណសាសនា ។

លក្ខណៈជាគ្រឿងសំគាល់ ការកសាងធ្វើដោយប្រញាប់ ឥតពិនិត្យពិចៃ ធ្វើដោយថ្មរភក់ ហើយមានក្បាច់និងឧជាងជាច្រើន ធ្វើជារឿងផ្សេងៗក្នុងសាសនា មានរូបធំដែលឆ្លាក់ឲ្យចេញក្រឡោតឡើង ។

ប្រាសាទដែលមានក្នុងសម័យនេះគឺ កំផែងនគរធំនឹងទ្វារចូលទាំង ៥ ប្រាសាទបាយ័ន ព្រះខ័ន តាព្រហ្ម បន្ទាយក្តី នាគពន្ធ ក្រោលគោ តាសោម តានៃ ។ ល. ល ។

ខេមាខេមសរណកថា

ព្រះមហាពិទូរក្រសេម រៀបរៀង

(៣)

បំណែកឯបច្ចុប្បញ្ញត្តិ  គឺបញ្ញត្តិឡើងដោយប្រើវិចរណៈញាណពិនិត្យសព្វគ្រប់ហើយ  អាស្រ័យសេចក្ដីសមពិតជាគោលទើបគាត់យកជាសរណៈ  ការដល់សរណៈដូច្នេះ តោងបានការទាំងអស់ ព្រោះជាសរណៈដ៏ក្សេម មិនធ្វើឲ្យអ្នករាប់អានផុតអំពើ ដូច្នេះតើនឹងចូលចិត្តខាងផុតអំពើ ឬនឹងចូលចិត្តខាងបានការ  តែជឿថាត្រង់ដែលបានការសមស័ក្តិសមប្រកបគង់គ្មានអ្នកណាបដិសេធ ក៏វេលានេះសរណៈមានព្រមទាំង ២ បែបតាមតែចិត្តស្រឡាញ់បែបណា តែបើឃើញដល់ដំឡែខ្លួន ក៏គួរជាស្រិតយកតែសរណៈដែលឧត្តម ទើបមិនផុតអំពើ  អាចឲ្យសមប្រកបរហូតទៅតាមសម់គួរដល់បំណាច់ដែលខ្លួនធ្វើទុក ។

អំពីនេះនឹងលើកយកសរណវត្ថុផ្សេង ៗ  ដែលមានចំនួនមនុស្សរាប់អានច្រើន  ព្រមទាំងលទ្ធិសាសនាមកប្រជុំសំដែងក្នុងទីនេះ  ដើម្បីនឹងឲ្យអ្នកមានបញ្ញាលើកឡើងប្រៀបធៀបគ្នាហើយវិនិច្ឆ័យយកយ៉ាងឯណានីមួយជាសរណៈប្រចាំជីវិតរបស់ខ្លួន តែនឹងសំដែងតែដោយសង្ខេបល្មមសមគួរ  ព្រោះប្រញាប់នឹងបញ្ចប់រឿងនេះ  ឲ្យចប់ចុះដោយមិនច្រើនទំព័រ ។

លទ្ធិ: បានតែងរបៀបទំនៀមទម្លាប់ដែលធ្លាប់កាន់តៗមក សំដែងសេចក្ដីថា លោកនេះមានអ្នកសាងសុខឬទុក្ខដែលមនុស្សត្រូវបានទទួលសោយ នៅក្នុងអំណាចអ្នកសាងស្រេចហើយ តែអ្នកសាងនឹងអំណោយយ៉ាងណា ឲ្យដល់អ្នកណាវេលាណា បរិយាយរឿងអភិនិហារយ៉ាងពន្លឹកអស្ចារ្យមុខគួរស្ញែងនឹងសំដែងវិធីបំពេញវត្តសម្រាប់យកចិត្តអ្នកសាងនោះយ៉ាងតឹងម៉ឹងក៏មាន យ៉ាងធូរស្បើតក៏មាន ។

សាសនា: ចង្អុលដល់សភាវធម៌ទាំងពួងកើតអំពីហេតុគឺសុខទុក្ខដែលមនុស្សបានទទួលសោយសព្វថ្ងៃនេះ មកអំពីហេតុជាអ្នកអំណោយ បដិសេធសេចក្ដីដែលថា មានព្រះជាម្ចាស់ជាអ្នកអំណោយ សឹងមិនមែនជាតួហេតុ បរិយាយសេចក្ដីទៅតាមក្រសែធម្មជាតិ-ធម្មតា សភាវៈដែលពិតមិនបំផ្លើសលើស ឬក្រោមាត្រា សំដែងវត្តបដិបត្តិជាគោលសម្រាប់បំពេញបុណ្យកុសលតែល្មមយ៉ាងកណ្ដាល មិនធូរពេកម៉ឺនតឹងពេក ។

លទ្ធិនឹងសាសនាច្រើនតែច្រឡូកច្រឡំលាយគ្នា គួរវាដូចស្រូវនឹងស្មៅក្នុងស្រែជាមួយគ្នា ក្នុងស្រែ១មានទាំងស្រូវទាំងស្មៅ តែលោកហៅថាស្រែស្រូវ ព្រោះស្រូវមានចំនួនច្រើនជាង ហៅថាស្រែស្មៅព្រោះស្មៅមានចំនួនច្រើនជាង ដែលហៅថាលទ្ធិហិណ្ឌូ លទ្ធិសោរោអស្ទើរ លទ្ធិយិវ ។ ល ។ អំបាលនេះជាដើម នឹងបដិសេធថាគ្មានសាសនាតែម្តងមិនបាន ដ្បិតក្នុងបំណោមនេះមានពាក្យប្រដៅថា កុំធ្វើសេចក្តីអាក្រក់ ចូរធ្វើតែសេចក្តីល្អផង សំដីនេះសរឲ្យឃើញច្បាស់ថា ខសាសនាមាននៅក្នុងលទ្ធិទាំងនោះ ដែលលោកហៅដូច្នេះ ដោយសំដៅយកត្រង់ដែលមានចំនួនច្រើន បើច្រើនទៅដោយលទ្ធិ ទោះបីមានខសាសនាលាយខ្លះក៏រូមហៅថាលទ្ធិ ខាងសាសនាក៏ដូចគ្នា មានលទ្ធិតិចមានខសាសនាច្រើនក៏តោងហៅថា សាសនា លទ្ធិឬសាសនាបើប្រមូលជាគម្ពីរ ដូចយ៉ាងគម្ពីរព្រះវេទ គម្ពីរព្រះត្រៃបិដក គម្ពីរប៊ីព្លេស គម្ពីរកុអាន គម្ពីរអាទិគ្រន្ថ ក៏រាប់ជាសរណៈមួយយ៉ាង ៗ ដោយបំពោះឬរួមទាំងម្ចាស់ដើមនៃគម្ពីរទាំងនេះផងក៏មាន តែដែលរដាប់រដោបគ្រាន់តែជាវាទៈពោយរាបេ

របស់អ្នកពណ៌នាសេចក្ដីនៃគម្ពីរ គឺជំពូកអដ្ឋកថា ជួនកាលក៏មិនរាប់ជាសរណៈ គម្ពីរណាជាលទ្ធិ គម្ពីរណាជាសាសនាមិនបាច់បង្គុលឲ្យជាប់ខាតក្នុងទីនេះ សុំតែថាលទ្ធិជាសរណៈដែលបញ្ញត្តិឡើងដោយអនុមានៈ សាសនាបញ្ញត្តិឡើងដោយលំអានដែលពិត ។ រួមខ្លឹមសេចក្ដីក្នុងសាសនាទាំងពួងគង់មានតែ ១ យ៉ាង គឺឲ្យមនុស្សយើង ប្រព្រឹត្តកាយវាចាចិត្តសុភាពល្អ មិនបៀតបៀនមនុស្សសត្វឲ្យក្ដៅក្រហាយ ដែលហៅថាមនុស្ស ក្នុងលោក នឹងឲ្យផុតអំពីទុក្ខភ័យក្នុងលោកនេះផង សាស. ប្រៀបដូចបន្ទាត់ ឬដូចត្រីវិស័យសម្រាប់ចង្អុលទិស ត្រីវិស័យជាគ្រឿងនាំផ្លូវឲ្យត្រង់ មិនឲ្យយើងវង្វេងទៅផ្ដេសផ្ដាស ព្រោះហេតុនេះ កាលយើងនឹងកាន់សាសនា នឹងរាប់អានសាស្ដា ត្រូវរើសយកតែសាសនានឹងសាស្ដាដែលល្អបំផុតទើបមិនបង់សៀត ។

ត្លយ៉ាងសរណៈ មនុស្សយើងក្នុងលោកនេះ អ្នកខ្លះរាប់អានសរណៈដែលមានរូប ដូចយ៉ាងព្រះអាទិត្យ ព្រះច័ន្ទ ព្រះពុទ្ធ ព្រះយេស៊ូ ព្រះមហាម៉ូទ ជាដើម អ្នកខ្លះរាប់អានសរណ

ដែលមិនប្រាកដរូបដូចយ៉ាងព្រះព្រហ្ម ព្រះឥស្វរ ព្រះនារាយណ៍ ព្រះយហោវ៉ា ព្រះអាលោះហ៍ នឹងសៀនហង់តេជាដើម ។ ឯរូបសរណៈនោះជំពូកខ្លះឃើញថាមានគុណសម្បត្តិគួររាប់អានត្រឹមតែបន្តិចបន្តួច ជំពូកខ្លះមានគុណសម្បត្តិគួររាប់អានច្រើនបំណែក ឯអរូបសរណៈគិតមិនឃើញថាត្រូវរាប់អានដោយផ្លូវណា មិនដឹងបើនឹងរាប់អានទៅលើអ្វី ព្រោះតាំងតែពីកើតមានលោកនេះឡើង គ្មានអ្នកណាដែលឃើញរូបរាងព្រះជាម្ចាស់នោះសោះ គ្មានអ្នកណានឹងអាចបង្អុលបានថា រូបរាងដូចម្ដេចមានតែស្មានថា រូបរាងគង់យ៉ាងនេះយ៉ាងនោះប៉ុណ្ណោះឯង នឹងយកជាពិតគង់មិនបាន កាលបើដូច្នេះ ម្ដេចនឹងដឹងបានថាព្រះជាម្ចាស់មាននៅក្នុងលោក តែណ្ហើយបុះព្រះជាម្ចាស់ជាមានពិតឬគ្មានក៏ដោយ កាលមនុស្សឧបអរយកជាទីពឹងហើយអាចជួយឲ្យរួចចាកទុក្ខបានមែន ៗ ក៏គួរដែរ ដែលនឹងរាប់អានយកជាទីពឹង ។

គតិដើមពួកព្រាហ្មណ៍រាប់អានព្រះអាទិត្យ ។ល។ ក្នុងសម័យមុនពុទ្ធកាលប្រមាណ ៥-៦ ពាន់ឆ្នាំ មនុស្សក្នុងជម្ពូទ្វីប

ដែលគេហៅដោយឈ្មោះជាតិថាទស្យុ ផ្ដើមរាប់អានព្រះអាទិត្យ ព្រះចន្ទ្រ ក្រៅអំពីនេះនៅមានរាប់អានព្រះពាយ ព្រះវរុណ និង ព្រៃភ្នំដើមឈើធំៗ រហូតដល់សត្វតិរច្ឆានជំពូកខ្លះ មាននាគជាដើមយកជាសរណៈទីពឹង ដោយឃើញថាជារបស់អស្ចារ្យ គង់ជាមានរបស់វិសេសសំខាន់អ្វីមួយយ៉ាងនៅក្នុងនោះ ដូចយ៉ាងព្រះអាទិត្យ ព្រះចន្ទ្រ ម្ដេចក៏មានពន្លឺរស្មីបំភ្លឺលោកឲ្យភ្លឺបាន អ្វីបណ្ដាលឲ្យព្រះពាយបោកបក់មកបាន អ្វីបណ្ដាលឲ្យព្រះវរុណ (ភ្លៀង) ធ្លាក់ចុះមកបាន ដូច្នេះជាដើម ។

ក្រោយនោះមានជនជាតិអរិយៈ ដែលនៅកណ្ដាលទ្វីបអាស៊ី គឺអាហ្វឃានិស្ថាន រហូតមកដល់ប្រទេសទីបេត៍ ជាជាតិដែលរុងរឿងជាងជនជាតិទស្យុ បានលើកព្យុហទៅកម្រាបពួកទស្យុក្នុងជម្ពូទ្វីបបានហើយតាំងភូមិលំនៅ ៗ ក្នុងប្រទេសដែលហៅថា ភារតវិស្រ បានទទួលរាប់អានព្រះអាទិត្យ ព្រះចន្ទ្រ ព្រះវរុណ និងអ្នកជាធំដែលបណ្ដាលវត្ថុទាំងពួងឲ្យកើតឲ្យមានឡើងក្នុងលោក ដែលហៅដោយឈ្មោះថា ព្រះឥន្ទ្រ និងរាប់អានអ្នកមានឫទ្ធិមានអំណាចអាចមកផ្ដាច់យកជីវិតមនុស្សសត្វទៅ

បាន ដែលហៅថា ម្រិត្យ ឬព្រះយម ហើយក៏តែងតាំងជាគំរាប់គំរាសម្រាប់ធ្វើពិធីបូជាអ្នកវិសេសអំបាលនេះ ដោយគិតប្រឌិតឡើងខ្លួនឯង ទើបកើតជាគំរាសៃយសាស្ត្របែបរបស់ពួកទស្សុនឹងពួកអរិយលាយគ្នា ដូចជានឹងមានពោលទៅខាងមុខ ។

លុះអំណើសយូរមកពួកអរិយជនសួរពួកព្រាហ្មណ៍គឺពួកអ្នកកាន់លទ្ធិនេះដោយមាំមួនថា អ្នកណាជាអ្នកបង្កើតព្រះអាទិត្យ ព្រះចន្ទ ព្រះអគ្និ ឬព្រះអគ្គី ព្រះពាយ ព្រះវរុណ គង់ជាមានម្ដាយអាពុក បើគ្មានម្ដាយអាពុកនៅស្មៀមៗ ម្ដេចនឹងកើតមកបាន ពួកព្រាហ្មណ៍កាលត្រូវសួរដូច្នេះក៏ទ្រឹង ដោយនឹងប្រាប់ថា មិនដឹងក៏ឃើញផ្ដេសផ្ដាសពេកណាស់ ជាគ្រូបាអាចារ្យគេហើយ ត្រូវតែដឹង ត្រូវតែយល់ ទាំងខ្លួនក៏បានអួតប្រាប់គេថា ក្នុងវេលាដែលធ្វើពិធីបូជាព្រះភ្លើង ឮសូរសំឡេងព្រះអាទិត្យ ព្រះចន្ទ នឹងព្រះពាយហាក់ដូចជានិយាយនឹងខ្លួនទើបនិយាយបណ្ដោះបណ្ដាយថា សុំបង្អង់បន្តិចសិននឹងទៅធ្វើពិធីសួរព្រះជាម្ចាស់ ទើបដឹងបានជាក់ច្បាស់ ពួកព្រាហ្មណ៍

ថយទៅហើយ ក៏ហៅគ្នាមកប្រជុំប្រឹក្សារឿងនេះ ទាល់តែគិតឃើញផ្លូវតប គឺគេតបថា ក្នុងជាន់ដើមក្នុងលោកនេះមានតែទឹកនឹងព្រះធម៌ប៉ុណ្ណោះ ព្រះធម៌រមែងមាននៅក្នុងលោកនេះជាធម្មតា ព្រះធម៌នោះផ្សំគ្នាយូរ ៗ ទៅ ក៏កើតជាពងអណ្តែតទៅលើទឹកបំនួនមួយម៉ឺនកប្ប ហើយមានព្រះជាម្ចាស់ដែលហៅថាព្រះព្រហ្ម ឬបរព្រហ្មនៅក្នុងពងនោះ គេទើបហៅពងនោះថាព្រហ្មណ្ឌ ប្រែថាពងព្រះព្រហ្ម កាលគ្រប់កំណត់ហើយ ព្រះព្រហ្មក៏បណ្តាលឲ្យពងនោះបែកជា ២ បំហៀង ៗ ខាងលើលោកឲ្យទៅជាទេវលោក បំហៀងខាងក្រោមឲ្យទៅជាមនុស្សលោក ហើយទ្រង់សាងចលនវត្ថុនឹងអចលនវត្ថុ និងវិញ្ញាណកនឹងអវិញ្ញាណកទាំងពួង ឲ្យមានព្រមក្នុងទេវលោកនឹងក្នុងមនុស្សលោក បំណែកឯព្រះអង្គលោកក៏ទៅស្ថិតនៅឯស្ថានសួគ៌រហូតដល់សព្វថ្ងៃនេះ មិនបេះបុតប្រែប្រួលនាំឯណា ពួកអរិយៈក៏ជឿតាមន័យនេះ ។



លោកសង្ឃភូមាកាន់ផ្ចិតស្លឹកត្នោត ទំនៀមលោកសង្ឃភូមា សុទ្ធតែប្រើ
ផ្ចិតស្លឹកត្នោតរូបធំ ៗ ដូច្នេះ ។

# សាសនីវាទពាក្យកាព្យ

(ត)

បើអ្នកឯណា ស្រឡាញ់អាត្មា ត្រូវកាន់ច្បាប់ក្បួន របស់បណ្ឌិត គិតឲ្យមាំមួន ហៅស្រឡាញ់ខ្លួន ជួននឹងពុទ្ធដីកាច្បាប់នេះសង្ខេប ត្រូវរើសយកបែប ធម៌ដែលសាស្តា ប្រដៅគ្រហស្ថ បស់តាមត្រូវការ មករៀបរៀងគ្នា ទុកជារបៀបមួយជាផ្លូវប្រដៅ ដល់កូនដល់ចៅ ធ្វើមិនឲ្យព្រួយ ដើម្បីឲ្យសុខទុកជាជំនួយ បំណែកឲ្យជួយ ឧបដ្ឋកម្មបថ ។ ហៅធម៌សង្គ្រោះ ស្រង់យកបំពោះ យកតាមកំណត់ ល្មមជាត្រូវការដល់អ្នកប្រតិបត្តិ ដើម្បីកំចាត់ កំចាយទុក្ខទោស ។ រីឯមាតានឹងអស់បិតា មានធម៌សន្តោស ដល់កូនទាំងឡាយ ហៅធម៌សង្គ្រោះ លោកទុកបំពោះ មាន៥ប្រការ ។ ទី១ត្រូវឃាត់ ត្រូវហាមតាមបទ បុរាណាចារ្យ កុំធ្វើអាក្រក់ ប្រព្រឹត្តឥរិយា ទុច្ចរិតគ្រប់ប្រការ ដែលលោកបញ្ញត្តិ ។ ទី២ទូន្មាននៅក្នុងសីលទាន ឲ្យរៀនកំចាត់ កំចាលផ្លូវអា ក្រក់ឲ្យបាត់ស្ងាត់ ប្រយ័ត្នតែខ្លួន ធ្វើមារយាទល្អ ។ ទី៣ឲ្យសិក្សា នូវសីលវិជ្ជា លេខនឹងអក្សរ វិជ្ជាឯណា ដែលជាល្អៗ ទំរិតដំរឲ្យកូនរៀននឹងគេ ។ ទី៤បើខ្លួន កូនធំឡើងធ្លួន ល្មមគិតរិះរេ

រកប្ដីប្រពន្ធ គួរសមនឹងគេ ឬកពារនឹងឥ រិយាល្អសុទ្ធសុន ។ ទី៥ត្រូវបែក រលាក់រលែក ទ្រព្យធនដល់កូន ធ្វើជាដើមទុន កុំឲ្យសោះសូន្យ បែកឲ្យសំនួន តាមកំឡាំងទ្រព្យ ។ មាតា បិតា តែងតែត្រូវការ អម្រែងសព្វគ្រប់ ដល់បុត្រទាំងពួង នោះឲ្យសាយសព្វ មិនត្រូវការឈប់ គ្រប់រូបទាំងអស់ ។ រីអ្នក ឯណា ជាបុត្រធីតា សត្រីបុរស បើបានទទួល ធម៌ដែល សង្គ្រោះ លោកបានបំពោះ ដល់ខ្លួនរូបហើយ ។ ត្រូវតែធ្វើ កិច្ច នោះគួរកុំភ្លេច កុំនៅកន្ដើយ ត្រូវដោះបំណុល ត្រូវ តបឲ្យហើយ កុំទុកទៅឡើយ កុំឲ្យជាប់នៅ ។ កិច្ចតបទី១ ត្រូវឲ្យអ្នកជួយ[illegible]ការពារសត្រូវ ដែលគេបៀតបៀន ទោះខុស ទោះត្រូវ ឲ្យបានសុខនៅ ដោយស្រួលសប្បាយ ។ កិច្ចទី២ ទៀត ឲ្យខំឆ្លាក់ឆ្លៀត ជួយកិច្ចទាំងឡាយ ដែលមានធុរៈ ទោះយប់ទោះថ្ងៃ ត្រូវឲ្យខ្វល់ខ្វាយ ឈប់ការខ្លួនវិញ ។ កិច្ច ទី៣នោះ សំដៅបំពោះ ត្រង់ត្រកូលមិញ ឲ្យតាំងនៅមាំ ឲ្យខំបំពេញ ឲ្យស្ដុកស្ដម្ភវិញ កុំឲ្យរិលរិប កិច្ចទី៤ដាក់ បើលោកមរណៈ ត្រូវឈាបនកិច្ច រូបវែមធ្វើបុណ្យ ជូនដល់

កុំភ្លេច កុំភ្លើស្តាយរើប ទុកទ្រព្យធ្វើអ្វី ។ ព្រោះលោក មានគុណ លោកធ្វើកិច្ចមុន ដល់យើងប្រក្រតី យើងជាប់ បំណុល ព្រោះយើងបុលខ្ចី លោកមានប្រណី ដល់យើង ទាំងឡាយ ។ កាលណាធ្វើបុណ្យ ត្រូវតែដឹងគុណ ឧទ្ទិស ផលផ្សាយ បុណ្យជូនទៅដល់ ទោះយប់ទោះថ្ងៃ គួរឲ្យខ្វល់ ខ្វាយ ផ្សាយឲ្យរឿយ ៗ ។ កុំភាន់ប្រឡំ កុំភ្លើបន្លំ ធ្វើឲ្យ តែឡើយ យកបាយទៅដាក់ យកប្រាក់ទៅជួយ គ្មានខ្មោច ណាមួយ មកយកស៊ីបាន ។ ធ្វើមាន់ធ្វើទា ធ្វើជ្រូកធាភ្លា ជួសដាក់នឹងបាន ហើយពោលប្រកាស ឲ្យអ្នកបាកស្ថាន មកទទួលទាន តាមចិត្តប្រាថ្នា ។ ស្លាប់ជ្រូកមាន់ទា បបួល គ្នីគ្នា ថែមផឹកសុរា ស្រវឹងអឹងកង មិនពិចារណា មិនមាន ប្រាជ្ញា រកហេតុរកផល ៗ មានតែវេរា មានតែវេទនា នាំឲ្យអំពល់ អំពើដែលខុស នោះមិនបេះយល់ ហៅគ្មាន យោបល់ ធ្វើតែតាមគ្នា ។ នោះគឺភ្លើល្ងង់ ងងឹតស្ងួតស្ងុង ព្រោះគ្មានវិជ្ជា មិនដឹងទេឬ សត្វដែលមរណា ស្លាប់ទៅរាល់គ្នា តែងកាន់ភពថ្មី ។ ទៅកើតជាមនុស្ស ទោះស្រីទោះប្រុស

ឬតិរច្ឆានវៃ បើខ្លួនមានបុណ្យ ទៅសួគ៌ាលៃ មិនមាននៅព្រៃ
ទីផ្ទរនោះទេ ។ អ្នកធ្វើយ៉ាងហ្នឹង តាមខ្ញុំរំពឹង ខ្ញុំគិតរិះរេ
មិនត្រូវអ្វីសោះ ខុសអស់ទទេ ធ្វើតាមៗគេ ខុសនឹង
ពុទ្ធដីកា ។ ព្រោះសត្វទាំងឡាយ មានរូបមានកាយ
គប់គ្រងរក្សា ជាសត្វមិនទៀង បំពោះទីណា ព្រោះចាស់ជរា
វិលស្លាប់វិលកើត ។ នៅក្នុងភព៣ ភពតូចធំក្តី មិនទៀង
កំណើត ឥរណានៅស៊ី ឥរណាទៅកើត ឥរណានៅអើត
មើលសំណែនគេ ។ គិតទៅហិសស្ដក ដាក់ត្រៀបគរគោក
គ្មានបរិភោគទេ មានតែអ្នកសែន នោះឯងគេស៊ី ស្រវឹងរក់រី
ថែមឈ្លោះគ្នាផង ។ បើអ្នកធ្វើបុណ្យ នឹងដាប់ទ្រព្យធន
ត្រូវឲ្យទំនង បំពោះដល់សង្ឃ ផែរតាមគន្លង ប្រាប់អ្នកប្រាជ្ញផង
លោកតែងធ្វើមក ។ រូបឧទ្ទិសផល តាមតែសំគាល់ នឹងលៃ
នឹងលក ឈ្មោះជូនឈ្មោះតា មីងមាគរគោក តាមត្រូវការយក
ផ្សាយផលឲ្យទៅ ។ បើយើងឲ្យរបស់ មានរូបស្រស់ៗ
ធ្ងន់ណាស់ជាប់នៅ គួរយកទៅជូន របស់ស្រាលជូនទៅ
នេះគួរតាមផ្លូវ អ្នកប្រាជ្ញសម្តែង ។ ត្រូវកួនតបគុណ កុំធ្វើ

ទូរជន ត្រូវតែខែងវែង គួរតែខិតខំ ធ្វើកិច្ចនេះឯង តាមព្រះសម្តែង ថាជាមនុស្សល្អ ។ ១ទៀតអ្នកឯណា ស្វាមីភរិយា ត្រូវតែអំណរ សង្គ្រោះដល់គ្នា ជាការដ៏ល្អ សុខសាន្តបវរ ឥតមានទុក្ខសោក ។ បំណែកស្វាមី គឺខ្លួនជាប្តី ត្រូវឲ្យពិយោគ សង្គ្រោះភរិយា តាមច្បាប់ដែលលោក សម្តែងទុកមក មាន៥ប្រការ ។ ទី១ស្វាមី ពោលពាក្យស្រដី ទៅនឹងភរិយា ជាពាក្យផ្អែមល្ហែម មិនពោលខ្ញីខ្ញា ពោលតែពាក្យណា ជាការគួរសម ។ ទី២នោះណា មិនឲ្យបរិហារ ពោលពាក្យខ្វីខ្វៃ ទៅនឹងភរិយា ជេរប្រទេចស្តី មើលងាយដល់ស្ត្រីមិនមានអាណិត ។ ទី៣នោះនៃ ត្រូវឲ្យស្វាមី ត្រង់អស់ពីចិត្ត ពីថ្លើមប្រមាត់ មិនបេញទៅផិត គឺថាមិនគិត យកស្ត្រីដទៃ ។ ទី៤នោះឯង សម្បត្តិសម្បែង វត្ថុចាស់ថ្មី មានមាសមានប្រាក់ ឬរបស់អ្វី ប្រគល់ឲ្យស្ត្រី ថែទាំទុកដាក់ ។ រីឯទី៥ បំផុតបណ្តាំ ត្រូវឲ្យចាំជាក់ ត្រូវមានអំណោយ មានមាសមានប្រាក់ របស់ស្លៀកពាក់ ឲ្យដល់ភរិយា ។

មិនត្រូវហ៊្វេងហែង ត្រូវឲ្យហត់បែង ឲ្យតាមទ្រព្យ ដែលខ្លួនរកបាន កំណាញ់រុញរា ឲ្យដល់ភរិយា តាមកំឡាំងទ្រព្យ ។ បំណែកភរិយា បានទទួលការ កិច្ចគួរគំនាប់ តបទៅស្វាមី ដែលប្ដីគេរាប់ ត្រូវតែឲ្យផ្គាប់ ទៅស្វាមីវិញ ។ កុំធ្វើប្រើងម៉ើង កុំធ្វើឫកឡើង មានចិត្តទោមេ្មញ ឃើញប្ដីគេគួរ គួរនឹងគេវិញ ត្រូវតែបញ្ចេញ កិច្ចរបស់ខ្លួនស្នង ។ ទី ១ នោះឯង ត្រូវឲ្យហត់បែង ភោជនាហារផង ឲ្យធ្វើផ្ចិតផ្ចង់ អស់ពីចិត្តហោង រៀបឲ្យទំនង ទាន់កាលវេលា ។ បើមានលោកសង្ឃ ១ អង្គ ២ អង្គ ឬប្រើនអង្គា ឬញាតិសន្ដាន មកជួបជុំគ្នា នៅក្នុងវេលា ពេលគ្រានោះឯង ។ ត្រូវធ្វើឲ្យស្អាត យកចិត្តសង្វាត ឲ្យខំខ្នះខ្នែង ត្រូវឲ្យពិនិត្យ ជាងស៊ីខ្លួនឯង កុំឲ្យចម្បែង ព្រួយដល់ចិត្តប្ដី ។ បំណែកឋាសបាន សមស្លាបព្រាមាន បង្កើះនោះនែ ត្រូវឲ្យដុសលាង សំអាតឃ្មាតខ្មី គ្រប់វត្ថុអ្វី ៗ កុំបីទុកនៅ ។ ដុសលាងរួចរាល់ ឲ្យយកះទៅថ្កល់

លើតុនោះក្ដារ រួចយកកន្សែង សស្អាតជូតទៅ កុំឲ្យទឹកនៅជាប់របស់នោះឯង ។ កុំយកក្រមា សំពត់ឯណា ប្រើប្រាស់តុបតែង ធ្វើការជានិច្ច សំពត់អង្កង់ យកមកបាត់បែង ជូតបានជូតហាស ។ ធាត់ពិសាហើយ កុំរង់រាឡើយ លើកចាប់រហ័ស យកទៅដុសលាង កុំទុកផ្ដេសផ្ដាស ទុកបានទុកហាស ទុកតាមរបៀប ។

(នៅមានតទៀត)

# រឿងធ្មេញដែបណ្ឌិត

(គ)

ឯព្រះមហាក្សត្រគិតក្នុងព្រះរាជហឫទ័យថា អាជៃនេះវាមានប្រាជ្ញាណាស់នឹងជេញប្រាជ្ញវាមិនទាន់ បើដូច្នេះអញនឹងឲ្យវាយកមាន់វាមកជល់នឹងមាន់អញ ហើយអញនឹងឲ្យហាមប្រាមក្នុងនគរអញ កុំឲ្យនរណាឲ្យមាន់ខ្លាំងប្រជល់មកធ្មេញជៃវិញខ្វី បើនរណាឲ្យខ្ចីឬលក់ឲ្យធ្មេញជៃនឹងយកទោសខុសមិនខានឡើយ គិតក្នុងព្រះរាជហឫទ័យដូច្នោះហើយស្តេចក្រសាលសប្បាយទៅ លុះដល់ព្រឹកឡើងស្តេចចេញមកគង់នៅសាលាក្រៅ ទ្រង់ឲ្យហៅអស់នាម៉ឺនមកជួបជុំហើយមានព្រះបន្ទូលបង្គាប់ឲ្យរកមាន់មកជល់នៅមុខព្រះលាន ហើយឲ្យហៅធ្មេញជៃមកដល់ហើយមានព្រះបន្ទូលបង្គាប់ថា អាជៃឯងទៅយកមាន់អាឯងមកជល់នឹងមាន់អញឲ្យបានមកឥឡូវនេះឯង ឯធ្មេញជៃក្រាបថ្វាយបង្គំលាហើយគិតថា ព្រះមហាក្សត្រលោកនឹងផ្ចាញ់ប្រាជ្ញាអញហើយ បើអញនឹងរកទិញមាន់គេ លោកហាមប្រាមមិនឲ្យនរណាលក់ឲ្យឡើយ បើដូច្នេះវាងាយទេ អញនឹងយកមាន់អញនេះឯង គង់តែនឹងជល់ឈ្នះមាន់ព្រះមហាក្សត្រមិនខានឡើយ គិតហើយក៏ដើរទៅដល់ផ្ទះខ្លួនហើយទៅ

ចាប់យកកូនមាន់ដែលទើបនឹងជុះក្រាស់នោះមក ហើយយកសំពត់សរុំមាន់នោះរួចដើរទៅ លុះដល់ព្រះមហាក្សត្រនោះហើយក្រាបថ្វាយបង្គំ ស្តេចទតមើលមិនឃើញធ្មេញជៃយកមាន់មកជល់ដូចទ្រង់បង្គាប់នោះ ក៏មានព្រះបន្ទូលសួរថា អាជៃឯណាមាន់អាឯង ដែលជល់នឹងមាន់អញនោះ ឯធ្មេញជៃក៏ក្រាបទូលថា ឲ្យយកតែមាន់ព្រះរាជទ្រព្យនោះមកនឹងជល់នឹងមាន់ទូលបង្គំជាខ្ញុំ ទើបព្រះមហាក្សត្រត្រាស់ប្រើឲ្យទៅយកមាន់ព្រះរាជទ្រព្យមកដល់ហើយឲ្យលែងមាន់នោះទៅនៅទីដែលប្រជល់នោះឯង ឯអស់មាន់នាម៉ឺនក៏ដាក់ឲ្យជល់គ្នាដោយគូ ៗគប់គ្នា ឯព្រះមហាក្សត្រមានព្រះបន្ទូលតឿនទៅថា អាជៃចាំឥមិនលែងមាន់អាឯងទៅមើល ឯធ្មេញជៃឮព្រះបន្ទូលតឿនដូច្នោះហើយ ក៏យកកូនមាន់ដែលគ្របនឹងសំពត់សដាក់ទៅឲ្យជល់នឹងមាន់ព្រះរាជទ្រព្យ ឯកូនមាន់នោះវាឃើញមាន់ធំនោះហើយវាថាជាមេវា ហើយរត់ទៅត្រសុលក្រោមពោះមាន់ធំនោះ ឯមាន់ធំវាឃើញកូនមាន់នោះរត់មកត្រសុលក្រោមពោះដូច្នោះហើយក៏វារត់ចេញ ឯធ្មេញជៃក៏ស្រែកទះដៃថាមាន់ធំនោះ

បាញ់មាន់អញហើយមិនហ៊ានជល់ទេវារត់ទៅហើយ ឯព្រះមហាក្សត្រក៏ទ្រង់ព្រះក្រោធនឹងធ្មេញជៃ ហើយក៏វិលចូលទៅក្នុងព្រះរាជមន្ទីរវិញ ហើយទ្រង់ព្រះចិន្តាថា បើដូច្នោះអញនឹងប្រជល់ក្របីវិញ ។

មានកាល ១ ថ្ងៃស្ដេចត្រាស់ហៅអស់នាម៉ឺនមក ហើយមានព្រះបន្ទូលហាមអស់នាម៉ឺនថា បើអាជៃវារកខ្ចីក្របីនរណា កុំឲ្យរាស្ត្រណាឲ្យឡើយ បើនរណាឲ្យខ្ចីហើយនឹងមានទោសខុស ទ្រង់ហាមអស់នាម៉ឺនស្រេចហើយស្ដេចក៏យាងចូលទៅក្នុងដំណាក់វិញ ឯធ្មេញជៃនឹងបានដឹងថាស្ដេចហាមដូច្នោះក៏ទេ ។

លុះដល់ព្រឹកឡើងហើយស្ដេចចេញមកគង់នៅសាលាក្រៅហើយប្រើឲ្យយកក្របីព្រះរាជទ្រព្យ ១ ដែលវាឡើងកវាខ្លាំងមកជល់ ឥតមានក្របីឯណានឹងជល់បានឡើយ យកមកដល់ហើយមានព្រះបន្ទូលឲ្យទៅហៅធ្មេញជៃឲ្យយកក្របីមកប្រជល់នឹងក្របីព្រះរាជទ្រព្យកុំឲ្យខានឡើយ ឲ្យមកជាមួយនឹងបម្រើកុំឲ្យខាន ឯបម្រើស្ដាប់ហើយ ក៏ទៅប្រាប់ធ្មេញជៃដូចមានព្រះបន្ទូលបង្គាប់នោះឯង ធ្មេញជៃស្ដាប់ព្រះបន្ទូលដូច្នោះ

ហើយ ក៏ចុះអំពីផ្ទះទៅចាប់យកកូនក្របីទើបនឹងសម្រាល ១០ ថ្ងៃហើយចងកកូនក្របីនោះឯង ដឹកនាំទៅជាមួយនឹងបម្រើ ទៅដល់ហើយក្រាបថ្វាយបង្គំគាល់ ឯព្រះមហាក្សត្រស្ដេចទត មកយល់ក្របីធ្មេញដែដឹកយកមកដល់ ហើយក៏ទ្រង់បង្គាប់ធ្មេញដែថា ឲ្យយកក្របីអាងឯងឲ្យវាជល់នឹងមើល ទើបធ្មេញដែដឹកកូនក្របីទៅទៀបក្របីធំនោះ ហើយក៏លែងទៅឲ្យជល់នឹងក្របីធំនោះឯង ឯកូនក្របីនោះវាមើលទៅឃើញក្របីធំនោះហើយវាស្មានជាមេវា ហើយវារត់ទៅបៅពងប្លោកក្របីនោះ ។

ឯក្របីធំនោះវារសើបវា ក៏ស្ទុះបោលដាច់ខ្សែនឹងចាប់ក៏មិនបាន ឯធ្មេញដែស្រែកថាចាញ់ហើយ ៗ ឯកូនក្របីនោះ ក៏បោលតាមក្របីឈ្មោលនោះឯងវាថាតែមេវា ឯព្រះមហាក្សត្រទតទៅឃើញក្របីព្រះរាជទ្រព្យនោះវាបោលទៅ ហើយឃើញកូនក្របីបោលតាមពីក្រោយដូច្នោះ ក៏អៀនក្នុងព្រះរាជហឫទ័យណាស់ ។

ហើយស្ដេចមានព្រះបន្ទូលអស់នាម៉ឺនឲ្យឃាត់ធ្មេញដែកុំឲ្យចូលក្នុងព្រះរាជវាំងឡើយ ។

បើនរណាឲ្យធ្មេញដែរវាចូលក្នុងវាំង អញនឹងយកទោសខុសមិនលែងឡើយ មានព្រះបន្ទូលហាមហើយស្ដេចចូលទៅក្នុងដំណាក់វិញ ឯអស់នាម៉ឺនហៅធ្មេញជៃមកប្រាប់ថា ដ្បិតស្ដេចទ្រង់បង្គាប់ឲ្យប្រាប់អាជៃឯងថា ពីថ្ងៃនេះទៅដល់ ១០ ឆ្នាំទៀតកុំឲ្យចូលក្នុងព្រះរាជវាំងទៀតឡើយ បើឯងមិនស្ដាប់ឯងនឹងបានសេចក្ដីខុសមិនលែងឡើយ ឯធ្មេញជៃស្ដាប់ហើយក៏ស្ងៀមនៅ ក៏លាដើរទៅផ្ទះអាត្មាវិញ លុះយូរប្រមាណបានបួនថ្ងៃនឹងដល់ថ្ងៃសីល ស្ដេចនឹងនិមន្តលោកគ្រូសង្ឃរាជចូលទៅទេសនា នោះធ្មេញជៃដឹងដូច្នោះហើយដើរទៅអង្គុយក្នុងសាលា ជួបនឹងអស់នាម៉ឺនមុខមន្ត្រីធំតូចជុំគ្នាច្រើន ហើយធ្មេញជៃធ្វើជាស្រដីថា ក្នុងថ្ងៃសីលនេះស្ដេចនឹងហៅអញទៅក្នុងវាំងមិនខានឡើយ ឯអស់នាម៉ឺនឮធ្មេញជៃថាដូច្នោះក៏សើចទាំងអស់គ្នាហើយថា អើអាជៃគេចូលទៅបានមែនហើយ ថាដូច្នោះហើយក៏ចុះដើរទៅផ្ទះរៀង ៗ ហើយឯធ្មេញជៃនោះក៏ទៅផ្ទះវិញ លុះដល់ព្រឹកឡើងនោះជាថ្ងៃសីល ស្ដេចឲ្យទៅនិមន្តលោកគ្រូសង្ឃរាជចូលទៅទេសនាក្នុងព្រះរាជវាំង ឯធ្មេញជៃក៏

ទៅអង្គុយចាំផ្លូវលោកសង្ឃរាជ ឯលោកគ្រូសង្ឃរាជក៏ដើរតាមផ្លូវទៅជួបនឹងធ្មេញដៃ ឯធ្មេញដៃមើលឃើញលោកសង្ឃរាជដើរមកដល់ហើយក៏ក្រាបថ្វាយបង្គំទូលថា សូមលោកគ្រូមេត្តាឈប់សិន ដ្បិតខ្ញុំដឹងការ ១ ជាមន្ទិលខ្ញុំនឹងទូលឲ្យទ្រង់ជ្រាប ឯលោកសង្ឃរាជស្តាប់ហើយក៏ឈប់នៅ ឯធ្មេញដៃក៏ដើរចូលទៅជិតហើយក៏ទូលថា មើលទៅសក់ក្បាលខ្ញុំដូចជាសក់ក្អែក មើលទៅមុខលោកជាងពីត្រពោកខ្ញុំ ឯលោកគ្រូសង្ឃរាជស្តាប់ហើយខ្ញាល់នឹងធ្មេញដៃដៀលមុខដូច្នោះហើយលោកគិតថា អញនឹងទៅទូលមហាក្សត្រ លុះទៅដល់ជួបនឹងស្តេចហើយថ្វាយព្រះពរទូលថា ដ្បិតអាដៃវាស្រដីឲ្យអាត្មាភាពថា មើលទៅសក់ខ្ញុំដូចជាសក់ក្អែក មើលទៅមុខលោកជាងពីត្រពោកខ្ញុំ សូមឲ្យមហារាជយកធ្មេញដៃមកជំរះឲ្យអាត្មាភាពសុខចិត្តផងទើបបាន កុំឲ្យអាដៃវាធ្លាប់ស្រដីឲ្យអាត្មាភាពដូច្នោះទៀត ឯព្រះមហាក្សត្រស្តាប់ព្រះពុទ្ធដីកាលោកគ្រូសង្ឃរាជដូច្នោះហើយ ស្តេចត្រាស់ប្រើមហាឡឹកម្នាក់ឲ្យទៅហៅធ្មេញដៃឲ្យចូលទៅគាល់ស្តេចឲ្យឆាប់កុំយូរឡើយ ឯចៅធ្មេញដៃស្រដីឲ្យលោក

ដូច្នោះហើយទៅអង្គុយនៅសាលាជាមួយនឹងអស់នាម៉ឺនហើយ ថា បន្តិចទៅស្ដេចឲ្យមកហៅអញចូលទៅគាល់មិនខានឡើយ ឯអស់នាម៉ឺនឮធ្មេញជៃស្រដីដូច្នោះហើយ ក៏នាម៉ឺនអស់នោះស្រដីបំអកថា មែនហើយបន្តិចគេចូលទៅគាល់មិនខានឡើយ ឯបម្រើនោះដើរទៅដល់ឃើញធ្មេញជៃហើយប្រាប់ថា ដ្បិតព្រះករុណាមានព្រះបន្ទូលឲ្យហៅធ្មេញជៃឯងទៅឥឡូវនេះជាកុំឲ្យខានឡើយ ឯធ្មេញជៃស្ដាប់ហើយក៏ប្រាប់អស់នាម៉ឺនថា ខ្ញុំថាម្ចាស់នឹងឲ្យហៅខ្ញុំចូលទៅក្នុងវាំងមិនខានឡើយ អស់នាម៉ឺនមិនជឿខ្ញុំថា ធ្មេញជៃក៏ចុះដើរតាមបម្រើចូលទៅក្នុងវាំង ដល់ហើយក្រាបថ្វាយបង្គំស្ងៀមនៅ ឯព្រះមហាក្សត្រទតទៅយល់ធ្មេញជៃដល់មកហើយមានព្រះបន្ទូលសួរថា អាជៃឯងបានស្រដីថាដូចម្ដេចឲ្យលោកសង្ឃរាជមែនឬ ឯធ្មេញជៃថាទូលបង្គំថាមែន តែខ្ញុំនឹងថាជៀលត្នះលោកក៏ទេ ថានោះជាឧបមាឲ្យខ្លួនខ្ញុំទូលបង្គំទេ ដ្បិតលោកចូលក្នុងវាំង ឯខ្លួនខ្ញុំមិនបានចូល បានជាខ្ញុំថា មើលសក់ក្បាលខ្ញុំដូចជាសក់ក្ងោក មើលទៅមុខលោកជាងពីត្រពោកខ្ញុំ ឯព្រះមហាក្សត្រស្ដាប់ហើយមានព្រះបន្ទូល

ទៅនឹងលោកសង្ឃរាជថា លោកកុំខ្វល់នឹងអាដៃឡើយ វាថា ឧបមាខ្លួនវាទេ ហើយស្ដេចបណ្ដេញថា អាដៃឯងកុំចូលមកក្នុងវាំងអញទៀត ធ្មេញដៃស្ដាប់ហើយក៏ថ្វាយបង្គំលាទៅផ្ទះវិញ ស្ដេចមានព្រះបន្ទូលដូច្នោះហើយគិតក្នុងព្រះរាជហឫទ័យថា តតអ្នកឯណានឹងដើញប្រាជ្ញាបាន អញហាមមិនឲ្យវាចូលវាំង តទៀវនេះវាគិតចូលបានមិនមានទើស ដ្បិតប្រាជ្ញាវាមាន ។

ទ្រង់គិតដូច្នោះហើយមានព្រះបន្ទូលថា កុំឲ្យអាដៃវាចូលមកអញទៀតឡើយ អញស្អប់មុខវាណាស់ហើយប្រើមនុស្សម្នាករត់ទៅប្រាប់ធ្មេញដៃ ឯធ្មេញដៃឮហើយក៏ស្ងៀមនៅ ឯផ្ទះធ្មេញដៃនោះនៅខាងផ្លូវផ្សារ មានកាល១ថ្ងៃស្ដេចត្រាស់ប្រាប់អស់នាម៉ឺនថា បីថ្ងៃទៀតស្ដេចនឹងចេញទៅទតផ្សារ ឯអស់នាម៉ឺនក៏និយាយប្រាប់រាស្ដ្រតៗគ្នាទៅដល់ធ្មេញដៃថា បីថ្ងៃទៀតស្ដេចនឹងចេញមកលេងផ្សារហើយចាំទុកក្នុងចិត្ត លុះដល់ថ្ងៃស្ដេចចេញមកនោះ ឯធ្មេញដៃក៏យកកំបោរមកលាបត្រពោកធ្វើជាភ្នែក ធ្វើជាច្រមុះធ្វើជាមាត់ហើយបើកជញ្ជាំងចេញហើយ

ក៏ចាំមើល បើស្ដេចចេញមកទើបបំពិតក្ដិតឲ្យល្អងឃើញ ឯព្រះមហាក្សត្រដល់កំណត់ថ្ងៃស្ដេចនឹងចេញនោះ ស្ដេចក៏ចេញទៅដល់ផ្លូវនឹងដល់ទៅផ្ទះធ្មេញដែនោះហើយ ឯធ្មេញដែក៏ដឹងថា ស្ដេចនឹងដល់មកផ្ទះខ្លួនហើយ ក៏បំពិតត្រពោកបង្ហាញទៅ ឯព្រះមហាក្សត្រស្ដេចយាងមកដល់ផ្ទះធ្មេញដៃហើយ ទតទៅឃើញត្រពោកលាបកំបោរស ៗ ជាភ្នែកជាច្រមុះជាមាត់ ហើយស្ដេចមានព្រះបន្ទូលសួរថា សត្វអ្វីស ៗ ជាភ្នែកជាច្រមុះជាមាត់ដូច្នោះ នោះអស់នាម៉ឺនចូលទៅមើលក៏ឃើញឯធ្មេញដៃគូរត្រពោកបំពិតមកថ្វាយល្អងដូច្នោះហើយ ក៏វិលមកក្រាបទូលថា អាដៃវាលាបកំបោរត្រពោកហើយបំពិតមកឲ្យស្ដេចឃើញ ឯព្រះមហាក្សត្រស្ដាប់ហើយ ក៏មានព្រះបន្ទូលឲ្យហៅអាដៃមកអញនឹងដណ្ដឹងវា ឯអមាត្យស្ដាប់ព្រះបន្ទូលហើយក៏រត់ទៅហៅធ្មេញដៃថា ឪ្យតមានព្រះបន្ទូលឲ្យហៅអាដៃឯង ឯធ្មេញដៃស្ដាប់អមាត្យប្រាប់ដូច្នោះហើយ ក៏ចុះអំពីផ្ទះដើរទៅជាមួយនឹងបម្រើ លុះដល់ហើយក្រាបថ្វាយបង្គំ ឯព្រះមហាក្សត្រស្ដេច

ទតទៅឃើញធ្មេញដៃមកដល់ហើយ ស្តេចមានព្រះបន្ទូលដណ្តឹងថាអាដៃឯងវាថ្វីក៏យកកំបោរលាបត្រពោក ហើយបំតិតមកឲ្យគេមើលដូច្នោះ ទើបធ្មេញដៃក្រាបទូលថា បានជាខ្ញុំទូលបង្គំពុំហ៊ានបង្ហាញមុខម្ចាស់ឃើញខ្លាចខុសនឹងព្រះបន្ទូល បានជាទូលព្រះបង្គំយកកំបោរលាបត្រពោកគួរធ្វើជាមុខថ្វាយបង្គំសូមជ្រាប ស្តេចស្តាប់ហើយក៏ទ្រង់ព្រះក្រោធដ្បិតធ្មេញដៃបង្ហាញត្រពោកមុខឲ្យខ្មាសអស់នាម៉ឺនមុខមន្ត្រីធំតូចផងទាំងឡាយដែលហែនោះ តែនឹងយកទោសធ្មេញដៃមិនបាន ។

(នៅមានត)

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT

เล่ม

๑๐-๑๑-๑๒

N° Du 2632

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ៨

ខែ ១០, ១១, ១២, រួមគ្នា

ក្បួនសៀវភៅនេះបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

PER 933

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៧៩

គ. ស. ១៩៣៦

ÉCOLE FRANÇAISE D'EXTRÊME ORIENT
BIBLIOTHÈQUE

# បញ្ជីរឿង


លេខទំព័រ

១ — បរិវត្តកមនាគម ដំណើរទង់គ្នារលោ ក្នុងដែនកូស័ងស៊ីន ខែត្រត្រាវិញ ព្រះសាសនសោភ័ណ ជ - ណាត រៀបរៀង (ត) ................ ១

២ — ខេមាខេមសរណកថា ព្រះមហាពិទូរក្រសេម ឥន្ទារង្សបណ្ឌិតរៀបរៀង (ត) . ៣៣

៣ — សាសនិកទ ពាក្យកាព្យ ឃុនស្នេហា ហ៊ុម តែង (តចប់) ....... ៤៣

៤ — រឿងធនញ្ជ័យបណ្ឌិត សេចក្ដីចាស់ (ត) ............... ៥៣


# រូបក្រៅរឿងផ្សេង ៗ


១ — ដួងសម្រិទ្ធិ ១ ស្ដេចភូមាឃាត់ទុកនៅវត្តបតុមាវតី ក្រុងអមរបុរ ..... ៣១

២ — កូនក្មេងភូមាតែងខ្លួនរៀបហែទៅបួស ................ ៤១

# TABLE DES MATIÈRES


Pages

I. Tournée en Cochinchine de M. le secrétaire général de l'Institut Bouddhique (Travinh)........................ 1

II. Khemā Khema Saranakatha ou Religions, refuge des hommes par Préas Maha Pitou Krasem à la Bibliothèque Royale (à suivre).................................. 33

III. Sāsanivāda poème ou conseils aux hommes d'après la Morale Bouddhique par Khhunsnehā Him............. 43

V. Conte populaire cambodgien inédit:
Histoire de Thmenh-Chhey (à suivre).................. 53


## HORS TEXTE:


I. Cloche en bronze de la Pagode de Patadawgyi-Amarapura (Birmanie)................................................ 31

II. Futurs novices devant les offrandes qu'ils vont recevoir Pagan (Birmanie)........................................ 41

# បរិវដ្តគមនាគមដំណើរអន់ត្បូរណោ

## ស្រុកកូសាំងស៊ីន

# ខេត្តត្រាវិញ

ថ្ងៃអង្គារ ១៩ ធ្នូ ១៩៣៣ (៣ កើតខែបុស្ស)

ម៉ោង ១៥ ប្រជុំនៅវត្តកំពង់[១] ឃុំឡង់ផឹក ខណ្ឌត្រាវិញ (នៅក្នុងទីរួមខេត្ត) ។ វត្តនេះមានសាលារៀន, គ្រូបង្រៀនឈ្មោះ គៀង-លិប មានសញ្ញាបត្រប្រថមសិក្សាខ្មែរ បេញពីសាលារៀនទីរួមខេត្តត្រាវិញ ក្នុងឆ្នាំ ១៩២៩, មានសិស្សកុមារ ២៦ នាក់ កុមារី ១៤ នាក់ ។ លោកមន្ត្រីបារាំងម្នាក់ឈ្មោះ ឌុយរ៉ង់ត៍ ជាអ៊ីងស្ប៉ិកទ័រក្រសួងសិក្សាធិការខេត្តត្រា-វិញក៏អញ្ជើញមកដែរ, ព្រមទាំងគ្រូបង្រៀនច្រើននាក់ក៏មកក្នុងទីប្រជុំនេះ; មានមនុស្សមកប្រជុំប្រហែល ៧០ នាក់ ។ ក្នុងឱកាសសន្និបាតនេះ បានពិគ្រោះប្រឹក្សាសម្រេចអំពីពេលនៃការសិក្សាក្នុងសាលារៀនរាល់វត្ត យល់ព្រមថា "សាលារៀនគ្រប់វត្តក្នុងខេត្តត្រាវិញនេះ ពេលព្រឹក ត្រូវចាប់ការរៀនពីត្រឹមម៉ោង ៧ទៅទល់នឹងម៉ោង ៩ ត្រូវឈប់ ពីព្រោះក្មេងសិស្សវត្ត

---

១ ព្រោះវត្តនេះកាលពីយូរមកហើយ មានលោកចៅអធិការ ១ រូបឈ្មោះមាស ពូកយួនហៅ អុងមាក ។

មានកិច្ចត្រូវចាត់ចែងបង្ហាត់ប្រគេនលោក តាមសណ្ដាប់រៀងមក ពេលល្ងាច ត្រូវចាប់ការរៀនពីត្រឹមម៉ោង ១៣ ដល់ម៉ោង ១៧ កន្លះ" ។

ថ្ងៃពុធ ២០ ធ្នូ ១៩៣៣ (៤ កើតខែបុស្ស)

ម៉ោង ៨ (ព្រឹក) ចេញពីទីរួមខេត្តទៅវត្តខ្ទឹង ក្នុងឃុំង៉ៀកហ្វា ខណ្ឌត្រាំក្ញូ (នៅខាងទិសពាយ័ព្យទីរួមខេត្ត), ម៉ោង ៩ ដល់វត្តខ្ទឹង ។ លោកអាចារ្យធន់ នៅវត្តពីសី (ជាវិន័យធរខេត្តត្រាវិញ) ទទួលភារៈជាអ្នកនាំផ្លូវជូនយើង រាល់ថ្ងៃ) ។ វត្តខ្ទឹងនេះមានសាលារៀន, គ្រូបង្រៀនឈ្មោះ សើង-ពុម មានសញ្ញាបត្រសាលាវត្តលង្កាពីក្នុងឆ្នាំ ១៩២៩, សាលារៀននេះមានសិស្សកុមារ ២៩ នាក់ កុមារី ២ នាក់ ។ កាលដែលចូលទៅដល់វត្តភ្លាម យើងបានចូលទៅក្នុងសាលារៀន បានឲ្យពួកសិស្សសាលាមើលសៀវភៅ, ឲ្យឆ្លើយបំណោទលេខ រួចហើយទើបចូលទៅកាន់ទីប្រជុំ ៗ នេះមានមនុស្សប្រហែលជាង ១០០ នាក់ ។ លុះធ្វើការរួចស្រេចហើយ លោកគ្រូហៅអធិការវត្តខ្ទឹងបានជំរាបលោកអគ្គលេខាធិការថា ពួកបព្វជិតបេវាគុត្តេរទាំង

អស់ក្នុងខែត្រត្រាវិញនេះ បានប្រជុំគ្នានៅវត្តកំពង់ម្ដងហើយ, ប្រឹក្សាយល់ព្រមគ្នាថា នឹងគិតបង្កើតឲ្យមានការសិក្សាខាងធម៌វិន័យព្រះពុទ្ធសាសនាឲ្យបានគ្រប់វត្ត, នឹងបង្កើតឲ្យមានសាលា ១ នៅវត្តកំពង់, ព្រោះវត្តនេះនៅក្នុងទីរួមខែត្រ, សាលានោះសម្រាប់ប្រជុំប្រឡងធម៌វិន័យក្នុង ១ ឆ្នាំម្ដង រៀងរាល់ឆ្នាំទៅ; ប៉ុន្តែក្រែងការដែលផ្ដើមគិតនោះ បែរជាមិនបានសម្រេចទៅវិញ ព្រោះក្នុងសម័យនេះអ្នកស្រុកក្រីក្រណាស់; បើប្រសិនជាពុទ្ធសាសនបណ្ឌិត្យជួយទំនុកបំរុង ជ្រោងការនោះឲ្យបានសម្រេចឡើងនោះយើងមានអំណរណាស់ ។

ម៉ោង ១១ កន្លះ ចេញពីវត្តខ្ទឹងទៅមើលសាលារៀននៅវត្តគោក ក្នុងឃុំងៀកហ្វ៉ា ខណ្ឌត្រាភ្វ (ដោយលោកចៅអធិការវត្តនេះសុំឲ្យឆ្លៀតចូល) ។ គ្រូបង្រៀនសាលានេះឈ្មោះត្រឹង-ធឹង ឥតសញ្ញាបត្រទេ ប៉ុន្តែបានរៀនអក្សរបារាំងនៅសាលាទីរួមខែត្រត្រាវិញដល់ថ្នាក់ឧត្តម (គួរស៊ុប៉េរីយើរ), សាលានេះមានសិស្សកុមារ ៤០ នាក់ កុមារី ២ នាក់ ។ លោកគ្រូចៅអធិការបានសង់សាលា ១ ផ្សេងទៀតសម្រាប់ឲ្យ

បង្រៀនបាឡី: លោកអាចារ្យ ឋាប់-ភឿន ជាសិស្សរបស់លោក (ដែលបានទៅរៀនឯស្រុកសៀមចំនួន ១០ ឆ្នាំ ប្រឡងបានសញ្ញាបត្រទីអ្នកធម្មជាន់ត្រី, សព្វថ្ងៃត្រឡប់មកនៅៗវត្តគោកនេះ) ជាអ្នកបង្រៀនបាឡីក្នុងសាលានេះ ។ លោកបានសាងទូ ១ ធំ មានបែបភាពប្លែកសម្រាប់ដាក់ព្រះត្រៃបិដកដែលពុទ្ធសាសនបណ្ឌិត្យបាត់ការបោះពុម្ពសព្វថ្ងៃនេះ ។ យើងបាននិយាយពន្យល់ដល់ពួកខ្មែរដែលមកប្រជុំក្នុងវត្តនេះតាមសមគួរ ហើយក៏ត្រឡប់មកឯទីរួមខេត្តវិញ ។

ម៉ោង ១៤ បេញទៅវត្តសាលាទ្រ (ពាក្យធម្មតាហៅថាវត្តឫទល់ ក្នុងឃុំមីភឿង ខណ្ឌត្រាញីវ (នៅខាងត្បូងទីរួមខេត្ត). ម៉ោង ១៥ កន្លះដល់វត្តនេះៗមិនទាន់មានសាលារៀនទេ ។ មានពួកបព្វជិតវត្តក្រៅ ២ វត្តមកប្រជុំក្នុងទីនេះ, មានមនុស្សមកប្រជុំប្រហែល ១០០ នាក់ ។ លុះធ្វើការរួចស្រេចហើយយើងត្រឡប់មកឯទីរួមខេត្តវិញ ។

ថ្ងៃព្រហស្បតិ៍ ២៨ ដេសម ១៩៣៣ (៥ កើតខែបុស្ស)

ម៉ោង ៨ (ព្រឹក) ចេញទៅវត្តបៃតីយ (ក្លាយពីពាក្យសំស្ក្រឹតថា "(ចៃត្យ)", បាឡីថា "(ចេតិយ)": យួនហៅជួថាប) ក្នុងឃុំតាប់សឹង ខណ្ឌង៉ាយហ្វាបឿង (នៅខាងត្បូងទីរួមខែត្រ); ម៉ោង ៩ កន្លះទៅដល់វត្តនេះ ។ យើងបានចូលទៅមើលសាលារៀនជាមុន; គ្រូបង្រៀនសាលានេះ ជាបព្វជិតឈ្មោះ គីម-ទិត មានសញ្ញាបត្រសាលាវត្តលង្កាពីក្នុងឆ្នាំ ១៩៣១, សិស្សសាលាវត្តនេះមាន ២២ នាក់ ។ មានលោកភិក្ខុ ១ រូបទៀតឈ្មោះ ថាច់-មាឃ មានសញ្ញាបត្រសាលាវត្តលង្កាពីក្នុងឆ្នាំ ១៩៣១, នៅក្នុងវត្តនេះដែរ, នៅទំនេរមិនទាន់បានធ្វើគ្រូបង្រៀននៅឡើយ ។ មានពួកបព្វជិតវត្តក្រៅ ១ វត្តមកប្រជុំក្នុងវត្តនេះដែរ, មានមនុស្សមកប្រជុំប្រហែល ៧០ នាក់ ។ មានខ្មែរជាចំណុះវត្តនេះប្រហែល ២០០ ផ្ទះ, ប៉ុន្តែមើលទៅប្រហែលជាមិនសូវត្រិះរិះការនឹងឲ្យកូនចូលរៀនក្នុងសាលាទេដឹង បានជាសាលារៀនវត្តនេះមានសិស្សតែ ២២ នាក់ប៉ុណ្ណោះ? លុះធ្វើការស្រេចហើយ យើងត្រឡប់មកឯទីរួមខែត្រវិញ ។

ម៉ោង ១៤ ចេញទៅវត្តកញ្ជោងភ្នំពេញ ក្នុងឃុំទឹកកង់ ខណ្ឌជាំយឡង់ (នៅខាងឯលិចទីរួមខែត្រ) ។ គ្រូបង្រៀនសាលាវត្តនេះឈ្មោះ ហាប់-សុខ មានសញ្ញាបត្រសាលាវត្តលង្កា ពីក្នុងឆ្នាំ ១៩៣២, មានសិស្សសាលា ៥០ នាក់ ។ មានពួកបព្វជិតវត្តកញ្ជោងកំពង់លាវ ១ មកប្រជុំក្នុងទីនេះដែរ, មានមនុស្សប្រហែល ៨០ នាក់ ។ លុះធ្វើការស្រេចហើយ យើងត្រឡប់មកចូលវត្តផ្សារដូង ព្រោះលោកអាចារ្យ ឈឿក-លឿក មានសញ្ញាបត្រសាលាបាឡីជាន់ខ្ពស់ក្រុងភ្នំពេញ ដែលសព្វថ្ងៃនៅៗវត្តនេះ, បានសុំឲ្យយើងឆ្លៀតចូលវត្តនេះផង ។ មានមនុស្សមកប្រជុំចាំយើងប្រហែលជាង ១០០ នាក់, សំដែងសេចក្ដីរីករាយពន់ពេក ។ លោកអាចារ្យហាប់ វ៉ិច មានសញ្ញាបត្រសាលាបាឡីជាន់ខ្ពស់ក្រុងភ្នំពេញ ដែលសព្វថ្ងៃនេះជាចៅអធិការវត្តផ្សារក្រោម (ជិតគ្នានឹងវត្តផ្សារដូងនេះ) ក៏មកជួបនឹងយើងក្នុងទីប្រជុំនេះដែរ ។ លុះសម្រេចកិច្ចការក្នុងទីប្រជុំនេះរួចហើយ យើងត្រឡប់មកឯទីរួមខែត្រវិញ ។

ថ្ងៃសុក្រ ២២ ដេសម ១៩៣៣ (៦កើតខែបុស្ស)

ម៉ោង ៨ (ព្រឹក) ចេញទៅវត្តប្ញូវ (ឃ្លួនហៅជ្រៃត្រាគ) ក្នុងឃុំទាញ់ផ្អៀង ខណ្ឌម៉ាយហ៊្វាបឿង (នៅខាងត្បូងទីរួមខេត្ត); ម៉ោង ៩ កន្លះដល់វត្តនេះ ៗ មានសាលារៀន កើតដោយកំឡាំងរបស់លោកចៅអធិការនឹងពួកបាសកបំណុះវត្ត, ប៉ុន្តែសព្វថ្ងៃនេះឈប់, ព្រោះគ្រូបង្រៀនមានជម្ងឺឈឺជាប់ នឹងបង្រៀនមិនកើត: គ្រូបង្រៀនសាលានេះឈ្មោះសើន-អិន ឥតសញ្ញាបត្រទេ តែបានទៅនៅរៀនរបៀបសិក្សានៅវត្តកន្លែងសេះក្នុងខេត្តនេះបំនួន ២ ឆ្នាំ ។ ក្នុងទីប្រជុំនេះមានពួកបព្វជិតវត្តក្រៅ ៣ វត្តមកផង, មានមនុស្សប្រហែលជាង ៩០ នាក់ ។ លុះធ្វើការក្នុងទីប្រជុំសព្វគ្រប់ហើយយើងធ្វើភត្តកិច្ចនៅវត្តនេះ ។

ម៉ោង ១២ ចេញពីវត្តប្ញូវនេះ ឆ្ពោះទៅវត្តជ្រោយទន្សារក្នុងឃុំជាមួយគ្នា (ដោយលោកចៅអធិការវត្តនេះសុំឲ្យឆ្លៀតទៅ); ម៉ោង ១២ កន្លះដល់វត្តនេះ ។ លោកចៅអធិការព្រមទាំងពួកបាសកជាបំណុះវត្តបានសង់សាលារៀន ១ ធំ ២ ជាន់ ធ្វើដោយឥដ្ឋ, គិតដីថ្លៃទាំងគ្រឿងប្រដាប់សម្រាប់សាលាផងអស់

បំនួន ៣ ពាន់ ៣ រយរៀល ។ ឈ្មោះអាចារ្យ គីម-ល័ក្ខណ៍ កាលនៅជាបព្វជិតនៅឡើយ បានទៅនៅរៀនព្រះបរិយត្តិធម៌ ឯវត្តឧណ្ណាលោមក្រុងភ្នំពេញយូរឆ្នាំ, លុះត្រឡប់មកវិញបាន ធ្វើជាគ្រូបង្រៀននៅវត្តនេះ ១៣ ឆ្នាំមកហើយ ឥតនិច្ចភត្តខែទេ, ទាំងសាលានេះសោតក៏ឥតទាន់មានការទំនុកបំរុងអ្វីអំពីរាជការ ទេ, ការសិក្សាក្នុងវត្តនេះកើតអំពីកំឡាំងរបស់លោកចៅអធិការ នឹងអ្នកស្រុក ។ សាលារៀននេះមានសិស្សកុមារ ៣០ នាក់ កុមារី ១៥ នាក់; មានសិស្សកុមារីម្នាក់ឈ្មោះ ឋាប់-ញឹក អាយុ ១៣ ឆ្នាំ ប្រឡងបានសញ្ញាបត្រប្រឋមសិក្សាខ្មែរពីសាលា សិក្សាធិការទីរួមខែត្រត្រាវិញ ក្នុងឆ្នាំ ១៩៣៣ នេះ; កុមារីនេះ មានបំណោះល្មមធ្វើជាគ្រូបង្រៀនពួកកុមារីផងគ្នាបាន ។ ពួក ខ្មែរក្នុងទីដំបន់នេះទាំងចាស់ទាំងក្មេង ច្រើនចេះធម៌អាថ៌ខាងព្រះ ពុទ្ធសាសនាគ្រាន់បើ, អាស្រ័យគ្រូបង្រៀនឈ្មោះ គីម-ល័ក្ខណ៍ ជាអ្នកមានព្យាយាមមួនមាំខំប្រឹងដាស់តឿនរំឭកណែនាំឲ្យរៀន សូត្រ ។ លុះធ្វើកិច្ចការសព្វគ្រប់ហើយ យើងត្រឡប់មក ឯទីរួមខែត្រវិញ ឈប់សម្រាកបន្តិច ។

ម៉ោង ១៤ ចេញទៅវត្តក្នុង ក្នុងឃុំហ៊ូឃ្លើយ ខណ្ឌត្រាំញីវ (នៅខាងកើតទីរួមខេត្ត) ។ គ្រូបង្រៀនសាលាវត្តក្នុងនេះឈ្មោះ សើង-សយ (ជាបព្វជិត) បានទៅនៅរៀនព្រះបរិយត្តិធម៌ឯស្រុកសៀម ៨ ឆ្នាំ ប្រឡងឯស្រុកសៀមបានសញ្ញាបត្រទីអ្នកធម្មជាន់ត្រី ។ សាលារៀននេះកើតឡើងអំពីកំឡាំងលោកចៅអធិការនឹងអ្នកស្រុក, រាជការពិតទាន់បានទំនុកបំរុងសោះទេ; សព្វថ្ងៃនេះមានសិស្សកុមារ ៤២ នាក់ កុមារី ៨ នាក់, សិស្សទាំងនេះមានសេចក្ដីឈ្លាសវៃគ្រាន់បើ ។ ក្នុងទីសន្និបាតនេះមានពួកបព្វជិតវត្តក្រៅ ៣ វត្តមកប្រជុំផង, មានមនុស្សមកប្រជុំប្រហែល ១៥០ នាក់ ។

លុះស្រេចកិច្ចការក្នុងទីប្រជុំនេះហើយ យើងចេញមកវិញឆ្ពោះទៅវត្តកំពង់ខ្វាយ ក្នុងឃុំឡង់ឹក ខណ្ឌត្រាំញីវ (ដោយលោកចៅអធិការវត្តនេះសុំឲ្យឆ្លៀតទៅ) ។ មានលោកភិក្ខុ ១ រូបឈ្មោះគិម-ជីវ មានសញ្ញាបត្រសាលាវត្តលង្កាក្នុងឆ្នាំ១៩៣៣ នេះ, ប៉ុន្តែវត្តនេះមិនទាន់មានសាលារៀននៅឡើយទេ; លោកចៅអធិការត្អូញថា អ្នកស្រុកកំពុងទ័លក្រណាស់ នឹងគិតសង់

សាលារៀនមិនកើត ។ ក្នុងទីប្រជុំនេះមានមនុស្សប្រហែល ៧០ នាក់ ។ លុះបានធ្វើកិច្ចការសព្វគ្រប់ហើយ, ម៉ោង ២០ យើងត្រឡប់មកឯទីរួមខែត្រវិញ ។

ថ្ងៃសៅរ៍ ២៣ ធ្នូ ១៩៣៣ (៧ កើតខែបុស្ស)

ម៉ោង ៧ កន្លះ (ព្រឹក) ចេញទៅវត្តជ្រោះរាំង ក្នុងឃុំឡង់សឹង ខណ្ឌរវិញហ្លួយ (នៅខាងត្បូងទីរួមខែត្រ), ម៉ោង៩ ទៅដល់វត្តជ្រោះរាំង ។ មានពួកបព្វជិតវត្តក្រៅ ៥ វត្តមកក្នុងទីប្រជុំនេះ ។ មានមនុស្សប្រហែល ៨០ នាក់ ។ លុះយើងធ្វើកិច្ចការសព្វគ្រប់ហើយ, លោកព្រះវិន័យធរឈ្មោះ ឋាប់-ឯក (ជាគេវាទារបស់សម្ដេចព្រះមហាសង្ឃរាជទ្រង់ព្រះនាមទៀង ក្នុងព្រះកោដ្ឋ) ដែលធ្លាប់នៅឯវត្តឧណ្ណាលោមក្រុងភ្នំពេញយូរឆ្នាំ ធ្លាប់ស្គាល់ស្និទ្ធស្នាលនឹងខ្ញុំមកអស់កាលយូរ, សព្វថ្ងៃនេះមកនៅធ្វើជាចៅ-អធិការវត្តបុងមេសថ្មី, បានថ្វាយលោកអគ្គលេខាធិការសុំឲ្យមេត្តាឆ្លៀតអញ្ជើញទៅឯវត្តលោកបាន ១ ម៉ោង, ដើម្បីឲ្យបានឃើញសាលារៀនរបស់លោកផង ។

ម៉ោង ១២ យើងចេញពីវត្តផ្អោររាំងទៅវត្តបុងមេសថ្មី ក្នុងឃុំញីទ្រើង ខណ្ឌវិញហ្លើយ ។ វត្តនេះធំទូហេយ ស្អាតបាតណាស់; លោកព្រះវិន័យធរថាប់-ឯក ព្រមទាំងពួកបាសកបំណុះវត្តបានសង់សាលារៀនមួយមានទ្រង់ទ្រាយសមរម្យ, គិតដំឡៃទាំងគ្រឿងប្រដាប់សម្រាប់សាលាផងអស់ជាង ៨១០ រៀល, ធ្វើហើយស្រេចចំនួន ២ ឆ្នាំមកហើយ; សព្វថ្ងៃនេះលោកភិក្ខុឈ្មោះ ថាប់-សុខ មានសញ្ញាបត្រសាលាបាលីវត្តលង្កាពីក្នុងឆ្នាំ ១៩៣១, ធ្វើជាគ្រូបង្រៀននៅសាលានេះ, មានសិស្សកុមារ ៣២ នាក់ កុមារី ១០ នាក់, សិស្សទាំងនេះមានសេចក្តីឈ្លាសវៃគ្រាន់បើ ។ ពួកភិក្ខុសាមណេរក្នុងវត្តនេះ មានសណ្តាប់ធ្នាប់សុភាពរាបសា ស្លៀកដណ្តប់ចុះបែបរបៀបសមណសារូបស្រួលបួលណាស់ ។ លោកអគ្គលេខាធិការបានថតរូបពួកបព្វជិត ១ លើក រួចហើយចេញពីវត្តបុងមេសតាមផ្លូវដដែលមកវិញ ។

លុះចេញពីវត្តបុងមេសមក យើងបង្ហួសឆ្ពោះទៅវត្តបេកជ្រៃក្នុងឃុំគីមហ្វា ខណ្ឌវិញហ្លើយ (ព្រោះពីថ្ងៃម្សិល លោក

ចៅអធិការបានទៅជួបនឹងយើងឯទីរួមខែត្រត្រាំវិញ សុំឲ្យយើងឆៀតចូលទៅមើលសាលារៀននៅវត្តលោកផង). ម៉ោង ១៤ កន្លះទៅដល់វត្តបេកជ្រិ ។ វត្តនេះមានសាលារៀនធ្វើដោយឥដ្ឋប្រក់ក្បឿងស្រទបបេក ជាសាលាធំទូលាយ, កើតដោយកំឡាំងរបស់លោកចៅអធិការនឹងអ្នកស្រុក; លោកភិក្ខុឈ្មោះ ឋាប់-ឆេង មិនមានសញ្ញាបត្រទេ, ធ្វើជាគ្រូបង្រៀននៅសាលានេះ, មានសិស្សកុមារ ៣០ នាក់ កុមារីតែ ១ នាក់ ។ លោកចៅអធិការត្អូញថា បានប្តឹងលោកអ័ងស្ប៉ិកទ័រក្រសួងសិក្សាធិការច្រើនដងហើយសុំឲ្យរាជការជួយទំនុកបំរុងសាលារៀននេះផង, ក៏មិនទាន់មានឃើញទំនុកបំរុងអ្វីនៅឡើយ ។ ក្នុងទីសន្និបាតនេះ មានពួកបព្វជិត ៥ វត្តជា ៦ នឹងវត្តនេះ, ទាំងបព្វជិតទាំងគ្រហស្ថប្រហែលជាង ២០០ នាក់ មកប្រជុំ ។

ម៉ោង ១៥ កន្លះ យើងចេញពីវត្តបេកជ្រិត្រឡប់មកឯទីរួមខែត្រវិញ ហើយបង្ហួសទៅវត្តអង្គ ក្នុងឃុំហ្លៀងសា ខណ្ឌត្រាំក្ង (នៅខាងឯលិចទីរួមខែត្រ); ម៉ោង ១៦ កន្លះទៅដល់វត្តអង្គ ។ វត្តនេះមានសាលារៀន, គ្រូបង្រៀនឈ្មោះ ឋាប់-ស៊ុំ មាន

សញ្ញាបត្រសាលាវត្តលង្កាពីក្នុងឆ្នាំ ១៩២៩, មានសិស្សកុមារ ៣០ នាក់ កុមារី ២ នាក់ ។ មានពួកបព្វជិតវត្តក្រៅ ៨ វត្ត មកប្រជុំផង. ក្នុងទីប្រជុំនេះមានមនុស្សប្រហែល ១៧០ នាក់ ។ ក្នុងវត្តអង្គនេះមានបុរាណវត្ថុព្រមទាំងទេវរូបខ្លះខាងប៉ែកសាសនាព្រាហ្មណ៍ បង្គួលភ័ស្តុតាងឲ្យឃើញថាពីដើម ជាកន្លែងប្រតិស្ឋាននៃសិវលិង្គនឹងទេវរូបផ្សេង ៗ ដែលបុព្វបុរសពីក្នុងសម័យបុរាណរបស់ខ្មែរយើងគោរពប្រណិប័តន៍មក ។ នៅត្រង់ជ្រុងទិសអគ្នេយ៍វិហារវត្តនេះ មានខ្ទមតូច ១ បែបសណ្ឋានដូចខ្ទមអ្នកតា ឃើញមានព្រះពុទ្ធរូបថ្មបុរាណអង្គតូច ៗ គេដាក់ផ្ដាល់នឹងដីប្រឡូកប្រឡល់ជាមួយនឹងទេវរូប ។ ខ្ញុំបានសួរគេថា ហេតុម្ដេចក៏មិនយកព្រះពុទ្ធរូបទាំងនេះទៅដំកល់ក្នុងវិហារឬក្នុងទីកុដិសាលាផ្សេងទៅ? គេប្រាប់ថា មិនហ៊ានយកចេញពីទីនេះទេ ព្រោះចាស់បុរាណធ្លាប់តែដំកល់ត្រង់ទីនេះយូរអង្វែងណាស់មកហើយ...។ ខ្ញុំបាននិយាយពន្យល់ថា ធ្វើដូច្នេះមិនគួរទេ ដ្បិតព្រះពុទ្ធរូបជាឧទ្ទេសិកចេតិយ ជាទីគោរពរបស់យើងអ្នកកាន់ព្រះពុទ្ធសាសនា, បើយើងឃើញថាស្ថិតនៅក្នុងទីមិន

សមគួរយ៉ាងនេះហើយ ត្រូវតែយើងមានសេចក្ដីគោរព នាំគ្នាយកទៅដំកល់ក្នុងទីដែលឧត្ដមជាងនេះទៅ ទើបសមគួ... ។ លុះនិយាយពន្យល់សព្វគ្រប់ទៅ អ្នកទាំងនោះក៏នៅស្ងៀម ។ ក្នុងខែត្រត្រាវិញ (ព្រះត្រពាំង) ឃើញត្រង់ទីដីបន់នេះជាកន្លែងចាស់ជាងទីឯទៀត បានជាវត្តនេះមាននាមថា "វត្តអង្គ" ដូច្នេះ ពីព្រោះមានស្រះបុរាណតូច ១ នៅខាងទិសអគ្នេយ៍វិហារ របៀបស្រដៀងគ្នានឹងពួកស្រះនៅទីដីបន់នគរវត្ត ឬនៅទីឯទៀតក្នុងកម្ពុជរដ្ឋ ដែលពួកអ្នកកាន់សាសនាព្រាហ្មណ៍សន្មតថាជាស្រះស័ក្តិសិទ្ធិ គេហៅថា "អង្គ" ដោយហេតុមានរូបអង្គជាតិព្រះឥស្សូរ (សិវលិង្គ) ដំកល់នៅទីជិតនោះ ។

លុះស្រេចកិច្ចការក្នុងទីប្រជុំនេះហើយ យើងចេញពីវត្តអង្គនេះមកវិញ, បានឆ្លៀតចូលទៅក្នុងវត្តស្រះនាគ បរុំហឿងហ៊ា ខណ្ឌត្រាភូ ដែលនៅជិតផ្លូវរាជការ (ពីព្រោះលោកចៅអធិការវត្តនេះសុំឲ្យយើងឆ្លៀតចូលបាន១ម៉ោង) ។ គេប្រាប់យើងថាវត្តនេះ, កាលពីក្នុងឆ្នាំ ១៩៣១ មានសាលារៀនម្ដងហើយ, ប៉ុន្តែដល់មិនឃើញរាជការទំនុកបំរុងសោះ, អ្នកស្រុកទំលក្រ

ណាស់ មិនមានប្រាក់កាសនឹងទំនុកបំរុង, ក៏បែរជាឈប់បង្អង់ទៅសិន ។ យើងបាននិយាយរំឭកពន្យល់ថា ក្នុងសម័យនេះរាជការកំពុងទ័លប្រាក់កាសណាស់, គួរតែយើងខំទ្រាំប្រឹងប្រែងទំនុកបំរុងការសិក្សាខ្លួនយើងខ្លះបណ្ដើរៗសិនទៅ, ដល់រាជការធូរទូលាយប្រាក់កាសជាងសព្វថ្ងៃនេះបន្តិចឡើង ក៏គង់តែនឹងជួយទំនុកបំរុងមិនខានទេ...។ មានបាសកខ្លះឆ្លើយតបមកវិញថា យើងខ្ញុំដឹងច្បាស់ថាសព្វថ្ងៃនេះរាជការទ័លក្រមែនហើយ ប៉ុន្តែបើខាងសាលារៀនអក្សរយួនមានស្ទើរតែនឹងគ្រប់ទីដិបន់ ម្ដេចក៏រាជការបេះទ្រាំទ្រជួយទំនុកបំរុងបាន? គួរតែរាជការអាណិតមេត្តារំលែកការទំនុកបំរុងនោះមកឲ្យយើងជាតិខ្មែរខ្លះផងទើបសម, ព្រោះប្រាក់ពន្ធដារយើងក៏បង់ជូនរាជការរាល់ឆ្នាំរាល់ដូរស្មើៗគ្នានឹងជាតិយួនដែរ...។ កាលដែលអ្នកទាំងនេះតវ៉ាដូច្នេះខ្ញុំក៏បាននិយាយពន្យល់សព្វគ្រប់ល្មមស្ដាប់យល់បាន ។

លុះចេញពីវត្តស្រះនាគមក យើងហួសតាមផ្លូវបែកចូលទៅវត្តបុងទ័ព ទៅក្នុងឃុំហឿងហ្វា ខណ្ឌត្រាភូដែរ (ព្រោះលោកចៅអធិការវត្តនេះសុំឲ្យយើងឆ្លៀតចូលបាន១ស្របក់) ។

មានមនុស្សមកប្រជុំចាំយើងប្រហែលជាង ២០០ នាក់ ។ គេប្រាប់ថា នៅភូមិជិតវត្តចុងទំពនេះ មានខ្មែរចូលសាសន៍គ្រិស្ត (កាតូលិក) ប្រហែលជាង ១០ ផ្ទះ ។ ក្នុងទីប្រជុំនេះ ខ្ញុំបាននិយាយពន្យល់អំពីលទ្ធិសាសនាផ្សេងៗ ហើយពន្យល់អំពីលទ្ធិព្រះពុទ្ធសាសនាដែលនាំមនុស្សអ្នករៀនចេះប្រាកដ ឲ្យមានប្រាជ្ញាល្អ, ស្គាល់ការពិត, ស្គាល់គុណស្គាល់ទោសច្បាស់, មានសេចក្ដីស្លូតត្រង់, មានអៀនខ្មាស, មានព្យាយាមល្អ ចេះធ្វើការរកស៊ី... ។ លុះស្រេចកិច្ចការក្នុងទីប្រជុំនេះហើយ ម៉ោង ២០ កន្លះ យើងត្រឡប់មកឯទីរួមខេត្តវិញ ។

ថ្ងៃអាទិត្យ ២៤ ធ្នូ ១៩៣៣ (៨ កើតបុស្ស)

ម៉ោង ៨ (ព្រឹក) ចេញទៅវត្តតាសឹក (យួនហៅថ្លូត្រាសិក) ក្នុងឃុំហួយឡង់ ខណ្ឌម៉ាយហ្សាទ្រុង (នៅខាងត្បូងទីរួមខេត្ត); ម៉ោង ៩ ដល់វត្តតាសឹក ។ វត្តនេះមានសាលារៀន តាំងពីក្នុងឆ្នាំ ១៩២៩ រៀងមក, មានគ្រូបង្រៀន ២ នាក់, គ្រូម្នាក់ជាគ្រូហស្ថ ឈ្មោះ ថាច់-មាស (ហៅភៅ) មានសញ្ញាបត្របឋមសិក្សា

ខាងអក្សរយួន (តាមដាន់ដើម) ចេះនិយាយភាសាបារាំង-សែស, ជាអ្នកបង្រៀនខាងអក្សរខ្មែរ-បារាំង, រាជការឲ្យនិច្ចភត្ត ១ខែ ១៨រៀល; គ្រូ ១ រូបទៀតជាបព្វជិតឈ្មោះ ហាំង-ផែម បង្រៀនបំពោះតែអក្សរខ្មែរ, បានទៅនៅរៀនក្នុងសាលាវិត្ត លង្កាពីក្នុងឆ្នាំ ១៩៣១ ពេញ ១ ឆ្នាំ ប៉ុន្តែមិនបានប្រឡងទេ ពី-ព្រោះកាលនោះផ្ញើសំបុត្រជាតិមិនទាន់, ឥឡូវហិបំរុងនឹងសុំចូល រៀនក្នុងសាលាវិត្តលង្កាម្តងទៀត ។ សាលារៀនវិត្តតាសឹកនេះ មានសិស្សចូលប្រឡងជាប់បានសញ្ញាបត្រប្រឋមសិក្សាខ្មែរ សម្រាប់សាលាសិក្សាធិការទីរួមខែត្រត្រាំវិញរៀងរាល់ឆ្នាំ រួម ទាំងអស់ជាប់បាន ១០ នាក់ហើយ; សព្វថ្ងៃនេះ មានសិស្ស កុមារ ៣៤ នាក់ កុមារី ៥ នាក់ ។ ក្នុងសន្និបាតនេះ មាន ពួកបព្វជិតវិត្តក្រៅ ១៣ វិត្ត មកប្រជុំផង; បណ្តាវិត្តទាំង ១៣ នោះ, វិត្ត ៥ មានសាលារៀន, គឺ វិត្តផ្អោរអណ្តូង គ្រូបង្រៀនជាបព្វជិត ឈ្មោះថាប់-ហឹម មានសញ្ញាបត្រសាលាសិក្សាធិការខែត្រ ត្រាំវិញ; វិត្តគោបាលនិគ្រោធ (ពាក្យធម្មតាហៅវិត្តផ្អោរព្រាល) គ្រូបង្រៀនជាបព្វជិត ឈ្មោះថាប់-ហើយ មានសញ្ញាបត្រ

សាលាវិត្តលង្កាក្នុងឆ្នាំ ១៩៣៣ នេះ; វត្តកំពង់សាលា គ្រូបង្រៀនជាបព្វជិត ឈ្មោះ ឋាប់-អ៊ុយ-ប៊ុប្ល (ជាចៅអធិការវត្តនេះ) មានសញ្ញាបត្រសាលាវិត្តលង្កា ក្នុងឆ្នាំ ១៩៣១; វត្តតាលភេរី (ពាក្យធម្មតាហៅវត្តរំដួល) គ្រូបង្រៀនជាគ្រហស្ថ ឈ្មោះម៉ឺន មានសញ្ញាបត្រសាលាសិក្សាធិការខេត្តត្រាវិញ; វត្តបាយ៉ាម គ្រូបង្រៀនជាគ្រហស្ថ ឈ្មោះគីម-ផេង មានសញ្ញាបត្រសាលាសិក្សាធិការខេត្តត្រាវិញ ។ ក្នុងទីប្រជុំនេះមានមនុស្សប្រហែលជិត ២០០ នាក់ ។ លុះធ្វើការក្នុងសន្និបាតរួបស្រេចហើយ យើងធ្វើភត្តកិច្ចនៅវត្តនេះ ។

ម៉ោង ១៣ ចេញពីវត្តតាសឹកទៅវត្តកំពង់សាលា ក្នុងឃុំហឹបឡឹម ខណ្ឌង៉ាយហ្សាទ្រុំង (ដោយលោកចៅអធិការ ឋាប់-អ៊ុយ-ប៊ុប្ល ទទួចសុំឲ្យបានទៅមើលសាលារៀននៅវត្តលោកផង) ។ សាលារៀនវត្តនេះ កើតមានតាំងពីឆ្នាំ ១៩២៣ រៀងមក គឺលោកចៅអធិការនេះផ្តើមបង្កើតឲ្យមានឡើងតាំងពីរាជការមិនទាន់បង្កើតឲ្យមានសាលាសិក្សាអក្សរខ្មែរក្នុងវត្តអារាមនៅឡើយ; សព្វថ្ងៃនេះមានសិស្សសុទ្ធតែកុមារចំនួន ៣៩

នាក់, សិស្សទាំងនេះមានសេចក្ដីឈ្លាសវៃគ្រាន់បើដែរ ។ ក្នុងទីប្រជុំនេះមានមនុស្សប្រហែល៩០នាក់ ។ យើងបាននិយាយពន្យល់តាមសមគួរហើយ ក៏ត្រឡប់តាមផ្លូវដដែលមកវិញហួសចូលទៅវត្តខ្មើន ។

ម៉ោង ១៦ ចូលទៅដល់វត្តខ្មើន ក្នុងឃុំមីលឿង ខណ្ឌត្រាញីវ (នៅខាងត្បូងជិតទីរួមខេត្តត្រាវិញ) ។ វត្តនេះមានសាលារៀន, គ្រូបង្រៀនជាបព្វជិតឈ្មោះ ថាច់-បន្ទ-អ៊ី មានសញ្ញាបត្រសាលាវត្តលង្កាក្នុងឆ្នាំ ១៩៣០, មានសិស្សសាលា ២៨ នាក់ ។ បើតាមឮដំណឹងតាំងពីយូរឆ្នាំមកហើយថាបណ្ដាវត្តទាំង ១១០ ក្នុងខេត្តត្រាវិញ មានតែវត្តខ្មើននេះឯងជាវត្តផ្ដួចផ្ដើមខំប្រឹងរៀនសូត្រធម៌វិន័យជជីកផ្ទៀងផ្ទាត់សង្កេតរកឲ្យឃើញផ្លូវខុសត្រូវមុនវត្តឯទៀត ។; ក្នុងវេលានេះ សង្កេតមើលទៅកុដិលំនៅសម្រាប់សង្ឃ ក៏ឃើញមានរបៀបប្លែកខ្លះអំពីវត្តឯទៀតក្នុងខេត្តនេះ; សព្វថ្ងៃនេះ មានភិក្ខុ៤០រូប សាមណេរ៣៥រូប, ក្នុងទីប្រជុំនេះ រួមទាំងពួកបព្វជិតវត្តបម្ការ ១០ រូបដែលមកប្រជុំផង មានចំនួនបព្វជិត ៨៥ រូប, ឃើញមានរបៀបស្លៀក

ដណ្ដាប់ត្រឹមត្រូវជាសមណសារូបរម្យទមទាំងអស់; បំណែកខាងពួកគ្រហស្ថដែលមកប្រជុំប្រហែលជាង ១០០ នាក់ ក៏មានសណ្ដាប់ធ្នាប់សុភាពរាបសាស្មើរតែនឹងទាំងអស់គ្នា ។ ពួកខ្មែរជាបំណុះវត្តនេះ ឋាមានចំនួនច្រើនប្រហែល ១៤០ ផ្ទះ, ប៉ុន្តែទៅជាមានកុមារសិស្សសាលាតិចពេក បានតែត្រឹម២៨ នាក់, មិនសមនឹងចំនួនផ្ទះដែលមានច្រើនដល់ម្លោះ ។ លុះយើងធ្វើកិច្ចការរួចស្រេចហើយ ក៏ត្រឡប់មកឯទីរួមខែត្រវិញ ។

ថ្ងៃចន្ទ ២៤ ដេសម ១៩៧៣ (៩ កើតបុស្ស)

ម៉ោង ៧ កន្លះ (ព្រឹក) ចេញទៅវត្តតាលភេរ៍ (ពាក្យធម្មតាហៅវត្តរំដួល(១)) ក្នុងឃុំដោងហួរ ខណ្ឌម៉ាយហ្សាទ្រុង (នៅខាងត្បូងទីរួមខែត្រ); ម៉ោង ៩ ទៅដល់វត្តនេះ ។ ក្នុងសន្និបាតនេះ មានពួកបព្វជិតវត្តក្រៅចំនួន ៩ វត្តមកប្រជុំ; បណ្ដាអស់លោកវត្តទាំងនោះ; មានលោកវត្តខ្លះបានទៅប្រជុំឯវត្តតាសឹកពី

---

១ វត្តរំដួលនេះនៅខាងឯនាយវត្តតាសឹក, លោកចៅអធិការនឹងពួកបព្វជិតខ្លះមកប្រជុំនៅវត្តតាសឹកពីក្នុងថ្ងៃម្សិលរួចហើយ, ប៉ុន្តែមានទំនងត្រូវឲ្យយើងទៅតាមវត្តនោះទៀត តាមបញ្ជីកំណត់ពេលម៉ោងប្រជុំដែលរាជការខែត្រនេះបានកំណត់ស្រេចហើយ (នឹងខានពុំបាន) ។

ក្នុងថ្ងៃម្សិលរួចម្ដងហើយ ប៉ុន្តែលោកមានសេចក្ដីពេញចិត្តចង់ស្ដាប់ពាក្យពន្យល់របស់យើង លោកក៏និមន្តមកម្ដងទៀតដោយមិនមានបង្អាប់អំពីរាជការឃុំទេ ។ ក្នុងទីប្រជុំនេះមានមនុស្សប្រហែល ១៥០ នាក់ ។ លុះចប់សេចក្ដីពន្យល់របស់លោកអគ្គ-លេខាធិការហើយ, ពួកសន្និបាតនេះឈ្មួញស្រែកអង្វរហ៊ាសុំឲ្យខ្ញុំនិយាយពន្យល់ជាស់តឿនរំឭកឲ្យបានច្រើនបន្តិច ដ្បិតស្ដាប់ពីម្សិលមិញមិនទាន់អស់ចិត្ត ព្រោះហេតុនេះបានជាតាមមកស្ដាប់ក្នុងវេលានេះទៀត... ។ ខ្ញុំក៏បានប្រឹងនិយាយពន្យល់ដោយពេញកំឡាំង អំពីការរំឭកជាស់តឿននឹងអំពីធម៌វិន័យផ្លូវព្រះពុទ្ធសាសនាខ្លះ តាមគួរដល់វេលា រួចហើយយើងធ្វើភត្តកិច្ចនៅវត្តនេះ ។ លុះស្រេចភត្តកិច្ចហើយ, លោកចៅ-អធិការវត្តបាយ៉ាមសុំឲ្យយើងឆ្លៀតចូលទៅវត្តលោកបាន ១ ស្រ-បក់ផង ។

ម៉ោង ១២ ចេញអំពីវត្តតាលភេរីទៅវត្តបាយ៉ាម ។ វត្តនេះមានលោកអាចារ្យបព្វជិត ១ រូបឈ្មោះម៉ាយ-ញើង (ហៅយ៉ាន) បានទៅនៅរៀនព្រះបរិយត្តិធម៌ឯស្រុកសៀមចំនួន ១០

ឆ្នាំ ប្រឡង (ឯស្រុកសៀម) បានសញ្ញាបត្រទីមហា ៣ ប្រយោគ, បានត្រឡប់មកនៅវត្តបាយ៉ាមនេះវិញ ៥ ឆ្នាំហើយ ។ តាំងពីដួចមកនៅវត្តនេះ ក៏បានតាំងផ្ដើមឲ្យមានរបៀបរៀន បាឡី, រៀនវិន័យ, រៀនធម៌ប្រែសម្រាប់សូត្រ; របៀបរៀននោះ មានជាប់រហូតមកដល់សព្វថ្ងៃនេះៗ មានភិក្ខុសាមណេរអ្នករៀន ចំនួន ៨០ រូប; មានអ្នករៀនបានប្រែចប់គម្ពីរព្រះធម្មបទដ្ឋកថា ខ្លះហើយ, មានអ្នករៀនប្រែដល់គម្ពីរមង្គលត្ថទីបនី ល្មមធ្វើជា អាចារ្យរងជួយបង្រៀនលោកមហាយ៉ានបានខ្លះហើយ ។ លោកចៅអធិការបានសុំឱកាសយើង ឲ្យភិក្ខុសាមណេរទាំង ៨០ រូប សូត្រវិន័យសម្រាយដែលទន្ទេញចាំមាត់ តាមសៀវភៅ ពុទ្ធសាសនបណ្ឌិត្យ ឲ្យយើងស្ដាប់ ១ ស្របក់; បន្ទាប់មក បាន ជំរាបលោកអគ្គលេខាធិការសុំឲ្យមេត្តារាប់បញ្ចូលសាលាបាឡី នេះឲ្យបានសិប់ក្នុងបញ្ជីរបស់ពុទ្ធសាសនបណ្ឌិត្យ ឲ្យពេញទី ជាសាលាបាឡីរងផង ។ វត្តនេះមានសាលាសិក្សា ១ ផ្សេង សម្រាប់ពួកកុមារ (ដូចមានក្នុងសេចក្ដីរៀបរាប់ខាងវត្តតាសឹក ឯណោះរួចហើយ); មានសិស្សកុមារចំនួន ៤០ នាក់ ។

មានពួកលោកចៅអធិការវត្តឯទៀតខ្លះ ដែលបានទៅប្រជុំឯវត្តតាសឹកនឹងវត្តតាលភរីរួបហើយនោះ ក៏ខំនិមន្តស្រែតតាមផ្លូវកាត់ឲ្យបានឆាប់ មកជួបជុំក្នុងទីនេះទៀត, សំដែងអាការឲ្យឃើញថាពេញចិត្តនឹងការរៀនការស្តាប់ ។ ពួកភិក្ខុសាមណេរក្នុងទីប្រជុំនេះ មានសណ្តាប់ធ្នាប់រៀបរយគួរឲ្យជ្រះថ្លាចង់ឃើញចង់ជួប ។

ម៉ោង ១៣ កន្លះ យើងចេញអំពីវត្តបាយ៉ាមត្រឡប់តាមផ្លូវដើមមកវិញ បង្ហួសសំដៅទៅវត្តពីសី (ជាវត្តលំនៅរបស់លោកព្រះវិន័យធរ ធន ដែលជូនតាំផ្លូវយើងរាល់ថ្ងៃក្នុងខែត្រនេះ) នៅក្នុងឃុំភ្លើងឆាញ់ ខណ្ឌចិញ្ចៀក (នៅខាងទិសពាយ័ព្យធៀងឯជើងទីរួមខែត្រ); ម៉ោង ១៤ ទៅដល់វត្តពីសី ។ វត្តនេះមានសាលារៀនតាំងពីឆ្នាំ ១៩២៩, មានគ្រូបង្រៀនគ្រហស្ថ ២ នាក់, គ្រូម្នាក់ឈ្មោះ ថាច់-យី មានសញ្ញាបត្រប្រថមសិក្សាសាលាត្រាវិញ (បេះនិយាយបារាំង), គ្រូម្នាក់ទៀតឈ្មោះ គីម-ទៀង មានសញ្ញាបត្រសាលាវត្តលង្កា; មានសិស្សកុមារ ៦០ នាក់ កុមារី ១២ នាក់ ។ ក្នុងទីប្រជុំនេះមានមនុស្ស

ប្រហែល ១៥០ នាក់; ពួកភិក្ខុសាមណេរក្នុងវត្តនេះមានរបៀបរបបសុភាពរាបសាស្រួលបួលណាស់ ។ លោកចៅអធិការនឹងព្រះវិន័យធរ ធន ជំរាបលោកអគ្គលេខាធិការថាដល់ឆ្នាំ ១៩៣៤ លោកនឹងគិតបង្កើតឲ្យមានសាលាបាឡីក្នុងវត្តនេះបំរុងនឹងសុំអាចារ្យជាបព្វជិត ១ រូបដែលមានសញ្ញាបត្រសាលាបាឡីជាន់ខ្ពស់ក្រុងភ្នំពេញ ឲ្យមកនៅបង្រៀន ដោយសេចក្ដីទំនុកបំរុងរបស់អ្នកស្រុកជាបំណុះវត្តនេះ ។

ម៉ោង ១៦ យើងចេញពីវត្តពីសីហ្លួសទៅវត្តកន្លែងសេះក្នុងឃុំបញ្ញាភ្វ ខណ្ឌបញ្ញាខាញ់ (ដោយលោកចៅអធិការវត្តនេះសុំឲ្យឆ្លៀតទៅបាន ១ ម៉ោង) ។ វត្តនេះមានសាលារៀនតាំង ៥ ឆ្នាំមកហើយ; លោកអាចារ្យឈ្មោះ កែ-វិញ មានសញ្ញាបត្រសាលាបាឡីជាន់ខ្ពស់ក្រុងភ្នំពេញ បានទទួលការធ្វើជាគ្រូបង្រៀននៅសាលានេះ (តាំងពីដើមដំបូងរៀងមកដល់សព្វថ្ងៃនេះ ៥ ឆ្នាំហើយ); មានសិស្សកុមារ ៤៧ នាក់ កុមារី ១១ នាក់ ។ មានពួកបព្វជិតវត្តក្រៅ ២ វត្តមកកាន់ទីប្រជុំនេះ

ទីប្រជុំនេះមានមនុស្សប្រហែល ៨០ នាក់ ។ ម៉ោង ១៨ កន្លះ យើងចេញពីវត្តកន្លែងសេះត្រឡប់មកឯទីរួមខេត្តវិញ ។

បញ្ជីកំណត់ម៉ោងពេលប្រជុំក្នុងទីវត្តនីមួយ ៗ សម្រាប់បរិវេណគមគាគមក្នុងខេត្តតាវិញនេះ ប្លែកណាស់អំពីរបៀបក្នុងខេត្តទាំង ៨ ឯទៀត, ប្លែកដូច្នេះគឺៈ ក្នុងថ្ងៃមួយ ៗ វេលាព្រឹកចេញទៅខាងជើងទីរួមខេត្ត, វេលាល្ងាច ទៅខាងត្បូង; ស្អែកឡើង វេលាព្រឹក ចេញតាមផ្លូវពីម្សិលដដែល ទៅខាងត្បូង, ល្ងាចទៅខាងលិច; ខានស្អែកឡើង វេលាព្រឹក ចេញតាមផ្លូវពីម្សិលដដែល ទៅខាងត្បូង, ល្ងាចទៅខាងលិច ឬខាងកើត; ទៅ ៗ មក ៗ សាចុះសាឡើងខាត់ខ្វែងតាមផ្លូវដដែល ៗ, យ៉ាងនេះរាល់ថ្ងៃ ។ មានវត្តខ្លះនៅជិត ៗ គ្នា ល្មមប្រមូលមនុស្សឲ្យមកប្រជុំតែក្នុងវត្តមួយតែ ១ លើកប៉ុណ្ណោះក៏បានហើយ, គួររំលែកវេលាទុកប្រជុំនៅវត្តណាដែលឆ្ងាយ ៗ ពីនោះទៅវិញស្រួល ។ គួរបើដែរ, ដូចយ៉ាងវត្តតាសឹកនឹងវត្តតាលភេរីជាដើម មិនសមបើនឹងចាំបាច់រំលែកការប្រជុំដោយខ្លួនពីគ្នាសោះ,ហើយមានថែមទាំងកំណត់ថ្ងៃប្រជុំឲ្យផ្សេងពីគ្នា នាំឲ្យទៅមក ៗ តាម

ផ្លូវដដែល ៗ នោះទៅទៀត ។ ផ្លូវដែលត្រូវបេញទៅកាន់ទីប្រជុំមួយ ៗ, ខ្លះឆ្ងាយដល់ ៣០, ៤០, ៥០ គីឡូម៉ែត្រពីទីរួមខេត្តក៏មាន ។ ដោយហេតុដែលបាត់របៀបការទាស់ដំណើរយ៉ាងនេះ, វត្តខ្មែរក្នុងខេត្តត្រាវិញមានដល់ ១១០; សល់វត្តខ្លះមិនបានមកកាន់ទីប្រជុំណាមួយសោះក៏មាន ។ ខ្ញុំយល់ថា ការរៀបចំបញ្ជីយ៉ាងនេះ នាំឲ្យខាតប្រយោជន៍រាជការច្រើនណាស់, ខុសពីរបៀបបញ្ជីកំណត់ម៉ោងពេលប្រជុំក្នុងខេត្តឯទៀត ៗ (ប្រហែលជាពួកមន្ត្រីយួនរៀបចំបញ្ជីនោះជូនរាជការ ដោយនឹកឃើញយ៉ាងណា ក៏ធ្វើយ៉ាងនោះទៅ ទេដឹង ?); ដល់ឆ្នាំក្រោយត ៗ ទៅ គួរតែកុំប្រើរបៀបយ៉ាងនេះទៀត ទើបស្រួលនឹងមានប្រយោជន៍ច្រើន ។

ថ្ងៃអង្គារ ៤៦ ធ្នូ ១៩៣៣ (១០ កើតខែបុស្ស)

ម៉ោង ១០ កន្លះ យើងបេញពីទីរួមខេត្តត្រាវិញឆ្ពោះទៅក្រុងព្រៃនគរ; ម៉ោង ១៤ កន្លះដល់ក្រុងព្រៃនគរ ។ លុះបួលទៅ

ជួបនឹងលោកឡឺគុរ៉េរណើរដឹឡាកូសាំងស៊ីនរួចហើយ, យើងចេញពីក្រុងព្រៃនគរ ឆ្ពោះមកក្រុងភ្នំពេញវិញ; ម៉ោង ២៣ កន្លះ ដល់ក្រុងភ្នំពេញ ។

កំណត់ចំនួនថ្ងៃនៃបរិវដ្តគមនាគម (ដំណើរអង់គ្លរណេ) ខាងខែត្រតែនិញ ៤ ថ្ងៃ, តាំងពីខែត្របាតៀងរៀងរហូតដល់ខែត្រត្រាវិញ - ក្រុងព្រៃនគរ - ភ្នំពេញ ៣៦ ថ្ងៃ, រួមជា ៤០ ថ្ងៃ ។



ជួងសម្រិទ្ធិ ១ ល្អប្លែក ព្រះចៅភូមា ព្រះរាជទានទៅទុកនៅវត្ត បតទារតី
ក្រុងអមរបុរ កាល ព. ស. ២៣៦៣ ។

ខេមាខេមសរណគាថា

ព្រះមហាពិទូរក្រសេមគន្ធៈបទបណ្ឌិត រៀបរៀង

កាលពួកព្រាហ្មណ៍គិតបញ្ហាឃើញហើយតបពួកអរិយដូចពោលហើយ លំដាប់នោះគេក៏តែងប្រវត្តិព្រះព្រហ្មយកជាការមែនទែនថា ព្រះព្រហ្មជាឧប្បត្តិទេព កើតឡើងឯងគ្មានមាតាបិតា កាលលោកកើតឡើងហើយក៏ទ្រង់សាងលោកទាំងពួងទើបមានព្រះនាមថា ព្រះធាតា ប្រែថាព្រះអ្នកសាងលោកធាតុគឺព្រះអង្គនេះឯងជាបិតាលោក ៗ មានន័យ ១ និយាយបំពោះមនុស្សលោកថា ដំបូងព្រះព្រហ្មទ្រង់បែងភាគខ្លួនមកកើតជាបុរស (ភេតប្រុស) នឹងវិរដ្ឋា (ភេតស្រី) ជាមនុស្សតែមួយគូឡើងនៅក្នុងមនុស្សលោកនេះ បុរសនឹងវិរដ្ឋានោះរួមសំវាសគ្នាទៅ ក៏កើតជាកូនចៅជាចៅតចៅពង្សរៀងនៅក្នុងលោកនេះទើបមានមនុស្សច្រើន ដូចដែលយើងឃើញស្រាប់ហើយ ។ ន័យ ១ ទៀតថា ព្រះព្រហ្មមានទេពីឈ្មោះសរស្វតី មានព្រះបុត្រគឺព្រះទក្ស នឹងព្រះភ្ជុគុ ។ ព្រះទក្សបានជាប្រជាបតីនៃលោកគឺជាដើមវង្សនៃមនុស្សលោក ។ ន័យ ១ ទៀតថា វណ្ណ គឺប្រភេទនៃមនុស្សមាន ៤ យ៉ាង គឺពួកព្រាហ្មណ៍ ពួកក្សត្រិយ៍

ពួកវេសៈ ពួកសូទ្រៈ ។ ពួកព្រាហ្មណ៍ជាកូនច្បង កើតចេញអំពីព្រះឱស្ឋព្រះព្រហ្ម ។ ប្រគល់វេទទាំង ៤ ឲ្យ ក្សត្រិយ៍អ្នកជាព្រះរាជាៈកើតចេញអំពីព្រះហស្តខាងស្តាំ អ្នកជារាជិនីកើតចេញអំពីព្រះហស្តខាងឆ្វេង ពួកវេសៈទាំងប្រុសទាំងស្រីកើតចេញអំពីព្រះឩរូ ពួកសូទ្រៈកើតចេញអំពីចុងព្រះបាទ ទើបមានមនុស្ស ៤វណ្ណនេះនៅក្នុងលោក ហើយរៀនសូត្រនឹងប្រតិបត្តិតាមគម្ពីរវេទ ដែលលោកប្រទានមកនោះ វៀរលែងតែពួកសូទ្រៈដែលរាប់ថាជាជាតិថយថោកបំផុត មិនឲ្យរៀនគម្ពីរវេទ ។ រួមព្រះគុណរបស់ព្រះព្រហ្ម គឺព្រះអង្គជាអ្នកសាងលោក ជាអ្នកប្រទានសាសនា គឺគម្ពីរវេទទាំង ៤ ជាអ្នកមានឫទ្ធិមានអំណាចចង់ឲ្យល្អ ល្អបាន ចង់ឲ្យអាក្រក់ អាក្រក់បាន ។

### តនិកាលអានព្រះឥស្សូរ

មានសេចក្តីក្នុងគម្ពីររបស់ព្រាហ្មណ៍សំដែងអំពីជាតិប្រវត្តិរបស់ព្រះឥស្សូរថា គ្រាមួយនោះព្រះព្រហ្មយកឈើកៀរញើសនៅប្រជុំចិញ្ចើម រលោត់ស្បែកលោហិតហូរចេញស្រក់ទៅក្នុងទឹក

កើតឡើងជាទេវបុត្រ ១ អង្គនាម រុទ្រៈ គឺព្រះឥស្សរនេះឯង ដោយហេតុនេះត្រូវយល់ថា ព្រះរុទ្រៈនោះជាបុត្រព្រះព្រហ្ម វេលាក្រោយមកឈ្មោះនេះបានបំពេញតបៈធម៌យ៉ាងមាំមួន ទាល់តែបានជាព្រះ ១ អង្គ ទើបមាននាមហៅផ្សេង ៗ ទៅទៀតទាំងពាន់យ៉ាង មាននាមថា ឥស្សរ ឥសិរ ភវាធិបតី ជាដើម តែដែលថាបានជាព្រះនោះ មិនមែនបានជាព្រះអរហន្តឆ្ងាយចាកកិលេសក៏ទេ ដោយមានរឿងថា ក្នុងខណៈដែលព្រះឥស្សរកំពុងបំរើនឈាន ដើម្បីយកភូមិជាព្រះនោះ ពួកទេវតាមកជំនុំគ្នាថា ឥឡូវនេះព្រះឥស្សរបំរើនឈានមានសេចក្ដីស្ងប់ស្ងួត ជិតសម្រេចភូមិជាព្រះហើយ កាលលោកបានជាព្រះហើយនឹងលើកលែងគ្រប់គ្រងពួកយើងដែលជាគ្រហស្ថ លោកនឹងធ្វើតែកិច្ចរបស់ឫសីដូច្នេះគួរយើងគិតបំផ្លាញឈាននោះបេញ គណទេពទើបបង្គាប់ឲ្យទេវបុត្រ ១ អង្គ ឈ្មោះកាមទេពទៅជ្រែក ទំនងដូចមារជ្រែកព្រះពុទ្ធអង្គ វិធីដែលជ្រែកនោះ គឺក្នុងវេលាដែលព្រះឥស្សរកំពុងបំរើនឈាន កាមទេពបានលបទៅបាញ់ដោយធនូផ្កា ដែលហៅថា ធនូផ្កា គឺគេយកដើមអំពៅមកធ្វើជាដងធនូ យក

មេឃុំមកឲ្យវាចាប់ប្រតោងគ្នា ៗ ធ្វើជាខ្សែធ្នូ យកផ្កា ៥ ទង មកធ្វើជាព្រួញធ្នូ បាញ់ទៅត្រូវព្រះឥស្សរ ៗ បើកព្រះនេត្រឡើងឃើញជាកាមទេពក៏ក្រោធខ្លាំង បើកព្រះនេត្រកណ្ដាលសំឡក់ទៅកាមទេព ៗក៏ឆេះខ្ទេចទៅមួយរំពេច រកតែផេះបន្តិចបន្តួចក៏មិនមានសេសសល់ តែមិនស្លាប់សូន្យសោះ ទើបមាននាមជាថ្មីថា "អនង្គ" ប្រែថា គ្មានខ្លួន ។ រឿងនេះមានឆ្លាក់ជារូបភាពនៅប្រាសាទនគរវត្តត្រង់ជ្រុងហរតី ដោយមតិយល់ថាគេសំដែងជាបុគ្គលាធិដ្ឋាន ប្រៀបឲ្យឃើញជារូបជាអង្គបុគ្គលឡើង តែដែលពិតមិនដូច្នោះ គឺធម្មាធិដ្ឋាន ធៀបតាមផ្លូវពុទ្ធ-សាសនាគង់បានសេចក្ដីថា កាមទេព បានខឹងអារម្មណ៍ដែលធ្វើចិត្តឲ្យកើតសេចក្ដីរេកសេចក្ដីប្រាថ្នា ដែលឈ្មោះដូច្នេះព្រោះបើដូចជាទេវតាដ៏វិសេសអាចបណ្ដាលចិត្តមនុស្សឲ្យប្រ-ព្រឹត្តទៅផ្សេងៗបាន ធ្នូជាឈ្មោះនៃកិលេសមានរាគៈជាដើមដែលជាគ្រឿងចាក់ដោតសន្ដានសត្វឲ្យឈឺចាប់ ផ្កា ៥ ជាព្រួញធ្នូ បានខឹងកាមគុណទាំង ៥ ដែលជាគ្រឿងដឹកចិត្តសត្វឲ្យវង្វេង ។ ដើមអំពៅជាដងធ្នូ មេឃុំជាខ្សែធ្នូនោះ មាន

អធិប្បាយថា កាមគុណកាលជនពាលបរិភោគទៅ ក្នុងជាន់ដំបូងឲ្យឃើញផ្អែមឆ្ងាញ់បីដូចជាទឹកអំពៅ កាលបរិភោគយូរទៅនឹងត្រឡប់ទៅជារបស់ពិសស្លែង ធ្វើឲ្យជនពាលវិនាស មានន័យដូចដែលលោកប្រៀប ១ យ៉ាងទៀតថា កាមគុណដូចផ្ទាំងដែលគេដាក់ថ្នាំពិសហើយដាក់ទឹកឃ្មុំខាងលើ អ្នកណាលោតផឹកទៅនឹងស្លាប់ កាមទេពដែលក្លាយទៅជា អនង្គ បាននឹងបិត្តនេះឯង ដែលរាប់ថាជានាមធម៌ អធិប្បាយដូច្នេះទើបត្រូវតាមរូបរឿង ។

ព្រះឥស្សូរកាលត្រូវធនូផ្កាហើយ ក៏រសាយចិត្តនឹងបំរើនឈានតទៅ ត្រឡប់មានចិត្តជំរេកក្នុងកាមគុណ ទើបយកនាងឧមា ឬហៅថា ភគវតី ជាទេពី តាំងប្រាសាទរាជវាំងនៅលើកំពូលភ្នំកៃលាស មានឱរស ២ អង្គ គឺ ព្រះខន្ធកុមារ ១ ព្រះគណេសដែលខ្មែរយើងហៅ ព្រះភក្ដនេស ១ ហើយបានដំណែងធំជា ២ យ៉ាង គឺ ដំណែងជាព្រះ ដោយនាមថា មហាយោគី ១ យ៉ាង ដំណែងជាស្ដេចធំគ្រប់គ្រងទេវតាទាំងឡាយ ដោយនាមថា មហាទេព ១ យ៉ាង ។ មិនតែប៉ុណ្ណោះគេថាជាអ្នកសាងលោក

ដែរ ដោយមានសេចក្តីក្នុងគម្ពីរសិរិបុរាណមរបស់ព្រាហ្មណ៍ថា ដំបូងដែលមិនទាន់កើតលោកនេះឡើង ព្រះឥស្វរទ្រង់វះសាច់ភ្លៅរបស់ព្រះអង្គឲ្យលោហិតមួយដំណក់ស្រក់ចុះក្នុងទឹក កើតឡើងជាពងៗនោះទ្រង់បណ្តាលឲ្យបែកជា២បំហៀង បំហៀងខាងលើទ្រង់សាងទៅជាឋានសួគ៌ បំហៀងក្រោមទ្រង់សាងជាឋានមនុស្សលោក ហើយទ្រង់សាង បុម គឺ ជីវ គួវិញ្ញាណរបស់លោកឡើង គួវិញ្ញាណនោះក៏សាងប្រជាបតីនៃលោកតមក ពួកអ្នកកាន់សាសនាព្រាហ្មណ៍ ទើបហៅព្រះឥស្វរថាជាបិតាលោក ហៅនាង ឧមា ថា ភវានី ប្រែថា ម្តាយលោក ដោយសេចក្តីជឿដូច្នេះ គេទើបសាងរូបលិង្គព្រះឥស្វរទុកជាអនុស្សាវរីយ៍សំដែងហេតុដែលព្រះអង្គជាអ្នកបង្កើតលោក ។



កូនក្មេងភូមាតែងខ្លួនរៀបចេញទៅបួស ខាងក្រោយជាគ្រឿង
បរិក្ខារគេរៀបហែជូនទៅវត្ត ។

# សាសនីភាទ ពាក្យកាព្យ

(ត-បប់)

បំណែកឯឆ្នាំង រួចពេលហើយតាំង លាងផ្កាប់ទុករៀប កុំឲ្យក្រៀមនៅ មិនត្រូវរបៀប ដល់ពេលដាំទៀត ពិបាកលាងណាស់ ។ បើមានកិច្ចការ ប្រញាប់ទៅណា ជាការរហ័ស លាងទុកមិនទាន់ កុំបោលផ្តេសផ្តាស ដាក់ទៅគៀនកោះ ចាក់ទឹកត្រាំទៅ ។ បើមិនត្រាំទេ មិនបេះគ្នាន់គ្នេរ ទុកឲ្យក្រៀមនៅ ពេលដាំក្រោយទៀត លំបាកណាស់កូវ ក្រៀមក្តាំងជាប់នៅ ដុះលាងមិនជ្រះ ។ ពេលត្រូវទឹកក្តៅ រីកឡើងក្រហមខ្មៅ ដូចប្រែះដែកចាស់ អែបជាប់នឹងក្តាំង គៀនឆ្នាំងដេរដាស តែមើលមិនច្បាស់ ប្រឡាំបាយខ្លោច ។ នឹងដណ្តាំស្ល ពិនិត្យឲ្យល្អ យកទឹកលាងស្រោច ដុសខាត់ក្នុងក្រៅ កុំឲ្យអាសោច ប្តីស្តីប៉ោច ៗ ដោះសាខឹងវិញ ។ បំណែកផ្ទះបាយ ពួកស្រីទាំងឡាយ ត្រូវតែបួលបេញ មើលការខុសត្រូវ ព្រោះក្រសួងខ្លួនពេញ ទីនោះឯងមិញ មិនត្រូវប្រុសរវល់ ។ ទី ២ នោះនែ ត្រូវឲ្យសត្រី ភរិយាគោងស្គាល់ ញាតិមិត្រខាងប្តី ត្រូវស្រីជម្កល់ ប្រៀបដូចជាថ្នល់ តែងដើរទៅមក ។ កុំឲ្យស្មៀបរមាស់ កុំឲ្យមានទាស់ ឈ្លោះគ្នារបោក ហៅថាបិទផ្លូវ សំរាប់ទៅមក

នាំឲ្យថយហោក តែខ្លួនឯងទេ ។ ត្រូវឲ្យរាប់រ ត្រូវឲ្យសាទរ គួរតែគ្នាន់គ្នេរ មើលការខុសត្រូវ កុំនៅទំនេរ ធុរៈរបស់គេ ត្រូវជួយកិច្ចផង ។ កុំមើលនឹងភ្នែក កុំធ្វើឲ្យបែក ពីញាតិប្ដី ហោង តែបែកកាលណា នាំឲ្យសៅហ្មង ព្រោះប្អូននឹងបង វានាំញុះញង់ ។ បើប្ដីមិនខឹង គេស្ងៀមទ្រមឹង នោះនឹង គង់វង្ស ប្រយ័ត្នប្ដីភ្លើ រដើដោយស្លុង ខ្លួនយើងបំរុង តែឈ្លោះ គ្នាទៅ ។ ម្លោះហើយមិនសុខ នាំឲ្យអុកឡុក រហូតម៉ែរហូតឪ ព្រោះហេតុចិត្តស្រាល មិនអត់ស្ងៀមនៅ ព្រោះតែមិនស្ទូវ រាប់ ញាតិខាងប្ដី ។ ទី៣នោះណា ត្រូវឲ្យភរិយា មានចិត្តមេត្រី ធ្វើ ឲ្យស្លូតត្រង់ រួមនឹងស្វាមី គឺថាកុំបី មានប្រុសសហាយ ។ បើស្រីឯណា ធ្វើមារយាទភរិយា មានចិត្តក្លែងក្លាយ យក ប្រុសដទៃ តាមដោយសប្បាយ រួមចិត្តរួមកាយ ក្បត់នឹងប្ដី ឯង ។ កាលណាប្ដីដឹង ប្ដីគេខេវខឹង គេដាក់គេប៉ែង គេ ដាល់គេតប់ គេស្អប់គេលែង គេលក់ខ្លួនឯង គេលែងយក ប្រាក់ ។ ហើយថែមដាក់គុក ឲ្យឯងកើតទុក្ខ សស្រិកសស្រាក់ បើប្រុសចិត្តឆៅ មិនសំដៅលុយកាក់ ទាញកាំបិតផ្គាក់ ចាក់

កាប់ចោលទៅ ។ ឈ្មោះអាស្រូវភាស ថែមខ្លួនវិនាស អាប់ដល់ម៉ែឪ គេដៀលដល់ពូជ ខូចរហូតពង្សផៅ ជាប់ទៅដល់ចៅ ហៅពូជក្បត់ប្តី ។ បូរស្រីទាំងឡាយ ស្តាប់យើងអធិប្បាយ រំឭកស្មារតី កុំឱ្យប្រព្រឹត្ត ដូចជាសេចក្តី ខាងលើនេះនែ មិនល្អមិនជា ។ ត្រូវឱ្យស្លូតត្រង់ តាមព្រះពុទ្ធអង្គលោកទ្រង់ទេស្នា ឱ្យស្រីស្លូតត្រង់ នឹងប្តីអាត្មា ព្រោះព្រះសាស្តា ឃើញទោសទុក្ខច្រើន ។ ទី ៤ ប្រពៃ ភរិយានោះនែ ត្រូវឱ្យក្រវើន ទុកដាក់របស់ទ្រព្យ ទោះតិចទោះច្រើន ទ្រព្យបុងទ្រព្យដើម ទុកតាមរបៀប ។ គឺជាប្តីរក ពីជិតឆ្ងាយមក ឱ្យទុកឱ្យរៀប រក្សាឱ្យគង់ ប្រុងគំនិតមារយាទ កុំឱ្យបាត់ឃ្លាតទៅទីណាឡើយ ។ បើទ្រព្យណាល្អ រកបានដោយក្រ ទុកដាក់ឱ្យហើយ កុំចោលខ្ជះខ្ជាយ រាយធ្វើវាហី ល្មមដាក់ក្នុងក្តី ល្មមលៃដាក់ក្រៅ ។ ទុកដាក់របស់ទ្រព្យ ស្រីដែលប្រសប់ គឺមិនល្ងង់ខ្លៅ ទុកតាមរបៀប មានក្នុងមានក្រៅ ហើយទុកសំដៅ ទីមួយ ៗ នែ ។ បើយើងត្រូវការ ប្រញាប់ទៅណា ឆាប់រហ័សវៃ នឹងដើរទៅយក ពេលយប់ពេលថ្ងៃ ឥតមាន

សង្ស័យ មិនឲ្យរីមរាម ។ បើមិនកំណត់ ទុកមិនប្រាកដ យក មិនបានភ្លាម ព្រោះតែទុកភ្លើ រងើអន្តរធាន ហៅស្រីមិនមាន មារយាទជាល្អ ។ ហៃស្រីទាំងឡាយ ត្រូវប្រព្រឹត្តកាយ ទទួលត្រេកអរ ប្រតិបត្តិច្បាប់នេះ កុំធ្វើវៀវវ្ស លោកហៅ ស្រីល្អ បំពេញមុខប្ដី ។ ទីគំរប់៤ ត្រូវឲ្យចូលចាំ កុំភ្លេច ឡើយនែ នឹងធ្វើការងារ គ្រប់ជំពូកក្ដី ចាប់ធ្វើការអ្វី តោង ធ្វើឲ្យទំ ។ ហើយឲ្យម៉ត់ចត់ ធ្វើឲ្យប្រាកដ ឲ្យស្អួនឲ្យសម ឲ្យស្អាតឲ្យល្អ កុំទុកសម្ងំ សម្ងាត់បន្ធំ ត្រូវធ្វើឲ្យស្រេច ។ កុំធ្វើវ្សេះវ្សោះ កុំខ្ជិលឲ្យសោះ ធ្វើឲ្យសម្រេច កុំឲ្យទុកនៅ ទោះបីម្ដេចៗ កុំធ្វើបំភ្លេច ទុកខូចអាសារ ។ ហៃអស់ស្ត្រី ភរិយានោះនែ បើចង់ល្អជា ចង់បានក្ដីសុខ យកទុកគ្រប់គ្នា ពិតណាស់ហៅមហា ពិតពេកកន្លង ។ បើអ្នកឯណា ធ្វើជា មាតា បិតានោះហោង ឬជាស្វាមី ភរិយានោះផង ធ្វើតាម គន្លង ច្បាប់នេះប្រពៃ ។ ទើបនឹងបានសុខ បានល្អស្រណុក សុខជាលោកិយ បើប្រាសចោលច្បាប់ ប្រៀបដូចចូលព្រៃ បន្លាដៃទេ មិនលែងមុតប្រាណ ។ ច្បាប់ព្រះជិតមារ ដ៏វិសេស

ជា ជាច្បាប់បូរាណ លោកសម្ដែងទុក ក្នុងសូត្រមួយមាន នាមឈ្មោះសិង្គា លោវាទសូត្រនោះ ។ ខ្ញុំឃើញធម៌ល្អ ចិត្តខ្ញុំត្រេកអរ ស្រឡាញ់បំពោះ បង់ឲ្យគេឯង បានដឹង ទាំងអស់ ទោះស្រីទោះប្រុស ស្រឡាញ់សុខគ្រប់គ្នា ។ បាន ជាគុណធម៌ នេះមកនាំល្អ បណ្ដាលចិត្តជា ឲ្យខ្ញុំដកយក របស់ត្រូវការ បង្ហាញគ្រប់គ្នា ឲ្យឃើញរបស់សុខ ។ ព្រោះមនុស្សពួក៤ ប្រើនរូបប្រើនខ្លួន តែងតែកើតទុក្ខ ព្រោះ មិនស្គាល់ធម៌ ជាហេតុឲ្យសុខ បានជាកើតទុក្ខ សុខនោះ តិចណាស់ ។ បំណែកមាតា នឹងអស់បិតា ខ្ញុំយល់ឃើញ ច្បាស់ នឹងទូន្មានកូន ខុសនឹងច្បាប់ព្រះ ប្រើនតែប្រើប្រាស់ ហាត់សម្លាប់សត្វ ។ ឲ្យបេះធ្វើលប ឲ្យរៀនរកម្ហូប បេះដាក់ បង្កាត់ ប្រដៅរាល់ថ្ងៃ មិនដែលមានស្ងាត់ ឯសម្លាប់សត្វ នោះត្រូវចិត្តហើយ ។ បានជាវាល្ងង់ ងងឹតសូន្យសុង វាធ្វើ កន្ត្រៃយ មិនស្គាល់ឪម៉ែ ហេតុតែគឹងហើយ បានជាមិនស្បើយ ទុក្ខទោសនោះនៃ ។ បើប្រដៅវា ឲ្យរៀនវិជ្ជា ដែលល្អប្រពៃ

ផលល្អនោះឯង ត្រឡប់វិលវៃ ដល់មាតាបិ តានោះពុំលែង ។ ឬឯស្វាមី នឹងភរិយាស្រី ក៏ដូច្នោះឯង គ្មានធម៌សង្គ្រោះ បំពោះ ដាក់ស្នែង បានជាទាស់ទែង លែងលះគ្នា ។ បើមិនលែង ទេ មិនដែលទំនេរ ពីទុក្ខវេទនា ទាស់ហេតុពីនេះ ពីនោះ រាល់គ្រា ទុក្ខហើយនឹងជា ជាតិបជាងទុក្ខ ។ ខ្ញុំឃើញហេតុ នេះ បានជាខ្ញុំរិះ រាំរៃលៃលក សរសេរបាត់បែង តែងសេចក្ដីមក លើកទុកជាល្បើក ឲ្យល្បីទូទៅ ។ ដ្បិតមនុស្សជិត ឆ្ងាយ ស្រីប្រុសទាំងឡាយ មានទីលំនៅ ដោយគៀនដោយ កោះ បន្ទោះព្រៃជ្រៅ អ្នកប្រាជ្ញណាទៅ ដល់ទីនោះឯង ។ បើមានក្បួនខ្នាត គាថាបាទឡបាទ ប្រើនតែសម្ដែង ជាពាក្យ ត្រង់ៗ គ្មានពាក្យល្បើកល្បែង បិត្តមនុស្សអ្នកលេង មិនស្វែ ត្រិការ ។ វាឮស្សរធម៌ មិនដែលត្រេកអរ នឹងលោកទេស្នា បំណែកដះប្រៀង មានតែជ្រៀតគ្នា បំពាក់បំពារ វាត្រេកអរ ណាស់ ។ ខ្ញុំយល់ដូច្នោះ ទោះបើត្រិខុស នោះសូមលោក ម្ចាស់ មេត្តាអាណិត កុំតិះដៀលផ្ទុះ ខ្ញុំសូមប្រកាស ឧបាយ

នេះឯង ។ ហើយសូមប្រាថ្នា ខ្ញុំសូមសច្ចា អាត្មាជាក់ស្តែង បើខ្ញុំរង្គាត់ ក្នុងភពនេះឯង សូមឲ្យខ្ញុំតែង បានសុខពិត ៗ ។ ហើយសូមប្រាថ្នា ឲ្យកើតបញ្ញា សារពេជ្រវិចិត្រ កុំឲ្យទើសទ័ល សល់ពីគំនិត គឺអង្គព្រះជិត មារនោះឯងហោង ។

# រឿងធ្មេញ្ញៃយបណ្ឌិត

## (គឺ ធុនញ្ញយបណ្ឌិត)

## (គ)

ស្ដេចវិលចូលក្នុងព្រះរាជវាំងវិញ ហើយមានព្រះបន្ទូលបង្គាប់ថា ឲ្យអស់ស្រីដែលនៅក្នុងវាំងជុះអាចម៍ដាក់ផ្ទះអាជៃ បើវាថាដូចម្ដេចៗ ឲ្យចាប់យកទោសខុសនឹងឲ្យសម្លាប់វាឲ្យហើយបេញ ឯស្រីអ្នកក្នុងវាំងបានឮព្រះបន្ទូលបង្គាប់ដូច្នោះហើយ ក៏បបួលគ្នាទៅជុះអាចម៍ដាក់ក្នុងផ្ទះធ្មេញ្ជៃយ ទៅដល់ហើយប្រាប់ធ្មេញ្ជៃយថា ដ្បិតម្ចាស់លោកឲ្យមកជុះអាចម៍ដាក់ផ្ទះធ្មេញ្ជៃយឯង ឯធ្មេញ្ជៃយស្ដាប់ហើយក៏ឆ្លើយថា បើមានព្រះបន្ទូលថាដូច្នោះហើយ ខ្ញុំមិនហ៊ានឃាត់តាមចិត្តអស់អ្នក បើចង់ជុះក៏ជុះចុះ តែជុះកុំនោម តែនោមផងហៅល្មើសព្រះបន្ទូលខ្ញុំមិនព្រមទេ ឯអស់អ្នកទាំងនោះស្ដាប់ធ្មេញ្ជៃយថាដូច្នោះហើយ ក៏បបួលគ្នាជុះអាចម៍ដាក់ផ្ទះធ្មេញ្ជៃយ តាមព្រះបន្ទូលស្ដេចបង្គាប់នោះ ឯធ្មេញ្ជៃយក៏ដើរមើល បើឃើញនោមផងនោះ ធ្មេញ្ជៃយវាយអស់ស្រីដែលជុះហើយនោមផង ឯអស់ស្រីទាំងនោះដឹងជាធ្មេញ្ជៃយវាយដូច្នោះហើយ ក៏រត់ទៅទូលស្ដេចឲ្យបានទ្រង់ជ្រាបលុះដល់ហើយក្រាបថ្វាយបង្គំទូលថា ដ្បិតម្ចាស់ប្រើឲ្យទៅជុះអាចម៍ដាក់ផ្ទះធ្មេញ្ជៃយ ឥឡូវនេះអស់យើងខ្ញុំទៅជុះដាក់ដូច

ព្រះបន្ទូល ឥឡូវនេះធ្មៃញ្ជយវាយអស់យើងខ្ញុំ វាថាវាមិនឲ្យជុះដាក់ផ្ទះវា សូមទ្រង់ជ្រាប ឯព្រះមហាក្សត្រស្តាប់ហើយត្រាស់ថា ឲ្យអស់ទាហានទៅចាប់អាជៃយកមកនឹងជំនុំ ឯអស់ទាហានស្តាប់ព្រះបន្ទូលដូច្នោះហើយ ក៏ទៅចាប់ធ្មៃញ្ជយដូចព្រះបន្ទូល លុះទៅដល់ផ្ទះធ្មៃញ្ជយហើយ ក៏ឡើងទៅលើផ្ទះហើយចាប់ដៃធ្មៃញ្ជយចងហើយប្រាប់ថា ដ្បិតមានព្រះបន្ទូលឲ្យមកចាប់យកឯងទៅ ដ្បិតស្តេចខ្ញាល់ណាស់ ឯធ្មៃញ្ជយស្តាប់ហើយគិតថា បើដូច្នោះនឹងគិតកុំឲ្យវាចងអញបាន គិតស្រេចហើយក៏ថា អស់ទាំងអ្នកឯងនឹងចងអញនេះមិនបានទេ តែអញថាឲ្យឯងស្លាប់ឯងស្លាប់មិនខាន ឯងមិនដឹងទេ នេះឯងហើយឈ្មោះធ្មៃញ្ជយអ្នកប្រាជ្ញ សូវិលែងចេញជាវិញ ឯអស់ទាំងទាហាននោះស្តាប់ពាក្យធ្មៃញ្ជយហើយ ក៏មិនហ៊ានចងដៃធ្មៃញ្ជយហើយស្រាយចេញ ឯធ្មៃញ្ជយក៏ដើរជើងទទេទៅដល់ហើយក្រាបថ្វាយបង្គំស្ងៀមនៅចាំស្តាប់ព្រះបន្ទូល ឯព្រះមហាក្សត្រទតមកឃើញធ្មៃញ្ជយមកដល់ហើយ មានព្រះបន្ទូលដណ្តឹងទៅថា អាជៃឯងដូចម្តេច ក៏បានជាអាឯងដេញ

វាយអស់សាវទ្បីកដែលអញឲ្យទៅជុះអាចម៍ដាក់ផ្ទះអាឯងនោះ តើអាឯងខុសឬអាឯងត្រូវ; ទើបធ្មេញ្ញោយយកសេចក្តីក្រាបទូល ថាបានជាខ្ញុំទូលបង្គំវាយនោះ ដ្បិតអស់អ្នកសាវទ្បីកធ្វើល្មើស ព្រះបន្ទូល ខុសមិនត្រូវ ដ្បិតទ្រង់បង្គាប់ថាឲ្យទៅជុះតែអាចម៍ទេ នឹងមានព្រះបន្ទូលថាឲ្យទៅនោមឯណា ឥឡូវនេះអស់អ្នកទាំងនោះ ទៅជុះហើយនោមផង ហេតុដូច្នេះបានជាខ្ញុំវាយ សូមស្តេចទ្រង់ជ្រាប ។ ឯមហាក្សត្រស្តាប់ហើយស្តេចក៏ស្ងៀមពុំមានព្រះបន្ទូលថាអ្វីៗឡើយ នឹងយកទោសធ្មេញ្ញោយមិនបាន ។

លុះឯក្រោយទៀតឮល្បីទៅដល់ស្តេចស្រុកចិនថាស្រុកខ្មែរមានអ្នកប្រាជ្ញម្នាក់មានប្រាជ្ញាណាស់ មិនមានអ្នកឯណានឹងផ្ចាញ់ប្រាជ្ញាបាន ស្តេចក្រុងចិន គិតនឹងអស់នាម៉ឺនថាយើងនឹងគិតធ្វើបំណោទ ទៅឲ្យអ្នកប្រាជ្ញស្រុកខ្មែររក ស្តេចក្រុងចិននឹងអស់នាម៉ឺនឲ្យរកផ្លែឪទ្បឹក ៣ ដ្បិតពូជឪទ្បឹកក្នុងស្រុកចិននោះមានបីយ៉ាង មួយយ៉ាងនោះក្នុងផ្លែ ១ មានគ្រាប់តែ ១ ផ្លែ ១ ទៀតមានគ្រាប់ពីរ ផ្លែ ១ ទៀតមានគ្រាប់បី ស្តេចស្រុកចិនឲ្យរៀបសំពៅទាំង ៥០០ ក្នុងសំពៅ ១ មានចិន ៥០០

ជាបំណុះសំពៅគ្រប់ទាំង ៥០០ សំពៅ ហើយធ្វើសំបុត្ររាជ-សារ ក្នុងសេចក្ដីសំបុត្រថា ដ្បិតស្រុកខ្មែរមានអ្នកប្រាជ្ញមានប្រាជ្ញាណាស់ឈ្មោះធ្មេញ្ជយ បើដូច្នេះស្ដេចស្រុកចិន ឲ្យនាំផ្លែឪឡឹកបីមកនឹងសំពៅ ៥០០ ក្នុងសំពៅ ១ មានមនុស្ស ៥០០ គ្រប់សំពៅដូច្នេះឯង នាំមកឲ្យអ្នកប្រាជ្ញស្រុកខ្មែរទាយផ្លែឪឡឹកទាំងបីនេះឯង ។ ឯឪឡឹក ១ មានគ្រាប់ប៉ុន្មាន បើអ្នកប្រាជ្ញស្រុកខ្មែរទាយត្រូវនោះយើងភ្ជាល់ដាក់សំពៅទាំង ៥០០ មនុស្សទាំងអស់ក្នុងបំណុះសំពៅនោះឯង ។ បើអ្នកប្រាជ្ញស្រុកខ្មែរទាយមិនត្រូវយើងនឹងយកនគរស្រុកខ្មែរ ។ លុះធ្វើសុភអក្សររួចហើយ ឲ្យនាម៉ឺនធំម្នាក់ នឹងអ្នកប្រាជ្ញម្នាក់នាំបេញមក លុះមកដល់ហើយនាម៉ឺនចិននាំសំបុត្រឡើងក្រាបទូលស្ដេចស្រុកខ្មែរ ៗ ឲ្យហៅធ្មេញ្ជយមកប្រាប់ថា ឥឡូវនេះស្ដេចស្រុកចិនឲ្យនាំសារមកថាឲ្យទាយផ្លែឪឡឹក ក្នុងផ្លែ១ តើគ្រាប់ប៉ុន្មាន បើអាឯងទាយត្រូវក៏ហើទៅ បើអាឯងទាយមិនត្រូវអញនឹងយកទោសដល់ជីវិតធ្មេញ្ជយព្រះហើយក្រាបទូលថា កុំព្រួយព្រះរាជហឫទ័យធារនាទូលបង្គំនឹងទាយឲ្យត្រូវ ប៉ុន្តែក្នុងចិត្តធ្មេញ្ជយភ័យណាស់ ដែល

បានជាអ្នកជាអ្នកប្រាជ្ញមានប្រាជ្ញាមកជាយូរហើយ ៗ ធ្មេញ្ជៃយលាទៅផ្ទះវិញ លុះទៅដល់ផ្ទះ ធ្មេញ្ជៃយដេកគិតរកប្រាជ្ញានឹងទាយផ្លែឪឡឹកនោះ ដេកអត់ទាំងបាយអំពីព្រឹកលុះត្រាតែល្ងាច ហើយធ្មេញ្ជៃយនឹកគិតរកមិនឃើញ, មកគិតថា ឥឡូវនេះស្តេចឲ្យដោះប្រស្នានឹងស្តេចស្រុកចិន បើដោះមិនរួចស្តេចនឹងសម្លាប់ បើដូច្នេះអញគង់តែនឹងស្លាប់ អញមុជទឹកឲ្យស្លាប់ទៅទើបជា. លុះដល់ព្រលប់យប់ងងឹតហើយធ្មេញ្ជៃយចុះទៅកំពង់ទឹកហើយចុះទៅមុជទឹកឲ្យស្លាប់ក្នុងទឹក ដល់មុជទៅបេះតែអណ្តែតខ្លួនឡើង ហើយរសាត់ទៅដល់បង្កួតសំពៅចិន ធ្មេញ្ជៃយងើបឡើងឃើញបង្កួត ទាំងឮនាម៉ឺនចិននឹងអ្នកប្រាជ្ញស្រុកចិននិយាយគ្នានៅក្នុងបាតសំពៅថា បើយើងធ្វើប្រស្នាឪឡឹកហើយតើយើងធ្វើប្រស្នាអ្វីតទៅទៀត ដ្បិតឪឡឹកនេះផ្លែវាតែបី ផ្លែ ១ គ្រាប់១ ផ្លែ ១ ទៀតគ្រាប់ពីរ ផ្លែ ១ ទៀតគ្រាប់បីតែប៉ុណ្ណោះ, យើងគិតធ្វើប្រស្នាពីរបីយ៉ាងទៀតបំណាច់ស្តេចប្រើមក បើគេទាយត្រូវមួយយ៉ាង នៅមួយយ៉ាងទៀត កុំឲ្យតែមួយយ៉ាងហើយអស់ទៅតែម្តង ហាក់ដូចជាប្រាជ្ញាតិច

ណាស់ ឯអ្នកប្រាជ្ញស្រុកចិនឆ្លើយឡើងថា យើងមានបំណោទ មួយពីរបីយ៉ាងទៀត ។ នាម៉ឺនដោះសួរថា បំណោទអីទៀត ។ អ្នកប្រាជ្ញថា យើងនិយាយគ្នានេះ កុំឲ្យនរណាដឹង ក្រែងមានមនុស្ស មកលបស្តាប់ ហើយនាម៉ឺននឹងអ្នកប្រាជ្ញរកមើលមនុស្សគ្មាន ក៏បបួលគ្នានិយាយអំពីប្រស្នាពីរបីយ៉ាងនោះ អ្នកប្រាជ្ញនិយាយ ថា យើងយកសាច់ជ្រូក ១ នាលឲ្យស្តេចស្រុកខ្មែរទុកសោយ បានពីរឆ្នាំ កុំឲ្យប្រែឡាក់អំបិល កុំឲ្យធ្វើជាងៀត ឲ្យ ទុកជាសាច់ស្រស់ស្តេចសោយបានពីរឆ្នាំកុំឲ្យស្អុយខូច នាម៉ឺន សួរថា ធ្វើដូចម្តេចនឹងបានពីរឆ្នាំ សាច់ជ្រូក១ នាលប៉ុណ្ណោះ ។ អ្នកប្រាជ្ញឆ្លើយថា បើដល់ជិតថ្ងៃនឹងដាច់ឆ្នាំ នឹងចូលឆ្នាំថ្មីយើង យកសាច់ជ្រូកទុកស៊ីតែពីរថ្ងៃក៏រាប់ថាពីរឆ្នាំ ដ្បិតឆ្នាំចាស់១ថ្ងៃ ឆ្នាំថ្មី១ថ្ងៃ ត្រូវជាពីរឆ្នាំ បើអ្នកប្រាជ្ញស្រុកខ្មែររកមិនឃើញ យើង នឹងយកនគរជាបំណុះយើង ។ ១ ទៀតនោះ យើងឲ្យមនុស្សចាប់ យកចាប១មក ហើយយកទៅឲ្យស្តេចស្រុកខ្មែរ ឲ្យរៀបធ្វើជា សំឡយកមកឲ្យពលយើងក្នុងសំពៅទាំង៥០០ស៊ីឲ្យឆ្អែត នាម៉ឺននោះសួរថា ដូចម្តេចសត្វតូច ១ ហើយឲ្យធ្វើសំឡមហូបមក

ឲ្យពលយើងទាំងអស់ស៊ីឲ្យឆ្អែតបាន អ្នកប្រាជ្ញនោះប្រាប់ថា បើគេមានប្រាជ្ញា គេឲ្យយកម្ជុលមកឲ្យយើងដំធ្វើជាពូថៅធំ ១ នឹងយកទៅពុះចាបយកសាច់ទៅស្លឲ្យពលស៊ី ។ ១ ទៀតយើងបង្គាប់ស្តេចស្រុកខ្មែរឲ្យធ្វើយុធការបាន៥០០ នឹងយកមកបោះចតសំពៅយើងឲ្យគ្រប់ទាំង ៥០០ ឲ្យធ្វើក្នុងមួយថ្ងៃឲ្យរួចក្នុងយុធការ១ទំហំ៣ចាប់ ។ នាម៉ឺនសួរថា ធ្វើដូចម្តេចនឹងធ្វើយុធការដល់១០០ឲ្យរួចក្នុងថ្ងៃ១នោះ ។ អ្នកប្រាជ្ញនោះថា ឲ្យយកបំបើងមកបងធ្វើជារាងយុធការហើយដាក់លើដី យកភ្លើងដុតឲ្យឆេះនៅតែស្នាមឆេះបំបើងជាប់នឹងដីហើយ ហៅមនុស្សឲ្យមកសែងយងទៅបោះបងសំពៅ បើជាអ្នកប្រាជ្ញមែនធ្វើប្រាជ្ញាយ៉ាងនេះៗ បានទល់ប្រាជ្ញាគ្នាបាន ។ ឯនាម៉ឺនឮអ្នកប្រាជ្ញប្រាប់សព្វគ្រប់ដូច្នោះមានចិត្តត្រេកអរណាស់ ថាស្រុកខ្មែរមុខជាកណ្តាប់ដៃយើងមិនខានទេ ។ ឯធ្មៃព្រាយតោងចង្កូតសំពៅចាំប្រុងត្រចៀកស្តាប់សព្វគ្រប់គ្មានខ្វះសោះឡើយ, ដល់នាម៉ឺននឹងអ្នកប្រាជ្ញចិនលែងនិយាយគ្នា ធ្មៃព្រាយហែលមុជមកឯកំពង់វិញ ហើយដើរឡើងទៅលើផ្ទះមានចិត្តអរណាស់ គិតថាអញ

អស់ស្លាប់ហើយ នេះគឺទេវតាជួយអញមិនឲ្យស្លាប់ លុះដល់ពេ-លាកាលណា នាម៉ឺនបិននឹងអ្នកប្រាជ្ញចិនយកផ្លែឪឡឹកទាំងបីឡើងមកអំពីសំពៅក្ងួលៈទៅគាល់ស្ដេចក្នុងព្រះរាជរោង ស្ដេចឲ្យហៅធ្មេញ្ញ ប្រជុំអស់នាម៉ឺនមុខមន្ត្រីពាសពេញក្នុងបុងព្រះរាជរោង នាម៉ឺនបិននឹងអ្នកប្រាជ្ញយកផ្លែឪឡឹកទាំងបីមកឲ្យធ្មេញ្ញទាយៈ ឯធ្មេញ្ញទាយត្រូវទាំងអស់ ។ អ្នកប្រាជ្ញស្រុកចិនលុះដល់ធ្មេញ្ញទាយត្រូវហើយ ធ្វើជាបំណោទទាំងបីយ៉ាងមកឲ្យធ្មេញ្ញទៀត ឯធ្មេញ្ញដោះបំណោទអ្នកប្រាជ្ញស្រុកចិនដូចយើងនិយាយមកពីមុនគ្មានសល់តិចឡើយ ។ ឯស្ដេចជ្រាបថា អ្នកប្រាជ្ញស្រុកចិនទ័លប្រាជ្ញានឹងធ្មេញ្ញហើយស្ដេចឲ្យយកសំពៅទាំង ៥០០ ទុកតែសំពៅ ១ ឲ្យនាម៉ឺននឹងអ្នកប្រាជ្ញត្រ-ឡប់ទៅស្រុកចិនវិញ ហើយស្ដេចព្រះរាជទានរង្វាន់ឲ្យធ្មេញ្ញជាច្រើន ។ ឯស្ដេចស្រុកចិនពីថ្ងៃនោះមកខ្លាចប្រាជ្ញាធ្មេញ្ញមិនហ៊ានឲ្យមកបោទប្រស្នាទៀត ប៉ុន្តែនឹកខ្លាចក្នុងព្រះទ័យថា បើឥតនឹងធ្មេញ្ញទៅកាលណានឹងឲ្យភ្នាល់បោទប្រស្នាទៀត ។

(មានត)

# បញ្ជីរឿង

លេខទំព័រ


១ — បរិវត្តគមនាគម ដំណើរអង់គ្លេសណោក្នុងដែនកូសាំងស៊ីន ខេត្រតៃនិញ ព្រះ
សាសនសោភ័ណ ជ-ណាត រៀបរៀង ក្នុងឆ្នាំ ១៩៣៣ . . . . . . ៦៧

២ — ខេមាខេមសរណកថា ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត រៀបរៀង (ត) ១០១

៣ — តម្រានាដសាស្ត្រ ( ក្បួនរាំ ) ត ព្រះមហាពិទូរ ក្រសេម ប្រែចេញពីភាសាសៀម ១០៣

៤ — អំពីការស្រាវជ្រាវនៅជាប់ម៉ាម (អណ្ណាម) លោកក្លៃយ៍ នៅសាលាបារាំងសែស
ចុងបូព៌ាប្រទេស រៀបរៀង . . . . . . . . . . . . . . . . . . ១៣១

៥ — សប្បុរិសធម៌ ពាក្យកាព្យ បាន-តេង គ្រូបង្រៀន រៀបរៀង . . . . . . ១៣៧

៦ — រឿងព្រេងខ្មែរដែលមិនទាន់បោះពុម្ពផ្សាយ:

១ រឿងចចកដល់នូវគ្រោះថ្នាក់ . . . . . . . . . . . . . . . . . . ១៤៣

២ រឿងអ្នកនៅផ្ទះភូមិជិតគ្នា . . . . . . . . . . . . . . . . . . ១៤៩


# រូបក្រៅរឿង


១ — ព្រះពុទ្ធរូបសៃយាសន៍ នៅវត្តស៊ិនប៊ិនថាលីយោង្គ ក្រុងបាគន (ភូមា) . . . ៩៩

២ — ប្រាសាទព្រះខ័ន ផ្លូវចូលទៅក្នុងប្រាសាទ . . . . . . . . . . . . . . . . ១២៩

# TABLE DES MATIÈRES


Pages

I. Tournée en Cochinchine de M. le secrétaire général de l'Institut Bouddhique (Tây-Ninh)........ 67

II. Khemā Khema Saranakatha ou Religions, refuge des hommes par Préas Maha Pitou Krasem à la Bibliothèque Royale (à suivre)........ 101

III. Le Théatu cambodgien (suite) par Préas Maha Pitou Krasem. 113

IV. Les fouilles de Thap-Nam près de Binh-Dinh — Annam — par M. Claeys de l'École Française d'Extrême-Orient.... 131

V. Sappurisadhama poème ou la générosité par Ban-Teng (à suivre)........ 137

VI. Contes populaires cambodgiens inédits:

I° Histoire du Margouillat........ 143

II° Le voisinage des hommes........ 149


## HORS TEXTE:


I. Profil du Grand Bouddha couché Pagode de Shinbintha-lyaung — Pagan (Birmanie)........ 99

II. Prah Khan — l'entrée de la cour intérieure........ 129

ដំណើរអង់ឡូរណោ

ខែត្រតៃវិញ ក្នុងឆ្នាំ១៩៣៣

"ដំណើរអង់គួរណោក្នុងខែត្រតៃនិញ (កូស័ងស៊ីន)"

នៃអគ្គលេខាធិការ-ពុទ្ធសាសនបណ្ឌិត្យ (ការប៉ឺឡែស), ព្រះសាសនសោភណ (ជួន-ណាត) ចាងហ្វាងវង់សាលាបាឡីជាន់ខ្ពស់ និងលេខាធិការ (ជួន-នុត) អ្នកប្រែភាសានៅព្រះរាជបណ្ណាល័យកម្ពុជា ភ្នំពេញ ។

ព្រះសាសនសោភណ ជាអ្នកកត់ត្រាហើយរៀបរៀងដូចមានសេចក្ដីតទៅនេះ:

ថ្ងៃសុក្រ ១ រោចខែកត្តិកឆ្នាំរកាបញ្ចស័ក ព. ស. ២៤៧៦ ត្រូវនឹងថ្ងៃ ៣ ណោវិម គ. ស. ១៩៣៣, ម៉ោង ៧ កន្លះព្រឹក ចេញពីភ្នំពេញ[១] តាមផ្លូវបទេសរាជ (ផ្លូវកូឡូនីញ៉ាល់) លេខ ១ ទៅដោយរថយន្តរាជការលេខ ៤៨ ។ ម៉ោង ១០ កន្លះដល់ទៅទីរួមខែត្រស្វាយរៀង; ខ្ញុំ (ព្រះសាសនសោភណ) ព្រមទាំងលេខាធិការ ជ-នុត (ប្អូនខ្ញុំ) នឹងសូហ្វ័រ (អ្នកបើក

---

១ ខ្ញុំបានធ្វើចុតហ្មាយថ្វាយព្រះពរលាព្រះករុណាជាម្ចាស់ជីវិត ព្រះចៅក្រុងកម្ពុជាធិបតី ។ បានទទួលព្រះរាជានុញ្ញាតហើយទើបចេញទៅអង់គួរណោនេះ ។

របិយន្ត) ឈ្មោះកេត-ផន ចូលទៅឈប់ទទួលភោជនាហារនៅវត្តព្រៃធ្លាក់ ។ លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យហួសទៅទទួលភោជនាហារឯភោជនាគារ (បង្គលោ) បារាំង ។ ម៉ោង ១១ ចេញពីទីរួមខេត្តស្វាយរៀង បែកតាមផ្លូវខាងឆ្វេងដែលសំដៅទៅខេត្តតៃនិញ (ខ្មែរហៅខេត្តរោងដំរី) ។ ម៉ោង ១៣ កន្លះ គឺម៉ោង ១ កន្លះរសៀល ដល់ទៅទីរួមខេត្តតៃនិញ ។ ម៉ោង ១៤ គឺម៉ោង ៣ រសៀល យើងចូលទៅជួបនឹងលោកឡាត់មិនិស្ត្រាទ័រនាម (វិលម៉ុងត៍) ឡឺរ៉េស៊ីដង់ត៍ទីរួមខេត្តតៃនិញ ។ លោកឡាត់មិនិស្ត្រាទ័របានធ្វើបដិសណ្ឋារៈមករកលោកអគ្គលេខាធិការ និងយើងទាំង ២ នាក់ដោយសេចក្ដីស្មោះសររួសរាយណាស់, ហើយលោកមានប្រសាសន៍ថ្លែងសេចក្ដីត្រេកអរដោយច្រើនបំពោះពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងព្រះរាជបណ្ណាល័យនឹងសាលាបាឡីជាន់ខ្ពស់ថា តាំងពីដួចក្រុងភ្នំពេញកើតមានស្ថានទាំង៣នេះឡើងហើយបានផ្សាយសៀវភៅមក, ក៏នាំឲ្យជនជាតិខ្មែរក្នុងខេត្តតៃនិញចេះខំប្រឹងរៀនសូត្របានចេះដឹងភ្ញាក់គំនិតមានអៀនខ្មាសខ្លះ

គ្រាន់បើជាងពីដើម; លោកមានសង្ឃឹមថា តពីនេះទៅទៀតពួកខ្មែរក្នុងខែត្រនេះមុខជានឹងបានចំរើនគ្រាន់បើបន្តិចម្តងៗឡើងពុំខាន ។ ហើយលោកមានប្រសាសន៍ថា ពួកកៅដាយដែលតាំងទីក្នុងខែត្រតៃនិញនេះ លោកបានកំចាត់ឲ្យខ្ចាត់ខ្ចាយអស់ទៅហើយ មិនមានអំណាចបញ្ឆោតបំពោតពួកមនុស្សល្ងង់ខ្លៅឲ្យចុះចូលដូចកាលពីមុននោះទេ. ឥឡូវស្ងប់ស្ងាត់ហើយ ....។ តមកលោកមានប្រសាសន៍បំពោះមកខ្ញុំថា សុំឲ្យលោកគ្រូនិយាយពន្យល់អស់ប្រជាជនជាតិខ្មែរក្នុងខែត្រតៃនិញនេះ ឲ្យយកចិត្តទុកដាក់ខំប្រឹងរៀនសូត្រតាមសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យ ដើម្បីឲ្យបានចេះដឹងកើតមានគំនិតប្រាជ្ញាល្អនឹងបានចេះអៀនខ្មាស, ខំប្រឹងធ្វើការរកស៊ីមិនខ្ជិលច្រអូស ។ ហើយលោកសុំឲ្យខ្ញុំនិយាយពន្យល់ថា ក្នុងរវាងពីរបីឆ្នាំមកហើយនេះរាស្ត្រប្រជាក្រីក្រលំបាកក្រៃពេកណាស់, អ្នកខ្លះស្ទើរតែនឹងរកបាយស៊ីគ្មាន; រាជការក៏បានដឹងហេតុនៃសេចក្តីក្រលំបាកនោះជាក់ណាស់, បានបើកអង្ករចែកឲ្យអ្នកក្រីក្រលំបាកទាំងនោះខ្លះក៏មានដែរហើយ, ព្រោះរាជការយល់ថា បើមិនចែកឲ្យមុខជានឹង

មានមនុស្សដាច់ពោះស្លាប់ខ្លះមិនខាន ។ សព្វថ្ងៃនេះរាជការបានលើកថ្នល់ ១ ក្នុងខេត្តនេះ កាត់ពីខណ្ឌឆ្វេងទៅប៉ែកតំបន់ខាងត្បូង ជាប្រយោជន៍ឲ្យអស់អាណាប្រជានុរាស្រ្តងាយទៅមករកស៊ីជាងពីដើម; ត្រូវឲ្យប្រជាជនទាំងអស់មានអំណរនឹងការលើកថ្នល់នោះ ។ម្យ៉ាងទៀតលោកឡាត់មិនិស្រ្តាទ័រសុំឲ្យខ្ញុំនិយាយពន្យល់ប្រជាជនជាតិខ្មែរ អំពីទោសផឹកស្រា, អំពីទោសលេងល្បែងភ្នាល់, អំពីឲ្យនាំគ្នាពេញចិត្តស្លៀកពាក់តាមសណ្ដាប់ជាតិខ្មែរ កុំឲ្យតាមបែបយួន, អំពីឲ្យខំប្រឹងដាំដំណាំកុំខ្ជិលច្រអូស កុំទុកដីឲ្យនៅទំនេរឥតប្រយោជន៍ ។

លុះនិយាយការសព្វគ្រប់ហើយ ក៏លាលោកឡាត់មិនិស្រ្តាទ័រចេញមក, លោកអគ្គលេខាធិការទៅសំណាក់ឯភោជនាគារ បារាំងក្នុងទីរួមខេត្តតៃនិញ យើងនាំគ្នាវិលមកសំណាក់ឯវត្តមន្រ្តីសាគរ (ពាក្យធម្មតាហៅវត្តត្រពាំងរបង) ឃុំត្រពាំងរបង (យួនហៅឡាងយ៉ាំងបង) ក្នុងខណ្ឌខាងឆ្វេង (យួនហៅតុងខាងធៀង) ខេត្តតៃនិញ ។ វត្តនេះនៅមកខាងអាយ (ជាខាងឯឡិច) ទីរួមខេត្តវិញ; កាលដែលយើងទៅពីអាយទៅដល់ផ្សារត្រពាំង-

របងនៅជិតវត្តនោះ, បានឃើញមនុស្សច្រើននាក់ខ្មែរខ្លះយួនខ្លះ មកឈរចាំទទួលយើង, និយាយថា សុំឲ្យឈប់សំណាក់នៅវត្តនោះសិន ចាំដល់ព្រឹកឡើងសឹមហួសទៅប៉ុស្តិ៍តែនិញ ព្រោះឯ-ណោះគ្មានវត្តលោកសង្ឃខ្មែរទេ... ។ យើងបានប្រាប់ថា "មិនអីទេចាំត្រឡប់មកសំណាក់ឯវត្តនេះវិញ..." ។ ម៉ោង ១៨ គឺម៉ោង៦ល្ងាចត្រឡប់មកដល់វត្តមន្ត្រីសាគរ; លោកគ្រូចៅអធិការព្រមទាំងលោកមេឃុំ ៗ ត្រពាំងរបងបានចាត់ការឲ្យរៀបកន្លែងសំណាក់បំរុងទុកឲ្យយើងនៅទីសាលាក្នុងវត្ត ។ វត្តមន្ត្រីសាគរនេះគេទើបនឹងកសាងបាន ៣ ឆ្នាំ; លោកក្រុមការឈ្មោះហង្ស (ជាតិខ្មែរ) កាលនៅជាចៅហ្វាយខណ្ឌខាងឆ្វេង (មិនទាន់រ៉ុត្រែតនៅឡើយ) បានសន្មតនាមជា "វត្តមន្ត្រីសាគរ" ព្រោះលោកមេឃុំឈ្មោះរៀលជាមន្ត្រីឃុំ បានផ្ដើមកសាងឲ្យបានកើតជាទីវត្តឡើង ។ វត្តនេះតូចល្មមដែរទេ ប៉ុន្តែមានស្ថានទីដីរាបស្មើល្អ, ដីក៏មានដីជាតិល្អ, សព្វថ្ងៃមានដំណាំដូង, ខ្នុរ, ស្វាយតាន់តាប់ កំពុងលូតលាស់ចំរើនជិតនឹងមានផ្លែខ្លះហើយ; ក្នុងទីវត្ត តាមតែជីកអណ្ដូងត្រង់ណាក៏ចេះតែមានទឹកទាំងអស់

ជីកជំរៅប្រហែលតែត្រឹម ២ ម៉ែត្រប៉ុណ្ណោះក៏ចេញទឹកហូរជងមិនចេះរីង ។ អំណើះតទៅខាងមុខ បើមានអ្នកទំនុកបំរុងថែទាំវត្តនេះគង់នឹងបានជាវត្តស្តុកស្តម្ភឡើងមិនខាន ។ លោកគ្រូចៅ-អធិការវត្តនេះឈ្មោះសៅរ៍ អាយុ៥៩ឆ្នាំ បួសបាន៣៣វស្សាហើយ, លោកគ្រូសូត្រឈ្មោះសុខ អាយុ៤៥ឆ្នាំ បួសបាន២០វស្សាហើយ; លោកគ្រូទាំង ២ រូបនេះចេញមកពីវត្តព្រៃកពកក្នុងឃុំឋ្នារធ្នង់ ខេត្តស្វាយរៀង ។ សព្វថ្ងៃនេះ បើមានការបំបួសកុលបុត្រ តែងទៅនិមន្តលោកគ្រូចៅអធិការវត្តព្រៃកពកមកធ្វើឧបជ្ឈាយ៍ជាដរាប ។

លោកមេឃុំត្រពាំងរបងនេះឈ្មោះស្នួង (ជាតិខ្មែរ ខេត្តស្វាយរៀង) ធ្លាប់មកនៅភ្នំពេញរៀនការរបនាអាស្រ័យនៅ ៗ ផ្ទះលោកឧកញ៉ារបនាប្រសើរ អ៊ុក-មៅ, ធ្លាប់ស្គាល់ខ្ញុំមកយូរហើយ; លុះបានឃើញខ្ញុំក្នុងគ្រានេះក៏សំដែងអំណរហាក់ដូចជាបានឃើញគ្រូបាអាចារ្យដែលខានជួបគ្នាអស់កាលយូរហើយ ។ ក្នុងវេលាយប់នោះ លោកគ្រូចៅអធិការព្រមទាំងភិក្ខុសាមណេរក្នុងវត្តនេះទាំងអស់ចំនួន ១៨ រូប នឹងពួកមន្ត្រីឃុំជាតិខ្មែរ

នូវអស់ឧបាសកឧបាសិកាប្រហែលជា ៤០ នាក់ នាំគ្នាមកប្រជុំក្នុងសាលាដែលយើងសំណាក់នោះ, បានសាកសួរអំពីធម៌អាថ៌ផ្សេងៗ; ខ្ញុំក៏បាននិយាយដោះស្រាយពន្យល់តាមគួរដល់វេលា; លុះខ្ញុំសិងទៅ, លេខាធិការនុតក៏បានជួយនិយាយពន្យល់ឲ្យពួកគ្រហស្ថ ដែលនៅកំដរទាំងប៉ុន្មាននាក់នោះស្តាប់តទៅទៀត ស្ទើរតែនឹងជិតពេលព្រឹក; អ្នកទាំងនោះក៏មានសេចក្តីរីករាយជាច្រើន ។

ថ្ងៃសៅរ៍ ៤ ណោវ៉ែម ១៩៣៣

ម៉ោង ៦ ព្រឹក យើងត្រឡប់ពីវត្តមន្ត្រីសាគរទៅទីរួមខេត្តតៃនិញវិញ ។ រថយន្តផ្ទុកសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យ ដែលកម្មការ "អ៊ួង-ជី" នឹងស្មៀន "យិន-ម៉ុ" បានចេញបរក្នុងខេត្តកំពង់ចាមជាវសៀវភៅព្រះរាជបណ្ណាល័យនឹងពុទ្ធសាសន-បណ្ឌិត្យ អស់ការក្នុងខេត្តនោះហើយ, បានបួលមកក្នុងខេត្តតៃនិញជួបនឹងយើងនៅវេលានោះ ។ លុះម៉ោង ៧ កន្លះព្រឹកនោះ យើងទាំងអស់គ្នាចេញពីទីរួមខេត្តតៃនិញតាមផ្លូវខាង

ទិសនិរតីយ៍សំដៅទៅវត្តត្បែងយុល ឃុំត្រពាំងព្រះស្រុក ខណ្ឌត្បែងយុល (យួនហៅតុងបាងយុង) ខេត្រតៃនិញ ។

ម៉ោង ៨ និង ៤៥ មិនុត ដល់ផ្លូវចូលទៅវត្ត; បានឃើញអ័តហ្ស៊ុយដង់ត៍ក្រុមរក្សាស្រុក (ជាតិយួន) ម្នាក់, គ្រូបង្រៀន (ជាតិយួន) ម្នាក់ និងមេឃុំ ៗ ត្រពាំងព្រះស្រុក (ជាតិខ្មែរ) ព្រមទាំងបណ្ដារាស្ត្រជាតិខ្មែរ ១០ នាក់ មកចាំនៅទីនោះ ៗ ជាព្រៃស្រោង, មានផ្លូវរទេះចូលទៅ; ឃើញមានរទេះក្របី ១ គេយកមកចាំទទួលយើង; លោកអគ្គលេខាធិការឡើងជិះរទេះក្របីសំយុងជើងទាំង ២ មកខាងកន្ទៀរទេះ; ផ្លូវនោះសុទ្ធសឹងតែភក់ផុង, ទាំងសងខាងផ្លូវសុទ្ធតែព្រៃញាតស្បាត; យើងទាំងអស់ក៏នាំគ្នាដើរលុយភក់ផុងនោះទៅ, ផុតពីព្រៃទៅដល់វាលស្រែ, ទៅឆ្ងាយប្រហែលជា ៣ គីឡូម៉ែត្រ ដល់ទៅភូមិជាប់ៗ; គ្រូបង្រៀនបាននាំយើងឲ្យចៀងចូលទៅមើលសាលារៀនអក្សរកុមារ ជាសាលាដែលរាជការឲ្យសង់ក្បែរភូមិសម្រាប់ឃុំនេះ, ឲ្យកូនអ្នកស្រុករៀនអក្សរខ្មែរនឹងលេខ, មានសិស្សក្មេងៗទាំងប្រុសទាំងស្រីចំនួន ៣៥ នាក់សុទ្ធតែកូនខ្មែរ ។ ខ្ញុំបានឲ្យសិស្ស

ដែលតូច ៗ ជាងគេ (ពីរបីនាក់) មើលសៀវភៅអក្សរខ្មែរ ហើយត្រូវបំណោទលេខខ្លះយ៉ាងស្រាល ៗ, ហើយបាននិយាយដាស់តឿនឲ្យខំប្រឹងរៀនសូត្រ...... ; រួចហើយលោកអគ្គលេខាធិការបានឲ្យបែកព្រះបរមរូបព្រះករុណាជាម្ចាស់ជីវិតព្រះបាទសម្ដេចព្រះស៊ីសុវត្ថិមុនីវង្សដែលទ្រព្រះហស្តសម្ដេចព្រះវររាជជននីព្រះវរមាតាព្រះអង្គ, ដល់ពួកសិស្សទាំងនោះ, ឯគ្រូបង្រៀនឲ្យរូបក្រដាសធំ ៗ ឲ្យទុកសម្រាប់សាលារៀន ។ គ្រូបង្រៀននេះឈ្មោះ ង្វៀង-យ៉ុង-ផាំ ជាតិយួន ប៉ុន្តែចេះអក្សរខ្មែរស្ទាត់, ជាសិស្សលោកគ្រូ តូច-ចាប ចៅអធិការវត្តព្រៃជើត[១] ។ លុះចែករូបរួចហើយ ចេញពីនេះសំដៅទៅវត្តត្បែងយុល, គ្រូបង្រៀននឹងសិស្សសាលាទាំងអស់ក៏ទៅជាមួយនឹងយើងដែរ ។

ម៉ោង ៩ កន្លះទៅដល់វត្ត ៗ ត្បែងយុលនេះសុកមម៉ុកសុទ្ធតែកូនឈើនឹងស្មៅដុះទ្រុបទ្រុលរកកល់នឹងស្អាតមិនដល់ភូមិបាសកផង ។ យើងនាំគ្នាឡើងទៅលើសាលាប្រក់ស្លឹកតូច ១ ឃើញលោកសង្ឃឈរខ្លះអង្គុយខ្លះ, ឃើញមានបាសក

---

១ មើលទៅខាងមុខត្រង់ថ្ងៃអាទិត្យ ៥ ណោវែម ១៩៣៣ ។

ទាំងប្រុសទាំងស្រីចាស់ក្មេងប្រហែល ៧០ នាក់. មកជួបជុំចាំនៅទីនោះ ។ គ្រូបង្រៀន វៀង-យ៉ាំង-ផាំ បានចាត់ការឲ្យមនុស្សរត់ទៅយកកៅអីពីសាលារៀនឯភូមិមកជូនលោកអគ្គលេខាធិការអង្គុយ, ឯយើងឈរទាំងអស់គ្នា ព្រោះលើសាលានោះឥតមានចាត់ការរៀបចំអ្វីទេ សូម្បីតែកន្ទេលក៏គ្មានក្រាល ។ លោកសង្ឃដែលប្រជុំក្នុងទីនោះមាន ៣ វត្ត គឺ វត្តត្រពាំងប្រិ. វត្តត្នោត, នឹងវត្តខ្សៀងយុលនេះ, រួមលោកសង្ឃទាំងអស់ ១៨ រូប ។ លោកអគ្គលេខាធិការមានប្រសាសន៍រៀបរាប់អំពីដំណើរដែលមកនេះដោយមានអនុញ្ញាតអំពីរាជការធំក្នុងកូសាំងស៊ីនបានដម្រូវឲ្យមកតាមដំណើរមុខការរបស់ពុទ្ធសាសនបណ្ឌិត្យដើម្បីនឹងបាននិយាយពន្យល់ដល់អស់បណ្ដាជនជាតិខ្មែរ ទាំងអ្នកបួសទាំងគ្រហស្ថឲ្យខំប្រឹងរៀនសូត្រ, ឲ្យខំប្រឹងធ្វើការរបររកស៊ីកុំខ្ជិលប្រអូស, កុំឲ្យបីយខ្សោយគំនិតប្រាជ្ញានឹងទ្រព្យធនជុនជាបទន់ទាបជាងជាតិគេឯទៀត ។ សព្វថ្ងៃនេះរាជការព្រួយមករកបណ្ដាជនជាតិខ្មែរច្រើនណាស់ ព្រោះឃើញខ្មែរច្រើនតែប្រហែសធ្វេសមិនសូវខំប្រឹងរៀនសូត្រ, មិនសូវខំប្រឹង

រកស៊ីធ្វើការ, មិនសូវមានអៀនខ្មាសចំពោះសេចក្ដីល្ងង់ខ្លៅ នឹងទ្រព្យធនដែលទន់ថយខ្សោយជាងជនជាតិឯទៀតនោះឡើយ, ខ្មែរច្រើនតែទំរន់រអ៊ូយបណ្ដោយគំនិតឲ្យលង់ក្នុងសេចក្ដីខ្ជិល...... ។ រួចលោកអគ្គលេខាធិការបានថ្លែងអំពីប្រយោជន៍ដែលរាជការបានបង្កើតសាលាបាឡី, បណ្ណាល័យនឹងពុទ្ធសាសនបណ្ឌិត្យ ឲ្យបណ្ដាជនទាំងនោះស្ដាប់ដោយសព្វគ្រប់រួចហើយបានដាក់ភារៈមកឲ្យខ្ញុំនិយាយពន្យល់តទៅទៀត ។

ខ្ញុំបាននិយាយចំពោះទោរកពួកលោកសង្ឃជាមុនថាៈ ជនជាតិខ្មែរយើងរមែងជាប់ចិត្តជឿព្រះពុទ្ធសាសនាស្ទើរតែនឹងទាំងអស់គ្នា ។ ពួកគ្រហស្ថខំប្រឹងនាំគ្នាបំណាយទ្រព្យកសាងវត្តអារាមដោយពេញកំឡាំង មិនសូវគិតដល់សេចក្ដីក្រីក្រលំបាកប៉ុន្មាន, ផ្ទះលំនៅរបស់ខ្លួន ទោះបីរខេករខាកយ៉ាងណាក៏ដោយចុះ, ស៊ូខំប្រឹងនាំគ្នាសង់វិហារ-សាលា-កុដិ សម្រាប់ពួកអ្នកបួសឲ្យតែខាងបានរុងរឿងជាងលំនៅរបស់ខ្លួន, ហើយថែមទាំងផ្គត់ផ្គង់ពួកអ្នកបួសដោយបច្ច័យមិនឲ្យខ្វះខាតផងទៀត; មិនត្រឹមតែប៉ុណ្ណោះឡើយ, សឹងនាំគ្នាគោរពក្រាបសំពះអ្នក

ឬសរកកល់ផាងការគោរពចំពោះមាតាបិតារបស់ខ្លួនទៅទៀត, ដោយមានសេចក្ដីសង្ឃឹមថា យកបុណ្យយកផលដែលនឹងផ្ដល់ប្រយោជន៍ប្រគល់សេចក្ដីសុខឲ្យពានក្នុងបច្ចុប្បន្ននេះ នឹងបរលោកនាយ, តាមដោយជំនឿរបស់អ្នកកាន់ព្រះពុទ្ធសាសនា ។ មានសង្ឃឹមម្យ៉ាងទៀតថា វត្តអារាមនោះទុកដូចជាឃ្លាំងបំណេះវិជ្ជារបស់កូនចៅរាល់គ្នា ព្រោះជាកន្លែងសម្រាប់រៀនអក្សររៀនលេខនឹងធម៌វិន័យរបស់កូនអ្នកស្រុក ។ កំកូនអ្នកស្រុកដែលមានបំណេះវិជ្ជមានគំនិតប្រាជ្ញាល្អ ឬដែលមកនៅវត្តដែរតែគ្មានបេះអ្វី កំមកតែអំរំមេឃ្លាំងគឺលោកគ្រូជាអ្នកបង្រៀន...។ ព្រោះហេតុនោះគួរលោកគ្រូគ្រប់វត្តខំប្រឹងយកចិត្តទុកដាក់បង្ហាត់បង្ហាញបំណេះវិជ្ជាសិស្សឲ្យពេញកំឡាំងកុំបណ្ដែតបណ្ដោយ, ឲ្យសមគួរដល់សេចក្ដីទំនុកបំរុងរបស់ពួកបាសកជើងវត្ត ដែលគេផ្គត់ផ្គង់យើងដោយកិច្ចសព្វគ្រប់; ម្យ៉ាងទៀត កុំឲ្យជនជាតិឯទៀតគេមើលងាយថា អ្នកបួសក្នុងព្រះពុទ្ធសាសនាខ្ជិលប្រអូស; ស្រុកពីដើមមែន មិនសូវមានបែបផែននឹងគ្រឿងប្រដាប់សម្រាប់រៀនសូត្រ, ឯសព្វថ្ងៃនេះ យើងបានរាជការ

ទំនុកបំរុងឲ្យមានគ្រឿងសម្រាប់រៀនសូត្របរិបូណ៌ហើយ ត្រូវតែយើងនាំគ្នាខំប្រឹងឲ្យពេញកំឡាំងកុំបណ្ដែតបណ្ដោយ, ដើម្បីនឹងយឹតយោងជាតិខ្មែរយើងឲ្យបានមានភ្នែកភ្លឺច្បាស់ ក្រោកដើរតាមផ្លូវធំទូលាយត្រង់ទៅរកទ្រព្យធនដ៍ស្ដុកស្ដម្ភមាំមួនឲ្យបានទាន់គេឡើង... ... ... ។

លុះខ្ញុំនិយាយពន្យល់សព្វគ្រប់ហើយ, លោកចៅអធិការវត្តត្បែងយុលឆ្លើយឡើងថា "បុះបើខំប្រឹងរៀនណាស់ដែរ ប៉ុន្តែរៀនមិនចាំមិនចេះ តើឲ្យធ្វើម៉េចទៅ?" ។ ខ្ញុំបានឆ្លើយតបទៅវិញដោយពាក្យទន់សុភាពថា "ករុណា, ចេះតែខំប្រឹងរៀនតាមកំឡាំងប្រាជ្ញាស្មារតីទៅហ្ន៎ះ! តែខំរៀនហើយ បើទុកជាមិនបានចេះច្រើន ក៏គង់នឹងបានចេះខ្លះពុំខាន" ។ លោកឆ្លើយមកទៀតថា "ខាន សព្វថ្ងៃខំប្រឹងណាស់ដែរ ប៉ុន្តែបើរៀនមិនចាំ មិនដឹងធ្វើម៉េចទេ" ។ ខ្ញុំឆ្លើយតបទៅទៀតដោយសេចក្ដីពន្យល់ថា "មិនមែនដូច្នោះទេលោកគ្រូ, សេចក្ដីខំប្រឹងប្រកបកិច្ចការអ្វីដែលត្រូវទំនងហើយមិនដែលសោះសូន្យទេ, បើមិនប្រទះនឹងប្រយោជន៍ធំក៏គង់ប្រទះនឹងប្រយោជន៍

យ៉ាងតូចណាមួយមិនខាន; សេចក្ដីចំរើនទាំងអស់សុទ្ធតែមកពីតិចពីតូច ទើបក្លាយទៅជាច្រើនជាធំ; លោកគ្រូមិនមើល, យ៉ាងដូចកណ្ដៀរពូនដីឲ្យកើតជាដំបូក, ឃ្មុំសន្សំលំអងនឹងទឹកដមផ្កា ធ្វើឲ្យកើតជាសំបុកជាផ្លិតឃ្មុំទឹកឃ្មុំច្រើនឡើងបាន, ឈើកើតពីពន្លក អាចក្លាយទៅជាដើមឈើធំៗបាន, មនុស្សសត្វកើតឡើងតូចៗ យូរៗទៅ ចំរើនប្រែជាធំៗឡើងបាន; ប៉ុន្ដែបើយើងនឹងសង្កេតរកឲ្យឃើញថាធំក្នុងមួយថ្ងៃៗ តើទំហំប៉ុន្មាន? នោះរកពាក្យនឹងនិយាយប្រាប់គ្នាឲ្យប្រាកដមិនកើត, គេអាចនិយាយបានត្រឹមតែថា មិនដឹងជាធំក្នុងមួយថ្ងៃៗប៉ុន្មានទេ, ស្រាប់តែឃើញធំប៉ុណ្ណឹងឡើងតែម្ដង; ដែលលោកគ្រូថាខំរៀនដែរ ប៉ុន្ដែមិនចាំនោះ ដូចជាមិនត្រូវនឹងទេដឹង? ត្រូវតែខំប្រឹងទៅ, ព្រោះសេចក្ដីចំរើនគ្រប់យ៉ាង កើតមកតែអំពីខំប្រឹងរៀនសូត្រ......" ។ លុះខំនិយាយពន្យល់ប៉ុណ្ណោះហើយ, លោកចៅអធិការនោះក៏ស្ងៀមលែងថាអ្វីតទៅទៀត ប៉ុន្ដែមើលទៅអាការដូចជាមិនគាប់ចិត្តនឹងសេចក្ដីពន្យល់នោះទេ; ឯលោក

សង្ស័យទៀតស្ងៀមៗមិនព្រមឆ្លើយថាអ្វីឡើយ, ប៉ុន្តែសង្កេតមើលទៅឃើញមានអាការថ្នឹង ៗ ដូចជាគ្នា ។

លុះនិយាយពន្យល់ពួកបញ្ជិតទាំងនោះរួចហើយ, ខ្ញុំបែរនិយាយទៅរកពួកគ្រហស្ថទាំងប៉ុន្មានដែលមកប្រជុំក្នុងទីនោះ មុនដំបូង ខ្ញុំសួរអំពីសេចក្តីក្រីក្រលំបាករបស់បណ្តាជនទាំងនោះបន្តិចសិនៈ អ្នកទាំងនោះក៏ឆ្លើយរញ៉ារាល់គ្នា ត្អូញអំពីសេចក្តីទាល់ក្រលំបាក, អំពីដំណើរទាល់គំនិតនឹងរកទ្រព្យន... ... ។ ខ្ញុំក៏បាននិយាយដាស់តឿនរំឭកឲ្យខំខ្នះខ្នែងងប្រឹងធ្វើការរបរផ្សេង ៗ មានឲ្យខំគាស់រានស្រែចំការាយដាំដំណាំអ្វីដែលមានប្រយោជន៍ទាន់ចិត្ត ឲ្យសមតាមលសម័យក្រីក្រនេះជាដើម ។ រួចហើយខ្ញុំនិយាយពន្យល់ោសសេចក្តីខ្ជិល, អំពីទោសលេងល្បែងភ្នាល់មានលេងអាប៉ោងជាដើម. អំពីទោសផឹកស្រា, តាមលំដាប់ហូរ-អ្នកទាំងនោះស្តាប់ ។ រួចនិយាយអំពីសណ្តាប់ធ្នាប់ពាក់របស់ជាតិខ្មែរដែលគួររក្សាទុកកុំឲ្យបាត់ ដើម្បីឲ្យខ្សែដល់ជាតិរបស់ខ្លួន... ។ រួចនិយាយពន្យល់អំពីដំណើរ

ឲ្យអស់រាស្ត្រប្រជាតាំងចិត្តស្លូតត្រង់នឹងរាជការ, អំពីគុណបំណាច់ដែលរាជការខំប្រឹងទំនុកបំរុងស្រោចស្រង់ប្រជាជនឲ្យបានសេចក្ដីសុខសេចក្ដីចំរើន ដូចជាមាតាបិតាបីបាច់រក្សាកូន, អំពីឲ្យមានអំណរនឹងការដែលរាជការលើកថ្កល់សង់ស្ពានឲ្យរាស្ត្រប្រជាទៅមករកស៊ីធ្វើការបានដោយស្រួលជាងពីដើម, អំ-ពីកុំឲ្យភ្ញាក់ផ្អើលឆោតភាន់គំនិតជឿពួកកោងាយ ...... ។

លុះនិយាយពន្យល់សព្វគ្រប់ទៅ, សង្កេតមើលអាការពួកគហស្ថទាំងនោះឃើញមានសេចក្ដីរីករាយស្រស់មុខរាល់គ្នា; បើតាមទំនងក្នុងវេលានោះ, គួរនឹងឲ្យមានសង្ឃឹមថាមុខជានឹងប្រែគំនិតខ្លះ, នឹងខំប្រឹងធ្វើការរកស៊ីបន្តិចឡើងជាងពីដើម, នឹងខំដាស់តឿនកូនចៅឲ្យប្រឹងរៀនសូត្រ; ប៉ុន្តែបើនឹងបែរជាលូតលាស់ដុះចំរើនឡើងមិនរួច ឬក៏បែរជាយឺតមិនអាចនឹងធ្វើសេច-ក្ដីចំរើនឲ្យកើនឡើងបាននោះ ក្រែងតែនឹងមានហេតុទាស់អំពីពួកបព្វជិតក្នុងវត្តទាំងនោះនាំអាទ៌ឲ្យទើសទាក់ដំណើរ, ព្រោះសង្កេតមើលទៅអាការរបស់បព្វជិតទាំងនោះឃើញនៅរឹងត្អឹងណាស់ ។

លុះនិយាយពន្យល់ដូច្នេះរួចហើយ, លោកអគ្គលេខាធិការបាន ឲ្យបែករូបថ្លុតពុម្ពដល់បព្វជិតនឹងគ្រហស្ថទាំងនោះ រួចលាគេ ត្រឡប់មកតាមផ្លូវដើមវិញ ។ គ្រូបង្រៀនឈ្មោះវៀង-យ៉ាំង-ផាំ ជាមួយនឹងសិស្សសាលាច្រើននាក់ ក៏តាមជូនយើងរហូតមក ដល់ទីដែលរថយន្តឈប់ចាំនោះវិញ ។ លោកអគ្គលេខាធិការ បានចែកសៀវភៅតូច ៗ ដែលនិយាយអំពីទោសលេងល្បែង ភ្នាល់នឹងទោសផឹកស្រាឲ្យកុមារសិស្សសាលាទាំងនោះ រួច ហើយក៏លាគេវិលត្រឡប់មកទីរួមខេត្តតែនិញវិញ ។ ម៉ោង ១១ ដល់មកទីរួមខេត្ត ។ លោកអគ្គលេខាធិការទៅទទួលភោ-ជនាហារឯភោជនាគារបារាំង, យើងទៅឯភោជនាគារចិនមួយ ដែលមានកន្លែងច្រើនអន្លើសមគួរដល់អ្នកដំណើរ សម្រេច ភត្តកិច្ចហើយឈប់សម្រាកបានតាមការស្រួលមិនបង្អៀតចិត្ត ។

លុះដល់ម៉ោង ១៣ គឺម៉ោង ១ រសៀល យើងចេញពីទីរួម-ខេត្តមកឯវត្តមន្ត្រីសាគរ, ម៉ោង ១៤ ដល់មកវត្តនោះ ។ កាល ដែលរថយន្តចូលទៅដល់ក្នុងវត្ត, ឃើញមានពួកលោកសង្ឃ នឹងគ្រហស្ថឈ្មោះមកឈរទទួលត្រៀបត្រាសំដែងអាការសាទរ

រីករាយទាំងអស់គ្នា ហើយគេនាំយើងឡើងទៅលើសាលា; នៅមុខសាលានោះគេមានធ្វើស៊ុម ១ សមរម្យគ្រាន់បើដែរ ត្រង់មុខស៊ុមនោះគេដោតផ្កាបារាំងព័ណ៌ ក្រហម, ស បម្រុះគ្នាជារូបតួអក្សរបារាំងដាក់ឈ្មោះឃុំ "ត្រពាំងរបង", មានដោតទង់ព្រោងព្រាតអមតាមផ្លូវក្នុងវត្តនឹងក្នុងសាលា ៗ នោះគេរៀបតុតាំងជាផ្លូវសង្កាត់មានកៅអីរៀបតាមលំដាប់, ខាងលើបងសុទ្ធ-តែពិតានសម្រាប់វត្តៈ នៅថ្នាក់សាលាខាងលើត្រង់ទីខាងមុខបង្អស់នោះ គេរៀបតាំងសុទ្ធតែមែកឈើជាប់ទាំងស្លឹកស្រស់ ៗ ដោតនឹងដប មានសាប់ឈើបន្ទះតូច ៗ បងភ្ជាប់នឹងដបទាំងនោះផង, ដបខ្លះដោតសុទ្ធតែវល្លិដំឡូងព្រៃច្រើនយ៉ាង (ដបមួយ ៗ ដោតមួយមុខ ៗ), ដបទាំងអស់សុទ្ធតែមានស្លាកសរសេរអក្សរខ្មែរប្រាប់ឈ្មោះឈើ នឹងវល្លិដំឡូងទាំងនោះផង, គេរើសយកបំពោះតែឈើនឹងដំឡូងណាដែលមានប្រយោជន៍ប្រើការកើត ដូចយ៉ាងឈើធ្នង់, គ្រើល, ត្រាច, ខ្លង, ត្បែងជាដើមៈ ដំឡូងជ្រូក, ដំឡូងទៀន, ដំឡូងទឹកជាដើម យកមកដាក់

តាំងតាមរបៀបរៀបរៀងជាជួរ ៗ គួរឲ្យចង់មើល ១ ស្របក់ទៅដែរ ។

ក្នុងទីប្រជុំនេះមានមនុស្សច្រើនប្រហែលជាង ២០០ នាក់ ។ មានលោកសង្ឃ ៧ វត្ត គឺ វត្តភូមិស្វាយ, វត្តរាជហង្ស, វត្តព្រះរមៀត, វត្តពោធិ៍សិរី, វត្តឈើទាលជ្រុំ, វត្តភ្នំកុមារ, ជា ៧ នឹងវត្តមន្ត្រីសាគរនេះ; រួមលោកសង្ឃទាំងអស់ ៣១ រូប ។ លោកចៅហ្វាយខណ្ឌនាមហ៊ិន[១] (ខណ្ឌត្រពាំងរបង) នឹងលោកគ្រូចៅអធិការវត្តមន្ត្រីសាគរព្រមទាំងលោកមេឃុំ ឈ្មោះ សួង បានចូលមកឈរក្នុងទីចំពោះមុខលោកអគ្គលេខាធិការ ថ្លែងសេចក្តីសោមនស្សទទួលអំណរដោយពាក្យសារសព្ទរៀប-រាប់មានប្រការផ្សេង ៗ; រួចហើយលោកមេឃុំសួងជំរាបលោកអគ្គលេខាធិការថា "សូមជំរាបលោកត្រី, ឈើនិងវល្លិដំឡូងទាំងប៉ុន្មានមុខនេះ ខ្ញុំបាទឲ្យរកយកមករៀបតាំងបង្ហាញលោកស្រីឲ្យបានជ្រាបថា: ស្រុកយើងខ្ញុំនេះជាស្រុកព្រៃ មិនមានរបស់

១ លោកចៅហ្វាយខណ្ឌ ហ៊ិន នេះ ជាកូនប្រុសរបស់លោកចៅហ្វាយខណ្ឌ ហង្ស ដែលទទួលរ៉ែត្រែតហើយ ។

អ្វីឲ្យប្លែកជាងនេះនឹងយកមកបង្ហាញលោកទេ. ឈើនឹងដំឡូងទាំងនេះហើយជារបររាយរងរបស់ប្រជាជនស្រុកយើង; ដើមគ្រើលនុ៎ះសម្រាប់យកជ័រធ្វើម្រាក់ដែលទុកជារបរ ១ យ៉ាងរបស់អ្នកស្រុកព្រៃ, ឈើឯទៀតក្រៅពីនោះសម្រាប់ប្រើការដោយមុខផ្សេងៗ ដូចលោកធ្លាប់ជ្រាបខ្លះហើយ; ដំឡូងព្រៃទាំងប៉ុន្មានយ៉ាងនុ៎ះសម្រាប់ប្រើជាអាហារចិញ្ចឹមជីវិត គឺជីកយកមើមមកស្ងោរទទួលទានតាមរដូវ ឬក៏កាលណាបើស្រុកកើតអំណត់អត់ឃ្លានដោយគ្មានស្រូវអង្ករបរិបូណ៌ អ្នកស្រុកនាំគ្នាចូលព្រៃជីកមើមដំឡូងទាំងនោះមកស្ងោរទទួលទានជំនួសបាយ ឬពុំ-នោះយកមកលាយបាយដើម្បីឲ្យចាល់កុំឲ្យអស់អង្ករច្រើន ។ ១៩, ឈើនឹងដំឡូងទាំងអស់នេះមានប្រយោជន៍យ៉ាងសំខាន់ដល់បណ្ដារាស្ត្រក្នុងស្រុកនេះ, ព្រោះហេតុនោះហើយបានជាខ្ញុំបាទហ៊ានប្រឹងប្រយ័ត្នរកយកមកដាក់រៀបតាំងបង្ហាញសុំឲ្យលោកបានជ្រាប" ។

លុះចប់សេចក្ដីរៀបរាប់របស់លោកមេឃុំ ស្នួង ហើយ, លោកអគ្គលេខាធិការក៏សំដែងអាការរីករាយដោយច្រើន ចំពោះ

ដំណើរដែលបានយកឈើនឹងវល្លិដំឡូងមកតាំងនោះ ហើយសរសើរលោកមេឃុំ សួង ថាមានប្រាជ្ញាពន្លាសវៃ បេះវិះរកគំនិតប្លែកកំបាំងដែលមិនមានអ្នកណាមួយគិតឃើញ... ... ។ ហើយលោកអគ្គលេខាធិការបានថ្លែងអំពីដំណើរដែលរាជការបានដម្រូវឲ្យមកអង្គុយណៅក្នុងខេត្រតែនិញនេះ ឲ្យអស់បណ្ដាជនទាំងនោះស្ដាប់សព្វគ្រប់, រួចទើបប្រគល់ភារៈមកឲ្យខ្ញុំនិយាយពន្យល់ទៀត, ខ្ញុំក៏បាននិយាយពន្យល់តាមហួរហែដូចគ្នានឹងរបៀបនិយាយឯវត្តត្បែងយុលដែរ ។

លុះចប់សេចក្ដីពន្យល់របស់ខ្ញុំហើយ, លោកគ្រូចៅអធិការនឹងលោកគ្រូសូត្រទាំង ៣ វត្តព្រមទាំងលោកមេឃុំត្រពាំងរបងបានជំរាបលោកអគ្គលេខាធិការថា សុំឲ្យលោកចៅអធិការគ្រប់វត្តក្នុងខេត្រតែនិញនេះ មានត្រាសម្រាប់ទីចៅអធិការឲ្យដូចរបៀបដែលរាជការក្នុងកម្ពុជរដ្ឋបានរៀបចំហើយនោះផង ដើម្បីនឹងបានបោះលើដាយាឬលើសំបុត្រដីកានីមួយ ៗ កុំឲ្យមានមនុស្សក្លែងក្លាយបន្លំបាន ។ លោកអគ្គលេខាធិការបានកត់ត្រាសេចក្ដីសុំនោះ ហើយមានប្រសាសន៍ថា ចាំខ្ញុំធ្វើសេចក្ដីប្ដឹង

រាជការធំខាងក្រសួងស៊ីវិល... ។ លុះនិយាយពន្យល់សព្វគ្រប់ហើយ បានបែករូបថតពុម្ពដល់ពួកសន្និបាតនោះ ។

ខ្ញុំសង្កេតមើលទៅការប្រជុំក្នុងវត្តមន្ត្រីសាគរនេះឃើញជាមានប្រយោជន៍ជាងការប្រជុំខាងវត្តត្បែងឃ្មុំលប្រើនណាស់ ពីព្រោះឃើញអាការរបស់ពួកសន្និបាតនេះ សំដែងទំនងលំនាំគួរឲ្យសង្ឃឹមថា តពីថ្ងៃនេះទៅ ពួកបព្វជិតនឹងគ្រហស្ថទាំងនោះនឹងភ្ញាក់រឭកនឹកឃើញដល់សេចក្ដីអៀនខ្មាស ហើយនឹងខំប្រឹងបំពេញការសិក្សាឲ្យបានចំរើនឡើងខ្លះមិនខាន ។

ម៉ោង ១៦ កន្លះ គឺម៉ោង ៤ កន្លះរសៀល យើងចេញពីវត្តមន្ត្រីសាគរត្រឡប់មកទីរួមខេត្តតៃនិញវិញ ។ យប់នោះយើងសំណាក់នៅភោជនាគារបារាំងក្នុងទីរួមខេត្តតៃនិញ ។

ថ្ងៃអាទិត្យ ៥ ណោវ៉ែម ១៩៣៣

ម៉ោង ៧ ព្រឹក យើងចេញពីភោជនាគារតៃនិញតាមផ្លូវខាងត្បូង សំដៅទៅវត្តព្រៃជេត ឃុំព្រៃជេត ខណ្ឌខាងឆ្វេង ខេត្តតៃនិញ ។ ម៉ោង ៨ ដល់ទៅផ្សារកំពង់ក្រាប់ (យួនហៅខយ៉ូវិហា),

ទីដំបន់នេះប្រៀបប្ចូបនឹងផ្លូវប្រទេសរាជលេខ ១ ពីភ្នំពេញទៅព្រៃនគរ; (នៅទីនេះមានស្ពានបេតុងអារម៉េ ១ ធំខ្ពស់វែងលៃឆ្លងព្រែក) ។ យើងឈប់ ១ ស្របក់ហើយបុះទូកបៃរ ២ ដែលអ្នករាជការឃុំព្រៃផេតបានចាត់មន្ត្រីឃុំ (ជាតិយួន) ទីជំទប់ ២ នាក់នឹងរាស្ត្រ (ជាតិយួន) ២ នាក់ឲ្យមកចាំទទួលយើងនៅទីនោះ ។ ចេញពីព្រែកធំនោះបន្តិចទៅ យួន ២ នាក់ដោលទូកតាមជ្រលងជលមាគ៌(១) ទៅខាងទិសនិរតីយ៍សំដៅទៅវត្តព្រៃផេត ។ ផ្លូវដែលទៅនេះកាត់វាលធំមានសុទ្ធតែស្មៅបបូតដុះទ្រុបទ្រុលតាន់តាប់ ក្រឡេកមើលទៅគ្រប់ទិសឃើញឆ្ងាយល្ហឹមដាច់កន្ទុយភ្នែក ។ អ្នកស្រុកនៅដំបន់នេះច្រើនធ្វើកន្ទួលបបូតដែលទុកជារបស់សំខាន់ ១ យ៉ាងក្នុងខេត្តនេះវិញ ។ ម៉ោង ១០ ដល់ភូមិកំពង់ថ្មី, ឃើញមានខ្មែរប្រុសស្រីច្រើននាក់នឹងរទេះក្របី ៣ មកចាំទទួលយើង ៗ ឡើងជិះរទេះក្របីបរតាមផ្លូវកាត់វាលស្រែទៅ; មានបណ្ដាជនខ្មែរប្រុសបិតចាស់ក្មេងច្រើននាក់ឈូឆរដើរមុខក្រោយរជយជាមួយនឹងយើងទៅ ។ ម៉ោង ១០ កន្លះដល់

១ ជ្រលងផ្លូវទឹក ។

ប្ជល់នោះមានមនុស្ស ២ នាក់ឈរកាន់ក្លស់យួនរំភាយប៉ាក់រូបនាគ, បើកក្លស់ឈរអមទាំង ២ ខាង (ក្លស់ទាំង ២ នេះគេគ្រាន់តែបើកកាន់ជាគ្រឿងលំអឲ្យរុងរឿងប៉ុណ្ណោះ. ជាក្លស់សម្រាប់វត្តនេះ) ។

លុះយើងទៅដល់ គេអុជផាវតូចធំឮសូរខ្ទរសង្កៀរត្រចៀក, លេងភ្លេងទាំង៣វង់ ព្រមទាំងទូងស្គរធំក្នុងវត្តទ្រហឹងអឹងអាប់ ។ លោកគ្រូចៅអធិការវត្តព្រមទាំងអ្នកមុខអ្នកការខ្លះចូលមកទទួលយើងដោយបដិសណ្ឋារៈដ៏សមគួរ ហើយសុំឲ្យលោកអគ្គលេខាធិការអញ្ជើញទៅមុន ជាមួយនឹងស្ត្រីក្រមុំខ្មែរ ៤ នាក់ ។ លុះលោកអគ្គលេខាធិការអញ្ជើញទៅដល់ត្រង់សង្កាត់ទី៧ ពួកស្ត្រីខ្មែរក្រមុំជំទង់ទាំងនោះនាំគ្នាដើរហែមរោមមុខក្រោយ នាំចូលទៅក្នុងរោងឧបោសថ (វិហារ) ហើយយកភ្លួងផ្កាជូនឲ្យលោកអគ្គលេខាធិការថ្វាយព្រះពុទ្ធរូប រួចស្ត្រីទាំងនោះក៏យកភ្លួងផ្កាដែលកាន់រាល់ដៃចូលទៅថ្វាយព្រះពុទ្ធរូបតាមលំដាប់គ្នា ។ រួចហើយគេនាំយើងចូលទៅក្នុងបារាំធំៗ នោះគេរៀបចំហិកហាក់ណាស់, លោកគ្រូចៅអធិការនិយាយប្រាប់ខ្ញុំថាត្រឹមតែចាត់ការ

រៀបចំនោះពេញកន្លះខែគត់ទើបហើយស្រេច ។ ដល់ម៉ោង ១១ យើងចេញពីបារាំនោះទៅទទួលភោជនាហារតាមទីដែលគេចាត់ការទទួលដោយឡែកៗ. រួចហើយសម្រាកតាមគួរដល់វេលា, រង់ចាំពេលឲ្យអស់បណ្ដាជនទាំងនោះហើយរវល់ដោយភត្តកិច្ចរាល់គ្នា ។

ម៉ោង ១៤ គឺម៉ោង ២ រសៀល[១] ចូលទៅប្រជុំក្នុងបារាំធំ; លោកគ្រូចៅអធិការព្រមទាំងអាចារ្យវត្តជំរាបលោកអគ្គលេខាធិការថា កាលបើចប់សេចក្ដីពន្យល់អំពីកិច្ចការទាំងពួងហើយ សុំលោកមេត្តាកុំប្រញាប់រួសរាន់ពេក, យើងសូមនិមន្តព្រះតេជព្រះគុណព្រះសាសនសោភ័ណសំដែងធម៌ឲ្យទានបាន ១ ម៉ោង ដ្បិតអស់ពួកញាតិញោមស្រុកនេះមិនដែលបានស្ដាប់ធម៌ព្រះ

---

១ អ្នកដែលមិនទាន់យល់ក្នុងដំណើររាប់ម៉ោងតាមបែបប្រើក្នុងសម័យសព្វថ្ងៃនេះ, គួរដឹងដូច្នេះ ៖ ពីត្រឹមបន្ទាប់ពេលអធ្រាត្រទៀងទៅ ត្រូវរាប់ថា ម៉ោង១, ម៉ោង ២ ។ ល ។ ដល់ម៉ោង ១២ (ថ្ងៃត្រង់); តពីនោះទៅ ត្រូវរាប់ថា ម៉ោង១៣, ម៉ោង១៤ ។ ល ។ ដល់ម៉ោង ២៤ (គឺម៉ោង ១២ អធ្រាត្រពីដើមនុ៎ះឯង) ។ ក្នុងថ្ងៃ ១ យប់ ១ មាន ២៤ ម៉ោងប៉ុណ្ណោះ, ហៅរួមថា "១ ថ្ងៃ" ឬថា "២៤ ម៉ោង" ក៏បាន ។ (តពីត្រឹមនេះទៅមិនបាច់មានពាក្យថែមប្រាប់ម៉ោងទៀតទេ) ។

តេជព្រះគុណអង្គនេះនោះ តាំងពីបានឮដំណឹងថា នឹងនិមន្តមកនោះ សឹងមានអំណរប្រុងត្រចៀកចាំស្ដាប់ធម៌តែរាល់គ្នា ។ លោកអគ្គលេខាធិការក៏មានសោមនស្សទទួលព្រមតាមពាក្យសុំនោះ, ហើយមានប្រសាសន៍ពន្យល់អំពីដំណើរដែលមកនេះ, រួចហើយប្រគលភារៈឲ្យខ្ញុំនិយាយពន្យល់តទៅទៀត, ខ្ញុំក៏បាននិយាយពន្យល់ដូចទំនងវត្តឡែងយុលនឹងវត្តមន្ត្រីសាគរសព្វគ្រប់ហើយ ក៏ឡើងអង្គុយលើគ្រែធម្មាសន៍ សំដែងធម៌-ទេសនាតាមទំនងសមគួរដល់ពួកសន្និបាតនោះ បំនួនកន្លះម៉ោងគត់ក៏បញ្ចប់ធម៌ទេសនា ។ បណ្ដាជនទាំងអស់ក៏ទទួលអនុមោ-ទនាថា "សាធុ" ព្រមគ្នា សំដែងអាការរីករាយច្រើន ។ រួចហើយលោអគ្គលេខាធិការបានឲ្យចែករូបផ្តិតពុម្ពដល់ពួកសន្និ-បាតនោះ ហើយថតរូបពួកលោកសង្ឃ ២ លើក, ពួកឧបាសក ២ លើក ។ ម៉ោង ១៦ កន្លះចេញពីវត្តព្រៃជេតត្រឡប់មកវិញៈ វេលានោះគេលេងភ្លេងតន្ត្រីទ្រហឹងអឹងអាប់ទៀត, មានមនុស្សរាប់រយឈរជូនចេញមក, ដល់ស៊ុមទ្វារនៅក្បាលថ្នល់ លោកអគ្គលេខាធិការថតរូប ២ លើកទៀត, រួចហើយលាគេមក;

មានមនុស្សច្រើននាក់តាមជូនយើងរហូតដល់មកភូមិកំពង់ថ្មី យើងលាគេបុះទូកមក, មន្ត្រីឃុំ ២ នាក់ដែលមកទទួលពីព្រឹក នោះក៏បុះទូកជូនយើងមកទៀត; ម៉ោង ១៩ ដល់មកកំពង់ក្រាប់ យើងលាគេឡើងរថយន្តមក, ម៉ោង ២០ ដល់ទីរួមខេត្តតែនិញ; យើងសំណាក់នៅភោជនាគារដដែលនោះទៀត ។

គួរសាទៅថ្លែងអំពីវត្តព្រៃផេតបន្តិចវិញៈ លោកគ្រូចៅ-អធិការវត្តនេះឈ្មោះ គួប-ចាប អាយុ ៥៤ ឆ្នាំ បួសបាន ៣៤ វស្សាហើយ, ចេះអក្សរយួនស្ទាត់, ចេះភាសាយួនយ៉ាងជ្រៅជ្រះ, មានប្រាជ្ញាឈ្លាសវាងវៃ យល់គតិលោកគតិធម៌នឹងទំនៀម សណ្ដាប់មិនសូវធ្លល់, ព្រមទាំងកិច្ចការដែលរាជការរៀបចំ ស្រុកទេស ឲ្យអស់ប្រជាជនបានសេចក្ដីសុខចំរើន, ឲ្យថ្កើងរុងរឿង, លោកគ្រូនេះក៏យល់មិនសូវជឿងធ្ងល់ណាស់ប៉ុន្មាន, ជាអ្នកមានអធ្យាស្រ័យទន់ភ្លន់សុភាពរាបសា ។ ខ្ញុំធ្លាប់ស្គាល់ លោកមកយូរហើយ, កាលពីក្នុងឆ្នាំ ១៩២៩ លោកគ្រូ គួប-ចាប នេះ បានសុំអនុញ្ញាតរាជការទៅនៅរៀនបែបបទបង្ហាត់ បង្រៀនអក្សរនឹងលេខព្រមទាំងរបៀបធម៌វិន័យឯសាលារៀន

នៅវត្តលង្កា, ប្រឡងបានសញ្ញាបត្រហើយវិលត្រឡប់មកនៅឯវត្តព្រៃជើតវិញ; បានខំប្រឹងបង្ហាត់បង្រៀនភិក្ខុសាមណេរនឹងពួកកុមារសិស្សសាលាវត្តនូវអស់ពួកបាសកទាយកឲ្យបានចំរើនដោយការចេះដឹង, មានរបៀបរបបរាបសាស្រួលបួលជាងវត្តទាំងអស់ក្នុងខេត្តតែនិញ ។

ថ្ងៃចន្ទ្រ ៦ ណោវិម ១៩៣៣

ម៉ោង ៩ ព្រឹក យើងចេញពីទីរួមខេត្តតាមផ្លូវទៅខាងទិសឧត្តរសំដៅទៅឃុំសែជរ (យួនហៅឡាងខែជង) ខណ្ឌជើងម្លែង ខេត្តតែនិញ ។ ម៉ោង ៩ កន្លះដល់ទៅសាលាប្រក់ស្លឹកតូច ១ ក្នុងឃុំសែជរ ជាសាលាគេសម្រាប់ប្រជុំគ្នាធ្វើបុណ្យម្ដង ៗ; មានមនុស្សមកប្រជុំចាំនៅនោះប្រហែលជា ៧០ នាក់; លោកចៅហ្វាយខណ្ឌឈ្មោះគង់ (ជាតិខ្មែរ) ព្រមទាំងមន្ត្រីឃុំពីរបីនាក់មកឈរចាំទទួលយើងនៅក្បែរថ្នល់, នាំយើងចូលទៅក្នុងរោងតូចនោះ។ក្នុងទីប្រជុំនេះមានលោកសង្ឃតែបីរូបគឺលោកចៅអធិការវត្តជីពាយ ១ វត្តក្អក ១ វត្តក្អម ១, ឋានៅមានវត្តត្រពាំងភ្លោះ ១ ទៀត លោកចៅអធិការមកមិនទាន់ពេល ។ ក្នុង

ខណ្ឌនេះមានវត្តលោកសង្ឃខ្មែរតែ ៤ ប៉ុណ្ណោះ, ជាវត្តនៅឆ្ងាយៗ ពីប្លល់រាជការណាស់, ព្រោះហេតុនោះបានជាគេនិមន្តលោកឲ្យមកប្រជុំក្នុងទីនេះ ។ លោកចៅហ្វាយខណ្ឌប្រាប់យើងថា ក្នុងខណ្ឌនេះមិនសូវមានខ្មែរសុទ្ធទេ ច្រើនមានតែជាតិកូនកាត់ គឺជាតិកូនសួនផ្ទាំងដែលក្លាយៗមកជាខ្មែរ, ក្រៅពីនោះមានសុទ្ធតែយួន: ខ្មែរក្លាយទាំងនោះច្រើនល្ងង់ខ្លៅណាស់ មិនសូវមានអ្នកចេះអក្សរទេ, ខាងកិច្ចការរបរចិញ្ចឹមជីវិតក៏ទន់ថយជុនដាបណាស់...... ។

លោកអគ្គលេខាធិការបានពន្យល់ដូចវត្តឯទៀត ហើយប្រគល់ភារៈមកឲ្យខ្ញុំ ៗ ក៏និយាយពន្យល់ដូចវត្តឯទៀតមុនៗនោះដែរ ។ រួចហើយចែករូបថតព្រះពុទ្ធដូចវត្តឯទៀត ។ លោកអគ្គលេខាធិការបានថតរូបពួកខ្មែរទាំងនោះ ២ លើក ។ ម៉ោង ១០ និង ២៥ មិនុតត្រឡប់មកឯទីរួមខេត្តតៃនិញវិញ: ម៉ោង ១០ និង ៥៥ មិនុតដល់ទីរួមខេត្ត ។ ម៉ោង ១២ កន្លះ យើងចេញពីទីរួមខេត្តតៃនិញតាមផ្លូវដដែលមកភ្នំពេញវិញ; ម៉ោង ២១ ដល់ភ្នំពេញ ។



ព្រះពុទ្ធរូបសៃយាសន៍ យ៉ាគធំ សាងក្នុងរាង ព. ស. ១៨៨០ នៅក្នុងវត្តស៊ុនប៊ុនថាលីយោគ្គ
ក្រុងពគន (ភូមា)

ទ៏មាទេមសរលាកថា

(ត)

# ព្រះមហាពិទូរ ក្រសេម ត្លរបនបណ្ឌិត

គតិរាប់អានព្រះនារាយណ៍

ព្រះនារាយណ៍នេះ រាប់ថាជាព្រះ ១ អង្គក្នុងសាសនាព្រាហ្មណ៍មានព្រះនាមសម្រាប់ហៅជាច្រើនយ៉ាង មានព្រះនាមថា វិស្ណុ, ហរិ, ជាដើម ។ ក្នុងរឿងដំណាលថា កាលដើមឡើយ ព្រះវិស្ណុជាទេវតាជាន់រង តមកកើតសង្គ្រាមធំៗជាច្រើនលើក ដូចមានប្រាកដក្នុងរឿងអវតាររបស់ព្រះវិស្ណុនោះស្រាប់ ជាអ្នកមានស្នាដៃក្នុងសង្គ្រាមយ៉ាងឯក ទើបបានជាព្រះ ១ អង្គរួមក្នុងលទ្ធិព្រហ្មញ្ញជាមួយគ្នា ព្រះតេជព្រះគុណរបស់ព្រះវិស្ណុ ក៏គឺជាស្តេចសឹកដ៏ឯក តែងតែកម្រាបសឹកសត្រូវ ដែលកើតបណ្ដា-បលៈឡើងក្នុងទេវលោក នឹងមនុស្សលោកដោយព្រះអង្គឯងខ្លះ ជួនកាលទ្រង់បែងភាគឲ្យមកកើតជាអ្នកឯណានីមួយ សម្រាប់កម្រាបសឹកឲ្យស្ងប់រាបទាបទៅ ដូចយ៉ាងកាលទ្រង់បែងភាគឲ្យមកកើតជាព្រះក្រិស្នា កម្រាបអសូរឈ្មោះពាណាសូរ, បែងភាគជាព្រះរាម កម្រាបស្តេចយក្ខឈ្មោះរាពណ៍, បែងភាគជាមនុស្សគម កម្រាបស្តេចបិសាច ឈ្មោះក្រុងពលីជាដើម

ខ្លះ ។ គេថា ព្រះនារាយណ៍នេះជាអ្នកសាងលោកដែរ តែមិន
ប្រទះរឿងថាសាងដូចម្ដេច មានតែរឿងបែងភាគនេះឯង ព្រោះ
នាម "នារាយណ" នេះប្រែថាជាដែនកើតនៃនរ គឺមនុស្ស ។
កំណើតរបស់លោកកើតអំពីអ្វី នៅមិនទាន់ប្រទះ ទីលំនៅ
របស់លោកឈ្មោះវៃកុណ្ឋ តែច្រើនតែប្រថាប់ទៅលើខ្នងនាគ
ក្នុងស្រមុទទឹកដោះ មានព្រះទេពីឈ្មោះលក្ស្មី មានព្រះបុត្រ
ឈ្មោះកាមទេព ។

ព្រះព្រហ្ម ព្រះឥស្វរ ព្រះនារាយណ៍ទាំង ៣ អង្គនេះជា
ព្រះធំបំផុតក្នុងលទ្ធិព្រហ្មញ្ញ ។ ពាក្យថា ឧ. អ. ម. នេះ
ជាត្រៃនាម គឺជាត្រៃសរណគមន៍របស់គេ គេរួមហៅជាមួយ
គ្នា ដូចយ៉ាងយើងរួមព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហៅថា ត្រៃ-
សរណគមន៍ដូច្នោះ តែតាមដែលឃើញគេយកមកប្រើសូតជា
អាគមថា ម. អ. ឧ. ដូច្នេះក៏មាន ។ ក្រៅអំពីព្រះដែលពោល
មកហើយ មានព្រះអាទិត្យជាដើម ពួកព្រាហ្មណ៍នៅមានរាប់
អានព្រះចតុលោកបាលទាំង ៤ គឺ កុវេរ ធតរដ្ឋ វិរូបក្ខ វិរុឡ្ហក.
នឹងក្រុងពលី ដែលជាស្ដេចនៃពួកបិសាច ព្រះយមរាជ ដែល

ជាស្ដេចនៃសត្វនរក ព្រះខន្ធកុមារ ឬហៅថា ព្រះស្កន្ទ ដែលជាស្ដេចនៃការបោរកម្ម នឹងជាមេទ័ពរបស់ទេវតា, ព្រះគណេសដែលមានខ្លួនជាមនុស្ស ក្បាលជាដំរី, ព្រះព្រហស្បតិ៍ ជាគ្រូនៃទេវតាទាំងឡាយ នឹងព្រះសរស្វតី ទេពីព្រះព្រហ្ម, ព្រះឧមាទេពីព្រះឥសូរ ព្រះលក្ស្មីទេពីព្រះវិស្ណុ ការដែលរាប់អានព្រះអំបាលនេះដោយគំនិតគេយល់ដូចម្ដេច ប្ដូរមើលក្នុងគតិបដិបត្តិក្នុងត្រៃវេទ ដូចមានពោលខាងមុខ ។

## គម្ពីរត្រៃវេទ

គម្ពីរក្នុងលទ្ធិនេះ បំណែកចេញជា ៣ ផ្នែក តែរួមគ្នាហៅថា "ត្រៃវេទ" ប្រែថា ព្រះវេទ ៣ ប្រការ មានអាការប្រហែលគ្នានឹងគម្ពីរព្រះត្រៃបិដកក្នុងពុទ្ធសាសន៍ សំដែងអំពីពិធីបួងសួងទេវតា នឹងពិធីបូជាយញ្ញ ព្រមទាំងមន្តសម្រាប់សែន នឹងសំដែងអំពីកិច្ចដែលគប្បីបំពេញមានប្រការផ្សេង ៗ ទៀត គឺ

១— សាមវេទ សំដែងអំពីពិធីអារក្ខាពលីកម្ម គឺធ្វើពលីកម្ម សូមឲ្យព្រះឥន្ទ្រនឹងព្រះពរុណអភិបាលមនុស្សលោក

ឲ្យបង្អោរភ្លៀងចុះមកស្រោចស្រង់លោកត្រីតាមរដូវកាល ឲ្យធញ្ញជាតិនឹងបណ្ដាដំណាំទាំងពួង ដុះលូតលាស់ល្អបរិបូណ៌ ឲ្យមនុស្សសត្វបានអាស្រ័យចិញ្ចឹមជីវិត មានកូនចៅចំរើនពូជពង្ស នឹងសូមឲ្យបានប្រាសចាកឧបទ្រពអន្តរាយដោយប្រការទាំងពួង ។

២– អស្សវេទ ឬហៅថា ឥរុវេទ សំដែងអំពីពិធីតុស្តិកម្ម សូមឲ្យព្រះវិស្ណុ ព្រះមារុត នឹងព្រះព្រហ្មប្រសិទ្ធិក្នុងការហត្ថកម្ម ពាណិជកម្ម ឲ្យបានសម្រេចផលប្រយោជន៍លុះលាភសក្ការៈផ្សេង ៗ ។

៣– យជុរវេទ (គឺយជយុទ្ធ) សំដែងអំពីពិធីយុទ្ធពលី-កម្ម សូមឲ្យមានឫទ្ធិតេជះខ្លាំងពូកែ អំពីព្រះឥស្សរ ព្រះនារាយ-ណ៍ ព្រះអាទិត្យ ព្រះអគ្គិនី ក្នុងកាប្រឡងវិជ័យយុទ្ធ នឹងសូមឲ្យកំចាត់បង់នូវចង្រៃឧបទ្រពទាំងឡាយ ។ បើនឹងរាប់គម្ពីរអថិពនវេទ ១ ទៀតត្រូវជា៤ ហៅថាចតុរវេទ ។

ក្នុងព្រះវេទ ៣ ប្រការនេះ ព្រះវេទនីមួយ ៗ លោកបែកចេញជាពីរចំណែក ហៅថា វេទ ឬព្រហ្ម ១ ចំណែក, មន្ត

១ បំណែក. វេទយាននឹងពិធីកម្មរបៀបការដែលនឹងបាត់គ្រឿងដង្វាយថ្វាយព្រះជាម្ចាស់, មន្តបាននឹងរបៀបសារស្លោកសម្រាប់តុស្តីអង្វរនឹងសរសើរព្រះជាម្ចាស់ទាំងឡាយ ដើម្បីនឹងឲ្យទ្រង់ករុណាប្រោសប្រសិទ្ធិប្រទានពរឲ្យតាមត្រូវការ ។

កតិបដិបត្តិក្នុងត្រៃវេទ

ក្នុងគម្ពីរព្រះវេទសំដែងថា លោកធាតុព្រមទាំងវត្ថុទាំងពួងដែលរួមនៅក្នុងលោកធាតុ ព្រះជាម្ចាស់ទ្រង់សាង ទ្រង់បង្កើតទាំងអស់ ពួកអ្នកកាន់លទ្ធិនេះក៏តោងមានសេចក្តីឃើញឱនទៅតាមសេចក្តីអភិប្រាយក្នុងព្រះគម្ពីរ បណ្តាកិច្ចការទាំងពួង ទាំងអាក្រក់ទាំងល្អ ស្រេចហើយនឹងព្រះជាម្ចាស់ប្រទានឲ្យដូច្នេះកាលត្រូវការអ្វី ក៏ធ្វើការក្រាបសំពះបួងសួងបន់ស្រន់ព្រះជាម្ចាស់ នឹងទេវតានោះ ៗ សុំឲ្យប្រសិទ្ធិប្រទានពរឲ្យ ឲ្យបានសម្រេចសមប្រាថ្នាក្នុងរឿងនោះៗ ដែលខ្លួនត្រូវការ ព្រោះសំ-គាល់ថា មនុស្សសត្វនឹងបានសុខ ព្រោះព្រះជាម្ចាស់ប្រទានឲ្យនឹងបានទុក្ខព្រោះព្រះជាម្ចាស់ដាក់បណ្តាសា គឺទាយឲ្យវិនាស

ហិនហោចមានប្រការផ្សេងៗ តាមកំហឹងរបស់ព្រះឬតាមសេចក្ដីកំហុះរបស់ខ្លួន, អ្វីទាំងអស់ស្រេចនឹងព្រះជាម្ចាស់ ព្រះជាម្ចាស់ឋាឲ្យរស់ក៏រស់ ឋាឲ្យស្លាប់ក៏ស្លាប់ ដូច្នេះត្រូវយកចិត្តព្រះជាម្ចាស់ឲ្យក្រែលៗទើបសុខខ្លួន កាលត្រូវការអ្វី ក៏បំពេញតបៈ ឬធ្វើពិធីបូជាយញ្ញថ្វាយព្រះជាម្ចាស់ៗ ឃើញចិត្តដែលភក្ដីដល់លោកអែនៗក៏ប្រសិទ្ធិប្រទានពរឲ្យៗ សម្រេចរបស់ដែលត្រូវការនោះ ក៏ឯកិច្ចដែលនឹងគប្បីបំពេញថ្វាយព្រះជាម្ចាស់នោះ ដោយសារុបមាន ៣ ប្រការ គឺៈ

១ ធ្វើទុក្ករកិរិយាទូន្មានរាងកាយ ហៅថាបំពេញតបៈ

២ តាំងពិធីបួងសួងទេវតា ហៅថាបូជាអគ្គិនីឬបូជាយញ្ញ

៣ ធ្វើពិធីជំរះលាងបាបក្នុងគង្គា ហៅថាពិធីសិវរាត្រី ។

ការបំពេញតបៈនោះបាននឹងប្រព្រឹត្តទូន្មានរាងកាយ ឲ្យបានសេចក្ដីលំបាកដោយប្រការផ្សេងៗ ដូចយ៉ាងប្រព្រឹត្តឈរតែជើងម្ខាងៗយូរ មិនដេក ដើរ អង្គុយ ប្រព្រឹត្តស៊ីតែផ្លែឈើ មិនស៊ីបាយ មិនស៊ីនំ ប្រព្រឹត្តដេកកប់ខ្លួនក្នុងដីខ្សាច់ដែលក្ដៅ ប្រព្រឹត្តផ្ដេរខ្លួនដោយភ្លើងជាដើម កាលប្រព្រឹត្តដូច្នេះហើយ

ព្រះជាម្ចាស់ឃើញសេចក្ដីព្យាយាមនិងសេចក្ដីភក្ដី ក៏ប្រទានពរឲ្យតាមដែលត្រូវការ ។

ពិធីបូជាអគ្គនី គឺភ្លើងនេះ គេបំណែកភ្លើងជា ៣ យ៉ាង គឺភ្លើងដែលមាននៅក្នុងលោកនេះដែលមនុស្សយកមកប្រកបបំអិនអាហារនិងប្រើយកពន្លឺ ១ យ៉ាងហៅថា អគ្គនី ឬអគ្គិ, ភ្លើងនៅឯស្ថានសួគ៌ (គឺព្រះអាទិត្យ) ១ យ៉ាង ហៅថា សវិតិ, ភ្លើងនៅក្នុងអាកាស ១ យ៉ាងៈហៅថាវិទ្យុ ឬអគ្គិសនី (និយាយដល់អគ្គិសនីឃើញដូចជារបស់ថ្មី តែដែលពិតមិនដូច្នោះ មនុស្សក្នុងសម័យបូរាណដែលកន្លងទៅហើយ ៦–៧ ពាន់ឆ្នាំ គេក៏ដឹងថាភ្លើងអគ្គិសនីមាន) ជារបស់ប្លែកអស្ចារ្យ ទើបគេនាំគ្នារាប់អាន ។ តាមប្រវត្តិរបស់គេថា ព្រះអគ្គនីនេះជាអម្រិត គឺមិនចេះស្លាប់ ខ្លះថាជាបុត្រព្រះវស្ត្រិ ខ្លះថាជាបុត្រអាកាសនិងផែនដី សក់សម្បុរមាស ខ្លួនក្រហម មុខ ២ អណ្ដាត ៧ ដៃ ៧ ជើង ៣ រូបនោមក្មេងជានិច្ច ព្រោះកើតឡើងរាល់ថ្ងៃ រាប់ចូលក្នុងពពួកព្រះអាទិត្យ មានមុខការជាទូតទៅមកក្នុងរវាងស្ថានសួគ៌និងមនុស្សលោក ។

វិធីដែលគេបូជាយញ្ញ គឺគេជីករណ្ដៅនៅផ្ទៃ ៤ តំបន់ ឬនៅទីណាមួយ ហើយយកភ្លើងទៅបង្កាត់ឆេះសន្ធោឡើង លំដាប់នោះទើបយកសត្វឬមនុស្សទៅសម្លាប់ សំឡេះយកសាច់បង់បុះក្នុងគំនរភ្លើង មានទាំងមន្តសូត្រសរសើរភ្លើងទាំង ៣ យ៉ាង ដោយគិតថា មនុស្សយើងចូលចិត្តបរិភោគសាច់ខ្មោចឬទេវតាក៏គង់ជាចូលចិត្តបរិភោគសាច់ដែរ ។ ១ ទៀតព្រះអគ្គីជាទូតទៅមកក្នុងរវាងស្ថានសួគ៌នឹងមនុស្សលោក កាលបូជាដោយអាហារដ៏ប្រសើរដូច្នេះហើយ ទូតគង់ប្រទានបំណាច់រង្វាន់ ឬពុំនោះសោតក៏គង់នាំពណ៌ដ៏មាននេះទៅក្រាបទូលព្រះជាម្ចាស់ឯស្ថានសួគ៌ ព្រះជាម្ចាស់គង់ប្រទានរង្វាន់ដល់យើងក្នុងការដែលយើងធ្វើពលីដ៏ប្រសើរនេះ ។

ពិធីសិវរាត្រី ក៏គឺពិធីងូតទឹកជំរះលាងបាបក្នុងគង្គាក្នុងខណៈកំពុងងូតនោះឲ្យភាវនាថា គង្គា ៗ ទាល់តែងូតហើយ កាលធ្វើដូច្នេះ បាបនឹងជ្រះអស់អំពីសន្ដាន ដោយម្រិវត្តិថា មានស្ទឹង ១ ឈ្មោះថា ស្ទឹងគង្គានៅក្នុងប្រទេសឥណ្ឌៀ ជាស្ទឹងដ៏ស័ក្ដិសិទ្ធ ហូរបុះមកអំពីស្ថានសួគ៌ អ្នកណាមានបាបក្នុង

ខ្លួនទោះបីតិចច្រើនប៉ុន្មានក្តី កាលបង់ឡើងជ្រុះបាប ក៏តោងចុះងូតទឹកក្នុងស្ទឹងនេះ បាបទាំងអំបាលនោះសូម្បីធ្វើកន្លងមកហើយជាច្រើនជាតិ ក៏ជ្រុះស្រឡះអស់អំពីសន្តានបានឡើងទៅកើតឯស្ថានសួគ៌នៅជាសុខ មិនបេះបុតិប្រែប្រួលទៅកើតជាអ្វីទៀត ។ ហេតុនោះពួកឥណ្ឌៀដែលកាន់លទ្ធិនេះ ទើបត្រូវការណាស់កាលមុននឹងស្លាប់សុំឲ្យបានទៅងូតគង្គានោះ បើប្រសិនជាមិនទាន់បានទៅងូតហើយទទួលខនស្លាប់ទៅមុន ក៏សុំឲ្យតែពួកញាតិអ្នកដែលរស់នៅធ្វើឈាបនកិច្ចសពហើយ រើសយកឆ្អឹងជាតុទៅបណ្តែតចោលក្នុងស្ទឹងនោះ ក៏បានឡើងទៅកើតឯស្ថានសួគ៌ដែរ ប្រមាណមើលមនុស្សដែលទៅងូតនឹងយកឆ្អឹងទៅចោលក្នុងស្ទឹងនោះក្នុងមួយឆ្នាំៗជាច្រើនពាន់គ្នា ។ ស្ទឹងនេះស័ក្តិសិទ្ធិមែនឬហ្ន៎ អើបើលទ្ធិនេះត្រឹមត្រូវមែន បើស្ទឹងនេះស័ក្តិសិទ្ធិមែន ក៏គួរឲ្យអាណិតដល់អ្នកដែលមិនបានកាន់លទ្ធិនេះ គួរឲ្យអាសូរដល់អ្នកដែលមិនបានទៅងូតទឹកស្ទឹងនេះ ជាមនុស្សអភ័ព្វធំ ប្រហែលជាមិនបានទៅកើតឯស្ថានសួគ៌នឹងគេទេដឹង ? ផ្លូវដែលនឹងត្រូវពិចារណា ក៏គឺថាបើស្ទឹងនោះសក្តិសិទ្ធិមែន

ក៏ជាភ័ព្វធំរបស់អ្នកកាន់លទ្ធិនេះៗ ក៏តោងមិនព្រួយថា ក្រែង ទៅកើតក្នុងនរកឬក្នុងទីអាក្រក់ឯណានីមួយ ព្រោះមានមហាគង្គាដ៏ធំទូលាយ សម្រាប់ងូតជំរះបាបស្រាប់ហើយ កុំព្រួយពីរឿងបាប បើទោះបីជាធ្វើធ្ងន់ដែបន្តិចក្តី សុំឲ្យតែបានទៅងូតទឹកនោះហើយ បាបក៏ជ្រះចេញអំពីសន្តាន ការបញ្ញត្តិលទ្ធិនេះឡើងឃើញងាយស្រួល មនុស្សអាចធ្វើបានដោយងាយ គ្រាន់តែចុះងូតទឹកក្នុងគង្គានោះហើយបរិកម្មថា គង្គាៗ ប៉ុណ្ណោះ ក៏បានសម្បត្តិសួគ៌ទៅហើយ ដូច្នេះអ្នកកាន់សរណៈទាំងអស់គ្នានឹងគួរសន្និដ្ឋានដូចម្តេច ។

ភម្រាងានសាស្ត្រ

គីក្យទេរាំ (ត)

ព្រះមហាពិទូរ ក្រសេម គន្ថរបនបណ្ឌិត

ប្រែបេញពីភាសាសៀម

និយាយអំពីតំការបស់សៀម

តម្រានាងសាស្ត្រដែលពួកព្រាហ្មណ៍ឥណ្ឌៀនាំមកសំ-ដែងក្នុងស្យាមប្រទេសនេះ រូបតម្រានោះជាយ៉ាងម្តេច មិនមានផ្លូវដែលនឹងឲ្យដឹងច្បាស់ ព្រោះវេលាកន្លងមកយូរយាហើយ ទាំងជាសម័យដែលមិនទាន់ប្រើវិធីបោះពុម្ពសៀវភៅផង ក្នុងជាន់នោះ សេចក្តីចេះដឹងតម្រាប់តម្រាឯណានីមួយក៏ដោយអា-ស្រ័យស្វាធ្យាយចងចាំទុក ឬបើបានសរសេរចុះជាតួអក្សរក៏មានតិច មិនសូវសាយភាយ ទោះបីដូច្នោះក្តី ក៏នៅមានទំរោយល្មមឲ្យសន្និដ្ឋានបានថា តម្រានាងសាស្ត្រដែលពួកព្រាហ្មណ៍ឥណ្ឌៀនាំមកនោះ គង់បានប្រែចេញជាភាសាសៀមទាំងគម្ពីរ ឬតែបំណែកខ្លះ ហើយប្រាប់ប្រដៅគ្នាតមក ៗ ខដែលពោលមកនេះ ដឹងបានដោយមានតម្រាក្បាច់រាំរបស់សៀម និងមានឈ្មោះសម្រាប់ហៅក្បាច់ផ្សេង ៗ អំបាលនោះ ទំនងដូចគ្នានឹងតម្រានាងសាស្ត្ររបស់ព្រាហ្មណ៍ឥណ្ឌៀ គ្រាន់តែមកប្រែឈ្មោះហៅជាភាសាសៀម ដ៏ជាធម្មតារបស់ការប្រែ ឈ្មោះ

ក្បាច់រាំក្នុងតម្រាសៀមដែលស្រដៀងនឹងឈ្មោះក្បាច់រាំរបស់ពួកឥណ្ឌា ក៏នៅមានប្រាកដជាច្រើនឈ្មោះ ទាំងនេះឃើញបានជាគោលថា តម្រារាំរបស់សៀមដើមប្រែមកអំពីតម្រានាដសាស្ត្ររបស់ពួកឥណ្ឌា តែបានប្រែទុកត្រឹមណា ដើមច្បាប់ដែលប្រើនោះដូចម្ដេច មិនអាចដឹងបាន ព្រោះតម្រាផ្សេង ៗ របស់សៀមអន្តរធានបង់ កាលក្រុងស្រីអយុធ្យាខូចដោយដៃភូមានោះជាច្រើន តម្រារាំដែលប្រមូលមកទុកក្នុងហោសៀវភៅសព្វថ្ងៃនេះ មានយ៉ាងចាស់បំផុតត្រឹមសាងឡើងក្នុងរជ្ជកាលទី ១ ក្រុងរតនកោសិន្ទ្រ ជាគំរាក្បាច់រាំផ្សេង ៗ គូររូបពណ៌បិទមាស ១ ក្បាល នៅសល់តែភាគខាងដើម ខាងចុងដាច់បាត់ទៅហើយ ១ ក្បាលទៀតជាគំរាក្បាច់រាំ ដូចគ្នានឹងក្បាលដែលពោលមកហើយ រូបភាពជាស្នាដៃជាងក្នុងរជ្ជកាលទី ២ ឬទី ៣ គូរ តែមានភាពរាំបរិបូណ៌ដល់ទៅ ៦៦ លំនាំ សៀវភៅនេះបានមកអំពីក្នុងព្រះរាជវាំងបវរ ធៀបមើលនឹងគំរាក្នុងរជ្ជ-កាលទី ១ ឃើញរៀងលំដាប់ក្បាច់ផ្សេង ៗ ដារបៀបជាមួយគ្នាជាតឹកតាងដែលនឹងឲ្យឃើញថា គំរាដែលបានអំពីព្រះរាជវាំង

បរិវ ជារបស់បំរៀងអំពីតំរាក្នុងរជ្ជកាលទី ១ ហើយជាគោល ឲ្យដឹងបាន១យ៉ាងទៀតថា ក្បាច់រាំក្នុងសៀវភៅរជ្ជកាលទី ១ ដែលជាច់បាត់ទៅនោះជាក្បាច់បែបណា ៗ ខ្លះ អាស្រ័យគោល ដែលបានមកអំពីតំរានេះ ចូលចិត្តថា តំរារាំដូច្នេះមានមកតាំង អំពីសម័យក្រុងត្រៃអយុធ្យាហើយ តែអន្តរាយបង់កាលខូច ក្រុង ។ លុះដល់រជ្ជកាលទី ១ ព្រះបាទសម្តេចព្រះពុទ្ធយ៉តហ្វាចុឡាលោក គង់បានឲ្យប្រជុំពួកគ្រូល្ខោនធ្វើតំរាក្បាច់រាំ ឡើងជាថ្មី ទុកជាបែបផែនសម្រាប់ព្រះនគរ ។ លុះតមកស្តេច ដែលទ្រង់នូវយសស័ក្តិខ្ពស់ ដូចយ៉ាងក្រុមព្រះរាជវាំងបវរ ។ ជាដើម ទើបទ្រង់ឲ្យបំរៀងសំណៅតំរានោះទៅរក្សាទុកជាបែប ច្បាប់សម្រាប់ហាត់ល្ខោនខោលនឹងល្ខោនគ្រឿង តំរារាំជាន់ ចាស់បានប្រទះតែពីរ ២ ក្បាលដែលពោលមកប៉ុណ្ណោះ ឃើញ ថាគួរបោះពុម្ពរក្សាទុកក្នុងសៀវភៅនេះផង តែរូបភាពក្នុងច្បាប់ ដើម ច្បាប់ ១ នោះខូច ច្បាប់ ១ ទៀតគ្រាន់តែបែបគូរព្រាង ទើប សម្រេចយកបែបដែលមានគ្រប់នោះមកបោះពុម្ពទុកក្នុងទីនេះ ។

ឈ្មោះដែលហៅក្បាច់រាំផ្សេង ៗ ក្នុងតំរារបស់សៀមនោះ ពិគ្រោះមើលឃើញលាយឡំជាច្រើនជាន់ គឺដែលជាជាន់ដើម គង់តាមពាក្យប្រែអំពីតំរាឥណ្ឌៀក៏មាន ដែលឃ្លៀងឃ្លាតចាក ពាក្យដើម ដោយប្រាប់គ្នាមកច្រើនដំណាក់មាន នឹងដែល គិតប្រឌិតឡើងថ្មីក្នុងជាន់ក្រោយក៏មាន សេចក្ដីដែលពោល នេះឃើញបានក្នុងពាក្យក្លូនរបស់ចាស់ ដែលនិយាយពីតំរា រាំមាននៅ ៣ បែប គឺជាក្លូនសុភាពតែងជាតំរាប្រាប់ឈ្មោះ ក្បាច់រាំបូរាណ ១ បែប ក្នុងបទល្ខោនរឿងរាមកេរត៍ ព្រះរាជ-និពន្ធរជ្ជកាលទី ១ ត្រង់ព្រះនារាយណ៍បញ្ចោតនន្ទក ១ បែប ពាក្យសំពះគ្រូរបស់ពួកល្ខោនជាត្រី (នោហ៍រា មឿងនគរស្រី-ធម្មរាជ) ១ បែប ទាំង ៣ បែបនេះស្រង់យកបំពោះតែ ឈ្មោះក្បាច់រាំមករៀងទុក ដើម្បីសម្រាប់ធៀបគ្នា ដូចមានត ទៅនេះ

## ស្រន៑ពីគំរាក់មាន ៦៤ ឈ្មោះ

| | |
|---|---|
| ទេពប្រណម្យ | បបិម |
| ព្រហ្មមុខបួន | សៀតមាលា |
| សន្សិមនាងផ្ទឹ | បញ្ចៀងស្មើស្មា |
| ពិសម័យរៀងខ្មើយ | កង្ហាល់រន |
| សេកបួលសំបុក | ទន្សាយធៀងចន្ទ្រ |
| ព្រះចន្ទ្រទ្រង់ក្លស់ | ព្រះរថហោលសារ |
| មារត្រឡប់ | កែក្រាយ |
| ឈុយឆាយបួលរាំង | មង្ករសៀរប្រាំង |
| កិន្នររាំ | ដំរីស្នួយភ្លុក |
| ព្រះរាមយឹតសរ | កន្លង់ត្រែបផ្កា |
| មប្ឆាលេងវារី | វង្វេងបានសព |
| ហង្សលេលា | តោលេងកន្ទុយ |
| នាងបំពេខ្លួន | រាំជន្ល |
| ចាប់មេវ្ញាផាត់មុខ | ខ្យល់បក់ត្រួយពោក |
| បាំងព្រះសុរិយា | ហោរាលេងទឹក |

ឈូកស្ទួយផ្លែ　　នាគម្ពរកន្ទុយ
ប្រើសដើរព្រៃ　　នារាយណ៍បោលចក្រ
ដំរីលាស់ស្មៅ　　ហនុមានផ្លាញយក្ខ
ព្រះលក្ស្មណ៍ថ្លែងឫទ្ធិ　　កិន្នររាំ
មយូររាំកន្ទុយ　　ប្រទាស់ចាងណាង
សារថីអូសរថ　　ក្រវិលវេហាស៍
ជិះសេះវាយឃ្លី　　វាយគោន
ពស់ត្បាល់បោលខ្លួន　　រាំគ្រប់ ៤ ស្នៀត
បិនស្រាវពោះវៀន　　ទោបស្លូមែកឈើ
បោលដំបង　　មេខ្លាបោលកែវ
កិន្នរសៀរគុហា　　ណាំងមុខភ្លើង
ខ្លាទំលាយផ្ទះ　　ដំរីព្រេចរោង
បងក្បិនវាយដែក　　ចាក់វិស័យ
ក្លស់ព្រះសុមេរុ　　វល្លិ៍ព័ន្ធឈើ
នូរគិតប្រឌិតផ្ញើ　　ក្រវាត់ត្បូង

ជិះសេះប្រទក្សិណបន្ទាយ ទន្សាយជាប់បន្តឹង
កូតទ្រខ្សែបី ។

ស្រង់ពីបទធាតុនារាយណ៍មាន ១៨ ឈ្មោះ

ទេពប្រណម្យ បរើម
ព្រហ្មមុខបួន សៀតមាលា
ប្រើសដើរព្រៃ ហង្សហើរ
កិន្នរសៀរគុហា សន្សំមនាងផ្ទឹ
កន្លង់ត្រីបង្គា សេកបួលសំបុក
បញ្ចៀងស្នេហ៍ស្នា មេខល្លាបោលកែវ
មយូរារាំកន្ទុយ ខ្យល់បក់ត្រួយបេក
ព្រហ្មនិមិត្ត ពិសម័យរៀងខ្នើយ
មច្ឆាលេងសាគរ នារាយណ៍បោលចក្រ ។

ស្រង់ពីបទគ្មានសំពះគ្រូល្មោនជាត្រីមាន ៨ ឈ្មោះ

គ្រុឌក្រវែលរហោ គ្រុឌឆាបនាគ

ហណុមានធ្យាន ទេពលំនាំ
សារបីអ្នូសរបី មទ្រីដើរជើងភ្នំ
តាបស់បួលអស្រែម ប្រាសាទមុខបួន
(ឬហៅថា មុខព្រហ្ម) ។

## ឈ្មោះក្បាច់រាំ ២៦ បែប

### ចងជាពាក្យកាព្យ

ទេពប្រណម្យបរមនាដណាំទួន    ក្បាច់ព្រហ្មមុខបួន នឹងសៀតមាលា, សឡូមនាងផ្ទឹបញ្ចៀងស្មើស្មា ក្បាច់មួយទៀត ណាពិសម័យរួមខ្ទើយ ។ កង្ហាល់រនរង់កន្លង់ត្រីបផ្កាស្តុក សេកបូលស៍បុកទំនុកហៅបៅរើយ.    ទន្សាយផ្ទៀងចន្ទ្រចន្ទ្រ ទ្រង់ក្លស់រំភើយ រំភាយហើយនឹងព្រះរថបោលសារ ។ ផ្ទុះ ភ្លើងកល្បហេណុមានផ្លាញយក្ខ ព្រះហរិរក្ខឃឹតសរសិល្ប្លា, ដំរីស្លួយភ្លុកបាំទុកគ្រប់គ្នា គជសាររលាស់ស្មៅហៅក្បាច់របាំ ។ ជះសេះវាយឃ្លីសារបីអ្នូសរថ    ក្លស់សុមេរុសន្មតិបទលំនាំ, ក្រវិលវេហាស៍វេវាទន្ទាំ ទន្ទេងលំនាំនាគមួរកន្ទុយណា ។ ប្រើសដើរព្រៃនែនឹងហង្សលេលា ផ្គង់ដៃដាក់ងាម្សៅវាផាត់ភក្រ្តា. រេរាលេងទឹកគគឹកគគៀរ កិន្នរសៀរគុហាទាប្រឌិតរាំ ។ គាតត្បូងវាយដោនវាយបែបប៉ោលយ៉ោល    ពស់ត្បាល់បោល ខ្លួនគេះក្បួនរបាំ,    មច្ឆាលេងសាគរព្សូរគគ្រាំ    កិន្នររាំអ្នួត ឆោមហោមវិលាស ។ សិង្ហតោលេងកន្ទុយរាំវេរូន នាង

បំពេខ្លួននាងខ្លួនសៃយាសន៍ ឈូកស្នួយផ្ទៃបែរស្មើរស្មើត យាងយាស គរទ្រូងរវើរាសរាសរវង់រវៃលយ ។ ព្រះលក្ខណ៍ថ្លែង ឬទ័ថ្លែងរឿងសិល្បថ្លា ក្បាច់ខ្លាទំលាយធ្នះននះឰតដៃ. ដំរី ព្រៃបរោងតោងហាត់សព្វថ្ងៃ នឹងក្បាច់មួយនៃកែក្រាយចូល វាំង ។ ក្បាច់ណាំងមុខភ្លើងបើងមើុងដំណើរ វល្លិ៍ព័ន្ធដើមឈើ អុំទូកក្បែរប្រាំង. មង្ករលេងទឹកគគ្រឹកទូទាំង រាយោះយោរ ខ្លាំងខ្យល់បក់ត្រួយបេក ។ បិនស្រារិពោះរៀនរៀនចាក់រវស័យ មួយនៃទោចស្លមែកឈើយោកយេក. ជិះសេះប្រទក្សិណាបន្ទាយ ដុំដែក មយូរារំរេកកន្ទុយរំពើន ។ ប្រទាស់ចាងណាង បែបយ៉ាងតំរា មេខល្ហាបោលកៃរវើររវើទន្ទើន, ទន្សាយជាប់ បន្តឹង៖ប្រែប្រឹងក្រវើន គឃ្លើនបង់ក្បិនវាយដែក ។ ដំព្រា បាំងព្រះសុរិយាថាដកគ្រប៉ ប្រលៃយវាតពីរកិន្នរវាំជួបគ្នា. មារ ត្រឡប់ក្រោយបោលចាកបំណោម នឹងបញ្ចើរឆោមនារាយ-ណ៍បោលចក្រ ។ កូតទ្រវែ្យបីត្រសង្ខម្នា បែងចប់តំរា នាងសាស្ត្រហើយអ្នក, អញ្ជើញសិក្សាតំរាវាំវ៍- ក្បាបែបទុកដាក់ បុរាណនាយហោង ។

ឈ្មោះក្បាច់រាំ ២៧ បែប

| | |
|---|---|
| ១ ទេពប្រណម្យ | ១៥ ហណុមានផ្លាញយក្ខ |
| ២ បរេមនាង | ១៦ ព្រះហេរិរក្ខយឹតសរ (ព្រះរាមយឹតសរ) |
| ៣ ព្រហ្មមុខបួន | ១៧ ដំរីស្ទួយភ្លុក |
| ៤ សៀតមាលា | ១៨ ដំរីលាស់ស្មោ |
| ៥ សន្សិមនាងថ្មី | ១៩ ជិះសេះវាយឃ្លី |
| ៦ បញ្ចៀងស្មើស្មា | ២០ សារបីអូសរបិ |
| ៧ ពិសម័យរួមខ្មើយ | ២១ ក្លស់ព្រះសុមេរុ |
| ៨ កង្ហាល់រន | ២២ ក្រវិលវេហា |
| ៩ កន្លង់ត្របផ្កា | ២៣ នាគម្ហូរកន្ទុយ |
| ១០ សេកបួលសម្បុក | ២៤ ប្រើសដើរព្រៃ |
| ១១ ទន្សាយផ្ទៀងចន្ទ្រ | ២៥ ហង្សលេលា |
| ១២ ព្រះចន្ទ្រទ្រង់ក្លស់ | ២៦ បិទម្សៅផាត់ភក្ត្រ |
| ១៣ ព្រះរថបោលសារ | ២៧ ហោរាលេងទឹក |
| ១៤ ផ្លុះភ្លើងកល្ប | |

២៨ កិន្នរសៀរគុហា
២៩ ប្រិឱតភាំ
៣០ គាត់ត្បូង
៣១ ភាយជោន
៣២ ពស់ត្បាល់ហោលខ្លួន
៣៣ មច្ឆាលេងសាគរ
៣៤ កិន្នរបញ្ចើរឆោម
៣៥ សិង្ហតោលេងកន្ទុយ
៣៦ នាងបំពេខ្លួន
៣៧ ឈ្លូកស្ទួយផ្លែ
៣៨ គទ្រូង
៣០ ព្រះលក្ស្មណ៍ថ្លែងឫទ្ធិ
៤០ ខ្លាទំលាយផ្ទះ
៤១ ដំរីព្រៃរោង
៤២ កែក្រាយបួលរាំង
៤៣ ណាំងមុខភ្លើង
៤៤ រស្មិព័ទ្ធឈើ
៤៥ អុំទូក
៤៦ មង្ករលេងទឹក
៤៧ ខ្យល់បក់ត្រួយបេក
៤៨ ចិនស្រាវពោះវៀន
៤៩ បាក់វិស័យ
៥០ ទោចស្លមែកឈើ
៥១ ជិះសេះប្រទក្សិណ-
-បន្ទាយ
៥២ មយូរារាំកន្ទុយ
៥៣ ប្រទាស់ចាងណាង
៥៤ មេខល្ហាបោលកែវ
៥៥ ទន្សាយជាប់បន្តឹង
៥៦ បងក្បិនរាយដែក

៥៧ បាំងព្រះសុរិយា

៥៨ ជិកគ្រឹប៊ី

៥៩ ប្រលែយរាំត

៦០ កិន្នររាំ

៦១ កិន្នររាំ

៦២ មារត្រឡប់ក្រោយ

៦៣ បញ្ចើរធោម

៦៤ តារាយណ៍ពោលចក្រ

៦៥ ក្បូតទ្រខ្សែប៊ី

៦៦ ត្រសងម្ទីម្នា



ប្រាសាទព្រះខ័ន ផ្លូវចូលទៅក្នុងទីធ្លាខាងក្នុង ប្រាសាទនេះសាងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ២

### អំពីការស្រាវជ្រាវនៅថាប់អ៊ាម (អណ្ណាម)

របស់លោក ក្លេយ៍ នៅសាលាបារាំងសែសចុងបូព៌ាប្រទេស

ការស្រាវរបស់លោកក្លេយ៍ដែលទើបនឹងធ្វើ ឃើញមានប្រយោជន៍ដល់ជាតិខ្មែរដែរ គឺលោកបានរកឃើញថ្មចំឡាក់ដែលមានខ្លះនៅល្អឥតបាក់បែក គឺជាថ្មប្រាសាទបូរាណចាមដែលមានប្រយោជន៍ ។ ឯហោជាងតូចៗ តាំងជាបែបអង្កែសម្រាប់រូបមនុស្សតូចៗ ដែលមានភាពសណ្ឋានជាតាបសឬសីមានពុកចង្កា ខ្លះមានកាន់ផ្កាំនៅដៃមានទំនងដូចជាកំពុងតាំងបំរើនភាវនា, ខ្លះទៀតផ្គាប់មេដៃនឹងចង្អុលដៃជាមួយគ្នាហើយម្រាម ៣ ទៀតបញ្ឈរឡើងមានសណ្ឋានដូចជាបែបជដែកដេញដោល ។ នៅលើហោជាងធំៗ មានកំពស់ជាង ១ ម៉ែត្រនោះ នៅក្បាច់ក្នុងផ្ទៃខាងលើ គេឃើញមានរូបព្រះសិរិមានព្រះហស្ត ៤ ស្គាល់បានដោយមានគ្រឿងសំគាល់នៅម្កុដដែលប្រដាប់ដោយត្បូងរចនាជាពងត្រីរៀបរៀងជាជួរ នឹងដោយព្រះនេត្រទី ៣ នៅលើព្រះនលាត (ថ្ងាស) ព្រមទាំងសំគាល់បានដោយ

មានវាគដែលព័ទ្ធព្រះអង្គកាយ ដែលទុកជាខ្សែសម្រាប់សំគាល់ព្រាហ្មណសាសនា ។

មានរូបគ្រុឌជាពាហណៈរបស់ព្រះនារាយណ៍ ជើងពីរច្បាមកនាគដែលមានក្បាលច្រើន ហើយមាត់ខាំទូវកន្ទុយនាគនេះ ។

មានកន្លែងខ្លះរចនាដោយក្បាច់យ៉ាងសំខាន់ៗមានរូបខ្លួន ១ កំណាត់ខាងលើជាស្ត្រី ហើយ ១ កំណាត់ខាងក្រោមជាត្រី. មានរូបគ្រុឌមានរូបសត្វទឹកក្បាលជាក្រពើហើយមានប្រមោយដូចដំរី ។

ហើយនៅដុំថ្មធ្រុងធំ ៗ ជាងតាំងរចនាឡើងជារូបគ្រុឌឬជារាជសីហ៍ ដែលវេលាឃើញហើយនាំឲ្យនឹកឃើញដល់ប្រាសាទខ្លះនៅក្រុងមហានគរ ។ ត្រូវកុំភ្លេចថាកាលពីក្នុងរវាង ព. ស. ១៦៤៣ នគរចម្ប៉ាត្រូវខ្មែរចូលលុកលុយ ។

មានរូបធំ ១ បាក់បែកខ្លាំងឃើញបានតែ ១ បំណែក រូបនេះទំនងជារូបអ្នកតារក្សាប្រាសាទ ឬក៏ជារូប (ទ្វារបាល) ។

មានកំពូលប្រាសាទ ១ រាងជាចេតិយ, មានធុងសម្រាប់ដាក់ទឹកជំរះមន្ទិល ១ មានអាសនៈ ១ រាងបួនជ្រុងរបតាយ៉ាងសំខាន់មានក្បាច់ជ មានក្បាច់រាងត្រីធំៗ មានស៊ុមទ្វារ មានសសរ មានក្បាច់ភ្ញីវល្លិ នៅក្បាច់ភ្ញីវល្លិនេះមានក្លាយចេញជារូបមនុស្ស ឬក៏ជាសត្វផ្សេងៗ មានសត្វហង្សដែលជាពាហនៈព្រះព្រហ្ម នឹងគោនន្ទិនជាពាហនៈព្រះឥស្វរជាដើម ព្រមទាំងរូបរាជសីហ៍ដែលមានម្កុរចេញមកពីក្នុងមាត់; មានរូបនាគ រូបស្វា ។ល។ ដែលគាស់កកាយបានពីក្នុងដីមក វត្ថុទាំងនេះសុទ្ធតែធ្វើអំពីថ្មភក់ទាំងអស់ ។

# អារម្ភកថា

រឿងសប្បុរិសធម៌នេះ ខ្ញុំបាទមានមនោគតិគិតប្រើមឡើង ដោយឃើញថា ជាឧបការគុណដ៏ឧត្តម សំរាប់ពុទ្ធបរិស័ទ ដែលត្រូវការ ។

ប៉ុន្តែធម៌នេះ បំពួកប្រាជ្ញជាន់ខ្ពស់លោកបានប្រែពីបាឡី ធ្វើជាសេចក្តីអធិប្បាយជាធម្មទានក៏មាន តែងជាពាក្យសំរាយ បុះសៀវភៅ សំរាប់ឲ្យមើលផ្ទាល់ខ្លួនក៏មាន នោះពុទ្ធបរិស័ទ ទាំងឡាយសឹងបានជ្រាបខ្លះហើយ ។

ឥឡូវនេះ ខ្ញុំបាទតែងជាពាក្យកាព្យវិញដើម្បីជាការស្រួល សំរាប់ពុទ្ធបរិស័ទបំពួកខ្លះដែលត្រូវការស្តាប់ពាក្យកាព្យ អាចឲ្យ បំបាត់នូវសេចក្តីធុញទ្រាន់ក្នុងការមើលការស្តាប់បរិយាទពុទ្ធ-ភាសិតនេះផង ។

អវសានវាទនេះ ខ្ញុំបាទសូមប្រតិបត្តិថា សប្បុរិសធម៌ ដែលខ្ញុំបាទតែងនេះ ប្រហែលជាខាតខ្វះលើសលោះក្នុងបទ ឯណានីមួយខ្លះ ។

ប៉ុន្តែខ្ញុំបាទសង្ឃឹមថាមុខជាបានទទួលសេចក្ដីអភ័យអំពី ពុទ្ធបរិស័ទទាំងឡាយពុំខាន ។

សាហត្ថកនាម

បាន-តេង

## សប្បុរិសធម៌ពាក្យកាព្យ

សូមពោលសូត្រពុទ្ធឱស្ឋប្រោសទូគ្មាន ក្នុងបករណៈ
អង្គុត្តរជាប្រធាន កែកាព្យអត្ថបដិភាណវោហារ ។ នាមព្រះសូត្រ
សប្បុរិសធម្មោ គឺជាឱវាទពុទ្ធវិចារណ៍ ប្រទានជាប្រយោជន៍
យ៉ាងពិស្តារ បរិហារសព្វសត្វឲ្យបានសុខ ។ មានចំនួន
សត្តបទកំណត់ប្រាប់ បានសារសព្វអធិប្បាយជាបែបទុក ឲ្យ
មនុស្សភ្ញាក់កំណើតដើតទៅមុខ ស្គាល់វិថីផ្លូវសុខសប្បុរស ។
នឹងសាធកលើករឿងឡើងជាអាទិ៍ សូមផ្ទៀងសោតប្រសាទ
ស្តាប់ឲ្យអស់ ដួងសតិន្ទ្រីយ៍តាំងសោមនស្ស ខំរលាស់ដោះ
ចិត្តបាកកង្វល់ ។

ធម្មញ្ញូគួរដឹងកំណើតហេតុ គ្រប់ប្រភេទគឺហេតុបង្កើត
ផល ទាំងផែនភពសព្វសត្វសេពឥតសល់ ដឹងមិនដល់
ដោយខ្លៅដៅតែស្មាន ។ ហេតុនោះឬគឺកម្មដែលកសាង
មានពីរយ៉ាងគួរយល់សមុដ្ឋាន កម្មអាក្រក់នឹងល្អប្រចាំប្រាណ
ធ្វើប៉ុន្មានបានប៉ុណ្ណឹងកុំប្រឹងធ្វល់ ។ ចិត្តខិលខូចបង្ខូចផ្តើមប្លើម

ភ្លៀសកាប យ៉ាងនេះប្រាជ្ញប្រាប់ថាអកុសល អ្នកណាសាង អ្នកនោះឯងសោយផល ជាប់សកលកាយស្មែដូចស្លែកាន់ ។ ប្រព្រឹត្តត្រឹមត្រង់ត្រូវផ្លូវសុចរិត នោះបណ្ឌិតហៅថាកុសលក្នុង ត្រូវត្រង់ត្រាប់ត្រិះគិតឲ្យកើតធន្ម គង់ជួបសន្តិសុខសថាពរ ។ យើងជាអ្នកស្វែងមគ្គឲ្យដាក់ហេតុ នឹងប្រភេទភូមិផលកុំខ្វល់វរ ផ្លូវនេះលើកកម្មឡើងឧទ្ធរណ៍ ផ្តើមសុន្ទរវាទតខសំណៅ ។ សូមក្រវីប្រីជាបេះបំណភាន ជួយប្រោសប្រាណពន្យល់ដល់ជន ខ្លៅ ក្នុងធម្មញាតាតាមសំណៅ ប្រោសប្រដៅដុសខាត់ អធ្យាស្រ័យ ។

២ ក្នុងអត្តញ្ញាតាថាដឹងផល គួរសំគាល់វាទីវិនិច្ឆ័យ ព្រោះ តួហេតុប្រភេទដើមនិស្ស័យ ជាបច្ច័យដូចឧសនឹងអគ្គី ។ ប្រៀប ដូចធ្វើអំពើកម្មអាក្រក់ ផលខ្វក់ល្អក់ក៏ដក់ក្នុងតន្ត្រិយ អំពល់ចិត្ត ផតសុខទុក្ខពេញទី គ្មានវិថីណាជយឲ្យស្រាកស្រាន ។ បើ ធ្វើល្អផលល្អកំដរកាយ ឲ្យសប្បាយសមបែបសេពសុខសាន្ត ក្រ ក៏ខាត់ខ្សត់ក៏ខ្លាយឆ្ងាយបាកប្រាណ សុខសំរានរាល់ទិនមិន

ស្រាកស្រាន់ ។ កាលសុខទុក្ខមកដល់ប្តូរប្រែងចិត្ត រំលឹកគិតរំពឹងដឹងឲ្យទាន់ ទាំងគេយើងក្នុងភពរាប់ម៉ឺនពាន់ ទុកតែងជាន់សុខតាមជួយតែរាល់គ្នា ។ ត្រូវពិចិត្យសម្ទ័យទោសទុច្ចរិត ដែលបាំងបិទឥតភ្លឺគឺអវិជ្ជា បើជំរះឲ្យជ្រះពីអង្គា វេទនាគង់ស្ងប់រម្ងាប់កាយ ។ កាលចិត្តកាចកើតឡើងយើងលះបេញ ត្រូវបំពេញមេត្តាករុណាផ្សាយ ទើបបានសេពសន្តិសុខសប្បាយ អង្វែងឆ្ងាយតទៅហៅផលល្អ ។ ស្គាល់ធម៌ពីរនេះពេញជាស្គាល់ត្រូវ ព្រោះដងផ្លូវត្រូវកើតទ្រព្យរកក្រ ធម្មញ្ញូគួរដឹងថាដើមខ អត្ថញ្ញូលោកសរប្រាប់ថាចុង ។ ឯស្គាល់ដើមគឺស្គាល់ប្រធានហេតុ កំណត់ខេត្តខណ្ឌគ្នាជាក្រៅក្នុង ការស្គាល់ផលត្រូវយល់ដល់ស្គាល់ចុង តពីក្នុងតួហេតុប្រភេទបាស់ ។

៣ ក្នុងអត្ថញ្ញូតាថាស្គាល់ខ្លួន ត្រូវបេះស្ងួនស្ងប់ស្ងៀមចៀមកន្ត្រែខ្មាស ប្រុងប្រយ័ត្នមារយាទជាតិពុទ្ធសាសន៍ មើលឲ្យ

ច្បាស់ច្បាប់ធម៌ប្រដៅកាយ ។ ឲ្យដឹងខ្លួនដោយជាតិត្រកូល កើត ពូជកំណើតក្រុងស្រែសែសឡាយ សម្បូណ៌ទ្រព្យសម្បត្តិ ឬខ្សត់បាយ កំណត់កាយឲ្យដាក់ជាធម្មតា ។ លុះកំណត់ដឹង ជាតិដឹងកំណើត ដែលយើងកើតនៅក្នុងពូជពង្សណា ហើយ ដាក់ទុកខ្លួនប្រាណប្រើកិរិយា ឲ្យសមតាមអត្តាជាការគួរ ។ កុំធ្វើ បែបទូកមាតបង្អៀតព្រែក រាកន្ទែកប្ចូកបែរមិនត្រូវជួរ មួយ គប្បីកំណត់វិជ្ជាគួរ ឲ្យស្គាល់ខួរក្បាលខ្លួនជាព្រុងឆ្លាត ។ បើ ដឹងខ្លួនថាខ្លួនជាមនុស្សល្ងង់ កុំទ្រនង់ទ្រនើសទ្រើសហួសខ្នាត លើផែនដីក្រអឺប្រាជ្ញឆ្លៀវឆ្លាត ត្រូវសង្វាតយកជាគ្រូអាចារ្យ ។ តែបន្ទំចិត្តខ្លួនខាំងរាខ្លៅ អាចហ្នុងសៅស្ងួនឲ្យសពូទ្រព្យខ្លឹមសារ បើសម្បូណ៌សម្បត្តិបរិវារ កុំឱឡារិកព្រើលមើលងាយគេ ។ បុរាណពោលថាបើឈើរលំ ដើរកន្លងទាំងគុម្ពពុំអីទេ បើ មនុស្សដួលកុំអាលកន្លងគេ ត្រូវគ្នាន់គ្នេរគេមនុស្សជួបគ្នាដែរ ។ បើវ័យខ្លួនមិនទាន់បរិបូណ៌ច្រើន កុំព្រហើនហួសមាតជាតិកូន ខ្មែរ បំរើរាកអ្នកអាយុច្រើនក៏ដែរ ត្រូវបង្វែរសន្តានស្មានមើល

មាត ។ ឲ្យសមភូមិតាមភាពស្ថាបស្ទង់វ័យ ទើបប្រពៃពេញ វង្សត្រកូលពង្សជាតិ មានបំណោះត្រូវបេះប្រើមារយាទ កុំឃ្លោងឃ្លាតក្លាយខឹងស្រវឹងខ្លាំង ។ គួរបំរើនសីលទានតឿនអត្ថៈ ជាសារៈឧត្តមដល់រូបំ កែអត្តញ្ញាតាតាមអត្ថំ បបង់វិឃប់ស្លេះបុំណ្ណោះបុះ ។

(មានតទៀត)

# រឿងសត្វចចក

គ្រានេះនឹងនិយាយអំពីសត្វចចកមួយត្រោសធំ ដល់ខែរំហើយដើររកត្រពាំងបឹងបួរដែលរីងទឹកនឹងបានចាប់ត្រីស៊ី លុះទៅដល់ត្រពាំងមួយរីងទឹកអស់ នៅតែប្រឡង់មួយហើយជាភក់មានត្រីកំពឹសបង្កងក្តាមជាច្រើនណាស់ ចចកឃើញហើយមានចិត្តអរណាស់ធ្វើមុខរីករាយ ថាថ្ងៃនេះអញមានលាភធំណាស់ជាលាភចម្លែកជាងសព្វថ្ងៃ ។ ឯសត្វកំពឹសមានប្រាជ្ញាឮចចកថាដូច្នោះហើយនិយាយលួងលោមចចកថា យើងទាំងអស់ជាបំណើបងចចកទាំងអស់ប៉ុន្តែប្រឡាក់ភក់ បើបងឯងស៊ីយើងទាំងភក់ដូច្នេះនេះមិនឆ្ងាញ់ពិសាទេ ។ ចចកឆ្លើយឡើងថាធ្វើដូចម្តេចនឹងបានឆ្ងាញ់ពិសា ។ កំពឹសឆ្លើយថា បងចចកឯងយកយើងទៅលាងទឹកឲ្យជ្រះស្អាត ហើយសឹមស៊ីនោះនឹងឆ្ងាញ់ពិសា ។ ចចកថាធ្វើដូចម្តេចនឹងយកទៅលាងទឹកបានបើច្រើនដល់ម្លេះ នោះកំពឹសថាបងចចកកុំព្រួយចិត្ត ជានាខ្ញុំគិតឲ្យបងឯងប៉ុន្តែបងឯងតាមខ្ញុំ ។ ចចកឆ្លើយឡើងថា ធ្វើដូចម្តេចខ្ញុំតាមបងឯងទាំងអស់ ។ កំពឹសថាបងចុះមកដេកនៀលក្នុងភក់នេះ

ហើយយើងរាល់គ្នានឹងបានតោងពាំរោមបងឯងៗ នាំទៅរកស្វែង
បឹងបួរឯណាដែលមានទឹកថ្លាច្រើននឹងបានលាងឲ្យស្អាតហើយ
សឹមបងឯងស៊ីឲ្យឆ្ងាញ់ពិសាតាមចិត្តៗឯសត្វបបកជាអ្នកលោភ
ហើយល្ងង់ក៏ធ្វើតាមពាក្យកំពឹស; ឯកំពឹសនឹងត្រីបបួលគ្នាតោង
រោមបបកទៅ លុះទៅដល់បឹងមួយធំវែងមានទឹកថ្លាល្អបបកដើរ
ចុះទៅក្នុងទឹក អស់ត្រីកំពឹសលោតទៅក្នុងទឹកហើយប្រាប់ថា
បងបបកឯងទៅជញ្ជូនមកឲ្យអស់ សឹមមកស៊ីឲ្យឆ្អែតតែម្តង
យើងនៅចាំបងឯងនៅនេះ ឯបបកក៏ទៅជញ្ជូនត្រីកំពឹស
លុះត្រាតែអស់អំពីត្រពាំងនោះ; អស់ត្រីកំពឹសក្តាមខ្យងដឹងថា
បបកជញ្ជូនអស់ហើយក៏មុជក្នុងទឹកជ្រៅបាត់អស់ទៅ ។ ឯបបក
ដឹងជាកំពឹសបញ្ឆោតដូច្នោះហើយខឹងណាស់ដើរទៅបបួលអស់
សត្វធំតូច ដំរី រមាស ខ្លា គ្រប់ភាសាសត្វ ទាំងពស់ថ្លាន់
ពស់ធំ ពស់តូច ទាំងសត្វហើរ គ្មានសេសសល់ដល់តិច បបួល
គ្នាមកបាចទឹកបឹងនោះឲ្យរីង នឹងបានចាប់ត្រីក្នុងបឹងនេះស៊ីឲ្យ
អស់ ហើយឲ្យពស់ថ្លាន់ធ្វើជាទំនប់ទប់ទឹក; អស់សត្វឯទៀត
បបួលគ្នាបាចៗ សត្វក្នុងបឹងដឹងថា បបកបបួលគ្នាមកបាចទឹក

ឲ្យវិងទាំងបឹងហើយភ័យណាស់មកគិតគ្នាថា យើងធ្វើដូចម្ដេចនឹងបានឲ្យអស់សត្វទាំងនេះលែងបាបទឹក ។ កាល្មោះមានត្រីក្រាញ់ឆ្លើយឡើងថា ខ្ញុំឮគេនិយាយថាបងសុភាទន្សាយជាអ្នកមានប្រាជ្ញាបេះដោះទុក្ខមនុស្សសត្វផងជាច្រើនណាស់ហើយ បើដូច្នោះ ខ្ញុំនឹងទៅពឹងបងសុភាទន្សាយឲ្យមកជួយដោះទុក្ខអស់យើង; ឯត្រីគិតគ្នាហើយប្រើត្រីក្រាញ់ឲ្យទៅអញ្ជើញបងសុភាទន្សាយៈ ត្រីក្រាញ់ប្រឹងនៀលទៅលុះដល់ត្រីវថ្ងៃក្រៀមស្រៈកាអស់ ។ លុះដល់យប់ហើយ សុភាទន្សាយបេញមករកស៊ីក៏ឃើញត្រីក្រាញ់នៀលដូច្នោះ ហើយសួរថាបងត្រីក្រាញ់ទៅណា, ត្រីក្រាញ់ឃើញសុភាទន្សាយហើយមានចិត្តអរណាស់និយាយអង្វរថាបងសុភាទន្សាយអាណិតខ្ញុំ ដ្បិតត្រីក្នុងបឹងទាំងអស់គេប្រើខ្ញុំមកឲ្យអញ្ជើញបងសុភាទន្សាយ ដ្បិតឮល្បីដល់សត្វមនុស្សគេនិយាយថា ជាអ្នកមានប្រាជ្ញាកាត់សេចក្ដីដោះទុក្ខគេ ថាបើអ្នកឯណាកើតទុក្ខហើយតែងនឹងទៅដោះទុក្ខគេមិនដែលខាន ឥឡូវដ្បិតមានដំរីក្របីគោរមាសរមាំងព្រើសក្ដាន់ជ្រូកសត្វធំសត្វតូចទាំងសត្វហើរគឺកុកក្រៀលបង្កៀលខ្សឹង ទុង

ទោមក្អែកទឹកប្រឹកស្មោញ សត្វហើរទាំងអស់បបួលគ្នាមក បាចទឹកបឹងឡើងនឹងបាតហាប់អស់ត្រី អណ្តើក កន្ធាយ ស៊ីជា បំណាច់ឲ្យអស់ពីក្នុងបឹងនេះ ឲ្យពស់ថ្លាន់ៈ ពស់ធំពស់តូចធ្វើជា ទំនប់ទប់ទឹកបឹងនេះឯងៈ យើងឮច្នេះបងសុភាទន្សាយអាណិតជួយ ដោះទុក្ខអស់បងប្អូនខ្ញុំ ឲ្យបានរួចពីភ័យខ្ទង់នេះនឹងបានឮកេរ្តិ៍ ឈ្មោះតទៅ អស់យើងខ្ញុំនឹងតបគុណបងសុភាទន្សាយឯង យើង មិនភ្លេចគុណដរាបដល់អស់ជីវិត ៗឯទន្សាយឮត្រីក្រាញ់និយាយ អង្វរដូច្នោះហើយឆ្លើយថា បងត្រីក្រាញ់ទៅមុនចុះ ទៅប្រាប់អស់ បងប្អូនកុំឲ្យភិតភ័យ ថាខ្ញុំជួយដោះទុក្ខឲ្យរួចកុំអារម្មណ៍ឡើយ ឯ ត្រីក្រាញ់ក៏ត្រឡប់ទៅវិញ ទន្សាយលុះដល់ព្រឹកព្រហាមឡើង ទៅនៅមាត់បឹងឃើញអស់សត្វកំពុងតែបាចទឹក ក៏យកស្លឹកឈើ ដែលដង្កូវរាស៊ីធ្លុះៗ មកធ្វើជាសំបុត្រ ហើយស្រែកហៅអស់ សត្វទាំងនោះថា អស់បងប្អូនគ្រប់គ្នាស្តាប់ខ្ញុំ ដ្បិតព្រះឥន្ទ្រឲ្យខ្ញុំ នាំសំបុត្រមកប្រាប់គ្រប់គ្នាថា ព្រះឥន្ទ្រលោកនឹងមកកាប់ជើងត្រី

ប្រមុំជើងអក កាប់ក្បាលបបកដកភ្លុកដំរីស ។ អស់សត្វឮថាសំបុត្រព្រះឥន្ទ្រដូច្នោះភ័យណាស់ ផ្អើលបោលជាន់លើគ្នា ដំរីក្របីរមាសរមាំង ស្មុះបោលទៅជាន់លើពស់ថ្លាន់ជាទំនប់ជាប់ខ្លួនជាពីរបីកំណាត់ធ្លាយទំនប់លិចស្លាប់អស់; សត្វទាំងនោះទៅជាបំណើត្រីវិញ ។ អំពីថ្ងៃនោះមកអស់សត្វកោតខ្លាចប្រាជ្ញាសុភាទន្សាយ សឹងហៅសុភាទន្សាយទាំងអស់គ្នាអំពីថ្ងៃនោះមក ។

## រឿងអំពីមនុស្សពីរនាក់នៅផ្ទះភូមិជិតគ្នា

គ្រានេះនឹងនិយាយថាកាលអំពីដើមមានអ្នកពីរនាក់នៅផ្ទះភូមិជិតគ្នា  មានកាលមួយថ្ងៃនោះហៅទាំងពីរនាក់នោះបបួលគ្នាទៅដាក់អន្ទាក់សត្វ  គិតគ្នារួចស្រេចហើយ  ដល់ថ្ងៃរសៀលគងភ្នំក៏នាំគ្នាដើរចេញទៅ  លុះដល់ព្រៃកន្លែងដែលដាក់សត្វអ្នកទាំងពីរនាក់គិតគ្នានឹងដាក់  អ្នកមួយថាខ្ញុំនឹងដាក់នៅគល់ឈើនេះ  ដ្បិតឈើនេះមានផ្លែ  យប់ៗសត្វបំណាំតែមកស៊ីផ្លែឈើនេះ ។ អ្នកមួយឆ្លើយថាខ្ញុំក៏ចង់ដាក់កន្លែងហ្នឹងដែរ  ប៉ុន្តែឥឡូវនេះអ្នកដាក់នៅគល់ឈើ ខ្ញុំមានតែដាក់នៅចុងឈើ រួចអ្នកចាំមើលព្រឹកឡើងរបស់អ្នកណាជាប់សិមដឹង ។  និយាយគ្នាហើយក៏ម្នាក់ដាក់នៅគល់ឈើ  ម្នាក់ក៏ឡើងទៅដាក់លើចុងឈើស្រេចហើយក៏វិលមកផ្ទះវិញលាគ្នាទៅផ្ទះដោយខ្លួន ។ ឯអ្នកដែលដាក់អន្ទាក់នៅលើចុងឈើនោះ  លុះវិលមកដល់ផ្ទះហើយយប់នោះគិតគ្នាប្ដីប្រពន្ធថា  ពីដើមដូនជីតាមកមិនដែលឮអ្នកឯណាដាក់អន្ទាក់នៅលើចុងឈើហើយឲ្យជាប់សត្វជើងបួននៅដី

ផ្លូវនេះអញដាក់នៅលើចុងឈើ ឯអ្នកមួយដាក់នៅគល់ដូច្នេះ អញព្រឹកពីមាន់រងាវទៅមើល បើឃើញសត្វជាប់នៅដីអញដោះយកទៅបង់នឹងអន្ទាក់អញឯចុងឈើ ព្រឹកឡើងអញទៅមើលជាមួយអ្នកនោះ ហើយអញដោះយកសត្វទៅជូនសុភាសេក ថាបើវាមិនសុខចិត្តថាដូចម្ដេច ៗ កើតក្ដីគង់តែនឹងដល់សុភាសេកមិនខាន សុភាសេកនឹងកាត់សេចក្ដីឲ្យវាចាញ់អញប្រាកដ ប្ដីប្រពន្ធគិតគ្នាហើយដេកទៅ ដល់មាន់រងាវក្រោកពីដេកលាងមុខស៊ីស្លាហើយចេញពីផ្ទះដើរទៅដល់អន្ទាក់ហើយឃើញអន្ទាក់នៅដីជាប់ក្ដាន់ ១ ហើយដោះយកឡើងទៅបង់នឹងអន្ទាក់របស់ខ្លួន អន្ទាក់នៅដីដាក់ឡើងដូចដើមវិញ ក៏ប្រញាប់វិលមកផ្ទះវិញ លុះព្រឹកព្រហាមស្រាងឡើងក៏អ្នកមួយ ដែលដាក់អន្ទាក់នៅដីមកស្រែកហៅឲ្យទៅមើលអន្ទាក់ អ្នកមួយឆ្លើយថារលះរលាំងប្ដី អន្ទាក់ខ្ញុំ ៗ មិនសង្ឃឹមឡើយ ដ្បិតនៅលើចុងឈើ ក្រែងតែអន្ទាក់អ្នកនៅដីខ្ញុំមិនថា ថាបើបានចែកគ្នាស៊ីផង ពាក្យនិយាយបំអកឲ្យអ្នកមួយដ្បិតដឹងការមុន និយាយហើយចុះពីផ្ទះដើរចេញទៅដល់អន្ទាក់មិនឃើញសត្វជាប់នៅដី ឃើញ

ជាប់នៅលើចុងឈើវិញ ហើយចៅដែលជាម្ចាស់អន្ទាក់នៅចុងឈើថាហ្នឹ៎មើលខ្ញុំៗ ថាមិនជឿ ថាកុំដាក់នៅគល់ថាឲ្យដាក់នៅចុង ឥឡូវមើលរបស់នរណាជាប់ហ៍ ហើយក៏ឡើងទៅដោះយកបុះមកនាំគ្នាវិលមកផ្ទះវិញលាគ្នាទៅផ្ទះដោយខ្លួនទៅ ។ ឯចៅដែលបានក្តាន់ក៏ប្រញាប់យកទៅជូនសុភាសេក ហើយជំ-រាបថាដូច្នេះ ខ្ញុំហើយនឹងចៅមួយនោះទៅដាក់អន្ទាក់ផងគ្នា ខ្ញុំដាក់នៅចុងឈើ អ្នកមួយនោះដាក់នៅគល់ ខ្ញុំនេះជាមនុស្សវៀចក្តីគង់តែដល់លោក ដូច្នេះតាមតែលោកមេត្តាអាណិតរកសេចក្តីយ៉ាងណាឲ្យតែសេចក្តីខ្ញុំឈ្នះវា ខ្ញុំនឹងដឹងព្រះតេជព្រះគុណទៅមុខ ។ សុភាសេកបានសាច់ក្តាន់ហើយឆ្លើយវិញថា ឯងទៅរកស្លាមួយមកឲ្យឆាប់ឲ្យទាន់ព្រឹកនេះ បើវាមកប្តឹងអញ ៗ បង្គាប់ដូច្នឹងដែរ បើវាមកមិនទាន់អញនឹងកាត់សេចក្តីឲ្យវាចាញ់បានងាយ ឯងទៅចុះ ឯអ្នកដែលដាក់អន្ទាក់នៅគល់ឈើ លុះវិលមកផ្ទះហើយដង្ហើមតូច-ធំ មិនសុខចិត្តយកសេចក្តីទៅប្តឹងសុភាសេកៗ ក៏បង្គាប់សេចក្តីដូចសេចក្តីដែលបង្គាប់ចៅមុន លុះព្រឹកឡើងអ្នកមួយក៏យកអីវាន់ទៅដល់មុន ។ ឯចៅដែលដាក់

អន្ទាក់នៅដីខ្លួនជាអ្នកក្រីបាកគោកយ៉ាកដើររកវិញអីរាន់កុំ បានពុំទាន់ តែភ័យខ្លួនក្រែងចាញ់គេហើយគេចាប់ទោសផង រត់ពីភូមិ ១ ទៅស្រុក ១ ជួបនឹងសុភាទន្សាយ ៗ សួរថា មានដំណើរអីក៏បានជារត់ដូច្នេះឈប់សិន ព្រាននោះឆ្លើយថា លោកអើយអាណិតដោះទុក្ខខ្ញុំផង ដ្បិតខ្ញុំហើយនឹងអ្នកមួយទៅដាក់អន្ទាក់នឹងគ្នា ខ្ញុំដាក់នៅគល់ឈើ គេដាក់នៅចុងឈើ ព្រឹកឡើងទៅមើលពុំឃើញអន្ទាក់នៅដីជាប់សត្វ ឃើញឯអន្ទាក់នៅចុងឈើជាប់ក្តាន់មួយ យ៉ាងដូច្នេះខ្ញុំមិនសុខចិត្តយកសេចក្តីទៅប្តឹងសុភា ៗ គេថាអ្នកណាកអីរាន់យកទៅដល់មុន អ្នកនោះឈ្នះ ហេតុនេះបានជាខ្ញុំភ័យ ខ្លាចគេទៅដល់មុនហើយដូច្នេះតាមតែអាណិត សុភាទន្សាយឆ្លើយថា ហ្អើយកុំអៃចាំថ្ងៃស្អែកសឹមខ្ញុំនាំទៅ ព្រាននោះក៏អរ លុះថ្ងៃស្អែកសុភាទន្សាយនាំទៅដល់ផ្ទះសុភាសេក ៗ ស្រែកសួរមកថា ដូចម្តេចក៏យូរម្លេះសេចក្តីចាញ់គេហើយ សុភាទន្សាយឆ្លើយវិញថា យើងខ្ញុំបានជាយូរនេះ ពីព្រោះអាល័យតែចាំមើលត្រីត្រាញ់ហើរឡើងស៊ីស្លឹកអម្ពិល ។ សុភាសេកថា ពីដើមដូនជីតាមក

នរណាដែលឃើញដែលឮថាត្រីក្រាញ់ឡើងស៊ីស្លឹកអំពិល ។ សុភាទន្សាយឆ្លើយថាពីដីដូនពីជីតា ពីម៉ែបង្កើតមកនរណាដែលឃើញដែលឮថា ដាក់អន្ទាក់នៅគល់ឈើនៅដីមិនជាប់សត្វ ទៅជាប់សត្វឯចុងឈើហើយសត្វជើងបួនផង ដែលឮទេអស់អ្នកស្រុក នោះសុភាសេកស្ងៀមពុំហ៊ានស្រដីតបទៀត សុភាទន្សាយកាត់សេចក្ដីឲ្យចៅដែលដាក់អន្ទាក់នៅដីឈ្នះ ឯសុភាសេកដែលអង្គុយធ្វើជាសុភានោះក៏ខ្មាសគេដោយសារខ្លួនជាអ្នកល្មោភជំនួសសាច់ក្ងាន់ ក៏ស្ងៀមទុកមុខខាងជញ្ជាំងដូចឆ្មាលបកណ្ដុរ ។

# បញ្ជីរឿង

លេខទំព័រ


១ — បរិវត្តមាគធ ដំណើរអង្គរលោកក្នុងដែនកូសាំងស៊ីន សេចក្តីសរុប ព្រះសាសនសោភ័ណ ជ. ណាត រៀបរៀង (តចប់) . . . . . . . . . . . ១៥៩

២ — ខេមរាខេមរសរណកថា ព្រះមហាពិទូរក្រសេម គន្ធាជនបណ្ឌិត រៀបរៀង (ត) ១៨១

៣ — លោកន័យ ពាក្យកាព្យ របស់លោកវង្សាសារពេជន៍ នង តែង (ត) . . . ១៩៣

៤ — សប្បុរិសធម៌ ពាក្យកាព្យ ឃន-តេង គ្រូបង្រៀន តែង (ត) . . . . . . ២០៣

៥ — រឿងព្រេងខ្មែរ រឿងព្រោះឡាងាប់ . . . . . . . . . . . . . . . . . ២៤៥


## រូបក្រៅរឿងផ្សេង ៗ


១ — ព្រះប្រាង្គណ៌បញ្ចុះព្រះសារីរិកធាតុ នៅក្រុងមណ្ឌាលេ (ភូមា) . . . . . . . . ៣០៩

# TABLE DES MATIÈRES


| | | Pages |
|---|---|---|
| I. | Tournée en Cochinchine de M. le secrétaire général de l'Institut Bouddhique (Conclusion)...................... | 159 |
| II. | Khemā-Khema-Saraṇakathā ou Religions, refuge des hommes par Préas Maha Pitou Krasem (à suivre)........... | 181 |
| III. | Lokānaya poème par le Oknhā vaṅsāsarabeecana Nâng (à suivre)........................................ | 193 |
| IV. | Sappurisadhamma poème ou la générosité par Ban-Téng. . | 213 |
| V. | Conte populaire Cambodgien inédit Histoire d'un tigre. . . . | 225 |


## HORS TEXTE:


Escalier convert conduisant au sanctuaire des cendres du Bouddha sur la colline sacrée-Mandalay (Birmanie)...... 179

ដំណើរអង់គ្លូរណា

ស្រុកកូសាំងស៊ីន សេចក្ដីសរុប

(ចប់)

## សេចក្ដីសរុប

តាមទំនងស្រួលមើលស្រួលស្ដាប់. គួរតែស្ទង់ដំណើរការរាល់ទីប្រជុំឲ្យហើយស្រេចត្រង់ទីបំផុតបន្ទាប់អំពីសេចក្ដីរៀបរាប់រាល់អន្លើ គឺត្រូវស្ទង់ឬស្មានឲ្យឃើញថា ទីប្រជុំនេះ មានប្រយោជន៍ដូចម្ដេចខ្លះ, ពួកខ្មែរនៅទីតំបន់នេះ មានចិត្តគំនិតអធ្យាស្រ័យដូចម្ដេចខ្លះ, មានសេចក្ដីចំរើនឬមិនចំរើនដូចម្ដេចខ្លះ, ព្រោះហេតុអ្វី, តពីនេះទៅមុខតើនឹងប្រព្រឹត្តទៅដោយដំណើរយ៉ាងណា ។

បើជាស្ទង់ដំណើរការឲ្យហើយស្រេចរាល់អន្លើ (គ្រប់ទីប្រជុំមួយៗ) យ៉ាងនេះ ឃើញថាស្រួលមើលស្រួលស្ដាប់មែន ដ្បិតសំដែងនូវដំណើររៀបរាប់កិច្ចការបន្តជិតជាប់គ្នាមក, ប៉ុន្តែបើដូច្នេះ, នឹងក្លាយទៅជាសេចក្ដីមិនពិតខ្លះពុំខាន ពីព្រោះទីប្រជុំខ្លះ គ្រាន់តែសំដែងអាការខ្វះខ្វែង ធ្វើបដិសណ្ឋារៈរាក់ទាក់ស្រស់រាយសាទរនៅទីចំពោះមុខយើង, ហាក់ដូចជាគួរនឹងឲ្យស្មានបានថាសុទ្ធតែពេញចិត្តព្រមទទួលធ្វើតាមដំណើរ

បាត់ការរបស់ពុទ្ធសាសនបណ្ឌិត្យទាំងអស់ឥតមានទទឹងទាស់ទេ, ប៉ុន្តែមិនមែនសោះ, គ្រាន់តែសំដែងសំតាំនៅមុខយើងក្នុងវេលាប្រជុំនោះប៉ុណ្ណោះ, លុះរួចពីនោះមកនោងដែល គឺពីដើមរៀងមកធ្លាប់ប្រព្រឹត្តដូចម្ដេច, ក៏នៅជាដូច្នោះឯង ៗ ទីប្រជុំខ្លះ មិនដូច្នោះទេ. ដែលសំដែងអាការអើពើទៅមុខយើងយ៉ាងណា. សុទ្ធតែជាការពិត. លុះតមកក៏នៅប្រព្រឹត្តទៀងទាត់ដូច្នោះឯង គឺថា ទទួលស្ដាប់ ធ្វើតាមរបៀបការបាត់ចែងរបស់ពុទ្ធសាសនបណ្ឌិត្យ មិនហ៊ានបោះបង់. ព្រោះជឿសប់ថា ប្រាកដជាមានប្រយោជន៍មែន; សព្វថ្ងៃនេះ មនុស្សក្នុងទីតំបន់នោះក៏មានសេចក្ដីចំរើនគ្រាន់បើបន្តិចជាងពីដើមខ្លះហើយ, សំដែងទំនងឲ្យយើងស្ងប់ការដោយនូវស្មានបានថា តពីនេះទៅមុខជានឹងមានសេចក្ដីល្អតលាស់ចំរើនដោយចំណេះវិជ្ជាគំនិតប្រាជ្ញា ព្រមទាំងទ្រព្យធនរុងរឿងដោយលំដាប់ឡើងពុំខាន ៗ ទីប្រជុំខ្លះ ឬទីតំបន់ខ្លះ សំដែងអាការតោះតើយ មិនអើពើ ឬមិនទទួលកិច្ចធុរៈរបស់ពុទ្ធសាសនបណ្ឌិត្យសោះក៏មាន, បង្គួលទំនងឲ្យឃើញថា មិនកើតទេ. ប៉ុន្តែយើងនឹងអាចស្មានទាយដោយ

ជាប់ខាតថា "នឹងមិនប្រែគំនិតរហូតទៅ" ដូច្នេះក៏ថាមិនទាន់បានដែរ ។

ដោយហេតុដូចមានខាងលើនេះ នាំឲ្យខ្ញុំអ្នករាប់រៀបសេចក្ដី ជាស់គំនិត, រឹងមាត់, ញុះញង់ មិនហ៊ានស្ទង់ស្មានការឲ្យហើយស្រេចភ្លាមៗឡើយ ។ ខ្ញុំយល់ថាត្រូវលើកសេចក្ដីរៀបរាប់ដំណើរស្ទង់ការរាល់ទីប្រជុំទាំងនោះយកមករៀបរៀងដោយឡែកផ្សេងវិញ រាយការជាសរុបតាមលំដាប់ខេត្តទាំង៩ ដូចមានសេចក្ដីតទៅនេះៈ

## ខេត្តតៃនិញ

ពួកខ្មែរក្នុងខេត្តតៃនិញ (ខេត្តរោងដំរី), តាមដោយខ្ញុំបានសង្កេតមើលទៅ, ឃើញត្រង់វត្តព្រៃជេត មានសេចក្ដីភ្ញាក់រឭក មានអៀនខ្មាស, ខំប្រឹងរៀនសូត្រ, បណ្ដុះគំនិតប្រាជ្ញាឲ្យល្អតលាស់, មានសម្មាចារ គ្រាន់បើជាងពួកខ្មែរនៅទីតំបនឯទៀតក្នុងខេត្តនេះ ។ ហេតុដែលនាំឲ្យមានសេចក្ដីចំរើនគ្រាន់-

បើយ៉ាងនេះ ព្រោះអាស្រ័យលោកចៅអធិការវត្តព្រៃជេតនេះ ជាអ្នកឈ្លាសវៃ ប្រសប់ណែនាំមនុស្សឲ្យដើរតាមផ្លូវត្រង់, ហើយថែមមានគ្រហស្ថអ្នកមានសម្បត្តិគ្រាន់បើ ដែលមានសេចក្ដីភ្ញាក់រឭកឆាប់នឹកឃើញ, ស្គាល់ខុសត្រូវ, មានអៀនខ្មាស, ជាជំនួយជួយជាកំលាំងលោកចៅអធិការនោះផង ។ បំណែកខាងពួកខ្មែរនៅទីតំបន់ឯទៀត ច្រើនតែជាប់ចិត្តជប់ក្នុងការលេងល្បែងភ្នាល់, ផឹកទឹកស្រវឹង, ដើរលេងប្រឡែប្រកោ, ប្រហែសធ្វេស មិនសូវខំប្រឹងធ្វើការរកស៊ី ហើយថែមទាំងលើកយកការរៀនសូត្រធ្វើជាសត្រូវ ពោលពាក្យតិះដៀល និយាយដើម បន្តុះបង្អាប់ពួកអ្នករៀនផងក៏មាន ។

ខ្ញុំយល់ថា បើរាជការបេះតែឲ្យពុទ្ធសាសនបណ្ឌិត្យទទួលពន្យល់ណែនាំយ៉ាងនេះរឿយ ៗ រៀងទៅ កុំតែបោះបង់ឲ្យនោះ, ពួកខ្មែរខេត្រតែនិញនេះគង់នឹងមានសេចក្ដីចំរើនដោយលំដាប់ឡើងមិនខាន, ប៉ុន្តែយឺតណាស់ ។

## ខេត្រហាទៀង

ខេត្រហាទៀង (ខេត្រពាម) មានភូមិស្ថានសប្បាយដោយលំអភ្នំនឹងសមុទ្រ, ប៉ុន្តែខាងមុខការរបរនៃប្រជាជនមិនសូវចំរើនណាស់ណាទេ ។ ពួកខ្មែរក្នុងខេត្រនេះ មានសណ្ដាប់ធ្នាប់បែបបទស្រដៀងគ្នានឹងពួកខ្មែរក្នុងខណ្ឌកំពង់ត្រាច (ខេត្រកំពត), ខុសគ្នាខ្លះបន្តិចបន្តួចតែសំលៀកបំពាក់, ព្រោះខ្មែរហាទៀងប្រើនស្លៀកពាក់តាមបែបយួន ។ សង្កេតមើលទៅគំនិតជ្រាជ្រៅពួកខ្មែរក្នុងខេត្រនេះ ឃើញនៅខ្សោយណាស់ ព្រោះប្រើនជាប់ចិត្តលេងក្នុងការស៊ីផឹកនឹងល្បែងភ្នាល់នៅឡើយ ។ ចំណែកខាងពួកបព្វជិតក៏ប្រើនខ្សោយណាស់, មិនសូវស្រាវស្រទេញនឹងធម៌វិន័យប៉ុន្មាន ។ ប៉ុន្តែបើពុទ្ធសាសនបណ្ឌិតបេះតែប្រឹងទទួលណែនាំពន្យល់មិនបោះបង់ទេ, យូរទៅក៏គង់នឹងមានសេចក្ដីចំរើនបន្តិច ៗ ឡើងពុំខាន, ព្រោះពួកខ្មែរខេត្រនេះមានសភាពជាអ្នកស្លូតបូតទេ ។

ខែត្រចូដុក

បណ្តាពួកខ្មែរក្នុងខែត្រចូដុក (ខែត្រមាត់ជ្រូក), ដែលគ្រាន់បើជាងគេ គឺខ្មែរនៅស្រុកទ្រឹតុង (ស្វាយទង), ព្រោះពួកខ្មែរស្រុកនេះ ច្រើនភ្ញាក់រឭកនឹកឃើញដល់ដំណើរទន់ខ្សោយរបស់ជាតិ ហើយបានខំប្រឹងរាស់តឿនគ្នា ណែនាំកូនចៅឲ្យសង្វាតរៀនសូត្រ ទាន់ពេលទាន់សម័យ, គឺច្រើនខំប្រឹងរៀនអក្សរខ្មែរ អក្សរយួន អក្សរបារាំង ដែលជាចំ-ណោះគួររៀនក្នុងសម័យនេះ; ច្រើនមានចំណេះវិជ្ជា បានធ្វើរាជការមានកេរ្តិ៍ឈ្មោះ ហើយមិនសូវមើលបំណាំគ្នា, ចេះជួយយោងអន្ទងញាតិមិត្រ, អ្នកស្រុកភូមិផងរបងជាមួយ ឲ្យខំខ្មីឃ្មាតសង្វាតធ្វើការរបរ, មិនសូវបណ្តោតបណ្តោយគ្នាឲ្យលង់ក្នុងសេចក្តីវិនាស ។ ពួកខ្មែរស្រុកទ្រឹតុង ដែលសព្វថ្ងៃនេះ, បានធ្វើជាអ្នករាជការ ជាមន្ត្រីមានស័ក្តិយស ក្នុងកម្ពុជរដ្ឋក៏មានច្រើន ។ ពួកខ្មែរស្រុកទ្រឹតុងដែលច្រើនល្អតលាស់យ៉ាងនេះកើតមកអំពីដំណើរអៀនខ្មាស ដែលទុកដូចជាមាតារបស់

សេចក្ដីបំរើន, គឺកើតអំពីខ្មាសល្ងង់ បានជាខំប្រឹងរៀនសូត្រឲ្យចេះដឹង កើតបានជាតួប្រាជ្ញ, ខ្មាសសេចក្ដីក្រីក្រលំបាក បានជាខំប្រឹងធ្វើប្រឹងរក កើតបានជាទ្រព្យសម្បត្តិ; ផ្សំនឹងសំណាងរបស់ខ្លួនស្រាប់មកផង ក៏ល្អតលាស់បំរើនឡើងតកូនតចៅ ។

បំណែកខាងពួកបព្វជិតក្នុងស្រុកទ្រឹតុង ដែលយកចិត្តទុកដាក់ខំខ្មីឃ្មាតសង្វាតរៀនទន្ទេញធម៌វិន័យ ព្រះពុទ្ធសាសនាក៏មានច្រើនវត្តដែរហើយ ។ ខ្ញុំស្ទង់មើលទៅឃើញថា មិនឃ្លូរឆ្នាំប៉ុន្មានទេ, បព្វជិតគ្រប់វត្តក្នុងស្រុកនេះ មុខជានឹងខំប្រឹងរៀនសូត្រដោយពេញកំលាំងដូចគ្នាទាំងអស់ពុំខាន, ព្រោះក្នុងស្រុកនេះ ពួកគ្រហស្ថអ្នកមានចំណេះវិជ្ជាទាំងប៉ុន្មាន គេច្រើនពេញចិត្តនឹងបព្វជិតអ្នករៀនសូត្រ ស្ទើរតែនឹងទាំងអស់គ្នាទៅហើយ, ពួកអ្នកបួសក៏គង់នឹងនឹកខ្មាសគ្រហស្ថ ហើយខំប្រឹងរៀនឯងៗ មិនចាំបាច់មានគេបង្ខំ ។

## ខែត្រឡុងធៀង

ពួកខ្មែរក្នុងខែត្រឡុងធៀង (ខែត្របារ៉ាច) មានបំនួនតិចបំផុតជាងខ្មែរខែត្រឯទៀតៗ (ក្នុងដែនកូសំងស៊ីន), ហើយ

ច្រើនតែអ្នកល្ងង់ខ្លៅ, មិនមានអ្នកណាយឹតយោងអន្ទងស្រោចស្រង់អ្នកណាបានឡើយ ។ ដូចជានៅភូមិក្បែរភ្នំបាថេ, មានខ្មែរច្រើននាក់ នាំគ្នាទៅចាប់ដីទំនេរ (ក្នុងខេត្រ៉ាច់យ៉ា) ឥតមានសុំអនុញ្ញាតរាជការឲ្យរាស់បែកឡើយ; លុះគាស់រានបានជាស្រែរកស៊ីអស់កាលយូរមក, ស្រាប់តែមានយួនអ្នកមានទ្រព្យគេចូលទៅសុំអនុញ្ញាតរាជការ ៗ បានចាត់បំរើតាមមុខក្រសួងឲ្យទៅវាស់ដីស្រែទាំងនោះប្រគល់ឲ្យជារបស់យួនអ្នកមានទ្រព្យនោះអស់ទៅ, ព្រោះរាជការយល់ត្រឹមតែថាដីទំនេរគ្មានម្ចាស់ ។ លុះដល់គេអ្នកក្រោយគេបង់ពន្ធជូនរាជការតាមច្បាប់ទៅ, ពួកខ្មែរអ្នកគាស់រានទាំងប៉ុន្មាននាក់នោះក៏អស់អំណាចមិនអាចនឹងប្ដឹងតវ៉ាដូចម្ដេចបាន, ព្រោះខ្លួនល្ងង់ជ្រុល នាំគ្នាប្រព្រឹត្តទាស់ផ្លូវច្បាប់ទាំងស្រុង, ធ្វើម្ដេចនឹងក្ដីឈ្នះគេ ។ កាលដែលយើងទៅក្នុងទីប្រជុំនៅវត្តភ្នំបាថេ, មានខ្មែរខ្លះនាំគ្នាមកគក់ទ្រូងគក់ស្មាស្រែករំពា ឲ្យលោកអគ្គលេខាធិការជួយស្រោចស្រង់ឲ្យបានដីស្រែនោះមកវិញ ។ ទុកជាលោកណាក៏រកជួយដូចម្ដេចមិនកើត ។ នេះហើយដែលសំដែងភ័ស្តុតាង

ឲ្យយើងដឹងថាខ្មែរក្នុងខេត្រនេះ សុទ្ធតែល្ងង់ខ្លៅទាំងអស់គ្នា ឥតមានអ្នកណានឹងអាចណែនាំពន្យល់ ឬជួយឃើតយោងអ្នកណាកើត ។

ម្យ៉ាងទៀត, ក្នុងខេត្រឡុងផៀងនេះ, បើទុកជាក្នុងសម័យឥឡូវ, រាជការនឹងត្រូវការសង្គ្រោះតាំងខ្មែរឲ្យធ្វើជាមន្ត្រីខ្លះឡើង, ក៏រកកល់នឹងតាំងមិនកើត, ពីព្រោះនឹងរកខ្មែរណាសូម្បីតែម្នាក់ដែលមានបំណេះវិជ្ជាល្មមធ្វើរាជការបាននោះគ្មាន; បើរាជការបេះតែទទួបតាំងទៅ ក៏ប៉ុនគេដាន់ពន្លិច, ព្រោះមន្ត្រីជាតិខ្មែរនោះមុខជានឹងមានសេចក្ដីភ្លោះភ្លោយដោយហេតុណាមួយមិនខាន; ដ្បិតអក្សរខ្មែរឬអក្សរយួនបេះមិនសូវប្រាកដ, អក្សរបារាំងឥតបេះសោះ, ខាងកិច្ចរាជការក៏មិនសូវប្រសប់ផងទៀត ។

ខ្ញុំស្ទង់មើលទៅឃើញថា ពួកខ្មែរខេត្រឡុងផៀងនេះក៏ដោយ ខេត្រឯទៀត ៗ ក៏ដោយ,[១] បើលុះតែពួកបព្វជិតរាល់វត្តភ្ញាក់រឭកនឹកដល់ឧបការៈរបស់ខ្លួនយក ហើយខំប្រឹងខ្នះខ្នែងជួយទំនុកបំរុងឲ្យពេញកំលាំងនោះទើបនឹងអាចដុះលូតលាស់

---

១ គោះខ្មែរគ្រប់ខេត្រក្នុងកម្ពុជក្រោមក៏ដោយ ។

ចំរើនឡើងបាន; ព្រោះប្រជាជនជាតិខ្មែរច្រើនតាំងចិត្តផ្ដេកផ្ដួល ជឿស្ដាប់លោកសង្ឃជាងគ្រហស្ថផងគ្នា ។ ការដែលពួកបព្វជិតត្រូវជួយទំនុកបំរុងគ្រហស្ថនោះដូច្នេះគឺៈ លោកគ្រូចៅអធិការក្ដី លោកគ្រូសូត្រក្ដី ត្រូវខំប្រឹងចាត់ការបង្រៀនកូនអ្នកស្រុកឲ្យបានចេះអក្សរខ្មែរនឹងលេខយ៉ាងស្ទាត់ជំនាញហើយ, ក្នុង ១ ឆ្នាំ ៗ, ត្រូវចាត់ភិក្ខុសាមណេរដែលជាសិស្សរបស់ខ្លួន បានពីរឬបីរូប ឲ្យទៅនៅឯទីក្រុងយ៉ាងដូចក្រុងភ្នំពេញជាដើម, ហើយជួយទំនុកបំរុងផ្គត់ផ្គង់ ត្រាតែអ្នករៀនទាំងនោះមានចំណេះវិជ្ជាល្មមប្រើការបាន, ហើយឲ្យត្រឡប់មកនៅឯវត្តរបស់ខ្លួនវិញខ្លះ, ឲ្យនៅឯទីក្រុងនោះខ្លះ គាត់ទុកជាកន្លែងជាផ្លូវ ឲ្យពួកកុមារកូនអ្នកស្រុកទៅនៅសំណាក់អាស្រ័យរៀនអក្សរបារាំងឯទីក្រុងនោះផង (ព្រោះក្នុងសម័យសព្វថ្ងៃនេះ អក្សរបារាំងជាចំណេះមានប្រយោជន៍ណាស់) ។ ចំណែកខាងពួកខ្មែរអ្នកស្រុកនោះ ត្រូវរួតដៃគ្នាហោមជួយទំនុកបំរុងផ្គត់ផ្គង់ ឲ្យទាល់តែអ្នករៀនទាំងនោះខ្លាបចិត្ត ហើយខំសង្វាតប្រឹងរៀនត្រាតែចេះ បានធ្វើរាជការកើត, ឬបើបែរជាមិនបានធ្វើរាជការទេ ក៏

ល្មមជាពន្លឺ ជាបង្អែកនៃអ្នកស្រុករបស់ខ្លួននោះបាន ។ អ្នករៀនទាំងនោះ, បើទុកជាដួបម្តេចក៏ដោយ, មុខជានឹងមិនហ៊ានធ្មេចភ្នែកបំភ្លេចគុណញាតិសន្តាននឹងអ្នកស្រុករបស់ខ្លួនទេ ពី-ព្រោះនឹកឃើញច្បាស់ថាខ្លួនបានចេះដឹងដោយសារគេជោមជួយទំនុកបំរុងរៀងមក ។ ធ្វើយ៉ាងនេះ បើយ៉ាងយូរណាស់ ត្រឹមតែ ៦ ឬ ៧ ឆ្នាំប៉ុណ្ណោះ ក៏នឹងឃើញផលប្រយោជន៍ដល់ភូមិស្រុកនីមួយ ៗ ជាប្រាកដ (នេះជាការបណ្តុះសេចក្តីចំរើនជាដំ-បូងបំផុត) ។ ខ្ញុំនិយាយយ៉ាងខ្លីប៉ុណ្ណោះ អ្នកមានគំនិតវាងវៃក៏គង់នឹងអាចឃើញឧបាយនៃសេចក្តីចំរើនដោយច្រើនជាងនេះទៅទៀត ។

## ខេត្ររ៉ាច់យ៉ា

ខ្មែរក្នុងខេត្ររ៉ាច់យ៉ា (ខេត្រក្រមួនស) មានចំនួនច្រើន, មានវត្តអារាមក៏ច្រើន ។ ពួកខ្មែរក្នុងខេត្រនេះ, ត្រង់ទីតំបន់ខ្លះនៅទន់ខ្សោយស្រដៀងគ្នានឹងខ្មែរខាងខេត្រឡុងផៀងដែរក៏មាន,

នៅទីតំបន់ខ្លះមានសេចក្ដីភ្ញាក់រឭកខំប្រឹងរៀនសូត្រគ្រាន់បើ, ខ្លះបានធ្វើជាមន្ត្រីក៏មាន. ចេះអក្សរបារាំងល្មមប្រើការកើតក៏មានខ្លះ, ត្រង់ទីតំបន់ខ្លះនៅជាប់ចិត្តនឹងល្បែងផ្សេងៗមិនទាន់អើពើមករកការរៀនសូត្រនៅឡើយក៏មាន, ដែលបានតាំងបង្កើតសាលារៀនឲ្យមានក្នុងវត្តអារាមក៏មានក្រែលដែរហើយ ប៉ុន្តែច្រើនមិនទាន់បានជាការមាំទាំនៅឡើយ ។

ខ្ញុំស្មង់មើលទៅឃើញថា ពួកខ្មែរក្នុងខែត្រប៉ាប់យ៉ានេះគង់នឹងមានសេចក្ដីចំរើនដោយលំដាប់ឡើងដែរ ប៉ុន្តែយឺតណាស់ ព្រោះលោកគ្រូចៅអធិការចាស់ៗដែលនៅប្រកាន់ក៏មានច្រើន ។ ក្នុងវេលាដែលយើងទៅនិយាយពន្យល់ ក៏សំដែងអាការខាងក្រៅដោយចាត់របៀបរៀបចំទទួលហិកហាក់គគ្រឹកគគ្រេង, សំដែងបដិសណ្ឋារៈរួសរាយរាក់ទាក់ ហាក់ដូចជាគាប់ចិត្តណាស់, ប៉ុន្តែមានទំនងផ្សេងទៀត គួរឲ្យស្មង់ការបានថា គួរសមយកតែលំនាំនៅមុខយើងប៉ុណ្ណោះទេ, លុះតមក ក៏នៅតែដដែលដូចពីដើមរៀងមកដូច្នោះឯង ។

ខេត្តបាក់លីវនិងខេត្តស្រុកត្រាំង

ក្នុងខេត្តបាក់លីវ (ខេត្តប៉ោលៀវ) និងខេត្តស្រុកត្រាំង (ខេត្តឃ្លាំង) ទាំង ២ នេះ មានបំនួនពួកខ្មែរនិងវត្តអារាមបន្ទាប់បន្សំគ្នា, ទាំងសណ្ដាប់ធ្នាប់របស់ជនានុជនក៏ប្រហែល ៗ គ្នា ។ ជនជាតិខ្មែរក្នុងខេត្តទាំង ២ នេះ ច្រើនមានសម្បកសម្បត្តិប្រដំប្រសងគ្នានឹងប្រជាជនជាតិយួនបាន ខ្លះ, ប៉ុន្តែខាងបំណោះវិជ្ជាសម្រាប់ស្រុក នៅតែខ្សោយថយជាងពួកយួនច្រើនណាស់, ព្រោះមកពីពួកខ្មែរមិនសូវត្រិវការនឹងឲ្យកូនចៅចូលរៀនក្នុងសាលារាជការ, ច្រើនគិតប្រយោជន៍ខាងការឃ្វាលគោក្របីជាងការសិក្សា ។ សព្វថ្ងៃនេះ សាលារៀនតាមវត្តខ្មែរក៏មានក្រៃលដែរហើយ, ប៉ុន្តែមិនទាន់បំពេនពេញទីនៅឡើយ ។

ខ្ញុំស្ទង់ការមើលទៅឃើញថា ខ្មែរក្នុងខេត្តទាំង ២ នេះ, បើតាមមនុស្សជំនាន់ក្មេង ៗ, រកកល់នឹងភ្ញាក់រឭកចូលចិត្តរៀនសូត្រតាមរបៀបរបស់រាជការ ស្ទើរតែនឹងទាំងអស់, ប៉ុន្តែទាស់នឹងនៅញញើតអធ្យាស្រ័យពួកលោកគ្រូចៅអធិការចាស់ ៗ ច្រើនវត្ត ដែលនៅរឹងត្អឹងប្រកាន់មាំតាមសណ្ដាប់របស់លោក

ដោយយកទម្លាប់មកជាគ្រឿងអាង  មិនទាន់ព្រមតាមរបៀបសព្វថ្ងៃនេះនៅឡើយ ។ លោកគ្រូចាស់ៗទាំងនោះ កាលដែលជួបនឹងយើងក្នុងទីប្រជុំមួយ ៗ ក៏ឥតមានប្រកែកទទឹងទាស់អ្វីទេ, ច្រើនឆ្លើយថាលោកពេញចិត្តព្រមតាម.  ខ្លះថាមានសេចក្ដីត្រេកអរណាស់; ប៉ុន្តែលុះតពីនោះមក. ច្រើនរករឿងរកហេតុសន្សំទោសពួកអ្នករៀនសូត្រ. នាំបណ្ដាលឲ្យការសិក្សារអាក់-រអួលមិនអាចនឹងដើរស្រួលទៅបាន ។ ខ្មែរខ្លះ ទៅចូលសមគំ-និតនឹងពួកយួន ឲ្យដៃឲ្យកំលាំងទៅយួនណាមួយ ជាមន្ត្រីត្រួត-ត្រាក្នុងឃុំខណ្ឌនោះ ៗ (ដែលមានគំនិតគិតតែខាងបក្សខ្មែរ), ឲ្យធ្វើទុក្ខបុកម្នេញ គំរាម កំហោកហោក ត្មះតិះដៀល ឬបង្អាប់បង្ខុសពួកខ្មែរគ្នាឯង ដែលជាអ្នកខំយកចិត្តទុកដាក់ប្រឹងសង្វាតរៀនសូត្រ, ឲ្យកើតក្ដៅក្រហាយរសាយចាកការសិក្សាទៅវិញក៏មាន ។ នេះហើយ ដែលជាហេតុនាំឲ្យសេចក្ដីចំរើនរបស់ពួកខ្មែរក្នុងខេត្តទាំង ២ នេះ លូតលាស់ឡើងមិនរួច. បើទុក-ជាបានលូតលាស់ខ្លះក៏យឺតណាស់.  ព្រោះមានខ្មែរខ្លះនៅមិនទាន់ជឿរបៀបសិក្សាដែលរាជការរៀបចំនោះថាជាការនឹងមាន

ប្រយោជន៍នៅឡើយៈ គេច្រើនទទួលស្ដាប់សំដី ជឿគំនិតពួកខ្មែរគ្នាឯងឬពួកយួនជាងដំណើរកិច្ចការរបស់រាជការ ។

(ខ) [illegible]

ពួកខ្មែរក្នុងខែត្រកំពង់ធំ (ខែត្រព្រែកឫស្សី) ត្រង់ទីតំបន់ខ្លះមានសណ្ដាប់ធ្នាប់ស្រដៀងគ្នានឹងពួកខ្មែរខែត្របាក់លីវនឹងសុកត្រាំង ខ្លះស្រដៀងគ្នានឹងខ្មែរខែត្រត្រាវិញ ។ ក្នុងខែត្រនេះ ដែលចំរើនខាងការសិក្សាគ្រាន់បើ បានតែត្រង់ទីតំបន់ខ្លះនៅស្រុកក្នុរកែ (កំពង់ស្ពាន) ក្រៅពីនោះ នៅទន់ថយខ្សោយណាស់ ។ ហេតុដែលនាំឲ្យការសិក្សារបស់ប្រជាជនជាតិខ្មែរជំនះលូតឡើងមិនរួចដូច្នេះ, មកតែអំពីពួកបព្វជិតក្នុងវត្តមួយៗរឹងត្អឹងប្រកាន់តាមសណ្ដាប់ទម្លាប់របស់ខ្លួន ។ ខ្លះតែភ្លាមឡើងក៏តាំងប្រញាប់រំអុកឲ្យរាជការជួយប្រាក់កាសៈ កាលបើយូរក្រៃបាន, ស្រាប់តែរាតគំនិតរលាស់កិច្ចការដែលត្រូវមានប្រយោជន៍ដល់ខ្លួននឹងកូនចៅនោះចោល ឥតនឹកស្ដាយ ។

ខេត្រត្រាវិញ

ក្នុងខេត្រត្រាវិញ (ខេត្រព្រះត្រពាំង) ជនជាតិខ្មែរមានចំនួនច្រើនជាងខ្មែរនៅខេត្រឯទៀត ៗ ក្នុងដែនកូស័ងស៊ីន ។ មានខ្មែរអ្នកទំប្រឹងខ្នះខ្នែងប្រជែងមុខការសិក្សាជាមួយនិងពួកយួនក៏ក្រៃលដែរ. ខ្មែរដែលនៅជិអក់ព្រកាន់តាមសណ្តាប់ទម្លាប់របស់ខ្លួននោះក៏មានច្រើន ។ សាលារៀនតាមវត្តខ្មែរក៏មានក្រៃលដែរហើយ. ប៉ុន្តែដែលលូតលាស់គ្រាន់បើនោះមានតិចពរាស់ ។ ធ្វើម្តេចនឹងឲ្យលូតលាស់បំរើនទាន់សាលាយួន ៗ ជុះបាក់ឫសមាំ ៗ ណាស់ទៅហើយ; ព្រោះពួកខ្មែរ អាល័យតែនាំគ្នាសំកុកខ្លះ, ដេកលក់មិនប្រែខ្លួនសោះក៏មានខ្លះ, ភ្ញាក់ពីដេកដែរ ប៉ុន្តែអង្គុយមើលតែមុខគេក៏មានខ្លះ, អាល័យតែលេងសប្បាយភ្លេចខ្លួនខ្លះ; លុះដល់ឃ្លានក៏លោតឹកបង់បរិភោគម្ហូបចំណី (ក្នុងស្តុកដែលរាជការដាក់ទានដល់សាធារណជនមិនរើសមុខនោះ) ណាស់ដែរ, ប៉ុន្តែនឹងជ្រែកវែកគេ ចូលទៅបរិភោគផងមិនកើត (ទើសបង្អៀតនឹងពួកយួន), ពីព្រោះយួនគេរហ័ស គេរវៀះវៃចូលអង្គុយហោមជុំជិតស្តុកនោះអស់

ទៅហើយ; បើទុកជាគេលែងបរិភោគ គេក្រោកបេញ, គេទាញដៃគ្នាគេ (ដែលល្មមអង្គុយត្រង់កន្លែងនោះបាន) ឲ្យចូលអង្គុយភ្លាម ១ រំពេច ។ ពួកខ្មែរគួរកុំបន្ទោសរាជការថា "យោគយល់តែយួន" ដូច្នេះឡើយ, ពីព្រោះមុខក្រសួងរាជការគ្រប់កន្លែងទាំងអស់ ជាសាធារណៈសម្រាប់មនុស្សអ្នកមានបំណោះ, អ្នកណាបេះ អ្នកនោះត្រូវបានកន្លែងត្រង់ណោះអង្គុយ, កន្លែងអស់នោះ មិនមែនសម្រាប់មនុស្សល្ងង់ទេ (ដូចជាម្ហូបចំណី សម្រាប់អ្នកបេះបរិភោគ ហើយដែលត្រូវការបរិភោគដូច្នោះឯង) ។

ខ្ញុំថ្លែងសេចក្ដីសង្ខេបប៉ុណ្ណោះគ្រាន់តែជាផ្ទុំគំនិត; សូមអស់លោកអ្នកមានប្រាជ្ញាគិតហើយគិតទៀតថែម ៗ ឲ្យឃើញសេចក្ដីវែងឆ្ងាយទូលាយជាងនេះទៅទៀតបុះ. នឹងបានបង្កើតសេចក្ដីអៀនខ្មាសដែលទុកដូចជាមាតានៃប្រយោជន៍គ្រប់យ៉ាងឲ្យមានរើបូណ៌ក្នុងចិត្តឡើង ។

ចប់តែប៉ុណ្ណោះ ។



ជណ្តើរមានគម្របឡើងទៅព្រះប្រាង្គណ៍បញ្ចុះព្រះសារីរិកធាតុ នៅលើភ្នំតូច ១
ក្នុងក្រុងមន្ទលេ (ភូមា)

ខេមាខេមសរណាគាថា

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត
រៀបរៀង (ត)

នៅមានផ្លូវដែលត្រូវពិនិត្យតទៅសឹងខានមិនបាន ក៏គឺថា ព្រះជាម្ចាស់ទាំងនោះ ទ្រង់គុណធម៌បរិសុទ្ធផូរផង់ គួរទទួលការក្រាបសំពះបូជា គួរជាទីតាំងនៃអនុស្សាវរីយៈ (គ្រឿងរឭក) របស់មនុស្សហើយឬនៅ ? តាមក្នុងរឿងមហាភារតៈ និងរឿងរាមាយណៈ ជាដើម សំដែងថា ព្រះជាម្ចាស់ទាំងនេះ រហូតដល់ពួកព្រហ្មឫសីដែលកាន់លទ្ធិព្រហ្មញ្ញ សុទ្ធតែមានប្រពន្ធកូនទាំងអស់ ព្រោះគេកាន់ថា បុរសណាគ្មានកូនប្រុសដ៏កើតអំពីលោហិតរបស់ខ្លួន បុរសនោះស្លាប់ទៅតោងធ្លាក់រណ្ដៅនរក១ឈ្មោះថា "បុត" បើមានកូនប្រុសៗនោះនឹងជួយយឹតយោងមិនឲ្យធ្លាក់នរកនោះបាន ពាក្យថា "បុត" ទើបជាឈ្មោះកូនប្រុស សម្រាប់ហៅកូនប្រុស ដល់សព្វថ្ងៃនេះ ប្រែថា កូនអ្នកការពារអាពុកឲ្យរួចពាកនរកឈ្មោះ "បុត" ហេតុនេះទេដឹងព្រះជាម្ចាស់ទាំងឡាយទើបសុទ្ធតែជាអ្នកមានប្រពន្ធកូន មាននាងទេពធីតាជាបរិវារគគ្រឹកគគ្រេងរាល់ថ្ងៃ ដូចពោលហើយ, នេះគួរឲ្យគិតមើលថា ក៏បើព្រះជាម្ចាស់លោកមានប្រពន្ធកូនបំរើទៅដោយកាមគុណគគ្រឹកគគ្រេងផ្លូវភាគៈ ដូចជាយើងរាល់គ្នា

ដូច្នេះហើយ កិលេសពីរកងទៀត គឺទោសៈនិងមោហៈ តើលោកនឹងមានដូចជាមានរាគៈដែរឬទេ គង់តបថា មានដូចគ្នា ព្រោះកិលេសទាំង ៣ កងនេះជាបច្ច័យនឹងគ្នា ថែមទាំងមានប្រាកដក្នុងរឿងផ្សេងៗ មានរឿងមហាភារតៈ និងរឿងរាមាយណៈជាដើម ដែលអាចឲ្យដឹងបានថា ព្រះអំបាលនេះនូវបេះនិងក្រោធ នូវបេះវង្វេងមិនយល់ខុសត្រូវ រហូតដល់ទៅធ្វើសង្គ្រាមកាប់សម្លាប់ទេវតាមនុស្សយក្ខអសុរ ឲ្យវិនាសដោយដៃខ្លួនរាប់ម៉ឺនសែន កិលេសទាំង ៣ កងដ៏ជាឫសគល់នៃអកុសលធម៌ទាំងពួង ជាដើមហេតុឲ្យប្រព្រឹត្តទុច្ចរិត ទាំងនេះគ្មានឃើញស្រាកស្រុតត្រង់ណាសោះ មិនប្លែកអ្វីនឹងមនុស្សយើងធម្មតាសព្វថ្ងៃ ដូច្នេះតើនឹងយឹតយោងយើងឲ្យរួចចាកទុក្ខដោយផ្លូវណា សមគួរហើយឬ ដែលយើងនឹងយឹតយកមកជាសរណៈទីពឹង ។

បំណែកឯកិច្ចការទាំងពួងដែលត្រូវប្រព្រឹត្តត្រូវធ្វើ ដូចយ៉ាងធ្វើពិធីបូជាយញ្ញ (បូជាយិជ) បំពេញតបៈទរមានរាងកាយថ្វាយព្រះជាម្ចាស់ក៏នៅក្នុងប្រាថ្នាផល សុទ្ធតែកាមគុណ

ទោះបីដូច្នោះក្ដី ក៏នូវរាប់អ្នកនោះថាជា ព្រហ្មឫសី រាជឫសីជាន់ខ្ពស់ គឺមានសេចក្ដីត្រាស់ដឹង នឹងតេជះផ្សេងៗគ្នា សូម្បីប្រាកដក្នុងរឿងហើយថា អ្នកនឹងលុះភូមិព្រហ្មឫសីបាន លុះតែសង្កត់ចិត្តឲ្យស្ងប់រម្ងាប់មែនៗទាល់តែរងោបសេចក្ដីដម្រែកជាដើម បើដោយគិតទៅ ពួកយើងបុថុជ្ជនសព្វថ្ងៃនេះមានកិលេស ៣ កងនេះជាធម្មតា ពួកព្រហ្មឫសីក៏មិនរលោះស្រកស្រុតទៅជាងយើងប៉ុន្មាន សុំលើកតួយ៉ាងឲ្យឃើញ ព្រះគោតមឫសីមាននាងអហលោជាភរិយា មានសតានន្ទមុនីជាបុត្រ នេះរាគៈ, ព្រះស្វាមិត្រព្រហ្ម-ឫសីញុះឲ្យព្រះរាមសម្លាប់នាងយក្ខិនីតារកា ឬហៅថា កាកនា-សូរ នេះទោសៈ, ព្រះវសិដ្ឋព្រហ្មឫសីចេញអំពីនគរមិថិលាទៅជាមួយនឹងព្រះបាទទសរថ ដើម្បីនឹងទៅនគរអយោធ្យា ប្រទះនឹងរាមបរសុ (គឺរាមាសូរ) ក្នុងរវាងផ្លូវខ្លាចត្រូវនឹងពូថៅរបស់រាមាសូរ តោងនិយាយបញ្អូរផ្អែរប្រាប់ពួកព្រាហ្មណ៍ជាមួយគ្នា នេះមោហៈ, ដូច្នេះការបំពេញតបៈរាប់ពាន់រាប់ម៉ឺនឆ្នាំ តើនឹងជាគ្រឿងបន្ទោកិលេសអ្វីបានខ្លះ? កាលមូលកិលេសទាំង ៣ នេះគ្របសង្កត់ចិត្តជាប់ហើយ ឈានវិសេសដែលសម្រាប់ធ្វើ

បាដិហារ្យ តើនឹងបង្កើតឡើងដោយផ្លូវណា ? បើទឹកមិនស្អាត យករបស់មិនស្អាតទៅលាងតើនឹងទៅជារបស់ស្អាតបានដោយហេតុអ្វី? គួរអ្នកនៅក្រោមអំណាចនឹងគប្បីពិចារណា ។

លទ្ធិសាភានុស្រ្ត

ក្នុងសម័យបុរាណកាល ប្រមាណមុនពុទ្ធសករាជ២០០ ឆ្នាំ ជនជាតិប៉ែរ្ស ដែលនៅស្រុកសិកឌី នឹងបាក់ទ្រីយ៉ាន គឺប្រទេសតុរកិស្ថាន បានរាប់អានលទ្ធិឬសាសនាសោភានុស្រ្ត លទ្ធិនេះដំណើរតាមពាក្យប្រដៅរបស់សាស្តាចារ្យ ដ៏មាននាមថា សោរោអស្ទើរ សឹងជាបុគ្គលនៅមិនទាន់ផុតចាកកិលេស ។ ក្នុងជាន់ដើម សោរោអស្ទើរមកត្រិះរិះទៅឃើញថា ក្នុងលោកនេះមានរបស់សំខាន់តែ ២ ប្រការ គឺសេចក្តីល្អនឹងសេចក្តីអាក្រក់ប៉ុណ្ណោះ របស់ទាំងពីរនេះបានប្រកួតប្រណាំងប្រឆាំងយកជ័យជំនះគ្នាទៅវិញទៅមកជានិច្ច មើលទៅហាក់ដូចជាមានខ្លួនមានវិញ្ញាណដ៏ស័ក្តិសិទ្ធិជាផ្លូវប្រឹងប្រែងឲ្យតស៊ូរគ្នាដូច្នោះ សោរោអស្ទើរ ហៅព្រះខាងល្អនេះថា ព្រះឱរមុស្ត ឬអហុរមស្តា ហៅព្រះខាងអាក្រក់ថា អរិម៉ែន ។ ពាក្យថា ឱរមុស្ត ឬ

អហុរមស្ដានោះ ប្រែថាព្រះម្ចាស់នៃបញ្ញា ជាអ្នកសាងលោក នឹងសរពើវត្ថុទាំងពួងក្នុងលោក នឹងទ្រង់នូវគុណធម៌សេចក្ដីល្អគ្រប់ប្រការ ព្រះអង្គមានទេពបរិវារជាអ្នកជំនួយដ៏ជាច្រើន ដូចយ៉ាងព្រះពរុណាដែលគេហៅថា ទីរ ជាអ្នកបណ្ដាលភ្លៀងឲ្យធ្លាក់ត្រូវតាមរដូវកាល នឹងព្រះអាទិត្យដែលហៅថា មិធរ៌ ជាម្ចាស់នៃពន្លឺ នឹងជាអ្នកចាំការពារមនុស្សឲ្យនិយាយតែពាក្យពិត ចាំធ្វើទោសអ្នកនិយាយកុហក ។ ចំណែកឯព្រះអរិម័នដែលជាព្រះខាងអាក្រក់ គេកាន់ថាជាមារចាំបំផ្លាញសេចក្ដីល្អ ជាម្ចាស់នៃបិសាចទាំងឡាយ មានបរិវារខាងអាក្រក់ចាំជ្រោមជ្រែងជាច្រើន បណ្ដាសេចក្ដីក្រខ្សត់ទីទ័លលំបាកផ្សេងៗ ដែលកើតមានឡើងនោះ សុទ្ធតែព្រះអរិម័នសាងឡើងទាំងអស់ ។ ព្រះល្អព្រះអាក្រក់ទាំង ២ នេះ បើហៅឲ្យត្រង់តាមភាសាខ្មែរគួរហៅថា ព្រះមហាចំរើន ព្រះមហាបំផ្លាញ ព្រះ ២ នេះមានន័យប្រហែលគ្នានឹងពាក្យប្រដៅក្នុងព្រះពុទ្ធសាសនាដែលហៅកុសល នឹងអកុសល ខុសគ្នាតែលទ្ធិនេះសំដែងជាបុគ្គលាធិដ្ឋាន ក្នុងព្រះពុទ្ធសាសនាសំដែងជាធម្មាធិដ្ឋានប៉ុណ្ណោះ ។ សារោអស្ដើរប្រដៅ

ថា មនុស្សយើងតាំងនៅរវាងកណ្ដាលនៃព្រះជាម្ចាស់ទាំង ២ បើអ្នកណាបែរទៅរាប់អានជ្រោមជ្រែងព្រះខាងណា ក៏នឹងបានទទួលផលនៃការដែលខ្លួនធ្វើនោះក្នុងលោកនេះនឹងលោកឯមុខ តែការតស៊ូគ្នារវាងព្រះជាម្ចាស់ទាំងពីរ ក្នុងទីបំផុតព្រះឧរមុស្ដ ជាអ្នកឈ្នះជាប្រាកដ ហេតុនោះមនុស្សទាំងឡាយត្រូវតែរាប់អាននឹងជួយព្រះឧរមុស្ដ ធ្វើការឲ្យប្រឆាំងប្រឆាំងទទឹងទាស់ផ្លូវដំណើរនៃព្រះអរិម័ន ដើម្បីកើតគុណប្រយោជន៍នឹងសេចក្ដីសុខដល់ខ្លួន ដូចយ៉ាងព្រះអរិម័នចូលចិត្តឲ្យនិយាយមុសាវាទ មនុស្សត្រូវនិយាយតែពាក្យពិត ព្រះអរិម័នចូលចិត្តធ្វើឲ្យស្រែចំការច្បារដំណាំខូចខាតផលប្រយោជន៍ មនុស្សត្រូវមានសេចក្ដីព្យាយាមថែទាំរក្សាដោយសេចក្ដីផ្ចិតផ្ចង់ជានិច្ចទៅ ។ មនុស្សដែលស្លាប់ ព្រោះព្រះអរិម័នធ្វើឲ្យស្លាប់ ដោយហេតុនេះគេទើបកាន់ថា សពរបស់អ្នកដែលស្លាប់នោះជាអពមង្គល មិនគួរនឹងប៉ះពាល់ត្រូវ សូម្បីតែផែនដីក៏មិនគួរឲ្យត្រូវ កាលមានមនុស្សស្លាប់គេយកក្រមួនបំពោកស្រោបសពហើយ ទើបយកទៅដុត ដើម្បីកុំឲ្យផែនដីត្រូវរបស់អពមង្គល ពុំនោះសោត

ក៏លើកសពដាក់លើគ្រែសែងទៅដាក់ចោលនៅទីវាលឲ្យត្មាតក្អែកស៊ី ។

គម្ពីរដែលចារិកពាក្យប្រដៅក្នុងសាសនានេះឈ្មោះហៅថា សេន្ទ៍អាវេស្តា សរសេរដោយភាសាសេន្ទ៍ដ៏ជាភាសាចាស់របស់ពួកនេះ មានបទបញ្ញត្តិដែលរាប់ថាជាពាក្យប្រដៅ ៤ ប្រការគឺ

១ ត្រូវនមស្សការព្រះឱរមុស្ត នឹងសូត្របំពេអង្វរព្រះអង្គ

២ ត្រូវមានគំនិត មានវាចា នឹងកិច្ចការដ៏បរិសុទ្ធិ

៣ ត្រូវមានសេចក្ដីស្លូតត្រង់ នឹងនិយាយតែពាក្យពិត

៤ ត្រូវជាអ្នកឧស្សាហ៍ធ្វើការងារ ។

មនុស្សយើងគ្រប់រូបកាលស្លាប់ហើយ ត្រោងទៅស្ដាប់ការពិភាក្សាបំពោះព្រះភក្ត្រព្រះឱរមុស្ត នឹងត្រូវទៅឆ្លងស្ពាន ១ កន្លែងដែលហៅថា "ជិនវ័ត" បើអ្នកណាកាលរស់នៅក្នុងមនុស្សលោកនេះបានធ្វើសេចក្ដីល្អទុកច្រើន វិញ្ញាណអ្នកនោះក៏ដើរឆ្លងស្ពានទៅរហូតដោយស្រួល មិនមានរន្ធត់ភិតភ័យហើយក៏ចូលទៅនៅក្នុងទីបរមសុខ ។ បំណែកឯអ្នកដែលកាលរស់នៅបានធ្វើសេចក្ដីអាក្រក់ទុកច្រើន វេលាស្លាប់ហើយ

វិញ្ញាណទៅឆ្លងស្ពាន ៗ ក៏រួញតូចបង្អៀតដើរមិនរួច ក៏ធ្លាក់ចុះ
ទៅកាន់ទុគ្គតិភូមិ សោយទុក្ខវេទនាតាមយថាកម្ម ។

សាសនានេះមិនមានធ្វើរូបគោរពជំនួសអង្គព្រះឱរមុស្ដ តែ
គេប្រើភ្លើងជំនួស ព្រោះគេកាន់ថាភ្លើងមកអំពីស្ថានសួគ៌ ជា
គ្រឿងសំគាល់នៃពន្លឺនិងសេចក្ដីបរិសុទ្ធ ហេតុនោះនៅទីបូជា
គឺក្នុងវិហារក្ដី ក្នុងផ្ទះក្ដី គេទើបអុជបង្កៀងភ្លើងទុកជានិច្ច
វេលានឹងធ្វើពិធីក្នុងសាសនា ពួកសាសនាចារ្យដុតភ្លើងឡើង
ជំនួសអង្គព្រះជាម្ចាស់ ហើយយកអាហារផ្សេង ៗ មករៀបដាក់
រៀងរាយហ៊ាយជាពលីកម្មខាងគំនរភ្លើងនោះ ។ មួយយ៉ាងទៀត
គេប្រើក្នុងក្បួនទ័ព ដូចយ៉ាងស្ដេចនឹងលើកទ័ពទៅឯណា ៗ
ក៏ទឹមរថសេះហើយដាក់ភ្លើងស័ក្ដិសិទ្ធិទៅក្នុងរថនោះផង ដើម្បី
ជាគ្រឿងក្រើនចិត្តទាហានឲ្យក្លា (របៀបនេះក៏ដូចគ្នានឹងគតិ
ដែលរាប់អានក្នុងសាសនាព្រាហ្មណ៍ កាលខ្មែរយើងនៅកំពុង
រាប់អានសាសនាព្រាហ្មណ៍ ក៏មានរាប់អានភ្លើងស័ក្ដិសិទ្ធិដូច្នេះ
វេលាព្រះមហាក្សត្រិយ៍ស្ដេចលើកទ័ពទៅធ្វើព្រះរាជសង្គ្រាមឯ
ណា មានមនុស្សសែងផ្ទះភ្លើងទៅជាមួយផងជាដរាប សូម

ឲ្យមើលរូបភាពក្បួនទ័ពខ្មែរក្នុងសម័យបុរាណ នៅប្រាសាទ
នគរវត្តជាន់ខាងត្បូង និងប្រាសាទបាយ័នជាន់ខាងកើតនឹង
ឃើញរូបមនុស្សសែងផ្ទះភ្លើងនៅជិតព្រះរូបព្រះមហាក្សត្រិយ៍
ដែលជាស្ដេចសឹក) ដោយហេតុនេះពួកឱរុបទើបហៅលទ្ធិសា-
សនាសារាធុស្ដ្រ ឬសោរោអស្ដើរនេះថា សាសនាបូជាភ្លើង ។
លទ្ធិនេះពួកប៉ែរ្សមិនបានកាន់ដរាបមក ព្រោះមកដល់សម័យ
កណ្ដាលមានលទ្ធិឥស្លាមផ្សាយចូលទៅជ្រែក ម៉ហាម៉ទ
ក៏សង្កត់សង្កិនឲ្យកាន់លទ្ធិឥស្លាម ទទឹងមិនបានក៏តោង
ទទួលកាន់ ដោយប្រទេសប៉ើស៊ីធ្លាក់ទៅជាស្រុកចំណុះប្រទេស
អារ៉ប មានពួកខ្លះមិនព្រមកាន់លទ្ធិឥស្លាម ក៏នាំគ្នារត់ទៅ
នៅក្នុងប្រទេសឥណ្ឌាភាគខាងលិច គឺតាំងពីទន្លេសិន្ធុ រហូត
ទៅដល់ជិតស្រុកប៊ុមបៃ នៅគង់វង្សកាន់លទ្ធិនេះតាមដើម ។

(មានតទៅទៀត)

លោកន័យ

ពាក្យកាព្យ

របស់ឧកញ៉ាវង្សាសារពេចន៍ (នង)

បឋគាថាគតិ

អហំនមា-មិសិរសា សុសម្ពុទ្ធំ អនុត្តរំ សេដ្ឋោវរំ តិលោកានំ លោកុត្តមោ ។ ជិតមារា អសមោអ-នន្តញ្ញា-ណោ បភគវា បនាយកោ ទសពលោ បអតុលំ ។ តារណោ-លេណោ មហាបញ្ញោ យថាទីបំ តមោនុទោ លោភោទោះ-តាំ មោហសត្តំ ភវាភវេ ។ បញ្ញារវោ បារភូតោ អត្តដ្ឋានេ បអរិយេ សព្វធម្មេ បនិប្បន្នេ បកាសេន្តោ ។ សុសរណំ ភគ-វន្តំ មហាវីរោ ឥមាមិហំ អយំធម្មោ និយ្យានិកោ ទេវជនំ ។ ឧជុមគ្គោ មោក្ខប្បត្តោ បវេសាយំ សន្តិករោ សង្ខារិរំ បុញ្ញក្ខេត្តំ សព្វគុណោ ។ វីរិច្ចកា- មេហិវិភា អសេសកេ ឥមា-មិហំ ទុក្ខភយេ បបញ្ចរេ បតេជសា ។ សព្វសេដ្ឋំ ពុទ្ធ-សាសនំ អតិក្កន្តា ទ្វេសហស្សំ សតំតិយា សត្តត្តិសា សំ-វច្ឆរេ ។ បតុម្មាស ទសទិន បច្ចុប្បន្នេ សំវច្ឆរេ ព្យគ្ឃមាសេ ភទ្របទេ វស្សន្តានំ ។ កាឡបក្ខេ បណ្ណរសេ បតិបិយំ ពុធ-វារេ ឥមេកាលំ អនាគតំ ទ្វេសហស្សា ។ សំវច្ឆរេ ធសត្ត ទ្វេ សដ្ឋីសត្ថា មាសេបណ្ណ-រសទិនា អវិសេសា ភវិស្សន្តិ ។

ខ្ញុំអរឱនអង្គ លុតលើកកផ្ទង់ អកដល់សិរសី កង្កញ កាយំ បញ្ចង្គប្រដី- ស្ថានបិតអភី- វាទអរបង្គំ ។ ក្រាបក្រោម កងចក្រ ព្រះបាទលាយលក្ខណ៍ សូមសរសើរសំ- ណាងនៃ ស្តេចស្តែង លើសលែងឥន្ទព្រហ្ម ទេពទាំងយក្ខយម- រាជរួញ ខ្លាចខ្លប ។ កោតព្រះសម្ភារ ផ្កាលផ្កាញ់អារា បាក់បែកបាន បម បរិបូណ៌បានបុណ្យ ឱនអង្គអត់អប ប្រួញប្រាណប្រែ ប្រែប បូលបុះបាញ់ចាល ។ ព្រោងព្រះរស្មី ទូទៅទាល់ទី មួយម៉ឺនចក្រវាឡ ដោយតេជតេជះ ទ្រង់បាដិហារ្យ រុងរឿង រន្ទាល ភ្លឺផ្លេកសាយសព្វ ។ ព្រះអង្គឧត្តមោ ឯកឥត ទុតិយោ ជាតិជាគ្រូគ្រប់ សព្វសត្វសាកល មណ្ឌលភូមិភព មូលមកឱនអព- ភិវន្ទបង្គំ ។ ព្រះប្រៀបប្រៀនប្រាណ សព្វ សត្វសឹងបាន លះលាកលែងលំ- នៅនៃតណ្ហា ជលសាគរគ- ម្ភីរភ័យសឹងសំ- ណោក់នឹងព្រះអង្គ ។ បង្គំព្រះធម៌ ប្រដូប សុព័ណ៌ អាត្រាត្រៃបត្រង់ កណ្ដាលរលក វេរករិះរង់ រួស រើសស្រោបស្រង់ សព្វសត្វសែនសល់ ។ លន្លោចលន្លង់ លន្លៀកលិចក្នុង ភូមិភពជាតិជល- សាសង្សារសោះ ផ្លេក

ផ្ដោះដាក់ជល់ ទីទួលថ្នាក់ថ្នល់ នគរនិព្វាន ។ បង្គំព្រះសង្ឃ ប្រសើរសឹងទ្រង់ សីលសុទ្ធជាយាន នាំសត្វពីក្នុង វដ្ដសង្សារ បាន សោយសុខសួគ៌ស្ថាន ផុតពីទុក្ខា ។ ជាតិនេះអញខ្ញុំ អភ័ពពេកពុំ ទាន់ព្រះសាស្តា ជាតិក្រោយសូមបាន ដូច ភ្នានបិន្ដា បរិបូណ៌ប្រុសប្រា- កដកុំឃ្លៀងឃ្លាត ។ ដោយ តេជះខ្ញុំ ថ្វាត់ថ្វាយបង្គំ ផ្ដោះព្រះនរនាថ សារពេជជិនស្រី ទាំងធម៌ជាអាទ៌ គុណគាប់សល់ខ្នាត ឥតឯគណនា ។ សូម ទេពទិសទស ទួទាំងសោឡស បំរើនតរា សូមសំរិទ្ធ ដូច ក្ដីប្រាថ្នា បំណងប្រុសប្រា- កដកបនាប់ធុត ។ សក្រាជ បួលម ឯកស័ព្ទឯកធ ស័កខាលបំហុត ប្រាំដណ្ដប់រោប រនោបពារពុធ ខែភទ្របទ សានសំរិទ្ធ ។ កាលរាជព្រះបាទ ព្រះបរមនាថ ព្រះនាមបក្រី នារាយណ៍រាជា រាមាធិបតី សម្ដេចព្រះស្រី- សុរិយោព៌ណ៌ពង្ស ។ ព្រះបរមសុរិ- ន្ទ្រា ទ្រើសភូមិន ទរាភិម- ង្គល់ព្រះមហាប- ក្រព័ត្ដិវិលរ- ង្សរាស័ក្ដិឧត្ដុង្គ ឧត្ដមឧត្ដលា ។ ព្រះបរមបពិត្រ អធិរាជ រឿងឫទ្ធិ រុងរឿងបេស្ដា ស្ដែងស្ដេចមកពី បូរីមា ក្រុង

ទេពមហា នគររម្យរដ្ឋ ។ វិលវិងបូរី បូរាណឯងឥ- ស្សរ
ឥន្ទ្របថ ក្រុងកម្ពុជា មហារវិឌ្ឍន៍ វិរេកចមក្សត្រ ឯកអគ្គ
រាជា ។ ស្តែងស្តេចទ្រើសទ្រង់ រាជ្យស្នងព្រះអង្គ ព្រះវរ
បិតា ពួករាស្ត្រសព្វហាន មិនមានទុក្ខា សឹងបានសុខសា-
ពាយបត់បារមី ។ ទ្រង់ព្រះប្រាជ្ញា ប្រាជ្ញប្រិសអធ្យា- ស្រ័យ
ស្រេចអស់ក្តី ស្តេចទ្រង់សីលំ សប្ចុខន្តី អាចអត់មេត្រី
ទោសទុក្ខសព្វសត្វ ។ ស្តេចទ្រង់ទសពិធ- រាជធម៌អង្គឥត
ភ្លឹកភ្លាំងភ្លេចភ្លាត់ ធម៌ព្រះកម្មដ្ឋាន រៀនបានប្រើនក្តាត់ គិត
គុណពុទ្ធវត្ថុ ត្រេកទ្រង់សទ្ធា ។ សព្វព្រះហឫទ័យ នឹងធម៌
លោកន័យ ពេកពន់មុះហិមា(១) ដ្បិតព្រះធម៌នោះ បំពោះ
ផាក់ផា ក្រមក្រឹត្យក្សត្រា សុទ្ធសឹងជាច្បាប់ ។ ព្រាហ្មណ៍
ព្រឹទ្ធមន្ត្រី ប្រជារាស្ត្រក្តី គួរត្រេកត្រងព្រាប់ ស្តេចបើកព្រះស្សូរ
បន្ទូលប្រញាប់ ទ្រង់ព្រះបង្គាប់ ត្រាស់លើសិរសា ។ អញ្ញុំ
នាមនង ជាតិជាខ្ញុំល្អង- ធូលីបាទា ព្រះរាជទាន ប្រោស

---

១ សំ. មហិម័ន; ម. មហិម > មហិមា "ដែលធំ, សំបើម, ស្តុំខ្ពស់..." ។ ក្នុងទីនេះ មានសេចក្តីថា "ណាស់" ។

ប្រាណករុណា ឲ្យជាទុកញ៉ វង្សក្សត្រិយ៍ ។ គន់គិតបែងចង
កាព្យកិច្ចទាក់ទង ស្រិតស្រាលស្រដី ដំណាលដំណើរ សរ-
សើរគម្ពីរ លោកន័យនី- ទានទៀងទុកនៅ ។ ជាបទស្លូតថ្វាយ
ក្សត្រថ្លៃប្រាជ្ញប្រាយ តាមដោយកំលៅ កំលាំងពុំយល់ ធ្ងាយ
ធ្ងល់ណាស់នៅ ដ្បិតធម៌នេះជ្រៅ បង្អៀតក្រកែ ។ ក្រែងខ្ញុំ
លើកលោះ ដំណើរខាតខុស ពាក្យពុំប្រពៃ បើលោកឯណា
ប្រាជ្ញាឈ្លាសវៃ ដឹងអធ្យាស្រ័យ កិច្ចការកាព្យ ។ សូម
លោកដម្រង់ ស្រេចស្រាលស្រិតស្រង់ កុំលោកនិន្ទា ជៀង
ជួយជាផល ដំកល់ទុកជា ដំណាសាស្នា សារពេជ្រជិនស្រី ។
កាលគិតកាព្យ នេះនឹងទុកញ៉ា ធម្មាធិបតី មកជួយបែងចង
ទំនងនាំនី- ទានទុកទៅទី អនាគតគាប់ ។ ធម៌នេះជាខ្លឹម
ផតងប្រៀបត្រឹម ប្តូលបេះបាំបាប់ រួសរករៀនរិះ ត្រេកត្រិះ
ត្រងត្រាប់ ទុកទៅជាច្បាប់ បំបាត់បាបបាន ។ បើអ្នកឯណា
បិត្តបង់ប្រាថ្នា សម្បត្តិនិព្វាន សម្បត្តិលោកិយ នេះក្តីសឹង
បាន ឲ្យស្តាប់និទាន ធម៌នេះថ្លៃថ្លា ។ ឲ្យរៀនត្រងត្រាប់

ធ្វើដោយសណ្តាប់ ធម៌ព្រះទេស្នា បង្កើតសប្បុរស ស័ក្តិ-
យសប្រាជ្ញា ប្រយោជន៍នៃមហា ជនផងទាំងឡាយ ។ មាន
ពាក្យបំណោទ បុច្ឆាចារ្យចោទ ជាធម្មបរិយាយ នេះអ្នកឯ
ណា ទេស្នាប្រាប់ប្រាយ បងជានិយាយ អត្ថលោកន័យ ។
វិសជ្ជនា អាចារ្យឆ្លើយថា ធម៌នេះប្រពៃ គឺអង្គសម្តេច សារ-
ពេជ្ញញាណរាញ្ញៃយ៍ ទេស្នានៅឲ្យ ព្រះជេតពន ។ មានមួយ
ទិវា សម្តេចសាស្តា បពិត្រមានបុណ្យ ចេញចាកសេយ្យា
សុរិយាទន់ៗ ព្រះមហាអានន្ទ នែបនិត្យពុំឃ្លាត ។ សម្តេច
មុនី- សារពេជ្ញជិនស្រី ស្តេចយាងព្រះបាទ គង់លើធម្មាសន៍
ឱភាសសល់ខ្នាត សឹងរ័ត្នព្រោងព្រាត រុងរឿងរស្មី ។
ទេស្នានិទាន លោកវាទទូន្មាន សង្គាលសេដ្ឋី នូវអស់បរិវារ
មិច្ឆាទិដ្ឋី សឹងរូបអំពី បណ្តាញឫស្យា ។ បានលុះមគ្គផល
ស្រោតាខ្លះដល់ សកិទាគា ខ្លះបានដល់ថ្នាក់ អរហត្តផលា
ផុតចាកទុក្ខា រួបដល់និព្វាន ។ ទើបព្រះអានន្ទ សរសើរ
ព្រះគុណ ទូលថាស្ងួចទាន បពិត្រសម្តេច សារពេជ្ញទ្រង់
ញាណ ព្រោសសេដ្ឋីបាន អស្ចារ្យមុះហិមា ។ កាលនោះ

ព្រះអង្គ សារពេជ្រពុទ្ធពង្ស ស្តេចស្តាប់ព្រះមហា- អានន្ទ
សរសើរ ដំណើរអក្ខរា ទើបទ្រង់បិន្ទា ដោយព្រះទិព្វញាណ ។
ជ្រាបជាព្រះបាទ បសេនទិរាជ កោសលរាជមាន ព្រះទ័យចង់
ស្តាប់ ធម៌គាប់ប្រធាន ហើយព្រះអង្គមាន ព្រះទ័យករុណា ។
ចង់ឲ្យឪរាទ- ទានធម៌ព្រះបាទ បសេនក្សត្រា ទើបបើក
ព្រះសូរ បន្ទូលត្រាស់ថា អានន្ទអើយបា សរសើរបារមី ។
ដ្បិតអញទូន្មាន ទេស្នាប្រោសប្រាណ សិង្គាលសេដ្ឋី ឲ្យរួច
ចេញចាក លះលោកអំពី មិច្ឆាទិដ្ឋិ ឬស្សាកំណាញ់ ។
ពុំរាប់ហៅជា អស្ចារ្យឡើយណា ជាព្រះពុទ្ធមិញ តែកាល
ពីព្រេង នោះឯងអង្គអញ បង្កើតជាធន- ញ្ជ័យកុមារា ។
ប្រាំពីរឆ្នាំគត់ ទេស្នាបំបាត់ ទូន្មានយក្សា មួយមានចិត្តរឹង
របឹងមុះហិមា ឲ្យនិរភៀសជា អស្ចារ្យគួរស្ញែង ។ ទើបព្រះ
អានន្ទ ក្រាបទូលនិមន្ត ទេស្នាថ្លាថ្លែង ទូន្មានអស់អាថ៌
ប្រស្នាចាយចែង សណ្តាប់សំដែង ដំណើរផ្ចិតម្តេច ។ កាល
នោះព្រះបាទ ព្រះមុនីនាថ ពុទ្ធពង្សសារពេជ្រ ព្រះភក្ត្រ
ប្រឹម- ញញឹមស្រួចស្រេច ទើបព្រះអង្គស្តេច បើកព្រះ

ឱស្ឋា ។ មានព្រះបន្ទូល ពីរោះដូចស្នូរ សំឡេងព្រហ្មា ផ្គោះនឹងអង្គុលី- មាលកាលនោះណា ភិក្ខុអើយរីមហា- ថេរ នោះពីព្រេង ។ កើតជាយក្សា ហប់អស់ម្រឹគា មនុស្ស សត្វឥតក្រែង ស៊ីឈាមយប់ព្រឹក ឥតភ្លឹកគួរស្ញែង ទើបព្រះ គម្ដែង សូត្រជាគាថា ។ ភូតបុព្វំ រាជានាមំ ធនញ្ជយា កោរព្យា- ជអតុលា ទេវីមហា- មហេសិយំ ។ ហៃភិក្ខុ ទាំងឡាយ កាលព្រេងមុននាយ អតិក្កន្តំ ក្នុងហាសិប ជាតិ និបាតកំបាំង ភពភ័ន្តវ៍ណ្ណខាំង អង្វែងយូរក្រៃ ។ កាលនោះមានមហា ក្សត្រមួយនាមា ព្រះបាទធនញ្ជ័យ កោរ- ព្យរាជ អំណាចថ្កើងក្រៃ សោយរាជ្យនៅឯ ឥន្ទបថ្បូរី ។ មានអគ្គជាយា នៈមនាងឧត្តលា ជាច្បងអស់ស្រី មួយហ្មឺន ហុកពាន់ កំណាន់ប្រក្រតី គង់គាល់ចក្រី អនេកត្រៀបត្រា ។ ស្ដេចគង់ប្រាសាទ ប្រសើរស្អាងស្អាត ទាំង៥របនា សឹង មាសប្រាសប្រាល រត្នាលថ្លៃថ្លា ជាសជាំត្បូងជា រុង- រឿងរស្មី ។ ស្ដែងស្ដេចសោយរាជ្យ ទ្រើសទ្រង់អំណាច

ព្រះបារមី គ្រប់គ្រងពលពង្ស ចតុរង្គមន្ត្រី បណ្ឌិតកវី ព្រាហ្មព្រឹទ្ធហោរា ។ មានរោងដំរី រោងរថពាជី ក្រាស់ក្រៃត្រៀបត្រា បន្ទាយ ៣ ជាន់ ខេត្តខណ្ឌសីមា ប្ដូរប្ដឹងឧទ្យា- រិករាជ្យពិភព ។ មានរាជបុរោហិត ឈ្មោះធជព្រាហ្មព្រឹទ្ធ ជាគ្រូបេះបប់ ត្រៃវេទសិល្បសាស្ត្រ ផ្ទះឆ្លាសសាយសព្វ ធម៌អាថ៌គ្រាន់គ្រប់ ទូន្មានក្សត្រា ។ មានសេនានោះ សន្មតនាមឈ្មោះ ឧជុកសេនា អស់ទាំងរេហ៍ពល សកលយោធា ប្រមាណបានជា អក្ខោភិនី ។ មានស្រុកជាធំ ទាំង ៤ នៅជុំ ទ្វាររាជបុរី ស្រុក ១ នៅនា បូព៌ាទិសទី មានមហាសេដ្ឋី ជាធំរក្សា ។ នាមហៅធនញ្ជ័យ ជាធំប្រពៃ មែនមានភរិយា ឈ្មោះសុខុមាលីទេវីថ្លៃថ្លា ស្រុកនោះឈ្មោះប្រា- ចីនគ្រាមរដ្ឋា ។ វិសាលសេដ្ឋីនិត្យនៅប្រក្រតី រក្សាព្យាបាល ស្រុកទិសទក្សិណ គាមរដ្ឋា ១ នោះនាមា សុបិសេដ្ឋី ។ គ្រប់គ្រងរក្សា បស្ចិមគាមា ជាធំប្រក្រតី ស្រុក ១ នាមា ឧត្តរាទិសទី សុទសសេដ្ឋី ជាធំរក្សា ។ រីឯស្រុកនោះ សន្មតនាមឈ្មោះ ឧត្តរគាមា សេដ្ឋីទាំង ៤ ស័ក្តិស្មួនស្មើគ្នា សឹងមានទ្រព្យា ៨០ ឃ្លាំងផង ។

មានទាំងសេដ្ឋី បម្រើប្រក្រតី សព្វថ្ងៃឥតហ្មង សឹងតែ ៥ រយ នីមួយខ្លួនហោង ជាធំគ្រប់គ្រង ទ្វាររាជសីមា ។ នេះនៅស្រដី ឯពង្សពោធិ- សត្តស្លូតសោភា សោយសម្បត្តិឲ្យ ស្លូតត្រៃត្រឹង្សា ឋិតលើប្រាង្គណ៍ប្រា- សាទមាសមណី ។ ព្រះអង្គបុត្រចាកស្លូតស្រែបស្រុត ចាប់ប្រដិសន្ធិ ឋិតក្នុងឧទរ បវរទេវីនាងសុខុមាលី ជាព្រះមាតា ។ រីឯទេវបុត្រ ៥ រយបុត្រព្រមជាបរិវារ មកយកបដិ- សន្ធិនៅនា បរិវារនៃមហា- សេដ្ឋីធនញ្ជ័យ ។ កាលនោះព្រះបាទ- ធនញ្ជ័យនរនាថ នាកាលសម័យ នោះស្ដេចចូលផ្ទំ បរមសុខសៃ- យាសយល់សប្ដិថ្លៃអស្ចារ្យមុះហិមា ។ យល់ដូចព្រះអង្គ ស្ដេចស្ដែងឡើងគង់លើរាជអាសនា អស់មុខមន្ត្រី សេនីសេនា គង់គាល់ក្សត្រាដូចកាលប្រក្រតី ។ ស្ដេចទតទៅឋាន ឯមុខព្រះលាន យល់ផ្នុកអគ្គី ក្បែរនោះមានផ្កា ក្រមុទ(១)ផុសពី កណ្ដាលអគ្គី ប៉ុនកង់រាជរថ ។ លំទោនទងផ្កា មកជិតក្សត្រា ស្ដេចឡើងគង់ផ្គត់ ភ្នែនព្រះបាទា លើផ្កាក្រមុទ ភ្លើងនោះរលត់ រលាយបាត់

១ សំ. ម. កុមុទ "ព្រលិត, លំពង់" ។

បង់ ។ រីផ្កាក្រមុទ នោះគឺប្រាកដ ទូទាំងកំលុង ជម្ពូទ្វីបា ថ្ងៃហ្វាយល់យង់ ស្ដេចតើនឡើងគង់ ស្រេបស្រាងសុរិយា ។ ស្ដេចសោយព្រះស្ងួន់ ជម្រះអស់ម-ន្ទិលទើបក្សត្រា យាស យាងព្រះបាទ សីហានាទយាត្រា បេញគង់ក្រឡា គំនាល់ពិ-បិត្រ ។ ក្សិណក្សត្រឥស្សូរ មានព្រះបន្ទូល នឹងបុរោហិត ដោយនាស្ដេចយល់ មង្គលនិម្មិត ចូរទាយដោយពិត សប្ដ កាចឬផា ។ ទើបព្រាហ្មណ៍បុរោហិត ដឹងអាថ៌និម្មិត ស្រេប ក្រាបទូលថា បពិត្រព្រះបាទ នរនាថថ្លៃថ្លា សប្ដនេះឯងជា មង្គលក្សត្រក្សាន្ត ។ នឹងមានអ្នកប្រាជ្ញ កើតសំរាប់រាជ្យ អម្ចាស់ប្តែងថ្កាន អាចផ្ចាញ់សត្រូវ ដោយនូវទិព្វញាណ ឲ្យ ព្រះអង្គបាន ប្តែងកេរ្ដិ៍យសា ។ អស់ទាំងជម្ពូ- ទ្វីបនេះឥតគូ ស្មើនឹងប្រាជ្ញា អ្នកប្រាជ្ញឧត្ដម យើងខ្ញុំករុណា នឹងអាប់ឱនប្រា-កដពុំឃ្លៀងឃ្លាត ។ ស្ដេចស្ដាប់ទំនួល ទំនាយព្រាហ្មណ៍ ទូល ក្សត្រថ្លៃភូវនាថ ទ្រង់ព្រះអំណរ សាទរសល់ខ្នាត ទៀង ទើបព្រះបាទ បើកបន្ទូលថា ។ ព្រាហ្មណ៍អើយឥឡូវ អ្នក ប្រាជ្ញនោះនៅ តំបន់ភេនណា ចូរព្រាហ្មណ៍ប្រាយប្រាប់

មកឆាប់រួសរ៉ា ទើបព្រាហ្មណ៍ទូលថា បពិត្រភូមី ។ ឥឡូវ អ្នកប្រាជ្ញ ទើបមកឯងអាប ចាប់បដិសន្ធិ ស្ថិតក្នុងឧទរ ព្រះ វរជននី ចាប់ដើមអំពី នេះទសមាសា បរិបូណ៌គ្រាន់គ្រប់ ទៀងទើបសម្ភព ចាកគភ៌មាតា ស្តេចស្តាប់ទំនូល ព្រាហ្មណ៍ ទូលក្សត្រា ត្រេកសោមនស្សា ឥតឯថ្លែងបាន ។ កាលនោះ ទេវី នាងសុខុមាលី វរលក្ខណ៍កល្យាណ ទ្រង់គភ៌ពោធិ-សត្វវិសេសសាន្ត លុះបរិបូណ៌បាន គ្រប់ទសមាសា ។ នាងប្រសូតបុត្រ ប្រាណប្រុសបរិសុទ្ធ រុងរឿងកាយា ដូច មាសនព្វគុណ ទិព្វតន់ថ្លៃថ្លា ហេតុព្រះអង្គជា ឥស្សរភពត្រៃ ។ ឯអស់ភរិយា សេដ្ឋីទាំងហា- រយសឹងឈឺផ្ទៃ ប្រសូតបុត្រា ពំងាប្លើមថ្លៃ កើតព្រមមួយថ្ងៃ នឹងពង្សពុទ្ធង្គ ។ កាលព្រះ សម្ភព សម្ភារស្បែងស្បប់ អស្ចារ្យពេកក្តាត់ ឯនន្ទគីរី ស្គរជ័យ មហាក្សត្រ បន្លឺសព្ទថ្វាត់ លាន់លាមុះហិមា ។ ទើបមហា-សេដ្ឋី ជាព្រះជននី ជនកថ្លៃថ្លា បំរើនាមករ ព្រះរាជបុត្រា សន្មតហៅថា ធ្នញ្ជ័យកុមារ ។ កាលនោះក្សត្រថ្លៃ ព្រះ បាទធ្នញ្ជ័យ អធិរាជភូវនាថ ស្តេចឮសព្ទស្គរ ខ្ទារខ្ទរតាកាល-

ណោះព្រះភូបាល ព្រួយព្រះហឫទ័យ ។ ដណ្ដឹងបុរោហិត ជាហៃព្រាហ្មព្រឹទ្ធ ឥន្ទ្រវិស្ណុរជ័យ លាន់ឮសព្ទឯង គគ្រេង ប្នេះនៃ យល់អស្ចារ្យក្រៃ មានហេតុដូចម្ដេច ។ ទើបព្រាហ្មណ៍ ប្រណម្យ ថ្វាត់ថ្វាយបង្គំ ទូលថាសម្ដេច ភូមិន្ទរាជ[១] អ្នកប្រាជ្ញកើតស្រេច ថ្ងៃនេះឯងស្ដេច កុំព្រួយព្រះទ័យ ។ ស្ដេចស្ដាប់ហើយអរ ទ្រង់ព្រះអំណរ សោមនស្សក្រៃ ក្សិណានោះ មហាក្សត្រ បន្ទូលថាហៃ អមាត្យប្រូលវៃ ឆាប់ៗម្នីម្នា ។ ចេញទៅទាំងបួន ទិសទីគ្រប់ខ្ទួន ឃើញក្មេងឯណា កើតថ្ងៃនេះឯង ព្រះស្ដែងយាត្រា វិលវឹងម្នីម្នា មកទូលឲ្យឆាប់ ។ កាលនោះអមាត្យ ទាំងបួនក្រាបបាទ លុតលាប្រញាប់ ដូចព្រះអាជ្ញា ក្សត្រាបង្គាប់ ចេញទៅឆាប់ៗ ពិតពុំផ្សងផ្សូរ ។ អមាត្យ ១ នោះ ចេញទៅចំពោះ ដោយទ្វារទិសបូព៌ ទៅដល់ធ្នញួយ សេដ្ឋីបរបួល ថ្លែងព្រះបន្ទូល សួររកក្មេងផង ។ កើតថ្ងៃនេះណា សេដ្ឋីប្រាប់ថា កូនខ្ញុំឯងហោង កើតថ្ងៃនេះឯង មានក្មេងកើតផង ៥រយជាម្ដង ព្រមនឹងកូនខ្ញុំ ។ អមាត្យស្ដែង

---

១ ម. ភូមិ+ឥន្ទ+រាជ> ភូមិន្ទរាជ "ស្ដេចជាធំលើផែនដី" ។

ស្លាប់ ហើយវិលត្រឡប់ មកថ្វាយបង្គំ ក្រាបទូលព្រះបាទ
នរនាថបរម- បពិត្រដោយដំ- ណើរគ្រប់ប្រការ ។ ដ្បិតកូន
ធនញ្ជ័យ សេដ្ឋីកើតថ្ងៃ នេះជាអស្ចារ្យ កើតក្មេង៥រយ ថ្ងៃ១
រួចរាល់ ស្ដេចជ្រាបអស់អាថ៌ អរតិតថ្លែងថ្លឹង ។ ថាឱអញ
បាទ អ្នកប្រាជ្ញថ្កើងថ្កាន ជាតិជាទីពឹង ស្ដេចប្រទានមាស
សហស្ស[១]ដំឡឹង នូវគ្រឿងគ្រប់នឹង មេនំបួននាក់ ។ ទៅ
ជូនសេដ្ឋី បិតាពោធិ- សត្វថ្លៃជៀងជាក់ ឲ្យជួមរក្សា បុត្រា
វរល័ក្ខណ៍ កុំឲ្យអន់អាក់ ចិត្តព្រួយបារម្ភ ។ ឯក្មេង៥រយ
នោះសឹងស្ដេចឲ្យ ទានជាមាសដុំ ៥រយដំឡឹង ហើយនឹងមេនំ
មួយនាក់ឲ្យបំ- បៅចាប់រក្សា ។ ហើយព្រះជៀស្ឋ[២]ជ័យ គិត
ក្នុងព្រះទ័យ ថាអស់កុមារ ដល់ធំបំណោរ ពរិស្សា ឲ្យរកប្រស្នា
ចង់ដឹងប្រាជ្ញប្រាយ ។ លុះអំលុងទៅ ពោធិបមបៅ បំរើន
ព្រះកាយ ធំឡើងទៅលេង នឹងក្មេងទាំងឡាយ សឹងមូលមក
ថ្វាយ ខ្លួនជាបរិវារ ។ ឯអង្គព្រះបាទ ធនញ្ជ័យនរនាថ

---

១ ម. ១ ពាន់ ។ ២ សំ. ជៀស្ឋ "ជាច្បង, ជាធំជាង" ។

យង់យល់កុមារ បំរើនបានប្រាំ- ពីរឆ្នាំនាកាល នោះព្រះភូ-
បាល បង់លងប្រាជ្ញា ។ ទើបស្តេចរិះគិត នឹងបុរោហិត
បន្ទូលត្រាស់ថា យើងបង់ល្បង លលងប្រាជ្ញា ធ្នញ័យកុមារ
នឹងហេតុកល់អ្វី ។ ទើបព្រាហ្មណ៍ទូលថា បពិត្រក្សត្រា ធ-
ស្សរសិរសី ខ្ញុំបង់រិះគិត គំនិតសេចក្តី ជាឃ្លាំងអំពី វិតក្កបញ្ហា ។
ព្រះបាទឥស្សរ ស្តេចស្តាប់ព្រាហ្មណ៍ទូល ព្រមព្រះបិត្នា ទើប
ទ្រង់ដំរាស់ ស្តេចត្រាស់ហៅអា- មាត្យ១ដែលជា ជំនិតក្សត្រ
ថ្លៃ ។ ថាម្នាលអាមាត្យ ព្រះស្តែងសង្ខាត បេញទៅវៃៗ នាំ
អាថ៌ប្រស្នា ប្រសើរប្រពៃ ទៅឋានធ្នញ័យ សេដ្ឋីម្ចាស់ ។
យកក្មេង៥រយ មកដល់ហើយឲ្យ អង្គុយជុំគ្នា ហើយព្រះ
ស្តែងចោទ បំណោទប្រស្នា វិតក្កបញ្ហា ឲ្យក្មេងនោះស្រាយ ។
បើក្មេងទាំងនោះ ពុំអាចឆ្លើយដោះ បញ្ហាធិប្បាយ នោះសឹម
ព្រះស្តែង ថ្លាថ្លែងនិយាយ អស់អាថ៌សម្ងាយ ប្រាប់ក្នុនសេដ្ឋី ។
បើឆ្លើយដោះបាន ហៅនាំពណាំជមាន មកទូលឆាប់ខ្មី អាមាត្យ
ក្រាបលា ក្សត្រាធិបតី ទៅដល់សេដ្ឋី ដូចព្រះអាជ្ញា ។
ប្រាប់សព្វសេចក្តី ទើបមហាសេដ្ឋី ឲ្យហៅកុមារា ទាំង៥-

រយចូល មកមូលគ្រប់គ្នា ទើបដណ្ដឹងថា អ្វីហៅវិតក្ក ។ អស់ក្មេងទាំងនោះ ពុំអាចឆ្លើយដោះ ភិតភ័យស្លេតស្លក់ ព្រួយបិត្តជាទុក្ខ ដាក់មុខអាក្រក់ ពត្លីសពត្លក់ គ្រប់តួទីទៃ ។ ទើបរាជអមច្ចា(១) ដណ្ដឹងប្រស្នា ឆ្ពោះទៅធ្នញ្ជ័យ ពោធិសត្វស្ដាប់ សារស័ព្ទសុម៉ៃ ហេតុព្រះប្រាជ្ញវៃ លើសលើលោកា ។ ទៀងទើបឆ្លាស់ឆ្លើយ ថាហៃទៅអើយ វិតក្កបញ្ហា ១ គឺរណ្ដៅរពៅផលា ១ ពុកបង្កា ១ ស្រីមានគភ៌ ។ រីរាជអមច្ចា ស្ដាប់ហើយឆ្លើយថា យើងពុំដឹងអាថ៌ ទៅថារណ្ដៅ ចូរទៅដោះសារ យើងនឹងចង់ស្គាល់ ចង់ដឹងសេចក្ដី ។ ពោធិសត្វថារណ្ដៅនោះណា អ្នកលោភអប្រិយ គេយកសសរ បញ្ឈរដាក់ដី ហើយយកអាចម៍ដី នោះឯងលុបវិញ ។ គេយកអង្រែបុកប្រិបខ្លែ ក៏រាមិនពេញ តើហេតុដូចអ្វី សេចក្ដីនោះមិញ ទៅដណ្ដឹងអញ ទៅដឹងឬទេ ។ អាមាត្យស្ដាប់ហើយ ពិតពុំដឹងឡើយ កត់ទុកបន្ថែ ទើបដណ្ដឹងទៀត តាទៅថាឯង រពៅមានផ្លែ នោះតើដូចម្ដេច ។ ចូរទៅសំដែង អស់អាថ៌

១ ម.; សំ. អមាត្យ, អាមាត្យ ។

ចាយបែង ប្រាយប្រាប់កលកិច្ច ឲ្យយើងបានដឹង ដំណឹង សេចក្រេប ដំណើរដូចម្ដេច បូរចៅចរចា ។ ពោធិសត្វ ឆ្លើយ ថាហៃចៅអើយ រពោធិលា ទទួលការធ្ងន់ ទំងន់មុះ-ហិមា ទងតែមួយវា មានផ្លែពីរបី ។ ទងនោះប៉ុនខ្សែ គោគួររីផ្លែ ធំៗអស់ក្ដី ពុំដាច់ទងវា គួរនាដូចអ្វី ចៅដឹង សេចក្ដី ឬមួយពុំដឹង ។ អាមាត្យស្ដាប់ហើយ ប្រាប់ថា ចៅអើយ យើងឥតដំណឹង ហើយអាមាត្យកត់ កំណត់ ទុកផ្សឹង ស្រេចទើបដំណឹង ទៅវិញៈទៀតខ្មី ។ ថាស្រី មានគភ៌ នោះតើហេតុអាថិ ម្ដេចបូរស្រដី ពោធិសត្វឆ្លើយ ចៅអើយឯស្រី ទាំងឡាយសឹងផ្ទុំ ចាយម្ទៃមួយនាឡី ។ នោះគភ៌ក្នុងផ្ទៃ ស៊ីដូចវិស័យ ទៀបទៅសំរាល រំងស៊ីញឹកៗ យប់ព្រឹកសព្វកាល នោះតើអាហារ ទុកនៅឯណា ។ ញាំងចៅឯងដឹង ឬឥតដំណឹង ដំណើរបញ្ហា អាមាត្យពុំដឹង ឡើយសឹងកត់ត្រា ទុកទើបសួរថា ហៃចៅធ្មញ្ញយ ។ នា ពុកបង្កា នោះតើមានប្រា- កដកលម្ដេចនែ ពោធិសត្វស្ដាប់ សារស័ព្ទសុម៉ែ ឆ្លាស់ឆ្លើយថាហៃ ចៅអាមាត្យអើយ ។

ឯពុកបង្កា បុរសនានា គេដកជ្រែះស្អាត ដណ្ដើមដុះឡើង បបើងជួជាតិ ដុះពុំមានខ្ចាត គេដកវាល់ខែ ។ រីរោម បិញ្ចើម វាពុំដណ្ដើម ដុះវែងលើសគេ ហៃរាជអមច្ចា ប្រស្នាទាំងនេះ ចៅដឹងឬទេ នោះគឺនរណា ។ អាមាត្យពុំដឹង អាចិនោះសោតសឹង សរសេរកត់ត្រា ទុកទើបនាំប្ដូន ពិមាន ព្រះមហា- ក្សត្រថ្លៃជាតិជា តស្ដូរហ្វើងក្ដល់ ។ បង្គំទូលថា វិតក្កបញ្ហា ចៅធនញ្ជ័យយល់ អាចិអាចឆ្លាស់ឆ្លើយ បំទើយ កិច្ចកល យើងខ្ញុំខ្លៅធ្ងល់ ពុំដឹងប្រស្នា ។ មហាក្សត្រស្ដាប់ ហើយ ស្ដេចពុំជ្រាបឡើយ បន្ទូលត្រាស់ថា ហៃអស់មន្ត្រី សេនីសេនា ចូររកប្រស្នា ទាំងបួនឲ្យយល់ អស់មុខមន្ត្រី សេនាបតី នូវបរិពារពល ចូលមកជួបជុំ ជំនុំរវល់ កើត កោលាហល អឺងកងគ្រប់គ្នា ។ កាលនោះបុរោហិត អ្នកប្រាជ្ញ- ព្រាហ្មណ៍ព្រឹទ្ធ ដណ្ដឹងសួរថា ប្រស្នាកម្រ នេះមកពីណា អ្នកផងប្រាប់ថា មកពីធនញ្ជ័យ ។

# សប្បុរិសជម៌ ពាក្យកាព្យ

(ត)

សរុបធម៌តជាសុភាសិត ប្រដៅចិត្តជនានុជននោះ

៤ ក្នុងទីបួនមានបទអត្ថសង្គ្រោះ លោកតាំងឈ្មោះហៅមត្តញ្ញុតា ។ បានដល់ស្គាល់ប្រាកដបទសេចក្ដី កិច្ចអ្វី ៗ ឲ្យស្គាល់ប្រមាណថា ដូចការរកចិញ្ចឹមជីពអាត្មា ការបេតនាធ្វើទានក៏ឲ្យគួរ ។ ស្វែងរកតាមសម្មាអាជីវោ មិនលោភោមោហៈហិនជាតិជួ ឲ្យដឹងថាគួរបានឬមិនគួរ កុំសាញស្ទួរធហោទដោយទុច្ចរិត ។ ជាតិមនុស្សលោភល្មោភលាភជញ្ជាបមាត់ក្រតែភ្ជាត់ចូលភ្លែតរកហេតុស្និទ្ធ យកតែខាងបានទ្រព្យទើបគាប់ចិត្ត នេះបណ្ឌិតបន្ទុះថាខុសធម៌ ។

របស់ដែលបានដោយផ្លូវអស័ត្យ គង់វិបត្តិកើតទុក្ខលំអក់ពណ៌ ដល់ជីវិតជិតក្ស័យទើបភ័យញ័រ នឹកដល់ធម៌មិនចាំកម្មាក្រាស់ ។ មួយគួរបេះប្រមាណមាត់បរិភោគ កុំកញ្ជោកស៊ីជ្រុលទំលចាក់ប្រាស ល្មើងជាថ្នាំថ្នែមឬមហើមពោះណាស់ ប្រាជ្ញប្រកាសប្រាប់ផ្លូវត្រូវប្រយ័ត្ន ។ គួរជ្រើសរើសបំណើកុំធ្មុំខុសឱជារសពីសាវាឈើប្ហាត់ យ៉ាងឬកឬរខ្មោះទាស់បញ្ញត្តិ ភ្លក់

មួយមាត់ភ្លាត់ខុសវាចុះផ្ទៃ ។ មួយឲ្យបេះប្រយ័ត្នសម្បត្តិទ្រព្យ
កុំទំលាប់ចាយធំពុំប្រពៃ ប្រាក់រាប់សែនមែនបើមិនបេះលៃ
គង់មានភ័យដល់កាយស្តាយកម្លាំង ។ ឯការរកទ្រព្យធនធ្ងន់
គំនិត ត្រូវព្រួយគិតប្រើកាយនឿយហត់ខ្លាំង ឃ្លាតប្រពន្ធឃ្លាត
កូនខ្លួនស្គមស្គាំង សែងសុរិយំបាំងក្បាលហាលទាំងកាយ ។
មានស្រីខ្លះប្រុសខំរកគ្រែង ខ្លួនល្បួចលេងតែល្បែងតាម
សប្បាយ គ្មានអាណិតគិតប្តីនឿយព្រួយកាយ តែប្រុសខ្លះជះ
ចាយទ្រព្យដូចគ្នា ។ កាលបើមានឱកាសគួរល្មមទៅ ដើរ
សំដៅរកបនមិនរង់រា បំពួកខ្លះស្រុះស្រួលបបួលគ្នា ព្រមទាំង
បុត្តភរិយាចរបួលវង់ ។ គួរសង្វេគពេកណាស់ទឹកឡើងហើយ
មិនសមឡើយពួកយើងវង្វេងល្ងង់ ប្រឹងបង្ហិនធនធានគ្មានឲ្យគង់
ហាក់បំរុងបង់តែឲ្យអស់ទៅ ។ ឈ្មោះថាទ្រព្យទ្រនាប់ដៃអ្នក
ចាយ បិញ្ចឹមកាយកាលឃ្លានគ្មានខុសត្រូវ បើអ្នកមានគំនិត
គិតរាក់ជ្រៅ រើសតែផ្លូវឲ្យគុណចាយធនធាន ។ ដូចបេញ
ទុនបួលហ៊ុនជួញលក់ដូរ គួរបង្ហូរចាយចុះព្រោះបង់មាន ប្អូន
យ៉ាងនេះហៅចេះប្រើធនធាន បើសល់មានទៀតទុកបង្ការ

កាយ ។ មួយឯស្រាអាភៀនញៀនបង្ហៀរ គួរលះវៀរទំភៀស ចៀសឲ្យឆ្ងាយ នឹងវិនាសសម្បត្តិទ្រព្យខាតខ្វាយ ផ្លូវអបាយ-មុខទុក្ខអាត្មា ។ ទោះមានច្រើនបើភ្លើនភ្លេចលែលក ទ្រព្យដែលរកមកនោះគង់កាលណា ទ្រព្យមានតិចប្របិចបាយហួសមាត្រា មិនប្រមាណអាត្មាផ្ទារប្រែងាង ។ សូមដាស់តឿនសតិជនប្រុសស្រី ដោយសេចក្ដីសុចរិតឥតអួតអាង ពន្យល់ផ្លូវប៉ុណ្ណោះជាបែបយ៉ាង នឹងសូមអាង១ប្រាំតាមបរិយាយ ។

១៨ ប្រាប់ថាកាលញ្ញុតា ក្នុងអត្ថាឲ្យស្គាល់កាលទាំងឡាយ មានសេចក្ដីរៀងរាយទូលាយឆ្ងាយ អធិប្បាយពីកាលយូរនឹងឆាប់ ។ បើកាលមានអាសន្នបន្ទាន់បង់ កុំបង្អង់ឲ្យយូរគួរប្រញាប់ ទើបទាន់ចិត្តឥតទាស់ថ្ងស់ចំណាប់ បូរាណប្រាប់ស្ដាប់បុះពីពោះពិត ។ ត្រូវលៃកាលមុនក្រោយឲ្យជាក់ច្បាស់ កាលរហ័សគួររហាន់ឲ្យទាន់គិត បើកាលយូរគួរយូរធូរគំនិត ចូលប្រព្រឹត្តឲ្យត្រូវផ្លូវប្រើការ ។ មានភាសិតប្រតិដ្ឋជាអត្ថ ថាកាលានុរូបំជាខ្លឹមសារ អ្នកហាត់ចិត្តគួរពិចារណ៍ ស្មានមើលការធូរតឹងដឹងឲ្យទាន់ ។ ឯកិរិយាកាលនោះមានពីរយ៉ាង

ជាតឹកតាងតាំងទុកតាមលក្ខណ៍ខណ្ឌ គឺកាលចរកាលប្រចាំ បំរុងកាន់ ជាកំណាន់គ្រប់ទិនមិនខុសទេ ។ កាលប្រចាំ ចាត់ជាកាលរំលឹក គឺពេលព្រឹកថ្ងៃត្រង់សាយល្ងាច ក្នុងរវាង ចន្លោះនោះគឺវេ- លាចរវិញដើញវេផ្សេរសម័យ ។ កិច្ចណាក្តី ត្រូវធ្វើប្រចាំកាល ដូចបំអិនអាហារយើងអាស្រ័យ ត្រូវ រករៀបរួសរាន់ឲ្យទាន់ថ្ងៃ ចាត់សំបែភោក្តាតាមការគួរ ។ លុះថ្ងៃតប្ពល់ស្កល់ស្កប់គិតកុំភ្លេច ត្រូវចាប់កិច្ចការធ្វើកុំខ្មោះខ្វះ បើហាត់ពេកសំរាកឲ្យតែគួរ កុំផ្អាកផ្អែកភ្នាក់ស្នូរដំរង់ខ្វង ។ លង់ លុះទាល់ដល់កាលពេលថ្ងៃត្រង់ សិមបង្អង់បង្អន់កិច្ចការផង រកអាហារបរិភោគតាមបំណង បំបាត់ស្រេកឃ្លានផងដែល នឿយហត់ ។ ដល់បរិភោគស្រេចស្រាប់ហាប់ការធ្វើ ប្តូរខំរើ ល្បើល្បឹងប្រឹងអំណត់ យកកំឡាំងប្បាំងការកុំគិតហត់ ស៊ូទ្រាំ អត់ដល់បច្ចសម័យ ។ ហើយងូតទឹកជុសកាយដែលស្មោក គ្រោក រួចបរិភោគភោជនតាមវិស័យ យ៉ាងនេះហៅកិច្ចការ ប្រចាំថ្ងៃ ក្រៅពីនោះកែខែជាការចរ ។ ដូចជាផ្ទះផ្ទុកតែគ្រឿង ក្រខ្វក់ សម្រាមដក់កកក្តាំងទាំងគំនរ គួរបោសប្រាសជុសខាត់

កុំទុកគរ ប្រើមិនប្រើកររររលំរក ។ ទ្រព្យមាសប្រាក់ទុកដាក់ តាមវគ្គស្មើ ត្រូវការប្រើមានព្រមតាមចិត្តភ្នក ណាមិនប្រើទើ តាំងដោយគៀនញក គន់មិនទាស់ខ្វះយើងរកយកបានងាយ ។ ហើយមើលកាលហាត់កូនតាមក្បួនខ្នាត ឲ្យឆ្លៀវឆ្លាតវាងវៃមិន ពាយមាយ ពន្យល់ផ្លូវត្រូវខុសឲ្យផ្ទុះធ្លាយ ការវិតាសនិយាយឲ្យ ចូលចិត្ត ។ ធម្មតាពត់ព្រឹក្សាលតាវល្លិ ត្រូវពត់ពាល់ពីខ្ចីទើប ទន់ស្និទ្ធ ការហ្វឹកហាត់កូនចៅឲ្យត្រូវចិត្ត គួរប្រៀនប្រិតពីតូច ទើបស្ទាត់ច្បាស់ ។ និងបន្លាយវែងទៅហួសផ្លូវកាព្យ នាំឲ្យ សាបរោហារសាញខ្លាំងណាស់ បានលើកកាលទាំងពីរឡើង ប្រកាស ឲ្យឃើញច្បាស់ប៉ុណ្ណោះស្លេះនិពន្ធ ។

សូមតែងត ៦ ដោយពាក្យថា បរិសញ្ញាតាអនុសន្ធ៍ ប្រែ តាមយល់ថាស្គាល់ប្រជុំជន គប្បីគន់គិតមើលឲ្យមាំមួន ។ មនុស្សល្អមែនគង់មានអធ្យាស្រ័យ ក្នុងហទ័យវត្ថុទុកជាក្បួន ចូលត្រង់ណាចូលបុះបេះបៀមខ្លួន មិនឲ្យស្លួនស្ទាត់ហួសជ្រួលសកាល ។ ធម្មតាបង្កើតកំណើតមនុស្ស មានជាន់ខ្ពស់ជាន់ ទាបជាន់កណ្ដាល មានទាំងប្រាជ្ញទាំងព្រើលទាំងខ្លូរស្រាល

ទាំងស្រីបាល ៗ គ្នាពេញពានី ។ មនុស្សគ្រប់ជាន់គួរសម្ពន្ធ មេត្រីចិត្ត បងជាមិត្តជាភក្តិសាមគ្គី តែឲ្យស្គាល់កិរិយាប្រវេណី រើសវិធីណាល្អប្រព្រឹត្តតាម ។ មារយាទអធ្យាស្រ័យកាយវាចា លោកនិយមយ៉ាងណាក្នុងទីស្នាម ត្រូវសំរួលផ្លូលដោយកុំឲ្យជាម ទើបសមតាមភេទៈទុកដាក់អង្គ ។ ទោះជាទាបក៏មិនទាបពីកំណើត ប្រើកិរិយាឲ្យធើតកុំលះបង់ ត្រូវស្គាល់ស័ព្ទបញ្ឆោរ ឬស្លូវត្រង់ កណ្តាលវង្សបំណោមប្រជុំជន ។ សម្លេងប្រាប់សំរែកដូចក្អែកបូល មារយាទប្រាប់តែកូលចូរប្រុងគន់ អធ្យាស្រ័យសមគួរឬស្លូវជន ផ្សាយបេញឯងឲ្យគន់ឃើញសខ្មៅ ។ ទោះរូបឆោមលោមព័ណ៌ល្អស្អាងស្អាត តែមារយាទខុសខាត គេថាខ្លៅ ស្រឡាញ់ខ្លួនស្ងួនកាយកុំឲ្យសៅ អាក្រក់ល្អក៏នៅតែលើខ្លួន ។

១៧ ក្បួលខ្ជប់បញ្ចប់ផ្តាច់ ព្រះសារពេជ្រត្រាស់ទុកតាមបំនួន ប្រសាទសុខារម្មណ៍ឲ្យមាំមួន កាលបើខ្លួនសេវនាសមាគម ។ បទដើមគឺបុគ្គលញ្ញាតា មានអត្ថាធិប្បាយដោយនិយម ប្រែថាស្គាល់ចរិតជនតូចធំ គួរសមាគមឬគេចមិនសេពគប់ ។

ឯមនុស្សនៅក្នុងក្រុងកម្ពុជាខេត្ត មានប្រភេទពីរយ៉ាងអាងប្រាកដ គឺពាលកាចនឹងប្រាជ្ញប្រាប់ឲ្យគ្រប់ មិនទាន់គប់គាស់កាយ ផ្សាយបេញឯង ។ ឯសញ្ជាតិជនពាលបណ្ដាលទាប គ្មានសុភាពរៀបរយគួរឲ្យក្រែង មានវិស័យចិត្តស្មុគ្រជាអ្នកល្បែង ច្រើនសំដែងអាការកាចតក់ម៉ក់ ។ ផ្លូវវិនាសរូបកាយអបាយមុខ ទទួលផ្ទុកគ្រប់យ៉ាងខាងអាក្រក់ អណ្ដាតផ្ដាច់បទភាសាធកុហក រៀចក្រងក់មុខងប់គ្រប់ប្រការ ។ តែទៅស្មិទ្ធប្ដិតអង្គបង់មារយាទ ឋោកឋយជាតិពូជពង្សវង្សាវិតារ គួរតែបៀសភៀសកាយឆ្ងាយឱបារ ទើបជាឧបការគុណដល់កាយ ។ ឯបណ្ឌិតត្រង់គិតមិនបេះខុស ជនស្រីប្រុសត្រង់ត្រាប់គង់សប្បាយនឹងប្ដីប្រពន្ធកេរត៍ឈ្មោះខ្ពស់វែងឆ្ងាយ បានសុខចិត្តសុខកាយគ្រប់ប្រការ ។ ពោលក៏ល្អធ្វើក៏ល្អិតគិតក៏ត្រូវ សំដៅផ្លូវសន្តិ-សុខសង្ខារ វាងវិថីកាមវ្យីមិច្ឆាចារ សាងតែការបុណ្យទានគ្មានខ្មោះខ្មា ។ ត្រឹមប៉ុណ្ណោះណែនាំឲ្យឃើញហេតុ គ្រឿងសង្កេតជាតិមនុស្សជាឬជ្ជ ក្នុងលោកនេះនឹងគប់គប្បីស្ន រ ឃើញសមគួរល្អពិតសិមប្ដិតអង្គ ។ ធម៌ខនេះជាច្បាប់សម្រាប់ប្រើ ឲ្យសប្បុរស

វើរកផ្លូវត្រង់ ក្នុងរឿងសន្តវមិត្តបិត្តបំណង់ ឲ្យផ្ទរផង់យឺនយូរ អង្វែងកប្ប ។ មុននឹងគប់គប្បីមើលមុខមិត្ត ឲ្យឃើញពិត តាមពុទ្ធដីកាប្រាប់ អាក្រក់ល្អសឡេះដាំបានឆាប់ មិនខុស ច្បាប់បណ្ឌិតដូចសំដែង ។ បើមនុស្សពាលតែពោលយល់ប្រ-ភេទ ឲ្យបើញហេតុឧបាយដែលក្លាយក្លែង គួរជ្រាបអត្ថរស ព្រះពុទ្ធថ្លែង កុំរឯងសង្ស័យអាល័យធ្វល់ ។ គប់ជនល្អគង់ ល្អប្រសើរធេត អាចឲ្យកើតសុភអត្ថពិភក្ឋផល គប់ជនអា-ក្រក់បិត្តល្អក់ក្រខ្វក់ខ្វល់ ទុក្ខដាបដល់សកលកាយរាល់គ្នា ។ មនុស្សយើងនេះឧត្តមដោយកំណើត មិនមែនកើតមកភ្លាមក៏ ខ្វបជា លុះប្រែបល់បូលជាប់ជាតិពាលា ខូបនឹងជាតោងស្អិត បិត្តអស់ស្អាត ។ បុគ្គលាធិដ្ឋានមានក្នុងអត្ថ បោតកោកូន សត្វសេកជាអាទ៌ កាលញាស់ឡើងដម្បូងគ្មានខ្វះខាត បិត្តក៏ ស្អាតបរិសុទ្ធឥតយោរយៅ ។ លុះខ្យល់បក់ផក់បាត់សាត់បាក ទី ក៏ព្រាត់ពីសម្បុកបែកគ្នាទៅ សេកមួយនោះជ្រិះធ្លាក់លើលំ-នៅ ព្រះតាបសវើសទៅបែរក្សា ។ សេកមួយទៀតភាតដាត់

សាត់ទៅដល់ ទីមណ្ឌលសំណាក់ពួកចោរ ចោររើសទៅ ចិញ្ចឹមដោយមេត្តា ជួមរក្សាឥតស្នៀបៃទាំទុក ។ សេកដែល នៅសំណាក់ព្រះតាបស ចិត្តសប្បុរសរកផលខ្វល់ចង់សុខ សោងសន្សំសុចរិតបិទផ្លូវទុក្ខ ឆ្ពោះតាំងមុខតាមមគ្គលោកអ្នក ប្រាជ្ញ ។ សេកដែលនៅនឹងចោរចិត្តអាក្រក់ រៀនតែធក់នឹង លួចប្លន់ស្វាកាប បេះខិលខូចឡេង្វបបោររកំណាប ក្លាឥតខ្លាប ឥតគិតជីវិតក្ស័យ ។ ចូរមើលបុះតែជាតិសត្វតិរច្ឆាន បើគប់ ពាលមិនខានខូចនិស្ស័យ បើគប់ប្រាជ្ញ ៗ ប្រៀនព្រះធម៌ថ្លៃ អធ្យាស្រ័យប្រែតាមស្មាមនោះហោង ។

រឿងប្រស់ខ្លាងាប់

ថាមានខ្លាមួយទៅរកស៊ីក្នុងព្រៃ ស៊ីរួចទៅដេកនៅចង្កេះដម្បូកមួយ ដេកនោះដេកទៅលើរន្ធពស់ ឯពស់នោះធុំក្លិនខ្លានោះហើយ ក៏ចេញមកចឹកឯខ្លានោះស្លាប់ទៅ កាលនោះមានតាចាស់ម្នាក់ទៅរកឧសក្នុងព្រៃ ឃើញខ្លានោះស្លាប់ដូច្នោះហើយមានចិត្តអាណិតថា ខ្លានោះវាប្ញីក៏ស្លាប់មើលភិនភាគសព្វគ្រប់ទៅឃើញពិសពស់ឡើងអស់ទាំងខ្លួន ក៏គិតថា ឥឡូវអញបេះស្តោះពិសពស់នេះ បើដូច្នោះអញស្តោះលងមើលក្រែងវារស់ឡើង គិតដូច្នោះហើយក៏ស្តោះពីក្បាលខ្លានោះទាល់តែដល់ទៅកន្ទុយ ខ្លានោះក៏រស់ឡើងពុំដឹងខ្លួនជាស្លាប់ឡើយ គិតខឹងទៅនឹងតាចាស់នោះវិញថា ហេតុដូចម្តេចបានជាតាឯងមកស្តោះឯក្បាលអញ ។ តាចាស់នោះប្រាប់ទៅវិញថា ខ្លាឯងស្លាប់ទេតើបានជាអញស្តោះ ។ ខ្លានោះវាថា អញស្លាប់ពីកាលណា អញដេកកំពុងតែស្រណុក មកស្តោះក្បាលអញទាល់តែភ្ញាក់ ម្ល៉េះហើយអញខាំក្បាលតាឯងឲ្យស្លាប់ ។ តាចាស់នោះឮខ្លាថានឹងខាំដូច្នោះ ក៏ពុំសុខចិត្តថា អញមិនទាន់សុខចិត្តឲ្យខ្លាឯង

ខាំអញទេ ចាំទៅរកចៅក្រមកាត់សេចក្តីសិន ខ្លានោះក៏មិនថាអ្វី បណ្តើរតាចាស់នោះទៅ លុះបណ្តើរឆ្ងាយបន្តិចទៅជួបនឹងត្មាតៗ ឃើញខ្លាបណ្តើរតាចាស់នោះមក ក៏សួរថា បងខ្លាបណ្តើរតាចាស់នេះទៅណា ខ្លាឮហើយប្រាប់តាមដំណើរនោះថា អើបង ជួបនឹងបងឯងនេះជាណាស់ហើយ ជួយកាត់សេចក្តីខ្ញុំបន្តិចបង ថាខ្ញុំដេកនៅប្របដម្បូកកំពុងតែស្រណុក ម្តេចឡើយក៏បានជាតាចាស់នេះមកស្តោះឯក្បាលខ្ញុំលេង ។ ឯតាចាស់នោះឆ្លើយថាទេ ដ្បិតខ្លានេះពស់វាចឹកស្លាប់ បានជាខ្ញុំស្តោះៗខ្លានេះក៏រស់ឡើង ឯត្មាតនោះមកគិតថា យើងសព្វថ្ងៃអាស្រ័យតែអំពារដែលបងខ្លានេះបរិភោគ គួរតែយើងកាត់សេចក្តីឲ្យបងខ្លានេះឈ្នះហោង ទើបត្មាតនោះស្រែកទៅថា ត្រូវបងខ្លាស៊ីតាចាស់នោះទៅ ដ្បិតគេដេកខ្លួនទៅស្តោះក្បាលគេ ។ ឯតាចាស់ថាទេ អញពុំទាន់សុខចិត្តឡើយ ទៅរកចៅក្រមមួយទៀត បណ្តើរគ្នាបន្តិចទៅ ឃើញក្អែកទំលើចុងឈើ តាចាស់នោះនិយាយទៅនឹងក្អែកថាជួយកាត់សេចក្តីខ្ញុំបន្តិច ថាខ្លានេះពស់វាចឹកស្លាប់ខ្ញុំទៅស្តោះរស់ឡើង ៗ ឯខ្លានោះឆ្លើយឡើងថា ខ្ញុំកំពុងតែដេក

តាចាស់នេះមកស្ដោះឯក្បាលខ្ញុំ ក្អែកនោះមកគិតថា យើងសព្វថ្ងៃបានគិរង់ស៊ីតែដែលខ្លា បើដូច្នោះយើងជួយបងខ្លាទើបបានស៊ី ក្អែកនោះកាត់សេចក្ដីថា ត្រូវបងខ្លាស៊ីតាចាស់នោះហើយ ដ្បិតតាចាស់នោះកាចណាស់ គេដេកហើយទៅស្ដោះក្បាលគេ ។ តាចាស់នោះថាទេខ្ញុំមិនទាន់សុខចិត្តទេ ទៅរកចៅក្រមទៀត បណ្ដើរគ្នាទៅទៀត ទៅបន្តិចទៅប្រទះនឹងទន្សាយ, ទន្សាយសួរថា តាចាស់នេះបណ្ដើរខ្លានេះទៅណា តាចាស់នោះប្រាប់ថា ឱបងទន្សាយអើយ ខ្ញុំថាធ្វើគុណនឹងគេ ដ្បិតខ្លានេះពស់វាចឹកស្លាប់ ខ្ញុំអាណិតខ្ញុំស្ដោះទៅខ្លានេះក៏រស់ឡើងឥឡូវនេះគេថាខ្ញុំនេះកាចស្ដោះក្បាលគេ ។ ឯខ្លានោះថាទេ ខ្ញុំកំពុងតែដេកលក់ស្រណុកស្រាប់តែតាចាស់នេះទៅស្ដោះឯក្បាលខ្ញុំ ។ តាចាស់នោះអង្វរទៅទន្សាយថា ឱអ្នកទន្សាយអើយមេត្តាកាត់សេចក្ដីឲ្យខ្ញុំផង ទើបសុភាទន្សាយថា បងខ្លាឯងឈប់សិន ដ្បិតអញមិនទាន់ឃើញទីឃើញកន្លែង បើដូច្នោះបងខ្លាឯងនាំអញទៅមើលទីនោះសិន រួចសឹមស៊ីជាក្រោយ